

ឯកសារគម្ពីព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥០០០ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សារ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ្គិចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ួច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ តន្នា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ អបទាន
# បញ្ចមភាគ
# ៧៦

បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ព. ស. ២៥០៧

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga  The Rev. Jitsujo Arima  The Rev. Yoshimichi Ito
The Rev. Keiichi Watai  The Rev. Gijun Sugitani  The Rev. Shincho Shigeta
The Rev. Risho Maeda  The Rev. Kyoshi Nakajima  Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដក

## ខុទ្ទកនិកាយ អបទាន

## បញ្ចមភាគ

## ៧៦

ព. ស. ២៥០៧

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស អបទានំ

# បញ្ចមោ ភាគោ

---

## ថេរិយាបទានំ

## បឋមោ សុមេធាវគ្គោ

### បឋមំ សុមេធាថេរិយាបទានំ

អថ ថេរិកាបទានានិ សុណាថ(១)

(១) ភគវតិ កោណាគមនេ សង្ឃារាមម្ហិ និវេសម្ហិ
សខិយោ តិស្សោ ជនិយោ វិហារទានំ អទម្ហសេ(២)។
ទសក្ខត្តុំ សតក្ខត្តុំ សតានំ ច សតក្ខត្តុំ
ទេវេសុ ឧបបជ្ជិម្ហ កោ វាទោ មានុសេ ភវេ។
ទេវេសុ មហិទ្ធិកា ហុត្វា មានុសកម្ហិ កោ វាទោ
សត្តរតនស្ស មហេសី ឥត្ថិរតនំ អហំ ភវឹ ។

---

១ ឱ. សុណោថ ។ ២- ឱ. ម. អទាសិម្ហ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ អបទាន

# បញ្ចមភាគ

ថេរិយាបទាន

## សុមេធាវគ្គ ទី ១

## សុមេធាថេរិយាបទាន ទី ១

លំដាប់តទៅនេះ ចូរចាំស្តាប់នូវថេរីអាបទានទាំងឡាយចុះ

(១) កាលព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ គង់នៅក្នុងសង្ឃារាម យើងជាស្ត្រី ៣ នាក់ ជាសំឡាញ់នឹងគ្នា បានថ្វាយនូវវិហារទាន ។ ពួកយើងបានទៅកើត ក្នុងពួកទេវតា អស់ ១០ ដងកិដង មួយរយដងកិដង មួយម៉ឺនដងកិដង ចាំបាច់និយាយថ្វីក្នុងការកើតជារបស់មនុស្ស ។ ខ្ញុំជាស្រីមានឫទ្ធិច្រើន ក្នុងពួកទេវតាទាំងឡាយ ចាំបាច់និយាយថ្វី ក្នុងការកើតជារបស់មនុស្ស ខ្ញុំកើតជាស្រីកែវ ធ្វើជាមហេសី របស់ស្តេច មានរតនៈ ៧ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

តត្ថ សញ្ចិតំ(១) កុសលំ   សុសមិទ្ធកុលប្បជា
ធនញ្ជានី ច ខេមា ច   អហំបិច តយោ ជនា ។
អារាមំ សុកតំ កត្វា   សព្វាវយវមណ្ឌិតំ
ពុទ្ធប្បមុខសង្ឃស្ស   និយ្យាទេត្វា បមោទិតា(២) ។
យត្ថ យត្ថូបបជ្ជាមិ   តស្ស កម្មស្ស វាហសា
ទេវេសុ អគ្គតំ បត្តា   មនុស្សេសុ តថេវ ច ។
ឥមស្មឹយេវ កប្បស្មឹ   ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន   ឧប្បជ្ជិ វទតំ វរោ ។
ឧបដ្ឋាកោ មហេសិស្ស   តទា អាសិ នរិស្សរោ
កាសិករាជា កិកី នាម   ពារាណសី បុរុត្តមេ ។
តស្សាសុំ សត្ត ធីតរោ   រាជកញ្ញា សុខេធិតា
ពុទ្ធុបដ្ឋាននិរតា   ព្រហ្មចរិយំ ចរឹសុ តា ។

១ ឱ. ម. ឥធ សញ្ចិតា ។ ម. ឥធ សញ្ចិត ។

ជន ៣ នាក់នោះ គឺ នាងធនញ្ជានី ១ នាងខេមា ១ និងខ្ញុំ ១ បានកើតក្នុងត្រកូល ដែលសម្រេចល្អ ដោយកុសលដែលយើងបានសន្សំហើយ ក្នុងភពនោះ ៗ ខ្ញុំបានកសាងអារាមល្អ ដ៏ប្រដាប់ដោយអវយវៈ (គ្រឿងតាក់តែង) គ្រប់យ៉ាង ហើយមានចិត្តរីករាយវេរថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ៗ ដោយផលនៃកុសលកម្មនោះ ខ្ញុំចូលទៅកើតក្នុងភពណាៗ តែងដល់នូវភាពដ៏ប្រសើរ ក្នុងទេវលោក ក្នុងមនុស្សលោក ក៏ដូចគ្នា ៗ ក្នុងកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ដ៏ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ៗ កាលនោះ ស្ដេចក្នុងដែនកាសី ទ្រង់ព្រះនាមកិកី ជាឥស្សរៈរបស់ជនក្នុងពារាណសីបុរី ដ៏ឧត្ដម ជាឧបដ្ឋាកនៃព្រះកស្សបៈ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ៗ ព្រះរាជាអង្គនោះ មានរាជកញ្ញាជាធីតា ៧ អង្គ ជាស្រីបិតនៅក្នុងសេចក្ដីសុខ ត្រេកអរក្នុងការបម្រើព្រះពុទ្ធ ធីតាទាំងនុះ ប្រព្រឹត្តព្រហ្មចរិយធម៌ ៗ

## បឋមំ សុមេធាថេរិយាបទានំ

តាសំ សហាយិកា ហុត្វា    សីលេសុ សុសមាហិតា
ទត្វា ទានានិ សក្កច្ចំ    អគារេវ វត្តំ ចរឹ ។
តេន កម្មេន សុកតេន    ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ    តាវត្តឹសូបគា អហំ ។
តតោ ចុតា យាមា សគ្គំ(១)    តតោហំ តុសិតំ គតា
តតោ ច និម្មានរតឹ    វសវត្តិបុរំ គតា(២) ។
យត្ថ យត្ថូបបជ្ជាមិ    បុញ្ញកម្មសមាហិតា
តត្ថ តត្ថេវ រាជូនំ    មហេសិត្តមការយឹ ។
តតោ ចុតា មនុស្សត្តេ    រាជូនំ ចក្កវត្តិនំ
មណ្ឌលីនញ្ច រាជូនំ    មហេសិត្តមការយឹ ។
សម្បត្តឹ អនុភោត្វាន    ទេវេសុ មានុសេសុ ច
សព្វត្ថ សុខិតា ហុត្វា    នេកជាតីសុ សំសរឹ ។

---

១ ឱ. យាមមគ្គំ ។ ២ ឱ. ម. គតោ ។

## សុមេធាថេរិយាបទាន ទី ១

ខ្ញុំជាសំឡាញ់នៃធីតាទាំងនោះ មានចិត្តតម្កល់មាំក្នុងសីល ឲ្យនូវទានទាំងឡាយដោយគោរព ប្រព្រឹត្តនូវវត្តក្នុងផ្ទះ ៗ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវសេចក្តីប្រាថ្នានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ៗ ខ្ញុំច្យុតអំពីឋាននោះមក ក៏បានទៅកើតក្នុងឋានយាមៈ លុះច្យុតអំពីឋានយាមៈនោះ បានទៅកើតក្នុងឋានតុសិត លុះច្យុតអំពីតុសិតនោះ បានទៅកើតក្នុងឋាននិម្មានរតី លុះច្យុតអំពីនិម្មានរតីនោះ បានទៅកើតក្នុងវសវត្តីបុរី ៗ ខ្ញុំជាស្រីប្រកបដោយបុញ្ញកម្មនោះ ទៅកើតក្នុងឋានណាៗ តែងបាននូវភាពជាមហេសី របស់ស្តេចទាំងឡាយ ក្នុងឋាននោះ ៗ ៗ លុះខ្ញុំច្យុតអំពីអត្តភាពនោះហើយ បានមកកើតជាមនុស្ស ក៏បាននូវភាពជាមហេសី នៃស្តេចចក្រពត្តិទាំងឡាយផង នៃស្តេចដែលមានមណ្ឌលទាំងឡាយផង ៗ ខ្ញុំទទួលនូវសម្បត្តិក្នុងទេវតាទាំងឡាយផង ក្នុងមនុស្សទាំងឡាយផង ជាស្ត្រីមានសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅអស់ច្រើនជាតិ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

សោ ហេតុ ច សោ បភវោ តំ មូលំ សាសនេ ខមំ
តំ បឋមំ សមោធានំ តំ ធម្មតាយ និព្វុតំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុមេធា ភិក្ខុនី ឥមា គាថា-
យោ អភាសិត្ថាតិ ។

សុមេធាថេរិយាបទានំ សមត្តំ ។

### សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

ហេតុនោះក្តី ដើមកំណើតនោះក្តី ឫសគល់នោះក្តី សេចក្តីគាប់ចិត្តក្នុងសាសនានោះក្តី ការប្រជុំចុះជាដំបូងនោះក្តី ធម្មជាតទាំងនោះបានរលត់ហើយ ដោយសេចក្តីត្រេកអរក្នុងធម៌ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុមេធាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុមេធាថេរិយាបទាន ។

# ទុតិយំ មេខលទាយិកាថេរិយាបទានំ

(២) សិទ្ធត្ថស្ស ភគវតោ ថូបការមកាសហំ(១)
មេខលិកា មយា ទិន្នា នវកម្មស្ស សត្ថុនោ ។
និដ្ឋិតេ ច មហាថូបេ មេខលំ បុនទាសហំ
លោកនាថស្ស មុនិនោ បសន្នា សេហិ បាណិភិ ។
ចតុន្នវុតេ ឥតោ កប្បេ មេខលំ អទទឹ តទា(២)
ទុគ្គតឹ នាភិជានាមិ ថូបការស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មេខលទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

មេខលទាយិកាថេរិយាបទានំ សមត្តំ ។

---

១- ឱ. ថូបំ ការាបិតា អហំ ។ ម. ថូបការាមិកា អហុំ ។ ២ ឱ. ម. បេ៉ មេខលមទំ តទា ។

# មេខលទាយិកាថេរិយាបទាន ទី ២

(២) ខ្ញុំបានធ្វើព្រះស្តូបថ្វាយព្រះមានព្រះភាគ ព្រះនាមសិទ្ធត្ថៈ ហើយបានថ្វាយខ្សែក្រវាត់ចំពោះព្រះសាស្តា ដើម្បីនវកម្ម ។ កាលមហាស្តូបសម្រេចហើយ ខ្ញុំមានចិត្តជ្រះថ្លា បានបូជាខ្សែក្រវាត់ ចំពោះព្រះមុនិលោកនាថ ដោយដៃរបស់ខ្លួនទៀត ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយខ្សែក្រវាត់ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការធ្វើស្តូប ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមេខលទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មេខលទាយិកាថេរិយាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# តតិយំ មណ្ឌបទាយិកាថេរិយាបទានំ

(៣) កោណាគមនពុទ្ធស្ស មណ្ឌបោ ការិតោ មយា
ធុវញ្ច បវរមទំ(១) ពុទ្ធស្ស លោកពន្ធុនោ ។
យំ យំ ជនបទំ យាមិ និគមេ រាជធានិយោ
សព្វត្ថ បូជិតា ហោមិ បុញ្ញកម្មស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

ឥត្ថំ សុទំ អាយស្មា មណ្ឌបទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

មណ្ឌបទាយិកាថេរិយាបទានំ សមត្តំ ។

---

១ ឱ. ធុវញ្ច ចីវរមទំ ។ ម. ធុវំ តិចីវរំ អទាសិំ ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# មណ្ឌបទាយិកាថេរិយាបទាន ទី ៣

(៣) ខ្ញុំបានកសាងមណ្ឌបថ្វាយព្រះពុទ្ធ ព្រះនាមកោនាគមនៈ ហើយថ្វាយព្រះស្តូបដ៏ប្រសើរ ដល់ព្រះពុទ្ធ ជាផៅពង្សនៃលោកថែមទៀត ។ ខ្ញុំទៅកាន់ជនបទ និគម រាជធានីណា ៗ ជាស្រីត្រូវគេបូជាក្នុងទីទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្វឹង ៗ ។ល។ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមណ្ឌបទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មណ្ឌបទាយិកាថេរិយាបទាន ។

# ចតុត្ថំ សង្កមនទាថេរិយាបទានំ

(៤) កោណ្ឌញ្ញស្ស(១) ភគវតោ លោកជេដ្ឋស្ស

តាទិនោ

វីថិយំ បដិបន្នស្ស តារយន្តស្ស បាណិនោ ។
ឃរតោ និក្ខមិត្វាន អវកុជ្ជ និបជ្ជហំ
អនុកម្បកោ លោកជេដ្ឋោ សិរសិ អក្កមិ តទា ។
អក្កមិត្វាន សិរសិ(២) អគមា លោកនាយកោ
តេន ចិត្តប្បសាទេន តុសិតំ អគមាសហំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

១ ម. វិបស្សិស្ស ។ ២ ម. សក្តុតោ ។

# សង្កមត្តាថេរិយាបទាន ទី ៤

(៤) កាលព្រះមានព្រះភាគ ព្រះនាមកោណ្ឌញ្ញៈ ជាធំជាងលោក ជាតាទិបុគ្គល ទ្រង់ស្តេចទៅក្នុងប្រក ទ្រង់ញុំាងសត្វទាំងឡាយឲ្យឆ្លង ៗ ខ្ញុំចេញអំពីផ្ទះ ហើយឱនក្រាបចុះ កាលនោះ ព្រះពុទ្ធជាធំជាងលោក ព្រះអង្គជាអ្នកអនុគ្រោះ បានជាន់លើក្បាលខ្ញុំ ៗ លុះព្រះលោកនាយកទ្រង់ជាន់លើក្បាលខ្ញុំ ហើយស្តេចហួសទៅ ខ្ញុំក៏បានទៅកើតក្នុងឋានតុសិត ដោយសេចក្តីជ្រះថ្លាក្នុងចិត្តនោះ ៗ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់ទន្ទូវទន្ទឹង ៗ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

ឥត្ថំ សុទំ អាយស្មា សង្កមនត្តា ភិក្ខុនី ឥមា គាថា-
យោ អភាសិត្ថាតិ ។

សង្កមនត្តាថេរិយាបទានំ សមត្តំ ។

# បញ្ចមំ នឡមាលិកាថេរិយាបទានំ

(៥) ចន្ទភាគា នទីតីរេ អហោសឹ កិន្នរី តទា
អទ្ទសំ វិរជំ ពុទ្ធំ សយម្ភុំ អបរាជិតំ ។
បសន្នចិត្តា សុមនា វេទជាតា កតញ្ជលី
នឡមាលំ គហេត្វាន សយម្ភុំ អភិបូជយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា កិន្នរីទេហំ(១) អគច្ឆឹ តិទសំ គណំ(២) ។
ឆត្តឹសទេវរាជូនំ មហេសិត្តមការយឹ
ទសន្នំ ចក្កវត្តីនំ មហេសិត្តមការយឹ ។
ទេវយិត្វាន(៣) កុសលំ បព្វជឹ អនគារិយំ
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា(៤)
សព្វាសវា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។

---

១ ឱ. ម. ចេតនាបណិធីហិ ច ជហិត្វា កិន្នរីទេហន្តិ ឥមេ បាឋា ន ទិស្សន្តិ ។ ២ ម. គតឹ ។
៣ ឱ. សំវេទយិត្វា ។ ម. សំវេជេត្វាន ។ ៤ ឱ. ភវា សង្ឃាដិតា មមំ ។ ម. ភវា សំឃាដិតា មម ។

បានពោលថា ព្រះសង្កមនត្តាភិក្ខុនី មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សង្កមនត្តាថេរិយាបទាន ។

## នឡមាលិកាថេរិយាបទាន ទី ៥

(៥) កាលនោះ ខ្ញុំជាកិន្នរី នៅជិតឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកធូលី គឺកិលេស ត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេសហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ កើតសេចក្ដីរីករាយ ធ្វើអញ្ជលី ហើយយកកម្រងផ្កាបបុះ បូជាព្រះសយម្ភូ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជាកិន្នរីហើយ ក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស ។ ខ្ញុំបាននូវភាពជាមហេសី នៃទេវរាជ ៣៦ ដង បាននូវភាពជាមហេសីនៃស្ដេចចក្រពត្តិ ១០ ដង ។ ខ្ញុំទទួលនូវកុសល បានចូលទៅកាន់ផ្នួស កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

## បញ្ចមំ នឡមាលិកាថេរិយាបទានំ

ចតុន្នវុតេ ឥតោ កប្បេ យំ បុប្ផមភិបូជយឹ

ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នឡមាលិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

នឡមាលិកាថេរិយាបទានំ សមត្តំ ។

## នឡមាលិកាថេរិយាបទាន ទី ៥

ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនឡមាលិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នឡមាលិកាថេរិយាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# ឆដ្ឋំ ឯកបិណ្ឌបាតទាយិកាថេរិយាបទានំ

(៦) នគរេ ពន្ធុមតិយា  ពន្ធុមា នាម ខត្តិយោ
តស្ស រញ្ញោ អហុំ ភរិយា  ឯកជ្ឈំ ភនយាមហំ(១) ។
រហោគតា និសីទិត្វា  ឯវំ ចិន្តេសហំ តទា
អាទាយ គមនីយំ ហិ  កុសលំ នត្ថិ មេ កតំ ។
មហាភិតាបំ កដុកំ  ឃោររូបំ សុទារុណំ
និរយំ នូន គច្ឆាមិ  ឯត្ថ មេ នត្ថិ សំសយោ ។
រាជានំ ឧបគន្ត្វាន(២)  ឥទំ វចនមព្រវឹ
ឯកំ មេ សមណំ ទេហិ  ភោជយិស្សាមិ ខត្តិយ ។
អទាសិ មេ មហារាជា  សមណំ ភាវិតិន្ទ្រិយំ
តស្ស បត្តំ គហេត្វាន  បរមន្នេន តប្បយឹ ។
បូជយិត្វា(៣) បរមន្នំ  គន្ធាលេបំ អកាសហំ
ជាលេន បិទហិត្វាន  បីតចោលេន(៤) ឆាទយឹ ។

---

១ ឱ. ម. ចារយាមហំ ។ ២ ឱ. ឧបសង្កម្ម ។ ៣ ឱ. ម. បូរយិត្វា ។ ៤ ឱ. មហានេលេន ។ ម. វត្ថយុគេន ។

# ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ទី ៦

(៦) ព្រះមហាក្សត្រព្រះនាមពន្ធុមៈ ក្នុងក្រុងពន្ធុមវតី ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានពោលនូវពាក្យខុះ (នឹងស្តេចនោះ) ។ កាលនោះ ខ្ញុំអង្គុយក្នុងទីស្ងាត់ ហើយគិតយ៉ាងនេះថា កុសលដែលអញគួរយកទៅបរលោក អញមិនបានធ្វើសោះ អញនឹងទៅកាន់នរក ដែលជាឋានក្តៅខ្លាំង ខ្លោចផ្សា មានសភាពគួរខ្លាច អាក្រក់ក្រៃលែងដោយពិត អញមិនមានសេចក្តីសង្ស័យ ក្នុងដំណើរនេះឡើយ ។ ខ្ញុំចូលទៅគាល់ព្រះរាជា ហើយក្រាបទូលដូច្នេះថា បពិត្រព្រះមហាក្សត្រ សូមព្រះអង្គប្រទាននូវសមណៈមួយអង្គ ដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់នឹងនិមន្តលោកឲ្យឆាន់ ។ ព្រះមហារាជ ទ្រង់ប្រទាននូវសមណៈមួយអង្គ ដែលមានឥន្ទ្រិយអប់រំហើយដល់ខ្ញុំ ខ្ញុំទទួលនូវបាត្ររបស់លោកហើយ បំពេញដោយបាយដ៏ប្រសើរ ។ លុះខ្ញុំបំពេញហើយ ធ្វើនូវបាយដ៏ប្រសើរ ឲ្យជាបាយលាយដោយវត្ថុមានក្លិនក្រអូប បិទដោយសំណាញ់ គ្របដោយសំពត់លឿង ។

អារម្មណំ មម ឯតំ សរាមិ យាវជីវិតំ
តត្ថ ចិត្តំ បសាទេត្វា តាវតឹសំ អគច្ឆហំ ។
តីសានំ ទេវរាជូនំ មហេសិត្តមការយឹ
មនសា បត្ថិតំ មយ្ហំ និព្វត្តតិ យថិច្ឆកំ ។
វីសានំ ចក្កវត្តីនំ មហេសិត្តមការយឹ
ឧបចិត្តា(១) ហុត្វាន សំសរាមិ ភវាភវេ(២) ។
សព្វពន្ធនមុត្តាហំ អបេតា មេ ឧបាទិកា
សព្វាសវបរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។
ឯកនវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ បិណ្ឌបាតស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. ម. ឧបិតត្តា ប ។ ២ ឱ. ម. ភវេសូហំ ។ ម. ភវេសុហំ ។

## ឯកបិណ្ឌបាតទាយិកាថេរីយាបទាន ទី ៦

កុសលនុ៎ះ ជាអារម្មណ៍របស់ខ្ញុំ ខ្ញុំរលឹកដរាបដល់អស់ជីវិត ខ្ញុំទៅកើតក្នុងឋានតាវត្តិង្ស ព្រោះញុំាងចិត្តឲ្យជ្រះថ្លាក្នុងកុសលនោះ ៗ ខ្ញុំបានទូវភាពនៃខ្លួនជាមហេសី នៃស្តេចទេវតាទាំង-ឡាយ ៣០ ដង សេចក្តីប្រាថ្នាដែលខ្ញុំប្រាថ្នាហើយក្នុងចិត្ត ក៏កើតឡើងដល់ខ្ញុំដូចសេចក្តីប្រាថ្នា ។ ខ្ញុំបានទូវភាពជាមហេសីនៃស្តេចចក្រពត្តិ ២០ ដង ខ្ញុំជាស្រីមានកុសលសន្សំហើយ តែងអន្ទោលទៅ ក្នុងភពតូចនិងភពធំ ។ ខ្ញុំរួចចាកបំណងទាំងអស់ហើយ ខ្ញុំជាអ្នកប្រាសចាកកំណើតហើយ អស់អាសវៈទាំងពួងរលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបិណ្ឌបាតទាន ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកបិណ្ឌបាតទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកបិណ្ឌបាតទាយិកាថេរិយាបទានំ សមត្តំ ។

## សត្តមំ កដច្ឆុភិក្ខទាយិកាថេរិយាបទានំ

(៧) បិណ្ឌចារំ ចរន្តស្ស តិស្សនាមស្ស សត្ថុនោ
កដច្ឆុភិក្ខំ បគ្គយ្ហ ពុទ្ធសេដ្ឋស្សទាសហំ ។
បដិគ្គហេត្វា សម្ពុទ្ធោ តិស្សោ លោកគ្គនាយកោ
វីថិយា សណ្ឋិតោ សត្ថា អកា មេ អនុមោទនំ ។
កដច្ឆុភិក្ខំ ទត្វាន តាវត្តឹសំ គមិស្សសិ
ឆត្តឹសទេវរាជូនំ មហេសិត្តំ ការិស្សសិ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបិណ្ឌបាតទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ។

## កដច្ឆុភិក្ខទាយិកាថេរិយាបទាន ទី ៧

(៧) កាលព្រះសាស្តា ព្រះនាមតិស្សៈ ទ្រង់ត្រាច់ទៅបិណ្ឌបាត ខ្ញុំបានយកចង្ក្រាន់មួយវែក ថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធ ព្រះនាមតិស្សៈ ជាសាស្តា ជានាយកដ៏លើសលុប ក្នុងលោក ទ្រង់ទទួលហើយ ទ្រង់គង់នៅក្នុងផ្លូវ ទ្រង់ធ្វើអនុមោទនាដល់ខ្ញុំថា

នាងប្រគេនចង្ក្រាន់មួយវែក នឹងបានទៅកើតក្នុងឋានតាវត្តិង្ស នឹងបានជាអគ្គមហេសី នៃស្តេចទេវតា ៣៦ ដង ។

## សត្តមំ កដច្ឆុភិក្ខទាយិកាថេរិយាបទានំ

បញ្ញាសចក្កវត្តីនំ មហេសិត្តំ ការិស្សសិ
មនសា បត្ថិតំ សព្វំ បដិលទ្ធសិ សព្វទា ។
សម្បត្តឹ អនុភោត្វាន បព្វជិស្សសិកិញ្ចនា
សព្វាសវេ បរិញ្ញាយ និព្វាយិស្សសិនាសវា ។
ឥទំ វត្វាន សម្ពុទ្ធោ តិស្សោ លោកគ្គនាយកោ
នភំ អព្ភុគ្គមិ ធីរោ ហំសរាជាវ អម្ពរេ ។
សុទិន្នមេវ មេ ទានំ សុយិដ្ឋា យាគសម្បទា
កដច្ឆុភិក្ខំ ទត្វាន បត្តាហំ អចលំ បទំ ។
ទ្វេនវុតេ ឥតោ កប្បេ យំ ទានមទទិន្តទា
ទុគ្គតឹ នាភិជានាមិ ភិក្ខាទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

## កដច្ឆុភិក្ខទាយិកាថេរិយាបទាន ទី ៣

ទឹងបានជាមហេសី នៃស្តេចចក្រពត្តិ ៨០ ដង ទឹងបាននូវសម្បត្តិទាំងពួងដែលនាងប្រាថ្នាហើយ តាមចិត្តប្រាថ្នាក្នុងកាលទាំងពួង ៗ នាងទឹងទទួលនូវសម្បត្តិ ជាស្ត្រីមិនមានសេចក្តីកង្វល់ ទឹងបួសកំណាត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ទឹងបរិនិព្វាន ៗ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏លើសលុបក្នុងលោក ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់នូវពាក្យនេះហើយ ក៏ហោះទៅឯអាកាស ដូចជាស្តេចហង្សហើរទៅឰដ៏អាកាស ៗ

ទានដែលខ្ញុំបានថ្វាយល្អហើយ យាគសម្បទា ខ្ញុំបានបូជាល្អហើយ ខ្ញុំបានថ្វាយនូវចង្ហាន់មួយវែក ហើយដល់នូវអចលបទ គឺព្រះនិព្វាន ៗ ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការថ្វាយចង្ហាន់ ៗ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំបានដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ៗ

សាគតំ វត មេ អាសិ  ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កដច្ឆុភិក្ខាទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

កដច្ឆុភិក្ខាទាយិកាថេរិយាបទានំ សមត្តំ ។

## អដ្ឋមំ សត្តុប្បលមាលិកាថេរិយាបទានំ

(៨) នគរេ អរុណាវតិយា  អរុណោ នាម(១) ខត្តិយោ
តស្ស រញ្ញោ អហុំ ភរិយា  ឯកុលំ ចារយាមហំ(២) ។
សត្ត មាលា គហេត្វាន  ឧប្បលា(៣) ទេវគន្ធិកា
និសជ្ជ បាសាទវរេ  ឯវំ ចិន្តេសិ តាវទេ ។
កិំ មេ ឥមាហិ មាលាហិ  សិរសា រោបិតាហិ(៤) មេ
វរំ មេ ពុទ្ធសេដ្ឋស្ស  ញាណម្ហិ អភិរោបិតំ ។

---

១ ឱ. ម. អរុណវា នាម ។ ២ ឱ. មាលំ ចារយាមហំ ។ ម. វារិតំ វារិយាមហំ ។
៣ ឱ. ឧប្បលី ។ ៤ ម. រោបិតេហិ ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកដច្ឆុភិក្ខាទាយិកាភិក្ខុនី មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កដច្ឆុភិក្ខាទាយិកាថេរិយាបទាន ។

## សត្តុប្បលមាលិកាថេរិយាបទាន ទី ៨

(៨) ក្នុងក្រុងអរុណវតី មានក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្ដេចនោះ បានចាត់ចែងនូវផ្កាដែលមិនទាន់ក្រងទុក ។ ខ្ញុំកាន់យកនូវផ្កាឧប្បល ៧ កម្រង មានក្លិនដូចជាក្លិនទិព្វ អង្គុយលើប្រាសាទដ៏ប្រសើរ គិតយ៉ាងនេះ ក្នុងខណៈនោះថា អញមានប្រយោជន៍អ្វី ដោយកម្រងផ្កានេះ ដែលអញពាក់លើក្បាលរបស់អញ បើអញបូជា ចំពោះញាណព្រះពុទ្ធដ៏ប្រសើរ ប្រសើរជាង ។

## អដ្ឋមំ សត្តឧប្បលមាលិកាទេរីយាបថានំ

សម្ពុទ្ធំ បដិមានេត្តិ    ទ្វាកសន្ទេ និសីនហំ
យទា ឋហិតិ(១) សម្ពុទ្ធោ    បូជយិស្សំ មហាមុនី ។
កក្កុដោ វិលសន្តោវ    មិគរាជាវ កេសរី
ភិក្ខុសង្ឃេន សហិតោ    អាគច្ឆិ វីជិយា ជិនោ ។
ពុទ្ធស្ស រំសី និស្វាន    ហដ្ឋា សំវិគ្គមានសា
ទ្វារំ អភាបុណិត្វាន    ពុទ្ធសេដ្ឋំ អបូជយឹ ។
សត្ត ឧប្បលបុប្ផានិ    សុវិត្តិណ្ណានិ(២) អន្តរេ
ឆាទី កកេដ្ឋា ពុទ្ធស្ស    មត្ថកេ ធារយន្តិ តេ ។
ឧទគ្គចិត្តា សុមនា    វេទជាតា កតញ្ជលី
តត្ថ ចិត្តំ បសាទេត្វា    តាវត្តិំសំ អគច្ឆហំ ។
មហាវេលស្ស ឆាទនំ    ធារេន្តិ មម មុទ្ធនិ
និព្ពត្តំ បភាយតិ(៣)    សត្តុប្បលានិនិំ ដលំ ។
កទាចិ នីយមានាយ    ញាតិសង្ឃេន មេ តទា
យាវតា បរិសា មយ្ហំ    មហាវេលំ ធរីយតិ ។

---

១ ឱ. ឯតីហិ ។ ២ ឱ. បរិត្តិណ្ណានិ ។ ម. បរិកិណ្ណានិ ។ ៣ ឱ. ម. បភាយាមិ ។

ជនទាំងឡាយតែងរាប់អាននូវព្រះសម្ពុទ្ធ អញអង្គុយនៅជិតទ្វារ កាលណា ព្រះសម្ពុទ្ធទ្រង់ហៅថា នាងចូរមក អញទើបបូជានូវព្រះមហាមុនី ក្នុងកាលនោះ ។ ព្រះជិនស្រីប្រកបដោយភិក្ខុសង្ឃ ស្តេចមកតាមផ្លូវថ្នល់ ទ្រង់ល្វាសល្វន់ដូចជាដើមថ្វាន់ត្រូវខ្យល់ ឬដូចជាកេសររាជសីហ៍ជាស្តេចម្រឹគ ។ ខ្ញុំជាអ្នកមានចិត្តរីករាយ លុះឃើញស្តេចព្រះពុទ្ធ ក៏មានចិត្តសង្វេគមិនទាន់ដល់ទ្វារ ក៏បូជាចំពោះព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំធ្វើផ្កាឧប្បល ៧ កម្រង ត្រដាងឰដ៏អាកាស ផ្កាទាំងនោះ ក៏បាំងខាងលើព្រះសិរនៃព្រះពុទ្ធ ។ ខ្ញុំមានចិត្តខ្ពស់ឡើង មានចិត្តរីករាយ មានចិត្តត្រេកអរ ធ្វើអញ្ជលី ហើយញុំាងចិត្តឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធនោះ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ផ្កាទាំងឡាយបាំងធ្វើជាដំបូលនៃពេនធំ ខាងលើក្បាលខ្ញុំ ក្លិនផ្កាទិព្វ ក៏ផ្សាយទៅ នេះជាផលនៃផ្កាឧប្បល ៧ កម្រង ។ កាលពួកញាតិនាំខ្ញុំទៅ ក្នុងកាលម្តង ៗ បរិស័ទរបស់ខ្ញុំ មានចំនួនត្រឹមណា ផ្កាទាំងឡាយក៏បាំងជាពេន មានចំនួនត្រឹមនោះ ។

សត្តតិ ទេវរាជូនំ　　មហេសិត្តំ អការយិំ
សព្វត្ថ ឥស្សរា ហុត្វា　　សំសរាមិ ភវាភវេ ។
តេសដ្ឋិចក្កវត្តីនំ　　មហេសិត្តំ អការយិំ
សព្វេ មំ អនុវត្តន្តិ(១)　　អាទេយ្យវចនា អហំ(២) ។
ឧប្បលស្សេវ មេ វណ្ណោ　　គន្ធោ ចេវ បវាយតិ
ទុគ្គតិំ(៣) នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។
ឥទ្ធិបាទេសុ កុសលា　　ពោជ្ឈង្គភាវនារតា
អភិញ្ញាបារមិប្បត្តា　　ពុទ្ធបូជាយិទំ ផលំ ។
សតិប្បដ្ឋានកុសលា　　សមាធិឈានគោចរា
សម្មប្បធានមនុយុត្តា　　ពុទ្ធបូជាយិទំ ផលំ ។
វីរិយំ មេ ធុរធោរយ្ហំ　　យោគក្ខេមាធិវាហនំ
សព្វាសវបរិក្ខីណា　　នត្ថិ ទានិ បុនព្ភវោ ។
ឯកត្តិំសេ ឥតោ កប្បេ　　យំ ពុទ្ធមភិបូជយិំ
ទុគ្គតិំ នាភិជានាមិ　　ពុទ្ធបូជាយិទំ ផលំ ។

---

១ ម. មមនុវត្តន្តិ ។ ២ ម. អហុំ ។ ៣ ម. ទុព្វណ្ណិយំ ។

ខ្ញុំបានជាមហេសី នៃទេវរាជ ៧០ ដង ខ្ញុំអន្ទោលទៅក្នុងភព តូចភពធំ រមែងបានជាធំក្នុងទីទាំងពួង ។ ខ្ញុំបានជាមហេសី នៃស្តេចចក្រពត្តិ ៦៣ ដង ជនទាំងពួង តែងប្រព្រឹត្តតាមខ្ញុំ ខ្ញុំមានពាក្យ គួរអ្នកផងជឿកាន់តាម ។ ពណ៌និងក្លិនរបស់ខ្ញុំ តែងផ្សាយទៅ ដូចជាក្លិននៃផ្កាឧប្បល ខ្ញុំមិនដែលស្គាល់ ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនពោជ្ឈង្គ ដល់នូវអភិញ្ញាបារមី នេះជា ផលនៃពុទ្ធបូជា ។ ខ្ញុំជាស្រីឈ្លាសក្នុងសតិប្បដ្ឋាន មានសមាធិជ្ឈានជាអារម្មណ៍ ប្រកបរឿយ ៗ នូវសម្មប្បធាន នេះជា ផលនៃពុទ្ធបូជា ។ សេចក្តីព្យាយាមរបស់ខ្ញុំ ជាគ្រឿងនាំទៅ នូវធុរៈ នាំមកនូវធម៌ក្សេមចាកយោគៈ ខ្ញុំមានអាសវៈអស់ ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុង កាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

នវមំ បញ្ចទីបិកាថេរិយាបទានំ

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សត្តុប្បលមាលិកា ភិក្ខុនី
ឥមា គាថាយោ អភាសិត្ថាតិ ។

សត្តុប្បលមាលិកាថេរិយាបទានំ សមត្តំ ។

## នវមំ បញ្ចទីបិកាថេរិយាបទានំ

(៩) នគរេ ហំសវតិយា ចារិនី(១) អាសហំ តទា
អារាមេនេវ(២) អារាមំ ចរាមិ កុសលត្ថិកា ។
កាឡបក្ខម្ហិ ទិវសេ អទ្ទសំ ពោធិមុត្តមំ
តត្ថ ចិត្តំ បសាទេត្វា ពោធិមូលេ និសីទហំ ។

---

១ ឱ. ម. ចារិកី ។ ២ ឱ. ម. អារាមេន ច ។

កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ៗ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

បានឮថា ព្រះសត្តុប្បលមាលិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៗ

ចប់ សត្តុប្បលមាលិកាថេរិយាបទាន ។

## បញ្ចទីបិកាថេរិយាបទាន ទី ៩

(៩) ក្នុងកាលនោះ ខ្ញុំជាអ្នកដំណើរ នៅអាស្រ័យក្នុងនគរហង្សវតី ជាស្រីពេញចិត្តក្នុងកុសល តែងទៅអំពីអារាម ទៅកាន់អារាម ៗ ខ្ញុំបានឃើញនូវពោធិព្រឹក្សដ៏ឧត្តម ក្នុងថ្ងៃកាឡបក្ខ ញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះពោធិ-ព្រឹក្សនោះ ហើយអង្គុយនៅក្បែរគល់ នៃពោធិព្រឹក្ស ៗ

ករុចិត្តំ ឧបដ្ឋេត្វា(១) សិរេ កត្វាន អញ្ជលឹ
សោមនស្សំ បវេទេត្វា ឃរំ ចិន្តេសិ តាវទេ ។
យទិ ពុទ្ធោ អមិតគុណោ អសមប្បដិបុគ្គលោ
ទស្សេតុ បាដិហីរំ មេ ពោធិ ឱភាសតុ អយំ ។
សហ អាវជ្ជិតេ មយ្ហំ ពោធិ បជ្ជលិ តាវទេ
សព្វសោវណ្ណមយា អាសិ ទិសា សព្វា វិរោចតិ ។
សត្តរត្តិន្ទិវំ តត្ថ ពោធិមូលេ និសីទហំ
សត្តមេ ទិវសេ បត្តេ ទីបបូជំ អកាសហំ ។
អាសនំ បរិវារេត្វា បញ្ចទីបានិ បជ្ជលុំ
យាវ ឧទេតិ សុរិយោ ទីបា មេ បជ្ជលុំ តទា ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ បញ្ចទីបាតិ វុច្ចតិ
សតយោជនមុព្វេធំ សដ្ឋិយោជនវិត្ថតំ(២) ។
អសង្ខេយ្យានិ ទីបានិ បរិវារេ ជលន្តិ មេ
យាវតា ទេវភវនំ ទីបាលោកេន ជោតតិ(៣) ។

---

១ ម. ឧបដ្ឋិត្វា ។ ២ ម. សដ្ឋិយោជនមុព្វេធំ ។ ម. តឹសយោជនវិត្ថតំ ។ ៣ ឱ. ជោតយិ ។

ខ្ញុំតាំងចិត្តគោរព ធ្វើអញ្ជលីលើក្បាល ហើយទទួលនូវសោមនស្ស ក៏គិតយ៉ាងនេះ ក្នុងខណៈនោះថា បើព្រះពុទ្ធមានគុណរាប់មិនបាន មិនមានបុគ្គលប្រៀបផ្ទឹមស្មើបានមែន សូមឲ្យពោធិព្រឹក្សនេះ សម្ដែងនូវបាដិហារ្យដល់អាត្មាអញ គឺសូមឲ្យភ្លឺស្វាងចុះ ៗ ក្នុងខណៈនោះ ពោធិព្រឹក្សប្រែជាមាសទាំងអស់ ភ្លឺស្វាងឡើងដំណាលគ្នានឹងខ្ញុំកំពុងពិចារណាឯទិសទាំងពួង ក៏ភ្លឺរុងរឿងឡើង ៗ ខ្ញុំអង្គុយនៅក្បែរគល់ពោធិព្រឹក្សនោះ អស់ ៧ យប់ ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ខ្ញុំបានបូជាប្រទីប ៗ ប្រទីបទាំង ៤ ក៏ភ្លឺរុងរឿងព័ទ្ធអាសនៈ កាលនោះ ប្រទីបទាំងឡាយរបស់ខ្ញុំ ក៏ភ្លឺរុងរឿង ដរាបដល់ព្រះអាទិត្យរះឡើង ៗ ខ្ញុំលះបង់នូវរាងកាយ ជារបស់មនុស្ស បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ៗ ប្រាសាទរបស់ខ្ញុំ ដែលបុញ្ញកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ ហៅថាបញ្ចទីបប្រាសាទ មានកម្ពស់ ១០០ យោជន៍ មានទំហំ ៦០ យោជន៍ ៗ ប្រទីបទាំងឡាយរបស់ខ្ញុំរាប់មិនអស់ តែងភ្លឺរុងរឿងជុំវិញខ្ញុំ ទាំងកពទេវតា ក៏ភ្លឺដោយពន្លឺប្រទីបនោះដែរ ៗ

## នវមំ បញ្ចទីបិកាថេរិយាបទានំ

បុរត្ថាភិមុខា(១) សន្តិ(២) យទិ ឥច្ឆាមិ បស្សិតុំ
ឧទ្ធំ អធោ ច តិរិយំ សព្វំ បស្សាមិ ចក្ខុនា ។
យាវតា អភិកង្ខាមិ ទដ្ឋុំ សុកតទុក្កដំ(៣)
តត្ថ អាវរណំ នត្ថិ រុក្ខេសុ បព្វតេសុ វា ។
អសីតិទេវរជ្ជំ មហាសិត្តមការយិំ
សតានំ ចក្កវត្តីនំ មហាសិត្តមការយិំ ។
យំ យំ យោនុបបជ្ជាមិ ទេវត្តំ អថ មានុសំ
ទីបសតសហស្សានិ បរិវារេ ជលន្តិ មេ ។
ទេវលោកា ចវិត្វាន ឧប្បជ្ជឹ(៤) មាតុកុច្ឆិយំ
មាតុ កុច្ឆិគតំ(៥) សន្តិ(៦) អក្ខិ មេ ន និមីលតិ ។
ទីបសតសហស្សានិ បុញ្ញកម្មសមង្គិនោ(៧)
សូតិឃរេ ជលន្តិ បញ្ចទីបានិទំ ផលំ ។
បច្ឆិមេ ភវេ សម្បត្តេ មានសំ វិនិវត្តយឹ
អជរាមរំ(៨) សីតិភាវំ និព្វានំ បស្សយឹ អហំ ។

---

១ ឱ. បរំមុខា ។ ២ ឱ. បីតា ។ ម. និសីទិត្វា ។ ៣ ឱ. សុកតទុក្កដេ ។ ម. សុកតទុក្កតេ ។ ៤ ឱ. ឧប្បជ្ជិ ។ ៥ ឱ. កុច្ឆិគតា ។ ៦ ឱ. សន្តី ។ ម. សន្តិ ។ ៧ ឱ. បុញ្ញកម្មសមង្គិតា ។ ម បុញ្ញកម្មសមង្គិកា ។ ៨ ឱ. អជរាមរណំ ។ ម. អជរាមតំ ។

## បញ្ចទីបិកត្ថេរាបទាន ទី ៥

ខ្ញុំអង្គុយបែរមុខទៅរកទិសខាងកើត បើខ្ញុំប្រាថ្នាដើម្បីមើលខាងលើ ខាងក្រោម និងទីទទឹង ខ្ញុំនឹងឃើញនូវវត្ថុទាំងពួងដោយចក្ខុ ។ ខ្ញុំប្រាថ្នាដើម្បីឃើញនូវកម្ម ដែលខ្ញុំធ្វើល្អនិងអាក្រក់ ដរាបណា គ្រឿងបិទបាំងក្នុងវត្ថុទាំងនោះ ទោះជាឈើឬភ្នំក៏មិនមាន ដរាបនោះ ។ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ១០០ ដង ។ ខ្ញុំដែលទៅកាន់កំណើតណា ៗ ទោះជាទេវតា ឬជាមនុស្ស ប្រទីបមួយសែន តែងបំភ្លឺជុំវិញខ្លួនខ្ញុំ ។ ខ្ញុំច្យុតចាកទេវលោក មកកើតក្នុងផ្ទៃនៃមាតា ភ្នែករបស់ខ្ញុំ ដែលនៅក្នុងផ្ទៃនៃមាតានោះ មិនដែលធ្មេចឡើយ ។ ប្រទីបមួយសែន ប្រកបដោយបុញ្ញកម្ម រមែងរុងរឿង ក្នុងផ្ទះជាទីប្រសូតិ នេះជាផលនៃប្រទីប ៥ ។ កាលភពជាទីបំផុតដល់ព្រម ហើយ ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅ ខ្ញុំឃើញនូវព្រះនិព្វាន ដែលមិនមានជរា និងមរណៈ មានសេចក្តីត្រជាក់ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ជាតិយា សត្តវស្សាហំ   អរហត្តំ អបាបុណឹ
ឧបសម្បាទយី ពុទ្ធោ   គុណមញ្ញាយ គោតមោ ។
មណ្ឌបេ រុក្ខមូលេ វា   បាសាទេសុ គុហាសុ វា
សុញ្ញាគារេ បជ្ឈាយន្តា(១)   បញ្ចទីបា ជលន្តិ មេ ។
ទិព្វចក្ខុ វិសុទ្ធំ មេ   សមាធិកុសលា អហំ
អភិញ្ញាបារមិប្បត្តា   បញ្ចទីបាជិនំ ជលំ ។
សព្វវោសិតវោសានា   កតកិច្ចា អនាសវា
បញ្ចទីបា មហាវីរ   បាទេ វន្ទាមិ ចក្ខុមា ។
សតសហស្សេតោ កប្បេ   យំ ទីបមទទី តទា
ទុគ្គតឹ នាភិជានាមិ   បញ្ចទីបាជិនំ ជលំ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. ម. សុញ្ញាគារេ ច ឈាយន្តា ។

ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត បានដល់នូវព្រះអរហត្ត ព្រះពុទ្ធព្រះនាមគោតម ទ្រង់ជ្រាបនូវគុណ ហើយឲ្យខ្ញុំបានឧបសម្បទា ។ ប្រទីបទាំង ៤ របស់ខ្ញុំ រមែងឆេះឡើងក្នុងមណ្ឌប ជិតគល់ឈើក្នុងប្រាសាទ ក្នុងគុហា ក្នុងផ្ទះស្ងាត់ ។ ទិព្វចក្ខុរបស់ខ្ញុំស្អាតវិសេស ខ្ញុំជាស្រីឈ្លាសក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃប្រទីប ៤ ។ បវិត្រព្រះអង្គមានព្យាយាមធំ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គមានការប្រព្រឹត្តធម៌ទាំងពួង ចប់អស់ហើយ មានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈ មានប្រទីប ៤ ខ្ញុំសូមថ្វាយបង្គំព្រះបាទា ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយប្រទីប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រទីប ៤ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។
ឥត្ថំ សុទំ អាយស្មា បញ្ចទីបិកា ភិក្ខុនី ឥមា
គាថាយោ អភាសិត្ថាតិ ។

បញ្ចទីបិកាថេរិយាបទានំ សមត្តំ ។

# ទសមំ ឧទកទាយិកាថេរិយាបទានំ

(១០) នគរេ ពន្ធុមតិយា អាសឹ ឧទកហារិកា[១]
ឧទហារេន[២] ជីវាមិ តេន បោសេមិ ទារកេ ។
ទេយ្យធម្មោ ច មេ នត្ថិ បុញ្ញក្ខេត្តេ អនុត្តរេ
កោដ្ឋកំ ឧបសង្កម្ម ឧទកំ បដ្ឋបេសហំ ។
តេន កម្មេន សុកតេន តាវត្តឹសំ អគញ្ឆហំ
តត្ថ មេ សុកតំ ព្យម្ហំ ឧទហារេន និម្មិតំ ។
អច្ឆរានំ សហស្សស្ស អហំ ហិ[៣] បវរា តទា
ទសដ្ឋានេហិ តា សព្វា អភិភោមិ តទា[៤] អហំ ។

---

១ ម. អហោសឹ ឧទហារិកា ។ ឱ. អាសឹ ឧទកហារិកា ។ ២ ឱ. ឧទហារេន ។ ៣ ឱ. អហម្បិ ។ ឱ. ម. សទា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបញ្ចទីបិកាភិក្ខុនី មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ចប់ បញ្ចទីបិកាថេរិយាបទាន ។**

# ឧទកទាយិកាថេរិយាបទាន ទី ១០

(១០) ខ្ញុំជាស្រីដងទឹក ក្នុងនគរពន្ធុមតី រស់នៅដោយការដងទឹក ចិញ្ចឹមទារកដោយការដងទឹកនោះ ។ ឯទេយ្យធម៌ របស់ខ្ញុំមិនមាន ខ្ញុំចូលទៅក្នុងបន្ទប់ បានតម្កល់ទុកនូវទឹក ចំពោះបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ ។ ខ្ញុំបានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះ ខ្ញុំមានវិមានខ្ញុំដ៏ល្អ ដែលជាផលនៃការដងទឹក បាននិម្មិតឲ្យ ក្នុងឋានតាវត្តិង្សនោះ ក្នុងកាលនោះ ខ្ញុំប្រសើរជាងពួកស្រីអប្សរ ១.០០០ នាក់ កាលនោះ ខ្ញុំគ្របសង្កត់ នូវស្រីអប្សរទាំងនោះ ដោយហេតុ ១០ យ៉ាង ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

បញ្ញាសំ ទេវរជ្ជំ មហោសិត្តមការយឹ
វីសតិចក្កវត្តីនំ មហោសិត្តមការយឹ ។
ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ
ទុគ្គតឹ នាភិជានាមិ ឧទកទានស្សិទំ ផលំ ។
បព្វតគ្គេ ទុមគ្គេ វា អន្តលិក្ខេ ច ភូមិយំ
យទា ឧទកមិច្ឆាមិ ខិប្បំ បដិលភាមហំ ។
អវុដ្ឋិកា ទិសា អត្ថិ[1] សន្តត្តា ខុប្បិតា ហិ នេ[2]
មម សង្កប្បមញ្ញាយ មហាមេឃោ បវស្សតិ ។
កទាចិ ធីយមានាយ ញាតិសង្ឃេន មេ តទា
យទា ឥច្ឆាមហំ វស្សំ មហាមេឃោ អជាយថ ។
ឧណ្ហំ វា បរិឡាហោ វា សរីរេ មេ ន វិជ្ជតិ
កាយេ ច មេ រជោ នត្ថិ ឧទកទានស្សិទំ ផលំ ។
វិសុទ្ធមនសា អជ្ជ អបេតមនធាបិកា
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។

---

១ ឱ. ម. នត្ថិ ។ ២ ឱ. សន្តត្តកឋិតា ន ប ។ ម. សន្តត្តកុឋិតាបិ ច ។

ខ្ញុំបានជាមហេសី នៃទេវរាជ ៩០ ដង បានជាមហេសី នៃស្តេចចក្រពត្តិ ២០ ដង ។ ខ្ញុំអន្ទោលទៅក្នុងភពទាំងពីរ គឺទេវតា និងមនុស្ស ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃទានទឹក ។ កាលណា ខ្ញុំចង់បានទឹក លើកំពូលភ្នំក្តី លើចុងឈើក្តី ឰដ៏អាកាសក្តី លើផែនដីក្តី ខ្ញុំក៏បានទទួលទឹកយ៉ាងឆាប់ ក្នុងកាលនោះ ទិសទាំងឡាយមិនធ្លាប់ភ្លៀងធ្លាក់សោះ ក៏ក្តៅសព្វ ខ្ញុំស្រែកទឹក មហាមេឃ បានដឹងនូវតម្រិះរបស់ខ្ញុំ ក៏បង្អុរភ្លៀងចុះមក ។ ជួនណា កាលពួកញាតិកំពុងនាំខ្ញុំទៅ ខ្ញុំចង់បានទឹក ក្នុងកាលណា មហាមេឃ ក៏ញាំងភ្លៀងឲ្យកើត ក្នុងកាលនោះ ។ កម្តៅក្តី សេចក្តីក្រហល់ក្រហាយក្តី មិនមានក្នុងសរីរៈរបស់ខ្ញុំឡើយ ធូលីក៏មិនមាន ក្នុងកាយរបស់ខ្ញុំ នេះជាផលនៃទានទឹក ។ ក្នុងថ្ងៃនេះ ខ្ញុំមានចិត្តស្អាតបរិសុទ្ធ ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

### ទសមំ ឧទកយិកាថេរិយាបទានំ

ឯកនវុតេ ឥតោ កប្បេ យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ ឧទកទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧទកទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ឧទកទាយិកាថេរិយាបទានំ សមត្តំ ។

## ឧទកទាយិកាថេរិយាបទាន ទី ១០

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃទានទឹក ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧទកទាយិកាភិក្ខុនី មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧទកទាយិកាថេរិយាបទាន ។

## ឧទ្ទានំ

សុមេធា មេខលទទា(១) មណ្ឌបសង្កមទ្ទទា(២)
នឡមាលិនី បិណ្ឌទទា(៣) កដច្ឆុឧប្បលប្បទា ។
ទីបោទកទាយី ច(៤) គាថាយោ គណិតាវិហ
ឯកគាថា សតញ្ចេវ សត្តរសំ(៥) តទុត្តរិ(៦) ។

សុមេធាវគ្គោ បឋមោ ។

---

១ ឱ. មេខលាទទា ។ ម. សុមេខលា ច ។ ២ ឱ. មណ្ឌបសង្កមន្ទទា ។ ៣ ម. បិណ្ឌពពា ។ ៤ ឱ. ទីបទោទកទា ចេវ ។ ៥ ឱ. សតាទស ។ ម. តឹសតិ ច ។ ៦ ឱ. តទុត្តរឹ ។

## ឧទ្ទាន

សុមេធាថេរិយាបទាន ១ មេខលទាយិកាថេរិយាបទាន ១ មណ្ឌបទាយិកាថេរិយាបទាន ១ សង្កមនទាថេរិយាបទាន ១ នឡមាលិកាថេរិយាបទាន ១ ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ១ កដច្ឆុភិក្ខទាយិកាថេរិយាបទាន ១ សត្តុប្បលមាលិកាថេរិយាបទាន ១ បញ្ចទីបិកាថេរិយាបទាន ១ ឧទកទាយិកាថេរិយាបទាន ១ ក្នុងវគ្គនេះ មានគាថា ១១៨ ដែលអ្នកប្រាជ្ញទាំងឡាយរាប់ឃើញហើយ ។

ចប់ សុមេធាវគ្គ ទី ១ ។

# ទុតិយោ ឯកុបោសថវគ្គោ(១)

## បឋមំ ឯកុបោសថិកាថេរិយាបទានំ

[១១] នគរេ ពន្ធុមតិយា ពន្ធុមា នាម ខត្តិយោ
ទិវសេ បុណ្ណមាយ សោ ឧបវសិ ឧបោសថំ ។
អហំ តេន សមយេន កុម្ភទាសី អហុ(២) តហិំ
ទិស្វា សរាជិកំ សេនំ ឯវាហំ ចិន្តយឹ តទា ។
រាជាបិ រជ្ជំ ឆឌ្ឌេត្វា ឧបវសិ(៣) ឧបោសថំ
សផលំ នូន តំ កម្មំ ជនកាយោ បមោទិតោ ។
យោនិសោ បច្ចវេក្ខិត្វា ទុគ្គតិញ្ច ទលិទ្ទតំ
មានសំ សម្បហំសិត្វា ឧបវសឹ ឧបោសថំ ។
អហំ ឧបោសថំ កត្វា សម្មាសម្ពុទ្ធសាសនេ
តេន កម្មេន សុកតេន តាវតឹសំ អគញ្ឆហំ ។

---

១ ឯកុបោសថិកវគ្គោ ។ ២ ឱ. អហុំ ។ ម. អហំ ។ ៣ ម. ឧបវសិំ ។

# ឯកុបោសថវគ្គ ទី ២

## ឯកុបោសថិកាថេរិយាបទាន ទី ១

(១១) មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់ព្រះនាមពន្ធុមៈ សោយរាជ្យក្នុងនគរពន្ធុមតី ព្រះអង្គរក្សាឧបោសថ ក្នុងថ្ងៃពេញបូណ៌មី ។ សម័យនោះ ខ្ញុំជាកុម្ភទាសី នៅក្នុងទីនោះ ខ្ញុំបានឃើញសេនា ព្រមទាំងព្រះរាជា ហើយក៏គិតយ៉ាងនេះថា សូម្បីស្តេចក៏ទ្រង់លះបង់រាជសម្បត្តិ ហើយរក្សាឧបោសថ កម្មនោះ ពិតជាប្រកបដោយផល បានជាពួកជនរីករាយហើយ ។ ខ្ញុំពិចារណានូវទុគ្គតិផង នូវសេចក្តីក្រីក្រផង ដោយឧបាយនៃប្រាជ្ញា ក៏ញ៉ាំងចិត្តឲ្យរីករាយ ហើយរក្សាឧបោសថ ។ លុះខ្ញុំរក្សាឧបោសថ ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធ ខ្ញុំក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

តត្ថ មេ សុកតំ ព្យម្ហំ ឧទ្ធំ(១) យោជនមុគ្គតំ
កូដាគារវរូបេតំ មហាសនំ សុភូសិតំ(២) ។
អដ្ឋរ សតសហស្សា ឧបតិដ្ឋន្តិ មំ សទា
អញ្ញោ ទេវ(៣) អតិក្កម្ម អតិរោចាមិ សព្វទា ។
ចតុស្សដ្ឋិទេវរជ្ជំ មហេសិត្តមការយឹ
តេសដ្ឋិចក្កវត្តីនំ មហេសិត្តមការយឹ ។
សុវណ្ណវណ្ណា ហុត្វាន ភវេសុ សំសរាមហំ
សព្វត្ថ បវរា ហោមិ ឱភាសជស្សិទំ ផលំ ។
ហត្ថិយានំ អស្សយានំ រថយានញ្ច កោវលិំ(៤)
លភាមិ សព្វមេតម្បិ ឱភាសជស្សិទំ ផលំ ។
សោវណ្ណមយំ រូបិមយំ អថោបិ ផលិកាមយំ
លោហិតង្គមយញ្ចេវ សព្វំ បដិលភាមហំ ។
កោសេយ្យកម្ពលកានិ(៥) ខោមកប្បាសិកានិ ច
មហគ្ឃានិ ច វត្ថានិ សព្វំ បដិលភាមហំ ។

---

១ ឱ. ឧច្ចំ ។ ម. ឧច្ច ។ ២ ឱ. មហាសយនភូសិតំ ។ ៣ ឱ. ម. អញ្ញេ ទេវេ ។
៤ ប. សិវិកំ ។ ៥ ឱ ប. កោសេយ្យកម្ពលិយានិ ។

វិមានរបស់ខ្ញុំ ដែលកុសលធ្វើល្អហើយក្នុងទីនោះ មានកំពស់ទៅខាងលើមួយយោជន៍ ប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈធំ ស្អិតស្អាងល្អហើយ ។ ស្រីអប្សរមួយសែន តែងបម្រើខ្ញុំ សព្វ ៗ កាល ខ្ញុំរុងរឿងកន្លងលើសទេវតាទាំងឡាយដទៃសព្វ ៗ កាល ។ ខ្ញុំបានជាមហេសីនៃទេវេន្ទ ៦៤ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ៣៦ ដង ។ ខ្ញុំមានពណ៌ដូចជាមាស តែងអន្ទោលទៅក្នុងភពទាំងឡាយ ខ្ញុំជាស្រីប្រសើរក្នុងទីទាំងពួង នេះជាផលនៃឧបោសថ ។ ខ្ញុំតែងបាននូវវត្ថុទាំងពួងនេះ គឺ យានដំរី យានសេះ យានរថទាំងអស់ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួង ជាវិការៈនៃមាស ជាវិការៈនៃប្រាក់ ជាវិការៈនៃកែវផលិក ជាវិការៈនៃកែវមានពណ៌ក្រហម ។ ខ្ញុំបាននូវវត្ថុទាំងពួង គឺ សំពត់កោសេយ្យពស្ត្រ និងសំពត់កម្ពលផង សំពត់សម្បកឈើ និងសំពត់អំបោះផង សំពត់មានថ្លៃដ៏ច្រើនផង ។

## បឋមំ ឯកុបោសថិកាថេរិយាបទានំ

អន្នបានំ ខាទនីយំ    វត្ថសេនាសនានិ ច
សព្វមេតំ បដិលភេ    ឧបោសថស្សិទំ ផលំ ។
វរគន្ធញ្ច មាលញ្ច    ចុណ្ណកញ្ច វិលេបនំ
សព្វមេតំ បដិលភេ    ឧបោសថស្សិទំ ផលំ ។
កូដាគារញ្ច បាសាទំ    មណ្ឌបំ ហម្មិយំ គុហំ
សព្វមេតំ បដិលភេ    ឧបោសថស្សិទំ ផលំ ។
ជាតិយា សត្តវស្សាហំ    បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ    អរហត្តំ អបាបុណឹ
សព្វាសវបរិក្ខីណា    នត្ថិ ទានិ បុនព្ភវោ ។
ឯកនវុតេ ឥតោ កប្បេ    យំ កម្មមករឹ តទា
ទុគ្គតឹ នាភិជានាមិ    ឧបោសថស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ    ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។

## ឯកុបោសថិកាថេរិយាបទាន ទី ១

ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺ បាយ ទឹក ខាទនីយៈ សំពត់ទិន សេនាសនៈ នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងពួងនេះ គឺ គ្រឿងក្រអូបដ៏ប្រសើរ និងកម្រងផ្កា លំអិតសម្រាប់លាប នេះជាផលនៃឧបោសថ ។ ខ្ញុំបាននូវវត្ថុទាំងនេះ គឺ ផ្ទះមានកំពូល ប្រាសាទ មណ្ឌប ប្រាសាទមានដំបូលរលីង និងគុហា នេះជាផលនៃឧបោសថ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត បានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ក៏បានសម្រេចព្រះអរហត្ត ខ្ញុំមានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានធ្វើកុសលកម្ម ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃឧបោសថ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកុបោសថិកោ ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកុបោសថិកាថេរិយាបទានំ សមត្តំ ។

## ទុតិយំ សលឡបុប្ផិកាថេរិយាបទានំ

(១២) ចន្ទភាគានទីតីរេ អហោសឹ កិន្នរី តទា
អទ្ទសំ(១) ទេវទេវំ ចង្កមន្តំ នរាសភំ ។
ឱចិនិត្វា សលឡបុប្ផំ(២) ពុទ្ធសេដ្ឋស្សទាសហំ
ឧបសិង្ឃិ(៣) មហាវីរោ សលឡំ ទេវគន្ធិកំ ។
បដិគ្គហេត្វា សម្ពុទ្ធោ វិបស្សី លោកនាយកោ
ឧបសិង្ឃិ(៣) មហាវីរោ បេក្ខមានាយ មេ តទា ។

---

១ ម. អទ្ទសំហំ ។ ២ ឱ. ម. ឱចិនិត្វាន សលឡំ ។ ៣ ឱ. ឧបសិង្ឃយិ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកុបោសថិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកុបោសថិកាថេរិយាបទាន ។

# សលឡបុប្ផិកាថេរិយាបទាន ទី ២

(១២) ក្នុងកាលនោះ ខ្ញុំកើតជាកិន្នរី នៅត្រើយស្ទឹងចន្ទភាគា គ្រានោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ជាទេវតាប្រសើរជាងទេវតា ព្រះអង្គប្រសើរជាងនរជន ទ្រង់កំពុងចង្រ្កម ។ ខ្ញុំបានបេះផ្កាស្រល់ យកទៅថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ឯព្រះមហាវីរៈ ទ្រង់ហិតនូវផ្កាស្រល់ ដែលមានក្លិនដូចជាទិព្វ ។ ព្រះសម្ពុទ្ធព្រះនាមវិបស្សី ជាលោក-នាយក មានព្យាយាមធំ ទ្រង់បានទទួលយកហើយ កាលដែលខ្ញុំកំពុងតែសំឡឹងមើល ទ្រង់ក៏ហិតក្នុងកាលនោះ ។

## ទុតិយំ សលឡបុប្ផិកាថេរិយាបទានំ

អញ្ជលឹ បគ្គហេត្វាន វន្ទិត្វា ទិបទុត្តមំ
សកំ ចិត្តំ បសាទេត្វា តតោ បព្វតមារុហឹ ។
ឯកានវុតេ ឥតោ កប្បេ យំ បុប្ផមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សលឡបុប្ផិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

សលឡបុប្ផិកាថេរិយាបទានំ សមត្តំ ។

## សលឡបុប្ផិកាថេរិយាបទាន ទី ២

ខ្ញុំផ្គងអញ្ជលីថ្វាយបង្គំព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងសត្វជើងពីរ ខ្ញុំញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ឡើងទៅកាន់ភ្នំ ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំ បានថ្វាយផ្កាក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសលឡបុប្ផិកត្ថេរ មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សលឡបុប្ផិកាថេរិយាបទាន ។

# តតិយំ មោទកទាយិកាថេរិយាបទានំ

(១៣) នគរេ ពន្ធុមតិយា កុម្ភទាសី អហោសហំ
មម ភាគំ គហេត្វាន គច្ឆំ(១) ឧទកហារិកេ(២) ។
បន្ថម្ហិ សមណំ ទិស្វា សន្តចិត្តំ សមាហិតំ
បសន្នចិត្តា សុមនា មោទកេ តីណិទាសហំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ឯកត្តឹស(៣) កប្បានិ វិនិបាតំ ន អគច្ឆហំ(៤) ។
សម្បត្តិញ្ច ករិត្វាន សព្វំ អនុភវឹ អហំ
មោទកេ តីណិ ទត្វាន បត្តាហំ អចលំ បទំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. គច្ឆី ។ ២ ឱ. ឧទកភារិកា ។ ម. ឧទកហារិកា ។ ៣ ឱ. ម. ឯកនវុតិ ។
៤ ឱ. ម នគច្ឆហំ ។

# មោទកទាយិកាថេរិយាបទាន ទី ៣

(១៣) ខ្ញុំជាកុម្ភទាសី នៅក្នុងនគរពន្ធុមតី បានកាន់យកនូវចំណែក (នំអន្សម) របស់ខ្ញុំ ហើយទៅកាន់កំពង់ទឹក ។ ខ្ញុំបានឃើញសមណៈមួយរូប ក្នុងទីពាក់កណ្ដាលផ្លូវ លោកមានចិត្តស្ងប់ស្ងាត់ មានចិត្តតម្កល់មាំមួន ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានប្រគេននំអន្សម ៣ ។ ខ្ញុំមិនដែលទៅកាន់វិនិបាតអស់ ២៩ កប្ប ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំធ្វើនូវកុសលហើយ ខ្ញុំបានទទួលសម្បត្តិទាំងអស់ ព្រោះបានធ្វើកុសលឲ្យជាសម្បត្តិ ខ្ញុំបានដល់នូវអចលបទ គឺព្រះនិព្វាន ព្រោះប្រគេននំអន្សម ៣ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មោទកទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

មោទកទាយិកាថេរិយាបទានំ សមត្តំ ។

## ចតុត្ថំ ឯកាសនទាយិកាថេរិយាបទានំ

(១៤) នគរេ ហំសវតិយា អហោសឹ មាលិកា តទា
មាតា ច មេ បិតា ចេវ កម្មន្តំ អគមំសុ តេ ។
មជ្ឈន្តិកម្ហិ សុរិយេ អទ្ទសំ សមណំ អហំ
វីថិយា អនុគច្ឆន្តំ អាសនំ បញ្ញបេសហំ ។
គោណកចិត្តកាទីហិ បញ្ញបេត្វាហមាសនំ[1]
បសន្នចិត្តា សុមនា ឥទំ វចនមព្រវឹ ។
សន្តត្តា កឋិតា[2] ភូមិ សូរោ មជ្ឈន្តិកោ[3] ឋិតោ
មាលុតា ច ន វាយន្តិ កាលោ ចេវត្ថ មេហិតិ[4] ។

---

១ ឱ. បញ្ញបេត្វា ហភាសនំ ។ ម. បញ្ញបេត្វា មមាសនំ ។ ២ ម. កុឋិតា ។ ឱ. ម. មជ្ឈន្តិកេ ។ ៤ ឱ. ចេវត្ថមេតិកំ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមោទកទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មោទកទាយិកាថេរិយាបទាន ។

# ឯកាសនទាយិកាថេរិយាបទាន ទី ៤

(១៤) ក្នុងកាលនោះ ខ្ញុំជាស្រីក្រងផ្កា នៅក្នុងនគរហង្សវតី មាតាបិតារបស់ខ្ញុំទាំងនោះ បានទៅធ្វើការងារ ។ កាលព្រះអាទិត្យកំពុងត្រង់ជាក់ ខ្ញុំឃើញព្រះសម្ពុទ្ធ ជាសមណៈកំពុងនិមន្តទៅតាមថ្នល់ ខ្ញុំក៏ក្រាលអាសនៈ ។ ខ្ញុំក្រាលអាសនៈដោយកម្រាល មានព្រំដែលមានរោមវែង ៤ ធ្នាប់ និងកម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ ជាដើម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានពោលពាក្យនេះថា ផែនដីក្តៅណាស់ ឈរនៅពុំបាន ព្រះអាទិត្យកំពុងត្រង់ជាក់ ខ្យល់ក៏មិនបក់ ទាំងកត្តកាល ក៏ជិតអស់ ។

បញ្ញត្តមាសនមិទំ តវត្ថាយ មហាមុនិ

អនុកម្បំ ឧបាទាយ និសីទ មម អាសនេ ។

និសីទិ តត្ថ សមណោ សុទន្តោ សុទ្ធមានសោ

តស្ស បត្តំ គហេត្វាន យថារទ្ធំ អទាសហំ ។

តេន កម្មេន សុកតេន ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ តាវត្តិំសំ អគញ្ឆហំ ។

តត្ថ មេ សុកតំ ព្យម្ហំ អាសនេន សុនិម្មិតំ

សដ្ឋិយោជនមុព្វេធំ តិំសយោជនវិត្ថតំ ។

សោណ្ណមយា មណិមយា អថោបិ ផលិកាមយា

លោហិតង្គមយា ចេវ បល្លង្កា វិវិធា មម ។

បពិត្រព្រះមហាមុនី អាសនៈនេះ ខ្ញុំក្រាលហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ សូមព្រះអង្គអាស្រ័យ នូវសេចក្តីអនុគ្រោះ គង់លើអាសនៈ របស់ខ្ញុំ ។ ព្រះសមណៈមានព្រះទ័យទូន្មានហើយ មានព្រះទ័យបរិសុទ្ធ គង់លើអាសនៈនោះ ខ្ញុំទទួលយកបាត្រនៃព្រះអង្គ បានប្រគេនចង្ហាន់ សមគួរដល់ការបំអិន ។ ខ្ញុំលះបង់រាងកាយ ជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ វិមានរបស់ខ្ញុំល្អ ត្រូវផលនៃអាសនៈនិម្មិតហើយ ក្នុងឋានតាវត្តិង្សនោះ មានកំពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ បល្ល័ង្កផ្សេងៗ របស់ខ្ញុំ ជាវិការៈនៃមាស ជាវិការៈនៃកែវមណី ជាវិការៈនៃកែវផលិក ជាវិការៈនៃមាសមានពណ៌ក្រហម ។

## ចតុត្ថំ ឯកាសនទាយិកាថេរិយាបទានំ

តូលិកាវិកតីហិ ច[១] កដិស្សចិត្តកាហិ ច[២]

ឧទ្ធំ ឯកន្តលោមិ ច បល្លង្កា មេ សុសណ្ឋិតា ។

យទា ឥច្ឆាមិ គមនំ ហាសខិឌ្ឌសមប្បិតា

សហ បល្លង្កសេដ្ឋេន គច្ឆាមិ មម បត្ថិតំ ។

អសីតិទេវរាជូនំ មហេសិត្តមការយឹ

សត្តតិចក្កវត្តីនំ មហេសិត្តមការយឹ ។

ភវាភវេ សំសរន្តី មហាភោគំ លភាមហំ

ភោគេ មេ ឩនតា នត្ថិ ឯកាសនផលំ ឥទំ ។

ទុវេ ភវេ សំសរាមិ ទេវត្តេ អថ មានុសេ

អញ្ញេ ភវេ ន ជានាមិ ឯកាសនផលំ ឥទំ ។

---

១ ឱ. ម. តូលិកាវិកត្ថិកាហិ ។ ២ ឱ. កដ្ឋិស្សវិកត្តិកាហិ ច ។

ឯកាសនទាយិកាថេរិយាបទាន ទី ៤

កម្រាលធ្វើដោយរោមសត្វ មានរោមប្រាំងទាំងពីរខាង បល្ល័ង្ក របស់ខ្ញុំ តាំងនៅល្អហើយ ដោយកម្រាលដែលញាត់ដោយគរ និងកម្រាលដែលធ្វើដោយរោមសត្វ ដ៏វិចិត្រដោយរូបសត្វ មានសីហៈនិងខ្លាធំជាដើមផង ដោយកម្រាលដែលធ្វើដោយ ឱនមាសនិងសូត្រ ហើយចាក់ស្រេះដោយរតនៈនិងកម្រាល ដែលធ្វើដោយរោមសត្វ វិចិត្រដោយរោមសត្វសាហាវផង ៗ ខ្ញុំស្កប់ស្កល់ដោយការសើចនិងការលេង កាលណា ខ្ញុំចង់ ទៅ ខ្ញុំក៏ទៅកាន់ទីដែលខ្ញុំប្រាថ្នា មួយអន្ទើដោយបល្ល័ង្ក ដ៏ប្រសើរ (ក្នុងកាលនោះ) ៗ ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ៧០ ដង ៗ ខ្ញុំ អន្ទោលទៅក្នុងភពតូចភពធំ តែងបានទូវភោគៈដ៏ច្រើន ខ្ញុំ មិនដែលខ្វះខាតភោគៈឡើយ នេះជាផលនៃអាសនៈឯក ៗ ខ្ញុំតែងអន្ទោលទៅក្នុងភពពីរ គឺទេវតានិងមនុស្ស ខ្ញុំមិន ដែលស្គាល់ភពដទៃឡើយ នេះជាផលនៃអាសនៈឯក ៗ

ទុវេ កុលេ បជាយាមិ ខត្តិយេ ចាបិ ព្រាហ្មណេ
ឧច្ចាកុលីនា សព្វត្ថ ឯកាសនផលំ ឥទំ ។
ទោមនស្សំ ន ជានាមិ ចិត្តសន្តាបនំ មម
វេវណ្ណិយំ ន ជានាមិ ឯកាសនផលំ ឥទំ ។
ធាតិយោ មំ ឧបដ្ឋន្តិ ខុជ្ជា ចេលាវិកា(១) ពហូ
អង្កេន អង្កំ គច្ឆាមិ ឯកាសនផលំ ឥទំ ។
អញ្ញា មមេវ ន្ហាបេន្តិ អញ្ញា ភោជេន្តិ ភោជនំ
អញ្ញា មំ អលង្ករោន្តិ អញ្ញា រមេន្តិ មំ សទា ។
អញ្ញា គន្ធំ វិលិម្បន្តិ ឯកាសនផលំ ឥទំ
មណ្ឌបេ រុក្ខមូលេ វា សុញ្ញាគារេ វសន្តិយា ។
មម សង្កប្បមញ្ញាយ បល្លង្កោ ឧបតិដ្ឋតិ
អយំ បច្ឆិមកោ មយ្ហំ ចរិមោ វត្តតេ ភវោ ។
អជ្ជាបិ រជ្ជំ ឆឌ្ឌេត្វា បព្វជឹ អនគារិយំ

---

១ ឱ. ចេលាវិកា ។ ម. ចេលាបិកា ។

ខ្ញុំតែងកើតក្នុងត្រកូលពីរ គឺក្សត្រិយ៍និងព្រាហ្មណ៍ ប្រកបដោយត្រកូលខ្ពស់ ក្នុងទីទាំងពួង នេះជាផលនៃអាសនៈឯក ។ ខ្ញុំមិនស្គាល់ទោមនស្ស ដែលញុំាងចិត្តរបស់ខ្ញុំឲ្យក្តៅ ខ្ញុំមិនស្គាល់នូវភេទផ្សេងៗ នេះជាផលនៃអាសនៈឯក ។ មេនំស្រីគម ស្រីកំពុងពេញល្បែងច្រើននាក់ តែងបម្រើខ្ញុំ ខ្ញុំទៅពីចង្កេះមួយទៅចង្កេះមួយ គឺគេពផ្លាស់ប្តូរគ្នា មិនដែលដើរដី នេះជាផលនៃអាសនៈឯក ។ ពួកស្រីដទៃផ្ងូតទឹកឲ្យខ្ញុំ ពួកស្រីដទៃឲ្យខ្ញុំបរិភោគភោជន ពួកស្រីដទៃប្រដាប់តាក់តែងឲ្យខ្ញុំ ពួកស្រីដទៃឲ្យខ្ញុំត្រេកអរ សព្វៗកាល ។ ពួកស្រីដទៃ លាបគ្រឿងក្រអូបឲ្យខ្ញុំ នេះជាផលនៃអាសនៈឯក ។ កាលខ្ញុំនៅក្នុងមណ្ឌបក្តី នៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី បល្ល័ង្កតែងកើតឡើង ព្រោះដឹងនូវតម្រិះរបស់ខ្ញុំ នេះភពទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតនេះកំពុងប្រព្រឹត្តទៅ ថ្ងៃនេះ ខ្ញុំទំលាក់ចោលនូវពង្ស ហើយចូលទៅកាន់ផ្នួស ។

## ចតុត្ថំ ឯកាសនទាយិកាថេរិយាបទានំ

សតសហស្សេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឯកាសនផលំ ឥទំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកាសនទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកាសនទាយិកាថេរិយាបទានំ សមត្តំ ។

## ឯកាសនទាយិកាថេរិយាបទាន ទី ៤

ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃអាសនៈឯក ៗ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ៗ ទុ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកាសនទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៗ

ចប់ ឯកាសនទាយិកាថេរិយាបទាន ។

## បញ្ចមំ បញ្ចទីបទាយិកាថេរិយាបទានំ

(១៥) នគរេ ហំសវតិយា ចារិកា(១) អាសហំ តទា
អារាមេន វិហារេន ចរាមិ កុសលត្ថិកា ។
កាឡបក្ខម្ហិ ទិវសេ អទ្ទសំ ពោធិមុត្តមំ
តត្ថ ចិត្តំ បសាទេត្វា ពោធិមូលេ និសីទហំ ។
គរុចិត្តំ ឧបដ្ឋេត្វា សិរេ កត្វាន អញ្ជលឹ
សោមនស្សំ បវេទេត្វា ឯវំ ចិន្តេសិ តាវទេ ។
យទិ ពុទ្ធោ អមិតគុណោ អសមប្បដិបុគ្គលោ
ទស្សេតុ បាដិហីរំ មេ ពោធិ ឱភាសតុ អយំ ។
សហ អាវជ្ជិតេ មយ្ហំ ពោធិ បជ្ជលិ តាវទេ
សព្វសោវណ្ណមយា អាសិ ទិសា សព្វា វិរោចតិ ។
សត្តរត្តិន្ទិវំ តត្ថ ពោធិមូលេ និសីទហំ
សត្តមេ ទិវសេ បត្តេ ទីបបូជំ អកាសហំ ។

---

១ ឱ. ម. ចារិកី ។

សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

# បញ្ចទីបទាយិកាថេរីយាបទាន ទី ៥

[ ១៥ ] ក្នុងកាលនោះ ខ្ញុំជាស្រីអ្នកដំណើរ នៅក្នុងនគរហង្សវតី ខ្ញុំជាស្រីត្រូវការដោយកុសល តែងដើរទៅកាន់អារាម ទៅកាន់វិហារ ៗ ខ្ញុំបានឃើញដើមពោធិព្រឹក្សដ៏ឧត្តមក្នុងថ្ងៃកាឡបក្ខ ហើយញុំាងចិត្តឲ្យជ្រះថ្លាចំពោះពោធិព្រឹក្សនោះ ក៏អង្គុយនៅក្បែរគល់នៃពោធិព្រឹក្ស ៗ ខ្ញុំតម្កល់ចិត្តគោរព ធ្វើនូវអញ្ជលីលើសិរ្ស: ហើយសំដែងនូវសោមនស្ស ក៏គិតយ៉ាងនេះ ក្នុងខណៈនោះថា បើព្រះពុទ្ធមានគុណរាប់មិនបាន មិនមានបុគ្គលផ្ទឹមស្មើមែន សូមឲ្យពោធិព្រឹក្សនេះ សំដែងនូវបាដិហារ្យ ដល់អាត្មាអញ គឺសូមឲ្យពោធិ-ព្រឹក្សភ្លឺស្វាង ៗ ដំណាលគ្នានឹងខ្ញុំកំពុងពិចារណា ពោធិព្រឹក្សក៏ភ្លឺស្វាង ក្លាយទៅជាពណ៌មាសទាំងអស់ ទិសទាំងពួងក៏រុងរឿង ក្នុងខណៈនោះ ៗ ខ្ញុំអង្គុយក្បែរគល់ពោធិព្រឹក្សនោះ អស់៧ថ្ងៃ៧យប់ ដល់ថ្ងៃទី ៧ ខ្ញុំបានបូជាប្រទីប ៗ

## បញ្ចមំ បញ្ចទីបទាយិកាថេរិយាបទានំ

អាសនំ បរិវារេត្វា បញ្ច ទីបានិ បជ្ជលិំ
យាវ ឧទេតិ សុរិយោ ទីបា មេ បជ្ជលុំ តទា ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគច្ឆហំ ។
តត្ថ មេ សុកតំ ព្យម្ហំ បញ្ចទីបាតិ វុច្ចតិ
សដ្ឋិយោជនមុព្ពេធំ តឹសយោជនវិត្ថតំ ។
អសង្ខិយានិ ទីបានិ បរិវារេ ជលឹសុ មេ
យាវតា ទេវភវនំ ទីបាលោកេន ជោតតិ ។
បុរត្ថាមុខា(១) និសីទិត្វា យទិ ឥច្ឆាមិ បស្សិតុំ
ឧទ្ធំ អធោ ច តិរិយំ សព្វំ បស្សាមិ ចក្ខុនា ។
យាវតា អភិកង្ខាមិ ទដ្ឋុំ សុកតទុក្កដំ(២)
តត្ថ អាវរណំ(៣) នត្ថិ រុក្ខេសុ បព្វតេសុ វា ។

---

១ ម. បុរត្ថាមុខា ។ ២ ឱ. សុកតទុក្កតេ ។ ម. សុគតទុគ្គតេ ។ ៣ ឱ. មេ វរណំ ។

## បញ្ចទីបទាយិកាថេរិយាបទាន ទី ៤

ប្រទីបទាំង៥នោះ ក៏ភ្លឺរុងរឿងឡើងព័ទ្ធអាសនៈ កាលនោះ ប្រទីបទាំងឡាយរបស់ខ្ញុំ ភ្លឺរុងរឿង ដរាបដល់ព្រះអាទិត្យរះឡើង ។ លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ប្រាសាទរបស់ខ្ញុំ ដែលបុញ្ញកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ លោកហៅថា បញ្ចទីបប្រាសាទ មានកំពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍ ។ ប្រទីបទាំងឡាយ របស់ខ្ញុំ មានចំនួនរាប់មិនអស់ តែងភ្លឺរុងរឿងជុំវិញ កពទេវតា ក៏ភ្លឺដោយពន្លឺប្រទីបនោះដែរ ។ ខ្ញុំអង្គុយបែរមុខទៅកាន់ទិសខាងកើត បើខ្ញុំប្រាថ្នាដើម្បីមើល ខាងលើ ខាងក្រោម និងទិសទទឹង ខ្ញុំក៏ឃើញនូវវត្ថុទាំងអស់ ដោយចក្ខុ ។ ខ្ញុំប្រាថ្នាដើម្បីឃើញនូវកម្មដែលខ្ញុំធ្វើល្អធ្វើអាក្រក់ ដរាបណា គ្រឿងបិទបាំងក្នុងវត្ថុទាំងនោះ ទោះជាឈើឬភ្នំ ក៏មិនមាន ដរាបនោះ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

អសីតិទេវរាជូនំ មហេសិត្តមការយឹ
សតានំ ចក្កវត្តីនំ មហេសិត្តមការយឹ ។
យំ យំ យោនូបបជ្ជាមិ ទេវត្តំ អថ មានុសំ
ទីបសតសហស្សានិ បរិវារេ ជលន្តិ មេ ។
ទេវលោកា ចវិត្វាន ឧប្បជ្ជឹ មាតុកុច្ឆិយំ
មាតុ កុច្ឆិគតំ សន្តិំ(១) អក្ខិ មេ ន និមីលតិ ។
ទីបសតសហស្សានិ បុញ្ញកម្មសមង្គិនោ(២)
ជលន្តិ សូតិកាគេហេ(៣) បញ្ចទីបានិទំ ផលំ ។
បច្ឆិមេ ភវសម្បត្តេ មានសំ វិនិវត្តយឹ(៤)
អជរាមរំ សីតិភាវំ និព្វានំ បស្សយឹ អហំ ។
ជាតិយា សត្តវស្សាហំ អរហត្តំ អបាបុណឹ
ឧបសម្បាទយិ ពុទ្ធោ បញ្ចទីបានិទំ ផលំ(៥) ។
មណ្ឌបេ រុក្ខមូលេ វា សុញ្ញាគារេ វសន្តិយា
សទា បជ្ជលតេ ទីបំ បញ្ចទីបានិទំ ផលំ ។

---

១ ឱ. មាតុ កុច្ឆិគតា សន្តី ។ ២ ឱ. បុញ្ញកម្មសមង្គិតា ។ ៣ ម. សូតិតេ គេហេ ។
៤ ឱ. វិនិវត្តិយំ ។ ៥ ម. គុណាមញ្ញាយ គោតមោ ។

ខ្ញុំបានជាមហេសីនៃទេវរាជ ៨០ ដង បានជាមហេសីនៃស្តេចចក្រពត្តិ ១០០ ដង ។ ខ្ញុំទៅកាន់កំណើតណា ៗ ជាទេវតាឬមនុស្ស ប្រទីបមានចំនួនមួយសែន ភ្លឺជុំវិញខ្ញុំ ។ លុះខ្ញុំច្យុតចាកទេវលោក មកកើតក្នុងផ្ទៃមាតា កាលខ្ញុំនៅក្នុងផ្ទៃនៃមាតា ភ្នែករបស់ខ្ញុំមិនដែលធ្មេចឡើយ ។ ប្រទីបចំនួនមួយសែន ដែលប្រកបដោយបុញ្ញកម្ម រមែងភ្លឺក្នុងផ្ទះជាទីប្រសូតិ នេះជាផលនៃប្រទីប ៥ ។ កាលភពជាទីបំផុតដល់ព្រមហើយ ខ្ញុំញុំាងចិត្តឲ្យប្រព្រឹត្តទៅ ខ្ញុំឃើញព្រះនិព្វាន មិនមានជរានិងមរណៈ មានសេចក្តីត្រជាក់ ។ ខ្ញុំមានអាយុ ៧ ឆ្នាំ អំពីកំណើត ក៏បានសម្រេចព្រះអរហត្ត ព្រះពុទ្ធទ្រង់ឲ្យឧបសម្បទាដល់ខ្ញុំ នេះជាផលនៃប្រទីប ៥ ។ កាលខ្ញុំនៅក្នុងមណ្ឌបក្តី ជិតគល់ឈើក្តី ក្នុងផ្ទះស្ងាត់ក្តី ប្រទីបតែងភ្លឺរុងរឿង សព្វ ៗ កាល នេះជាផលនៃប្រទីប ៥ ។

### បញ្ចមំ បញ្ចទីបិកាថេរិយាបទានំ

ទិព្វចក្ខុ(១) វិសុទ្ធំ មេ   សមាធិកុសលា អហំ
អភិញ្ញាបារមិប្បត្តា   បញ្ចទីបានិទំ ផលំ ៗ
សព្វវោសិតវោសានា   កតកិច្ចា អនាសវា
បញ្ចទីបា មហាវីរ   បាទេ វន្ទាមិ(២) ចក្ខុម ៗ
សតសហស្សិតោ កប្បេ   យំ ទានមទទឹ(៣) តទា
ទុគ្គតឹ នាភិជានាមិ   បញ្ចទីបានិទំ ផលំ ៗ
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវា ៗ
ស្វាគតំ វត មេ អាសិ   មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ៗ
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ៗ

---

១ ឱ. ទិព្វំ ចក្ខុំ ៗ ២ ឱ. ម. វន្ទតិ ៗ ៣ ម. ទីបមទទឹ ៗ

## បញ្ចទីបទាយិកាថេរិយាបទាន ទី ៩

ទិព្វចក្ខុរបស់ខ្ញុំ ស្អាតវិសេស ខ្ញុំជាស្រីឈ្លាសក្នុងសមាធិ ដល់នូវអភិញ្ញាបារមី នេះជាផលនៃប្រទីប ៥ ៗ បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់មានចក្ខុ ខ្ញុំមានការប្រព្រឹត្តិធម៌ចប់ស្រេចហើយ មានសោឡសកិច្ចធ្វើរួចហើយ មិនមានអាសវៈ ជាស្រីមានប្រទីប ៥ សូមថ្វាយបង្គំនូវព្រះបាទទាំងគូ ៗ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រទីប ៥ ៗ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្ដាច់នូវទន្ទឹង ៗ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

ឥត្ថំ សុទំ អាយស្មា បញ្ចទីបទាយិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

បញ្ចទីបទាយិកាថេរិយាបទានំ សមត្តំ ។

# ឆដ្ឋំ នឡមាលិកាថេរិយាបទានំ

(១៦) ចន្ទភាគានទីតីរេ អហោសឹ កិន្នរី តទា
អទ្ទសំ វិរជំ ពុទ្ធំ សយម្ភុំ អបរាជិតំ ។
បសន្នចិត្តា សុមនា វេទជាតា កតញ្ជលី
នឡមាលំ គហេត្វាន សយម្ភុំ អភិបូជយឹ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា កិន្នរីទេហំ តាវត្តិំសំ អគញ្ឆហំ ។
ឆត្តឹសទេវរាជូនំ មហេសិត្តមការយឹ
មនសា បត្ថិតំ មយ្ហំ និព្វត្តតិ យថិច្ឆិតំ ។
ទសន្នំ ចក្កវត្តីនំ មហេសិត្តមការយឹ
ឱចិតត្តាវ(១) ហុត្វាន សំសរាមិ ភវេសុហំ(២) ។

១ ឱ. សុចិត្តាវ ។ ២ ឱ. ភវេស្វហំ ។ ម. ភវេសហំ ។

បានឮថា ព្រះបញ្ចទីបទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បញ្ចទីបទាយិកាថេរិយាបទាន ។

## នឡមាលិកាថេរិយាបទាន ទី ៦

(១៦) កាលនោះឯង ខ្ញុំកើតជាកិន្នរញី នៅទៀបឆ្នេរស្ទឹងចន្ទភាគា ខ្ញុំបានឃើញព្រះពុទ្ធជាព្រះសយម្ភូ ទ្រង់ប្រាសចាកធូលី ទ្រង់ឈ្នះកិលេស ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយខ្លាំង មានចិត្តត្រេកអរ ធ្វើនូវអញ្ជលី ហើយកាន់យក នូវកម្រងផ្កាបបុះ ទៅបូជាចំពោះព្រះសយម្ភូ ។ ខ្ញុំលះបង់រាងកាយជាកិន្នរញី បានទៅកើតក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ។ ខ្ញុំបានជាមហេសី នៃទេវរាជ ៣៦ ដង សេចក្តីប្រាថ្នាដោយចិត្តរបស់ខ្ញុំ រមែងកើតឡើង តាមសមគួរដល់សេចក្តីប្រាថ្នា ។ ខ្ញុំបានជាអគ្គមហេសី នៃស្តេចចក្រពត្តិ ១០ ដង ព្រោះបានសន្សំកងកុសល ខ្ញុំតែងអន្ទោលទៅ ក្នុងភពទាំងឡាយ ។

## ឆដ្ឋំ នឡមាលិកាថេរិយាបទានំ

កុសលំ វិជ្ជតេ មយ្ហំ  បព្វជឹ អនគារិយំ
បូជារហា អហំ អជ្ជ  សក្យបុត្តស្ស សាសនេ ។
ចតុន្នវុតេ ឥតោ កប្បេ  យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ  នឡមាលាយិទំ ផលំ ។
វិសុទ្ធមនសា អជ្ជ  អបេតមនថាបិកា
សព្វាសវបរិក្ខីណា  នត្ថិ ទានិ បុនព្ភវោ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា  វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ  ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នឡមាលិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

នឡមាលិកាថេរិយាបទានំ សមត្តំ ។

នឡមាលិកាថេរិយាបទាន ទី ៦

កុសលរបស់ខ្ញុំ រមែងមាន ខ្ញុំបានចូលទៅកាន់ផ្នួស ថ្ងៃនេះ ខ្ញុំជាស្រីគួរដល់ការបូជា ក្នុងសាសនា នៃព្រះសក្យបុត្ត ៗ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃកម្រងផ្កាបបុះ ៗ ថ្ងៃនេះ ខ្ញុំមានចិត្តស្អាត ប្រាសចាកចិត្តលាមក មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ៗ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ៗ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ៗ

បានឮថា ព្រះនឡមាលិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ៗ

ចប់ នឡមាលិកាថេរិយាបទាន ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

# សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

(១៧) ឯកទា លោកបជ្ជោតោ វេសាលិយំ មហាវនេ
កូដាគារេ សុសាលាយ វសតេ នរសារថិ ។
តទា ជិនស្ស មាតុច្ឆា មហាគោតមិ ភិក្ខុនី
តហឹយេវ បុរេ រម្មេ វសិ ភិក្ខុនុបស្សយេ ។
ភិក្ខុនីហិ វិមុត្តាហិ សតេហិ សហ បញ្ចហិ
រហោគតាយ តស្សេវំ ចិត្តស្សាសិ វិតក្កិតំ ។
ពុទ្ធស្ស បរិនិព្វានំ សាវកគ្គយុគស្ស វា
រាហុលានន្ទនន្ទានំ នាហំ លច្ឆាមិ(១) បស្សិតុំ ។
បដិកច្ចាយុសង្ខារំ ឱសជ្ជិត្វាន និព្វុតឹ
គច្ឆេយ្យំ លោកនាថេន អនុញ្ញាតា មហេសិនា ។
តថា បញ្ចសតានំបិ ភិក្ខុនីនំ វិតក្កិតំ
អាសិ ខេមាទិកានម្បិ ឯតទេវ វិតក្កិតំ ។

១ ឱ. សក្កោមិ ។

# មហាបជាបតិគោតមីថេរិយាបទាន ទី ៧

(១៧) ក្នុងសម័យមួយ ព្រះសម្ពុទ្ធជាប្រទីបនៃលោក ព្រះអង្គជាសារថី ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់គង់នៅក្នុងកូដាគារសាលា ក្នុងមហាវ័ន ទៀបក្រុងវេសាលី ។ កាលនោះ ភិក្ខុនីឈ្មោះមហាបជាបតិគោតមី ជាព្រះមាតុច្ឆានៃព្រះជិនស្រី នៅក្នុងសំណាក់ភិក្ខុនី ជិតបុរីជាទីរីករាយនោះឯង ។ ព្រះនាងមហាបជាបតិគោតមីភិក្ខុនី នៅក្នុងទីស្ងាត់ ជាមួយនឹងពួកភិក្ខុនី ដែលមានចិត្តរួចស្រឡះចាកកិលេស ចំនួន ៥០០ រូប ព្រះនាងមានចិត្តត្រិះរិះយ៉ាងនេះថា អញ (បើរស់នៅ) មិនបានទាន់ការបរិនិព្វាន នៃព្រះសម្ពុទ្ធ នៃគូសាវ័ក នៃរាហុល អានន្ទនិងនន្ទទេ នឹងសុំអនុញ្ញាតព្រះលោកនាថជាមហេសី លះបង់នូវអាយុសង្ខារ ទៅកាន់ព្រះនិព្វានភ្លាម ៗ ។ សេចក្តីត្រិះរិះរបស់នាងភិក្ខុនី ៥០០ រូបក្តី សេចក្តីត្រិះរិះរបស់នាងភិក្ខុនីទាំងឡាយ មាននាងភិក្ខុនីឈ្មោះខេមាជាដើមនេះក្តី ក៏ដូចព្រះនាងគោតមីដែរ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ភូមិចាលោ តទា អាសិ នាទិតា ទេវទុន្ទុភិ
ឧបស្សយាធិវត្ថាយោ ទេវតា សោកបីឡិតា ។
វិលបន្តា សការុណំ តត្ថស្សុនិ បវត្តយុំ
សព្វា(១) ភិក្ខុនិយោ តាហិ ឧបគន្ត្វាន គោតមី ។
និបច្ច សិរសា បាទេ ឥទំ វចនមព្រវុំ
តត្ថ តោយលវាសិត្តា(២) មយមយ្យេ រហោគតា ។
សា ចលា ចលិតា ភូមិ នាទិតា ទេវទុន្ទុភិ
បរិទេវា ច សុយ្យន្តេ កិមត្ថំ នូន គោតមិ ។
តទា អវោច សា សព្វំ យថាបរិវិតក្កិតំ
តតោបិ(៣) សព្វា អាហំសុ(៤) យថាបរិវិតក្កិតំ ។
យទិ តេ រុចិតំ អយ្យេ និព្វានំ បរមំ សិវំ
និព្វាយិស្សាម សព្វាបិ ពុទ្ធានុញ្ញាតសុព្វតេ(៥) ។

---

១ ម. មិត្តា ។ ២ ឱ. តោយលវាសិត្តា ។ ៣ ឱ. ម. តាយោបិ ។ ៤ ម. អហំសុ ។
៥ ឱ. ម. ពុទ្ធានុញ្ញាយសុព្វតេ ។

គ្រានោះ មានការកក្រើកផែនដី ទាំងផ្គរក៏លាន់ឮឡើង ទេវតាទាំងឡាយ ដែលអាស្រ័យនៅក្នុងសំណាក់ភិក្ខុនី ក៏ត្រូវសេចក្តីសោកបៀតបៀន ។ (ទេវតាទាំងនោះ) យំទួញញាំងទឹកភ្នែកនិងសេចក្តីករុណាឲ្យប្រព្រឹត្តទៅក្នុងទីនោះ ភិក្ខុនីទាំងអស់ ចូលទៅជិតនាងគោតមីភិក្ខុនី ជាមួយនឹងទេវតាទាំងនោះ ហើយក្រាបចុះដោយសិរ្សៈទៀបបាទា ពោលនូវពាក្យនេះថា បពិត្រព្រះនាងជាម្ចាស់ យើងទាំងឡាយនៅក្នុងទីស្ងាត់ ត្រូវដំណក់ទឹកស្រោចស្រប់ហើយ ក្នុងទីនោះ ។ បពិត្រព្រះនាងគោតមីជាម្ចាស់ ផែនដីនោះ កក្រើកញាប់ញ័រ ទាំងផ្គរក៏លាន់ឮឡើង ទាំងសេចក្តីខ្សឹកខ្សួល ពួកយើងក៏បានឮដែរ តើមានហេតុដូចម្តេច ។ គ្រានោះ ព្រះនាងក៏ប្រាប់នូវហេតុទាំងអស់ ដែលនាងត្រិះរិះ ។ លំដាប់នោះ ភិក្ខុនីទាំងអស់ បានប្រាប់នូវហេតុដែលខ្លួនត្រិះរិះហើយដែរថា បពិត្រព្រះនាងជាម្ចាស់ ព្រះនិព្វានជាទីក្សេមយ៉ាងក្រៃលែង បើព្រះនាងពេញចិត្តហើយ បពិត្រព្រះនាងដែលបានព្រះពុទ្ធអនុញ្ញាតហើយ យើងទាំងអស់គ្នានឹងនិព្វានដែរ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

មយំ សហាវ និក្ខន្តា ឃរាបិច ករាបិច

សហាយេវ គមិស្សាមិ និព្វានំ បុរមុត្តមំ ។

និព្វានាយ វជន្តីនំ(១) កឹ វក្ខាមីតិ សា វទិ(២)

សហ សព្វាហិ និក្កព្ជិ ភិក្ខុនីលយនា តទា ។

ឧបស្សយេ យានិវត្តា ទេវតា តា ខមន្តុ មេ

ភិក្ខុនីលយនស្សេទំ បច្ឆិមំ ទស្សនំ មម ។

ន ជរា មច្ចុ វា យត្ថ អប្បិយេហិ សមាគមោ

បិយេហិ ន វិយោគោត្ថិ តំ វជ្ជិយំ(៣) អសង្ខតំ ។

អវីតរាគា តំ សុត្វា វចនំ សុគតោរសា

សោកដ្ដា បរិទេវីសុ អហោ នោ អប្បបុញ្ញតា ។

---

១ ម. វទន្តីនំ ។ ២ ឱ. វទិ ។ ៣ ឱ. ម. វជិស្សំ ។

យើងទាំងឡាយនឹងចេញចាកផ្ទះចាកភព ជាមួយនឹងព្រះនាងដែរ យើងនឹងទៅកាន់ព្រះនិព្វាន ជាបុរីដ៏ឧត្តម ជាមួយនឹងព្រះនាងទៀត ។ កាលភិក្ខុនីទាំងឡាយ ពោលដើម្បីនិព្វានគ្រានោះ ព្រះនាងក៏ពោលថា ខ្ញុំនឹងថាអ្វី ហើយក៏ចេញទៅចាកលំនៅភិក្ខុនី ជាមួយនឹងភិក្ខុនីទាំងអស់ រួចពោលថា ទេវតាណាដែលអាស្រ័យនៅ ក្នុងសំណាក់ភិក្ខុនី ទេវតាទាំងនោះ សូមអត់ទោសដល់ខ្ញុំ ការឃើញលំនៅនាងភិក្ខុនីនេះ ជាការឃើញទីបំផុតរបស់ខ្ញុំ ។ ជរាក្តី មច្ចុក្តី មិនមានក្នុងទីណា ការជួបប្រទះដោយសត្វនិងសង្ខារ មិនជាទីស្រឡាញ់ក្តី ការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ក្តី មិនមានក្នុងទីណា ទីនោះ ហៅថាអសង្ខតៈ ។ ពួកភិក្ខុនីជាឧរសរបស់ព្រះសុគត ដែលមិនទាន់ប្រាសចាករាគៈ បានស្តាប់នូវពាក្យនោះហើយ ត្រូវសេចក្តីសោកគ្របសង្កត់ ក៏ខ្សឹកខ្សួលថា ឧហ្ន៎ ! យើងទាំងឡាយ ជាបុគ្គលឥតបុណ្យ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ភិក្ខុនីនិលយោ សុញ្ញោ ភូតោ តាហិ វិនា អយំ
បភាតេ វិយ តារាយោ ន ទិស្សន្តិ ជិនោរសា ។
និព្វានំ គោតមី យាតិ សតេហិ សហ បញ្ចហិ
នទីសតេហិវ សហា គង្គា បញ្ចហិ សាគរំ ។
រថិយាយ វជន្តី តំ(១) ទិស្វា សទ្ធា ឧបាសិកា
ឃរា និក្ខម្ម បាទេសុ និបច្ច ឥទមព្រវុំ ។
បសីទស្សុ មហាភោគេ អនាថាយោ វិហាយ នោ
តយា ន យុត្តំ និព្វាតុំ ឥច្ឆដ្ដា វិលបិំសុ តា ។
តាសំ សោកបហានត្ថំ អវោច មធុរំ គិរំ
រុទិតេន អលំ បុត្តា ហាសកាលោយមជ្ជ វោ ។

---

១ ឱ. វជន្តីនំ ។ ម. វជន្តិយោ ។

ទីលំនៅភិក្ខុនីនេះ បើវៀរចាកពួកភិក្ខុនីទាំងនោះហើយ ក៏នឹងសូន្យឈឹង ពួកនាងភិក្ខុនី ជាឱរសរបស់ព្រះជិនស្រី ក៏លែងប្រាកដ ដូចជាផ្កាយ ដែលមិនប្រាកដក្នុងពេលភ្លឺច្បាស់ ។ ព្រះនាងគោតមី នឹងទៅកាន់និព្វាន ជាមួយភិក្ខុនី ៥០០ រូប ដូចទន្លេគង្គា ហូរទៅកាន់សាគរជាមួយស្ទឹង៥០០ ដូច្នោះ ។ ពួកឧបាសិកា ដែលមានសទ្ធា ចេញអំពីផ្ទះ ដើរទៅតាមច្រក បានឃើញព្រះនាងគោតមីនោះ ក៏ក្រាបទៀបបាទា ហើយពោលនូវពាក្យនេះថា ព្រះនាងម្ចាស់ ចូរជ្រះថ្លាក្នុងគោគៈដ៏ច្រើនចុះ ព្រះនាងមិនគួរលះបង់ នូវយើងខ្ញុំទាំងឡាយ ឲ្យនៅឥតទីពឹង ហើយនិព្វានទេ ឧបាសិកាទាំងនោះ ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ ហើយក៏យំរៀបរាប់ (យ៉ាងនេះ) ។ ព្រះនាងគោតមីបានពោលវាចាដ៏ពីរោះ ដើម្បីបន្ទោបង់នូវសេចក្ដីសោក របស់ស្រីទាំងនោះថា ម្នាលកូនទាំងឡាយ នាងទាំងឡាយមិនគួរយំស្រែកទេ ថ្ងៃនេះ ជាកាលគួរនាងទាំងឡាយសើចសប្បាយ ទេតើ ។

បរិញ្ញាតំ មយា ទុក្ខំ ទុក្ខហេតុ វិវជ្ជិតោ
និរោធោ មេ សច្ឆិកតោ មគ្គោ ចាបិ សុភាវិតោ ។

## បឋមំ ភាណវារំ ។

បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្សត្ថាយ(១) បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
ពុទ្ធោ តស្ស ច សទ្ធម្មោ អនូនោ យាវ តិដ្ឋតិ
និញ្ញាតុំ តាវ កាលោ មេ មា មំ សោចថ បុត្តិកា ។

---

១ ឱ. យស្សត្ថាយ ។

ព្រោះសេចក្តីទុក្ខ ខ្ញុំបានកំណត់ដឹងហើយ ហេតុនាំឲ្យកើតទុក្ខ ខ្ញុំវៀរស្រឡះហើយ ព្រះនិព្វានជាទីរលត់ទុក្ខ ខ្ញុំបានធ្វើឲ្យ ឲ្យជាក់ច្បាស់ហើយ ទាំងមគ្គទៀត ខ្ញុំក៏បានអប់រំល្អហើយ ។

**ចប់ ភាណវារៈ ទី ១ ។**

ព្រះសាស្តា ខ្ញុំបំរើហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាធម្ម-ជាតិនាំសត្វទៅកាន់ភព ខ្ញុំក៏បានដកចោលហើយ ។ ស្រីទាំងឡាយចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍ជាទីអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំក៏បានដល់ហើយ ។ ព្រះពុទ្ធក្តី ព្រះសទ្ធម្មរបស់ព្រះពុទ្ធនោះក្តី ឋិតនៅមិនខូចខាត ដរាបណា កាលនេះជាកាលគួរដើម្បីខ្ញុំនឹងនិព្វាន ដរាបនោះ ម្នាលកូនស្រីទាំងឡាយ នាងទាំងឡាយ កុំសោកស្តាយខ្ញុំឡើយ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

កោណ្ឌញ្ញានន្ទនន្ទាទិ តិដ្ឋន្តិ រាហុលោ ជិនោ

សុខិតោ សហិតោ សង្ឃោ ហតទព្វា ច(១) តិត្ថិយា ។

ឱក្កាកវំសស្ស យសោ ឧស្សិតោ មារមទ្ទនោ

ននុ សម្បត្តិកាលោ មេ និព្វានត្ថាយ បុត្តកា ។

ចិរប្បភុតិ យំ មយ្ហំ បត្ថិតំ អជ្ជ សិជ្ឈតេ

អានន្ទភេរិកាលោយំ កឹ វោ អស្សូហិ បុត្តកា ។

សចេ មយិ ទយា អត្ថិ យទិ ចត្ថិ កតញ្ញុតា

សទ្ធម្មដ្ឋិតិយា សព្វា ករោថ វីរិយំ ទឡ្ហំ ។

ថីនំ អទាសិ បព្វជ្ជំ សម្ពុទ្ធោ យាចិតោ មយា

តស្មា យថាហំ នន្ទិស្សំ(២) តថា តំ អនុតិដ្ឋថ ។

---

១ ម. ហតគព្វា ច ។ ២ ឱ. តស្មា យថាហមុទ្ទិស្ស ។

ព្រះកោណ្ឌញ្ញ ព្រះអានន្ទ ព្រះនន្ទ ព្រះរាហុល ព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ចូរឋិតនៅជាសុខចុះ ទាំងពួកតិរ្ថិយដែលមានសេចក្ដីល្ងង់ខ្លៅសាបសូន្យហើយ ក៏ឋិតនៅជាសុខចុះ ។ យសនៃវង្សរបស់ស្ដេចឧក្កាកៈ ចម្រើនឡើងហើយញាំញីនូវមារ ម្នាលកូនស្រីទាំងឡាយ ក្រែង ( កាលនេះ ) ជាសម្បត្តិកាល ដើម្បីឲ្យខ្ញុំនិព្វានហើយឬ ។ ចាប់តាំងអំពីយូរយារមកហើយ សេចក្ដីប្រាថ្នាណា ដែលខ្ញុំតម្កល់ទុក ( សេចក្ដីប្រាថ្នានោះ ) នឹងសម្រេចក្នុងថ្ងៃនេះ កាលនេះ ជាកាលគួរទូងគោរី គឺសេចក្ដីត្រេកអរក្នុងធម៌ ម្នាលកូនស្រីទាំងឡាយ នាងទាំងឡាយ មានប្រយោជន៍អ្វី នឹងសម្រក់ទឹកភ្នែក ។ បើនាងទាំងឡាយមានសេចក្ដីអាណិតខ្ញុំ ឬក៏ជាអ្នកកតញ្ញូនឹងខ្ញុំ នាងទាំងអស់គ្នា ចូរធ្វើព្យាយាមឲ្យមាំ ដើម្បីញុំាងព្រះសទ្ធម្ម ឲ្យតាំងនៅមាំចុះ ។ ព្រះសម្ពុទ្ធដែលខ្ញុំអង្វរសុំហើយ ព្រះអង្គក៏ទ្រង់ប្រទាននូវផ្នួសដល់ស្រីទាំងឡាយ ព្រោះហេតុនោះ ខ្ញុំនឹងត្រេកអរ យ៉ាងណា នាងទាំងឡាយ ចូរប្រព្រឹត្តតាមដំណើរនោះ យ៉ាងនោះចុះ ។

តា ឋវមនុស្សាសិត្វា ភិក្ខុនីហិ បុរក្ខតា
ឧបេច្ច ពុទ្ធំ វន្ទិត្វា ឥទំ វចនមព្រវី ។
អហំ សុគត តេ មាតា តុវំ(១) ធីរ បិតា មម
សទ្ធម្មសុខទោ នាថ តយា ជាតម្ហិ គោតម ។
សំវទ្ធិតោយំ សុគត រូបកាយោ មយា តវ
អានន្ទិយោ ធម្មកាយោ(២) មម សំវទ្ធិតោ តយា ។
មុហុត្តំ តណ្ហាសមនំ ខីរំ ត្វំ បាយិតោ មយា
តយាហំ សន្តមច្ចន្តំ ធម្មខីរម្បិ(៣) បាយិតា ។
ពន្ធនារក្ខនេ(៤) មយ្ហំ អនណោ ត្វំ មហាមុនេ
បុត្តកាមិត្ថិយោ យាចំ លភន្តិ(៥) តាទិសំ សុតំ ។

---

១ ឱ. ត្វំ ប ។ ២ ឱ. អនិន្ទិយោ ធម្មតនុ · ម. អនិន្ទិតោ ធម្មតនុ ។ ៣ ឱ. ធម្មខីរម្ហិ ។
៤ ឱ. វទ្ធនារក្ខនេ ។ ៥ ឱ. បុត្តកាមា បិយោ យាវ លភន្តំ ឥតិ ទិស្សន្តិ ។

ព្រះនាងគោតមី បានប្រៀនប្រដៅនូវពួកឧបាសិកាទាំងនោះ យ៉ាងនេះហើយ ពួកភិក្ខុនីក៏ហៅហាម ហើយចូលទៅថ្វាយបង្គំព្រះសម្ពុទ្ធ បានពោលនូវពាក្យនេះថា បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ជាព្រះមាតារបស់ព្រះអង្គ បពិត្រព្រះអង្គទ្រង់មានប្រាជ្ញា តែព្រះអង្គជាព្រះបិតានៃខ្ញុំព្រះអង្គ បពិត្រព្រះលោកនាថ ព្រោះព្រះអង្គទ្រង់ប្រទាននូវព្រះសទ្ធម្មនិងសេចក្ដីសុខ បពិត្រព្រះគោតម ខ្ញុំព្រះអង្គឈ្មោះថាកើតអំពីព្រះអង្គ ៗ បពិត្រព្រះសុគត រូបកាយនៃព្រះអង្គនេះ ខ្ញុំឲ្យចំរើនហើយ ធម្មកាយជាទីត្រេកអររបស់ខ្ញុំ ព្រះអង្គឲ្យចំរើនហើយ ៗ ខ្ញុំម្ចាស់ឲ្យព្រះអង្គបៅទឹកក្សីរ ដែលរម្ងាប់នូវសេចក្ដីស្រេកឃ្លានមួយរំពេច ព្រះអង្គឲ្យខ្ញុំបៅទឹកក្សីរគឺធម៌ មានសេចក្ដីស្ងប់រម្ងាប់ជាទីបំផុត បពិត្រព្រះមហាមុនី ព្រះអង្គមិនមានបំណុលដល់ខ្ញុំ ក្នុងការរក្សានូវបំណងទេ ស្រីទាំងឡាយចង់បានកូន កាលបន់ស្រន់ រមែងបានកូនប្រាកដដូចព្រះអង្គ ៗ

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

មន្ធាតាទិនរិន្ទានំ យា មាតា សា(១) ភវណ្ណវេ
និមុគ្គាហំ តយា បុត្ត តារិតា ភវសាគរា ។
រញ្ញោ មាតា មហេសីតិ សុលភំ នាមមិត្ថិនំ
ពុទ្ធមាតាតិ យំ នាមំ ឯតំ បរមទុល្លភំ ។
តញ្ច លទ្ធំ មហាវីរ(២) បណិធានំ មមន្តយា
អណុកំ វា មហន្តំ វា តំ សព្វំ បូរិតំ តយា(៣) ។
បរិនិព្វាតុមិច្ឆាមិ វិហាយេមំ កឡេវរំ
អនុជានាហិ មេ វីរ ទុក្ខន្តករ នាយក ។
ចក្កង្កុសធជាកិណ្ណេ បាទេ កមលកោមលេ
បសារេហិ បណាមន្តេ ករិស្សំ បុត្តបេមហំ(៤) ។

---

១ ឱ. ញ ។ ២ ឱ. មយា វីរ ។ ៣ ឱ. ម. មហេ ។ ៤ ខ. បុត្តបេមសា ។

បពិត្រព្រះអង្គជាទេវស មាតាណា របស់ស្តេចជាធំជាងនរៈ មានស្តេចមន្ធាតុជាដើម មាតានោះ គឺខ្ញុំព្រះអង្គដែលលិចចុះក្នុងសមុទ្ទគឺភព បានព្រះអង្គបំឡូងហើយ ចាកសមុទ្ទគឺភព ។ ព្រះនាម ជាព្រះមាតា ជាព្រះមហេសីរបស់ស្តេច គឺស្រីទាំងឡាយ តែងបានដោយងាយទេ ឯព្រះនាមថាព្រះពុទ្ធមាតានេះ គឺស្រីទាំងឡាយ សឹងបានដោយកម្រក្រៃពេក ។ បពិត្រព្រះមហាវីរៈ ឯសេចក្តីប្រាថ្នាជាដំបូងនោះ ខ្ញុំព្រះអង្គបានហើយដោយសារព្រះអង្គ សេចក្តីប្រាថ្នាទាំងអស់នោះ ទោះតូចក្តីធំក្តី ព្រះអង្គបានបំពេញឲ្យហើយ ។ ខ្ញុំម្ចាស់សូមលះបង់នូវសាកសពនេះ ប្រាថ្នានឹងបរិនិព្វាន បពិត្រព្រះអង្គមានព្យាយាមជានាយក ទ្រង់ធ្វើនូវទីបំផុតនៃទុក្ខ សូមព្រះអង្គអនុញ្ញាតដល់ខ្ញុំព្រះអង្គ ។ សូមព្រះអង្គសណ្តូក នូវព្រះបាទទាំងគូ ដ៏ទន់ល្វន់ដូចផ្កាឈូក ដេរដាសដោយស្នាមចក្រ កង្វេរនិងទង់ ខ្ញុំព្រះអង្គមានសេចក្តីស្រឡាញ់ ចំពោះព្រះទេវស នឹងថ្វាយបង្គំព្រះបាទទាំងគូនោះ ។

សុវណ្ណាភសិសង្កាសំ   សរីរំ កុរុថាកដំ
កត្វា នេតំ សុនិដ្ឋេត្វ   សទ្ធិំ(១) គច្ឆាមិ នាយក ។
ទ្វត្តឹសលក្ខណូបេតំ   សុប្បភាលង្កតំ តនុំ
សញ្ញក្ខនាវ ពាលត្ថំ(២)   អាតុដ្ឋំ ឧស្សយិ ជិនោ ។
ផុល្លារវិន្ទសង្កាសេ   តរុណាទិច្ចសប្បភេ
ចក្កង្កិតេ បាទតលេ   តតោ(៣) សា សិរសា បតិ ។
បណាមាមិ ឯកនិច្ចំ   អាទិច្ចកុលកេតុនំ
បច្ឆិមេ សរណំ(៤) មយ្ហំ(៥)   ឯតំ ឥត្ថាមហំ បុរេ(៦) ។
ឥត្ថិយោ នាម លោកគ្គ   សព្វទោសករា មតា
យទិ កោចត្ថិ ទោសោ មេ   ខមស្សុ ករុណាករ ។

---

១ ឱ. ម. សន្តឹ ។ ២ ឱ. ម. សញ្ញក្ខនាវ ពាលក្កំ ។ ៣ ឱ. បាទេ ។ ៤ ឱ. ម. មរណោ ។ ៥ ម. តុយ្ហំ ។ ៦ ម. ឥត្ថាមហំ បុរោ ។

សរីរៈរបស់ព្រះអង្គ ប្រាកដស្មើដោយគំនរមាសដែលប្រាកដក្នុងដែនកុរុ សូមព្រះអង្គធ្វើឲ្យជារាងកាយ គឺខ្ញុំព្រះអង្គឃើញបានដោយងាយ បពិត្រព្រះនាយក ខ្ញុំព្រះអង្គនឹងទៅកាន់ព្រះនិព្វាន ជាទីស្ងប់រម្ងាប់ ។ ព្រះជិនស្រី ទ្រង់សម្តែងនូវរាងកាយ ប្រកបដោយលក្ខណៈ ៣២ ប្រដាប់ដោយពន្លឺដ៏ល្អ ដូចព្រះអាទិត្យដ៏ស្រទន់នាអាកាស ក្នុងវេលាល្ងាច ។ លំដាប់នោះ ព្រះនាងគោតមីនោះ ក្រាបចុះដោយសិរ្សៈទៀបព្រះបាទា ប្រាកដស្មើដោយផ្កាឈូករីក មានរស្មីដូចព្រះអាទិត្យទើបនឹងរះ ប្រដាប់ដោយចក្រ ហើយទូលថា ខ្ញុំសូមថ្វាយបង្គំព្រះអង្គជាព្រះអាទិត្យរបស់នរជន ជាទង់ក្នុងអាទិច្ចត្រកូល ព្រះអង្គជាទីពឹងរបស់ខ្ញុំ ក្នុងកាលជាទីបំផុត ខ្ញុំមិនបានឃើញព្រះអង្គទៀតទេ ។ បពិត្រព្រះអង្គជាកំពូលនៃលោក ធម្មតាស្ត្រីទាំងឡាយ ធ្វើនូវទោសទាំងពួងហើយស្លាប់ទៅ បើទោសរបស់ខ្ញុំមានបន្តិចបន្តួច បពិត្រព្រះអង្គទ្រង់ធ្វើសេចក្តីករុណា សូមព្រះអង្គអត់ទោសនោះដល់ខ្ញុំ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ឥត្ថិកានញ្ច បព្វជ្ជំ យមហំ យាចឹ បុនប្បុនំ
តត្ថ ចេ អត្ថិ ទោសោ មេ តំ ខមស្សុ នរាសភ ។
មយា ភិក្ខុនិយោ វីរ តវានុញ្ញាយ សាសិតា
តត្ថ ចេ អត្ថិ ទុន្នីតំ តំ ខមស្សុ ខមាធិតិ(1) ។
អក្ខន្តេ នាម ខន្តព្វំ កឹ ភវេ គុណភូសនេ
កិមុត្តរន្តេ វក្ខាមិ និព្វានាយ វទន្តិយា(2) ។

សុទ្ធេ អនូនេ មម ភិក្ខុសង្ឃេ
លោកា ឥតោ និស្សរិតុំ ខមន្តេ
បភាតកាលេ ព្យសនង្គតានំ(3)
ទិស្វាន និយ្យាតិ ហិ(4) ចន្ទលេខា ។

---

១ ឱ. ខមាធិប ។ ម. ខមាបិតោ ។ ២ ឱ. ម. វជន្តិយា ។ ៣ ឱ. វ្យសនង្គហានំ ។
៤ ម. វិ ។

## មហាបជាបតិគោតមីថេរិយាបទាន ទី ៧

ម្យ៉ាងទៀត ខ្ញុំសូមផ្ទួសរឿយ ៗ ដើម្បីស្រីទាំងឡាយ បើខ្ញុំមានទោសក្នុងហេតុនោះ បពិត្រព្រះអង្គដ៏ប្រសើរជាងនរជន សូមព្រះអង្គអត់ នូវទោសនោះ ៗ បពិត្រព្រះអង្គមានព្យាយាម ភិក្ខុនីទាំងឡាយ ដែលខ្ញុំប្រៀនប្រដៅហើយ តាមសេចក្ដីអនុញ្ញាតរបស់ព្រះអង្គ បើខ្ញុំទូន្មានមិនល្អក្នុងរឿងនោះទេ បពិត្រព្រះអង្គទ្រង់មានសេចក្ដីអត់ធន់និងមានព្យាយាម សូមព្រះអង្គអត់នូវទោសនោះដល់ខ្ញុំ ។

(ព្រះសម្ពុទ្ធត្រាស់តបថា) តថាគតអត់ទោស ក្នុងហេតុដែលតថាគតមិនទាន់អត់ ប្រយោជន៍អ្វីក្នុងភព ដែលប្រដាប់ដោយគុណ តថាគតនឹងពោល នូវអ្វីដ៏លើសលុប ជាងនាងដែលពោលដើម្បីនិព្វាន ៗ កាលភិក្ខុសង្ឃរបស់តថាគត ស្អាតគ្រប់គ្រាន់ ភិក្ខុសង្ឃក៏គួរដើម្បីរើខ្លួន ចេញចាកលោកនេះ ដូចកាលព្រះចន្ទនិងផ្កាយទាំងឡាយ ដល់នូវសេចក្ដីវិនាស ក្នុងកាលព្រះអាទិត្យរះឡើង ស្នាមព្រះចន្ទដែលគេឃើញច្បាស់ ក៏រលុបបាត់ទៅ ។

អនេកា ភិក្ខុនិយោ ជិនន្តំ
តាវ ចក្ខានុគតា សុមេរុំ
បនក្ខិណំ កត្វា(១) និបច្ច ចាទេ
បិតា មុខន្តស្ស មុនិក្ខមាណា ។
ន តិត្តិបុព្វំ តវ ឥស្សរេន
ចក្ខុំ ន សោតំ តវ ភាសិតេន
ចិត្តំ មមំ កេវលមេកមេវ
បប្ពុយ្យ(២) តំ ធម្មរសេន តិត្តឹ ។
នទតោ បរិសាយន្តេ ភាគិនប្បបហារិនោ(៣)
យេ តេ ទក្ខន្តិ វទនំ ធញ្ញា តេ នរបុង្គវ ។
ទីឃង្គុលិ តម្ពនខេ សុភេ អាយតបណ្ហិកេ
យេ បាទេ បណាមយន្តិ(៤) តេបិ ធញ្ញា វណ្ណន្តរ(៥) ។

---

១ ម. កត្វ ។ ២ ឱ. បុព្វយ្យ ។ ៣ ឱ. ភាទិទប្បបភារិនោ ។ ៤ ឱ ម. បណាមិស្សន្តិ ។ ៥ ម. គុណន្តរ ។

ភិក្ខុនីដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ធ្វើប្រទក្សិណព្រះជិនស្រីដ៏ប្រសើរ ដូចជាផ្កាយប្រព្រឹត្ត ទៅតាមព្រះចន្ទ ដើរប្រទក្សិណភ្នំសិនេរុ ហើយក្រាបចុះទៀបព្រះបាទា រួចឈរមើលមើល នូវព្រះភក្ត្រនៃព្រះសាស្តានោះ ៗ ព្រះនាងបជាបតិគោតមីក្រាបទូលថា ភ្នែករបស់ខ្ញុំ មិនធ្លាប់ឆ្អែត ដោយការឃើញនូវព្រះអង្គ ត្រចៀករបស់ខ្ញុំ មិនធ្លាប់ឆ្អែត ដោយភាសិតរបស់ព្រះអង្គ ៗ ចិត្តរបស់ខ្ញុំតែមួយប៉ុណ្ណោះ ដល់នូវសេចក្តីឆ្អែត ដោយរសនៃធម៌ដ៏ពេញលេញ ៗ

កាលព្រះមានព្រះភាគទ្រង់បន្លឺឡើង ក្នុងកណ្តាលបរិស័ទ ទ្រង់ប្រហារនូវសេចក្តីងឿងឆ្ងឹង របស់ជនអ្នកមានរាគៈ ពួកជនណាបានឃើញព្រះឱរស្ស បពិត្រព្រះអង្គជាធំជាងនរៈ ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ៗ ជនទាំងឡាយណា ថ្វាយបង្គំនូវព្រះបាទា មានព្រះអង្គុលីវែង មានព្រះនខាក្រហម មានព្រះបណ្ហិវែងល្អ បពិត្រព្រះអង្គ ទ្រង់ដល់នូវទីបំផុតនៃសេចក្តីសៅហ្មង ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ៗ

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

មនុភានិ បហដ្ឋានិ  ឃោសណានិ ហិតានិ ច(១)
យេ តេ វាក្យានិ សុណន្តិ(២) តេបិ ជញ្ញា នុត្តម ។
ជញ្ញាហន្តេ មហាវីរ  ឆានបូជនតប្បរា(៣)
តិណ្ណំ សំសារកន្តារ  សុវាក្យេន សិរីមតោ(៤) ។
តតោ សា អនុសាវេត្វា  ភិក្ខុសង្ឃម្ហិ(៥) សុព្វតា
រាហុលានន្ទនន្ទេ ច  វន្ទិត្វា ឥទមព្រវិ ។
អាសិវិសាលយសមេ  រោគាវាសេ កលេវរេ
និព្វិណ្ណា ទុក្ខសង្ឃាតេ(៦)  ជរាមរណគោចរេ ។
នានាកុណបមលាកិណ្ណេ(៧) បរាយត្តេ និរីហកេ
តេន និព្វាតុមិច្ឆាមិ  អនុមញ្ញថ បុត្តកា ។

---

១ ឱ. ឃោសយាតី នហិតានិ ច ។ ម. ឃោសត្ប្បានិ ហិតានិ ច ។ ២ ឱ. សុស្សន្តិ ។ ម. សុយ្យន្តិ ។ ៣ ម. មានបូជនតប្បរា ។ ៤ ឱ. សុទ្ធម្មេន សិរីមតា ។ ៥ ម. អនុមានេត្វា ភិក្ខុ-សង្ឃំបិ ។ ៦ ឱ. ទុក្ខបង្កេ តេ ។ ម. ទុក្ខសង្ឃាដេ ។ ៧ ឱ. នានាកលលមាកិណ្ណេ ។ ម. នានាកាឡមលាកិណ្ណេ ។

ជនទាំងឡាយណា ស្តាប់នូវពាក្យទាំងឡាយដ៏ពីរោះ ជាទីរីករាយចិត្ត ជាគ្រឿងដុតបោលនូវទោស ជាទីនាំមកនូវប្រយោជន៍ បពិត្រព្រះអង្គប្រសើរជាងនរៈ ជនទាំងឡាយនោះ ឈ្មោះថាមានបុណ្យ ។ បពិត្រព្រះមហាវីរៈ ខ្ញុំជាស្រីមានបុណ្យ ជាអ្នកយកចិត្តទុកដាក់ ក្នុងការបូជានូវព្រះបាទារបស់ព្រះអង្គ ជាស្រីឆ្លងចាកផ្លូវលំបាកគឺសង្សារ តាមព្រះពុទ្ធដីកា របស់ព្រះអង្គមានសិរី ។ លំដាប់នោះ ព្រះនាងគោតមី បានក្រាបទូលព្រះមានព្រះភាគ ជាស្រីមានវត្តល្អចំពោះភិក្ខុសង្ឃ រួចថ្វាយបង្គំព្រះរាហុល ព្រះអានន្ទ និងព្រះនន្ទ ហើយពោលនូវពាក្យនេះថា ខ្ញុំមានសេចក្តីនឿយណាយក្នុងសាកសព ជាលំនៅរបស់រោគ ស្មើដោយលំនៅ នៃសត្វមានពិស ជាគ្រឿងកំណត់នៃទុក្ខ ជាទីគោចរនៃជរានិងមរណៈ ។ ជារូបដេរដាសដោយមន្ទិល គឺសាក-សពផ្សេងៗ ជាអាយត្ត(១) នៃបុគ្គលដទៃ ជារូបប្រាសចាកអំណាច ព្រោះហេតុនោះ ខ្ញុំប្រាថ្នាដើម្បីព្រះនិព្វាន បពិត្រកូនទាំងឡាយ លោកទាំងឡាយ ចូរសំគាល់ចុះ ។

---

១ ដែលពឹងផ្អែកអ្នកដទៃ ដែលឥតអំណាចលើខ្លួន ។

នន្ទោ រាហុលភទ្ទោ ច វីតសោកា និរាសវា
ឋិតាចលា ឋិតី ថីរា(១) ធម្មតមនុចិន្តយុំ ។
និរត្ថុ សង្ខតំ លោកំ(២) អសារំ កទលូបមំ
មាយាមរីចិសទិសំ ឥត្តរំ អនវដ្ឋិតំ ។
យត្ថ នាម ជិនស្សាយំ មាតុច្ឆា ពុទ្ធបោសិកា
គោតមី និធនំ យាតិ អនិច្ចំ សព្វសង្ខតំ ។
អានន្ទោ ច តទា សេក្ខោ កនិដ្ឋោ ជិនវច្ឆលោ
តត្ថស្សូនិ ករោន្តោ(៣) សោ ករុណំ បរិទេវតិ ។
ភាសន្តី(៤) គោតមី យាតិ នូន(៥) ពុទ្ធោបិ និព្វុតឹ
គច្ឆតិ ន ចិរេនេវ អគ្គិ វិយ និរិន្ធនោ ។

---

១ ឱ. ម. ឋិតាចលធីតិ ធីរា ។ ម. ឋិតាចលដ្ឋិតិ ថិរា ។ ២ ឱ. លោលំ ។ ៣ ឱ. ធរន្តោ ។ ៤ ឱ. ហាសន្តី ។ ម. ហាសន្តឹ ។ ៥ ឱ. នូនំ ។ ម ននុ ។

ព្រះនន្ទ និងព្រះរាហុលដ៏ចម្រើន ជាអ្នកមិនមានសេចក្តីសោក មិនមានអាសវៈ មានចិត្តនឹងធឹង មិនមានកម្រើក មានប្រាជ្ញា មានព្យាយាម គិតរំពឹងនូវធម៌ថា ហើយ ! សង្ខតធម៌ ជារបស់វិនាស ជារបស់មិនមានខ្លឹម មានឧបមាដូចដើមចេក ប្រាកដស្មើដោយកលមាយា និងថ្ងៃបណ្តើរកូន ជារបស់តិចតួច មិនបានតាំងនៅយឺនយូរឡើយ ។ ព្រះនាងគោតមីនេះ ជាព្រះមាតុច្ឆានៃព្រះជិនស្រី បានបញ្ចឹមព្រះសម្ពុទ្ធ ដើរទៅកាន់សេចក្តីស្លាប់ ក្នុងទីណា (ទីនោះ) មិនទៀង ត្រូវមានបច្ច័យតាក់តែងទាំងអស់ ។ ចំណែកឯព្រះអានន្ទ នៅជាសេក្ខបុគ្គល ជាប្អូនជាទីស្រឡាញ់នៃព្រះជិនស្រី ព្រះអានន្ទនោះ បង្ហូរទឹកភ្នែកក្នុងទីនោះ ធ្វើនូវសេចក្តីករុណា ទួញយំខ្សឹកខ្សួលថា ព្រះនាងគោតមី ពោលលាទៅកាន់ព្រះនិព្វានហើយ មិនយូរប៉ុន្មានទេ ព្រះសម្ពុទ្ធក៏គង់ទៅកាន់ព្រះនិព្វានពុំខានដែរ ដូចភ្លើងមិនមានកំញម ។

### សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ឯវំ វិលបមានន្តំ អានន្ទំ អាហ គោតមី
សុតិសាគរគម្ភីរំ ពុទ្ធោបដ្ឋានតប្បរំ ។
ន យុត្តំ សោចិតុំ បុត្ត ហាសកាលេ ឧបដ្ឋិតេ
តស្មា(១) មេ មរណំ(២) បុត្ត និព្វានន្តមុបាគតំ ។
តយា តាត សមជ្ឈិដ្ឋោ បព្វជ្ជំ អនុជានិ នោ
មា បុត្ត វិមនោ ហោហិ សផលោ តេ បរិស្សមោ ។
យំ ន ទិដ្ឋំ បុរាណេហិ តិត្ថិកាចរិយេហិ ច
តំ បទំ សុកុមារីហិ សត្តវស្សាហិ វេទិតំ ។
ពុទ្ធសាសនបាលេតា បច្ឆិមំ ទស្សនំ តវ
តត្ថ គច្ឆាមហំ បុត្ត គតោ(៣) យត្ថ ន ទិស្សតិ ។

---

១ ឱ. ម. តយា ។ ២ ឱ. ម. សរណំ ។ ៣ ម. គតា ។

ព្រះនាងគោតមី បានមានព្រះសវនីយ៍ ទៅកាន់ព្រះអានន្ទ ដែលកំពុងតែយំរៀបរាប់យ៉ាងនេះ ជាអ្នកមានវេទដ៏ជ្រៅដូចសាគរ ជាអ្នកយកចិត្តទុកដាក់ ក្នុងការបម្រើព្រះសម្ពុទ្ធថា បពិត្រលោកកូន កាលបើកាលជាទីរីករាយ ប្រាកដហើយ លោកកូនមិនគួរសោយសោកទេ បពិត្រលោកកូន សេចក្ដីស្លាប់របស់ខ្ញុំនោះ ជាកិច្ចចូលទៅកាន់ព្រះនិព្វានជាទីបំផុតវិញតើ ៗ បពិត្រលោកកូន ព្រះសាស្ដាដែលលោកកូនបានទូលសុំហើយ ទ្រង់ក៏អនុញ្ញាតនូវផ្នួសដល់យើង បពិត្រលោកកូន ចូរលោកកូនកុំតូចចិត្តឡើយ ព្រោះសេចក្ដីខ្វល់ខ្វាយរបស់លោកកូន ជាការមួយប្រកបដោយផល ៗ បទណាដែលពួកតិត្ថិកាចារ្យដ៏ចាស់ មិនបានយល់ បទនោះសូម្បីពួកកុមារីដែលមានអាយុ ៧ ឆ្នាំ ក៏យល់ច្បាស់ហើយ ៗ លោកកូនចូររក្សាព្រះពុទ្ធសាសនាចុះ ការឃើញលោកកូន (គ្រានេះ) ជាកិច្ចទីបំផុត (របស់ខ្ញុំ) បពិត្រលោកកូន បុគ្គលទៅហើយមិនប្រាកដ ក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ ៗ

កទាចិ ធម្មំ ទេសេន្តោ ទិបិ លោកគ្គនាយកោ

តទាហំ អាសីសកំ អបេខំ អនុកម្បិកោ ។

ចិរំ ជីវ មហាវីរ កប្បំ តិដ្ឋ មហាមុនេ

សព្វលោកហិតត្ថាយ ភវស្សុ អជរាមរោ ។

តំ តថាវាទិនឹ ពុទ្ធោ មមំ សោ ឯតទព្រវិ

ន ហេវំ វន្ទិយា ពុទ្ធា យថា វន្ទសិ គោតមិ ។

កថញ្ចរហិ សព្វញ្ញូ វន្ទិតព្វា តថាគតា

កថំ អវន្ទិយា ពុទ្ធា តំ មេ អក្ខាហិ បុច្ឆិតោ ។

ព្រះនាយក ជាកំពូលនៃលោក ទ្រង់សម្តែងធម៌ផ្សាយទៅក្នុងកាលណា កាលនោះ ខ្ញុំជាស្ត្រីអនុគ្រោះ ខ្ញុំបានពោលនូវវាចាឲ្យពរថា បពិត្រព្រះអង្គមានព្យាយាមធំ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ បពិត្រព្រះមហាមុនី សូមព្រះអង្គគង់នៅអស់មួយកប្បចុះ សូមព្រះអង្គកុំមានជរានិងមរណៈ ដើម្បីជាប្រយោជន៍ដល់សត្វលោកទាំងអស់ ។ ព្រះពុទ្ធនោះទ្រង់ត្រាស់នឹងខ្ញុំ ដែលជាអ្នកក្រាបទូលដូច្នោះ នូវពាក្យនេះថា បពិត្រព្រះនាងគោតមី ព្រះនាងថ្វាយបង្គំយ៉ាងណា ព្រះពុទ្ធទាំងឡាយ គេមិនដែលថ្វាយបង្គំ យ៉ាងនោះទេ ។

ព្រះតថាគតទាំងឡាយ ជាសព្វញ្ញូ បុគ្គលគប្បីថ្វាយបង្គំ ដោយប្រការដូចម្តេច ព្រះពុទ្ធទាំងឡាយ បុគ្គលមិនគប្បីថ្វាយបង្គំ តើដោយប្រការដូចម្តេច ព្រះអង្គដែលខ្ញុំសួរហើយ សូមប្រាប់នូវហេតុនោះឲ្យមាន ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

អារទ្ធវីរិយេ បហិតត្តេ    និច្ចំ ទឡ្ហបរក្កមេ
សមគ្គេ សាវកេ បស្ស    ឯតំ ពុទ្ធាន វន្ទនំ ។
តតោ ឧបស្សយំ គន្ត្វា    ឯកិកាហំ វិចិន្តយឹ
សមត្តំ បរិសំ នាថោ    រោចេតិ(១) តិករុត្តកោ ។
ហន្ទាហំ បរិនិព្វាយិំ(២)    មា វិបត្តឹ តមទ្ទសំ(៣)
ឯវាហំ ចិន្តយិត្វាន    ទិស្វាន ឥសិសត្តមំ ។
បរិនិព្វានកាលំ មំ(៤)    អារោចេមិ វិនាយកំ
តតោ សោ សមនុញ្ញាសិ    កាលំ ជានាហិ គោតមិ ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវា ។

---

១ ម. រោចេសិ ។ ២ ឱ. ម. បរិនិព្វិស្សំ ។ ៣ ឱ. ឥមទ្ទសំ ។ ៤ ឱ. មេ ។

## មហាបជាបតិគោតមីថេរិយាបទាន ទី ៧

នាងចូរមើលនូវសាវ័កទាំងឡាយ ដែលមានព្យាយាមតឹងតែង មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានសេចក្ដីប្រឹងប្រែងដ៏មាំជានិច្ច ជាអ្នកព្រមព្រៀងគ្នា នេះឈ្មោះថាការថ្វាយបង្គំនូវព្រះពុទ្ធទាំងឡាយ ។

លំដាប់នោះ ខ្ញុំទៅកាន់លំនៅភិក្ខុនីតែម្នាក់ឯង ក៏គិតយ៉ាងនេះថា ព្រះលោកនាថ ទ្រង់ដល់នូវទីបំផុតនៃត្រៃភព ទ្រង់ពេញព្រះហឫទ័យនឹងបរិស័ទ ដែលព្រមព្រៀងគ្នា ។ ណ្ហើយចុះ ខ្ញុំនឹងបរិព្វាន កុំឲ្យឃើញនូវវិបត្តិនោះ ខ្ញុំគិតយ៉ាងនេះហើយ ក៏ឃើញនូវព្រះពុទ្ធ ជាឥសីទី ៧ ។ ខ្ញុំក្រាបទូលនូវកាលបរិនិព្វានរបស់ខ្ញុំ ចំពោះព្រះនាយក លំដាប់នោះព្រះអង្គទ្រង់អនុញ្ញាតថា បពិត្រព្រះនាងគោតមី ព្រះនាងចូរដឹងនូវកាលជាទីបរិនិព្វានចុះ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំដកចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចមេដំរីកាត់ផ្ដាច់នូវទន្លីង ។

ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។
ថីនំ ធម្មាភិសមយេ   យេ ពាលា វិមតឹ គតា
តេសំ ទិដ្ឋិបហានត្ថំ   ឥទ្ធឹ ទស្សេហិ គោតមិ ។
តទា និបច្ច សម្ពុទ្ធំ   ឧបតិត្វាន អម្ពរំ
ឥទ្ធី អនេកា ទស្សេសិ   ពុទ្ធានុញ្ញាយ គោតមី ។
ឯកិកា ពហុធា អាសិ   ពហុកា ចេកិកា តថា
អាវិភាវំ តិរោភាវំ   តិរោកុឌ្ឌំ តិរោនគំ(១) ។
អសជ្ជមានា អគមា   ភូមិយម្បិ និមុជ្ជថ
អភិជ្ជមានេ ឧទកេ   អគញ្ឆិ មហិយំ យថា ។

---

១ ឱ. តិរោនភំ ។

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ពួកជនពាលណា ដល់នូវសេចក្ដីសង្ស័យក្នុងការត្រាស់ដឹងនូវធម៌ នៃស្ត្រីទាំងឡាយ បពិត្រព្រះនាងគោតមី ព្រះនាងចូរសម្ដែងនូវឫទ្ធិ ដើម្បីកំចាត់បង់នូវទិដ្ឋិនៃពួកជនពាលនោះ ។

គ្រានោះព្រះនាងគោតមី ក្រាបថ្វាយបង្គំ ព្រះសម្ពុទ្ធ ហើយហោះឡើងទៅ ឯអាកាស សម្ដែងនូវឫទ្ធិដ៏ច្រើនជាអនេក តាមពុទ្ធានុញ្ញាត គឺស្ត្រីតែម្នាក់ ធ្វើឲ្យទៅជាច្រើនអ្នកក៏បាន ស្ត្រីច្រើននាក់ ធ្វើឲ្យទៅជាម្នាក់ក៏បាន ទៅកាន់ទីវាល ជាទីខាងក្រៅ ខាងក្រៅជញ្ជាំង ខាងក្រៅភ្នំក៏បាន ដើរទៅមិនទើសទាក់ មុជចុះក្នុងផែនដីក៏បាន ដើរលើទឹកមិនបែកធ្លាយទឹក ហាក់ដូចជាដើរលើផែនដី ក៏បាន ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

សកុណីវ យថាកាសេ  បល្លង្កេន កមី តទា
វសំ វត្តេសិ កាយេន  យាវ ព្រហ្មនិវេសនំ ។
សិនេរុំ ទណ្ឌំ កត្វាន  ឆត្តំ កត្វា មហាមហឹ
សមូលំ បរិវត្តេត្វា  ធារយំ ចង្កមី នភេ ។
ឆស្សូរោទយកាលេវ[1]  លោកញ្ចាកាសិ ធុមិតំ[2]
យុគន្តេ វិយ តំ លោកំ[3]  ជាលមាលាកុលំ អកា ។
មុច្ចលិន្ទំ មហាសេលំ  មេរុំ មន្ទារទទ្ទរេ
សាសបានីវ[4] សព្វានិ  ឯកេនគ្គណ្ហិ មុដ្ឋិនា ។
អង្គុលគ្គេន ឆាទេសិ  ភាករំ សសិសាករំ
ចន្ទសុរិយសហស្សានិ[5]  អាវេឡមិវ ធារយិ ។
ចតុសាគរតោយានិ  ធារយិ ឯកបាណិនា
យុគន្តជលទាការំ[6]  មហាវស្សំ អវស្សថ[7] ។
ចក្កវត្តឹ សបរិសំ  មាបយិ សា នភត្តលេ
គរុឡំ ទ្វិរទំ សីហំ  វិនទន្តញ្ច ទស្សយិ[8] ។

---

១ ម. អស្សុរោទយកាលេវ ។ ២ ឱ. ធូមិតំ ។ ម. ធូមិកំ ។ ៣ ឱ. ម. យុគន្តេ វិយ លោកំ សា ។ ៤ ឱ. ម. សាសបាវិវ ។ ៥ ឱ. ម. ចន្ទសូរសហស្សានិ ។ ៦ ឱ. យុគន្ត-ផលទាការា ។ ៧ ម. បវស្សថ ។ ៨ ម. វិនទន្តំ បទស្សយិ ។

ទៅទាំងក្អែនលើអាកាស ដូចជាសត្វស្លាបក៏បាន ញុំាងអំ-
ណាចកាយឲ្យអណ្តែតទៅ ដរាបដល់លំនៅនៃព្រហ្ម ក៏
បាន ។ យកភ្នំសិនេរុធ្វើជាដងឆ័ត្រ យកផែនដីធំធ្វើជាឆ័ត្រ
បង្វិលដងឆ័ត្រ បាំងដើរលើផ្ទៃអាកាស ។ ធ្វើនូវលោកឲ្យ
រុងរឿង ដូចជាព្រះអាទិត្យ ៦ រះឡើងផង ធ្វើនូវលោក
នោះឲ្យជាកម្រងសំណាញ់ ដូចជានៅលើភ្នំយុគន្ធរផង ។
កាន់យកនូវវត្ថុទាំងពួង គឺ ដើមមុចលិន្ទ ភ្នំធំ ភ្នំសិនេរុ ដើម
មន្ទារនិងដើមទន្ទរៈទាំងឡាយ ដោយក្តាប់ដៃមួយ ដូចជា
កាន់គ្រាប់ស្ពៃ ។ បិទបាំងព្រះអាទិត្យ ព្រះចន្ទ្រ ដោយចុង
ម្រាម ទ្រនូវព្រះចន្ទ្រ ព្រះអាទិត្យមួយពាន់ ដូចជាទ្រនូវ
គ្រឿងប្រដាប់ក្បាល ទ្រនូវទឹកក្នុងសមុទ្រទាំង ៤ ដោយ
ដៃម្ខាង ញុំាងភ្លៀងធំមានអាការដូចជាទឹក ហូរអំពីភ្នំយុគន្ធរ
ឲ្យបង្អុរចុះ ។ ព្រះនាងគោតមីនោះ បាននិម្មិតជាស្តេច
ចក្រពត្តិ ព្រមទាំងបរិស័ទ សម្តែងនូវអត្តភាពជាគ្រុឌផង
ដំរីផង សីហៈផង បន្លឺនូវសម្រែក លើផ្ទៃនៃអាកាស ។

ឯកិកា អភិនិម្មិត្វា     អប្បមេយ្យំ ភិក្ខុនីគណំ
បុន អន្តរធាបេត្វា     ឯកិកា មុនិមព្រវិ ។
មាតុច្ឆា តេ មហាវីរ     តវ សាសនការិកា
អនុប្បត្តា សកំ អត្ថំ     បាទេ វន្ទាមិ(១) ចក្ខុមា ។
ទស្សេត្វា វិវិធំ ឥទ្ធី(២)     ឱរោហិត្វា នភត្តលា
វន្ទិត្វា លោកបជ្ជោតំ     ឯកមន្តំ និសីទិ សា ។
សា វីសវស្សសតិកា     ជាតិយាហំ មហាមុនិ
អលំ ឯត្តាវតា វីរ     និព្វាយិស្សាមិ នាយក ។
តទាតិវិម្ហិតា(៣) សព្វា     បរិសា សា កតញ្ជលី
អវោចយ្យេ កថំ អាសិ     អតុលិទ្ធិ បរក្កមេ ។
បទុមុត្តរេ នាម ជិនោ     សព្វធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ     កប្បេ ឧប្បជ្ជិ(៤) នាយកោ ។

---

១ ឱ. វន្ទតិ ។ ២ ឱ. វិវិធា ឥទ្ធី ។ ៣ ឱ. ម. តទា ហិ វិម្ហិតា ។ ៤ ឱ. ម. ឧប្បជ្ជិ ។

ព្រះនាងតែម្នាក់ឯងនិម្មិតនូវពួកកិន្នរី ដ៏ច្រើនប្រមាណមិនបាន ហើយឲ្យបាត់ទៅវិញ នៅតែម្នាក់ឯង ទើបពោលនឹងព្រះមុនីថា បពិត្រព្រះមហាវីរៈ ខ្ញុំជាមាតុច្ឆារបស់ព្រះអង្គ ជាស្ត្រីអ្នកធ្វើតាមនូវសាសនា របស់ព្រះអង្គ បានសម្រេចប្រយោជន៍របស់ខ្លួនហើយ បពិត្រព្រះអង្គមានចក្ខុ ខ្ញុំសូមថ្វាយបង្គំព្រះបាទាទាំងគូ ។ ព្រះនាងគោតមីនោះ លុះសម្តែងឫទ្ធិផ្សេងៗហើយ ក៏ចុះចាកផ្ទៃនៃអាកាស មកថ្វាយបង្គំព្រះសម្ពុទ្ធ ជាពន្លឺនៃលោក ហើយអង្គុយក្នុងទីដ៏សមគួរ រួចក្រាបទូលថា បពិត្រព្រះមហាមុនី ខ្ញុំកើតមកបានអាយុ ១២០ ហើយ បពិត្រព្រះមហាវីរៈ ខ្ញុំល្មមប៉ុណ្ណោះហើយ បពិត្រព្រះនាយក ខ្ញុំនឹងបរិនិព្វាន ។ គ្រានោះ បរិស័ទទាំងពួងនោះ មានសេចក្តីអស្ចារ្យក្រៃពេក ផ្គងអញ្ជលីហើយពោលថា បពិត្រព្រះនាងមានឫទ្ធិថឹងពុំបាន មានព្យាយាម កិច្ចទាំងពួង ព្រះនាងបានធ្វើហើយ ។

ព្រះជិនស្រីព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ជានាយក ទ្រង់ត្រាស់ឡើង ក្នុងកប្បទីមួយសែនអំពីកប្បនេះ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

តទាហំ ហំសវតិយា ជាតាមច្ចកុលេ អហុ
សព្វោបការសម្បន្នេ ឥទ្ធេ ផីតេ មហទ្ធនេ ។
កទាចិ បិតុនា សទ្ធិំ ទាសីគណបុរក្ខតា
មហតា បរិវារេន តំ ឧបេច្ច នរាសភំ ។
វាសវំ វិយ វស្សន្តំ ធម្មមេឃមនាសវំ(១)
សរទាទិច្ចសទិសំ រំសិមាលាកុលំ ជិនំ(២) ។
ទិស្វា ចិត្តំ បសាទេត្វា សុត្វា ចស្ស សុភាសិតំ
មាតុច្ឆំ ភិក្ខុនឹ អគ្គេ ឋបេន្តំ នរនាយកំ ។
សុត្វា ទត្វា មហាទានំ សត្តាហំ តស្ស តាទិនោ
សសង្ឃស្ស នរគ្គស្ស បច្ចយានិ ពហូនិ ច ។
និបច្ច បាទមូលម្ហិ តំ ឋានំ អភិបត្ថយឹ

១ ម. ធម្មមេឃំ បវស្សយំ ។ ២ ឱ. រសិជាលាកុលញ្ជិនំ ។ ម. រំសិជាលសមុជ្ជលំ ។

## មហាបជាបតិគោតមីថេរីយាបទាន ទី ៧

ក្នុងកាលនោះ ខ្ញុំកើតក្នុងត្រកូលនៃអាមាត្យ ក្នុងនគរហង្សវតី ជាត្រកូលបរិបូណ៌ដោយឧបការៈទាំងពួង ដ៏ស្ដុកស្ដម្ភមាំមួន មានទ្រព្យច្រើន ។ ក្នុងកាលមួយ ខ្ញុំទៅជាមួយនឹងបិតា មានពពួកខ្ញុំស្រីចោមរោម មានបរិវារច្រើន ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ព្រះអង្គប្រសើរជាងនរៈ ។ ខ្ញុំបានឃើញព្រះជិនស្រី មិនមានអាសវៈ ប្រាកដស្មើដោយព្រះអាទិត្យក្នុងសរទកាល ដ៏ដេរដាសដោយកម្រងគីរស្មី ទ្រង់បង្អុរចុះនូវភ្លៀងគឺធម៌ ដូចជាព្រះឥន្ទ្រ ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា បានស្ដាប់សុភាសិត នៃព្រះពុទ្ធនោះ ព្រះអង្គជានាយកនៃនរៈ ទ្រង់តាំងនូវនាងភិក្ខុនី ជាព្រះមាតុច្ឆា ក្នុងទីដ៏ប្រសើរលើស ។ លុះខ្ញុំស្ដាប់ហើយ ក៏បានថ្វាយនូវមហាទានផង នូវបច្ច័យដ៏ច្រើនផង ដល់ព្រះសម្ពុទ្ធ ដ៏ប្រសើរជាងនរជនអង្គនោះ ទ្រង់ជាតាទិបុគ្គល ព្រមទាំងព្រះសង្ឃ អស់ ៧ ថ្ងៃ រួចខ្ញុំក្រាបចុះទៀបព្រះបាទា ហើយប្រាថ្នានូវតំណែងនោះ ។

តតោ មហាបរិសតិ អវោច ឥសិសត្តមោ ។
យា សសង្ឃំ អភោជេសិ សត្តាហំ លោកនាយកំ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
គោតមី នាម នាមេន ហេស្សតិ សត្ថុសាវិកា ។
តស្ស ពុទ្ធស្ស មាតុច្ឆា ជីវិតាទាលិកា(១) អយំ
រត្តញ្ញូនញ្ច អគ្គត្តំ ភិក្ខុនីនំ លភិស្សតិ ។
តំ សុត្វាហំ បមុទិតា យាវជីវំ តទា ជិនំ
បច្ចយេហិ ឧបដ្ឋិត្វា តតោ កាលំ កតា អហំ ។

---

១ ឱ. ទីបិតាបាទិកា ។

លំដាប់នោះ ព្រះពុទ្ធជាឥសីទី ៧ បានពោលក្នុងបរិស័ទច្រើនថា ស្ត្រីណា បានញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់ អស់ ៧ ថ្ងៃ តថាគតនឹងសរសើរនូវស្ត្រីនោះ អ្នកទាំងឡាយចូរស្តាប់ នូវពាក្យដែលតថាគត នឹងសម្តែងដូចតទៅនេះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឧក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ ស្ត្រីនោះ នឹងបានជាឱរស ជាអ្នកទទួលមត៌ក ក្នុងធម៌នៃព្រះពុទ្ធនោះ ជាធម្មនិម្មិត ឈ្មោះនាងគោតមី នឹងបានជាសាវិកា នៃព្រះសាស្តាអង្គនោះ ។ នាងគោតមីនេះជាព្រះមាតុច្ឆា ជាអ្នករក្សានូវជីវិតនៃព្រះពុទ្ធនោះ នឹងបាននូវទីដ៏ប្រសើរលើស ជាងភិក្ខុនីទាំងឡាយ ជាអ្នកដឹងនូវរាត្រីដ៏វែង (មានអាយុវែង) ។ គ្រានោះ ខ្ញុំស្តាប់នូវព្រះពុទ្ធដីកានោះ ក៏មានចិត្តរីករាយ បានបម្រើនូវព្រះជិនស្រី ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត តមក ខ្ញុំក៏ធ្វើមរណកាល ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

តាវត្តឹសេសុ ទេវេសុ សព្វកាមសមិទ្ធិសុ
និព្វុតា ទសហង្គេហិ អញ្ញេ អភិភវឹ អហំ ។
រូបសទ្ទេហិ គន្ធេហិ រសេហិ ផុស្សនេហិ ច
អាយុនាបិច វណ្ណេន សុខេន យសសាបិច ។
តថេវាធិបតេយ្យេន អធិគយ្ហ វិរោចហំ
អហោសឹ អមរិន្ទស្ស មហេសី ទយិតា តហឹ ។
សំសារេ សំសរន្តីហិ(១) កម្មវាយុសមេរិតា
កាសិករញ្ញោ វិសយេ អជាយឹ ទាសគាមកេ ។
បញ្ចទាសសតានូនា និវសន្តិ តហឹ តទា
សព្វេសំ តត្ថ យោ ជេដ្ឋោ តស្ស ជាយា អហោសហំ ។
សយម្ភុនោ បញ្ចសតា គាមំ បិណ្ឌាយ បាវិសុំ
តេ ទិស្វាន អហំ តុដ្ឋា សហ សព្វេហិ ញាតិភិ ។
កត្វា បញ្ចសតំ កុដី(២) ចាតុម្មាសេ ឧបដ្ឋិយ(៣)
តិចីវរានិ ទត្វាន បសន្នម្ហា(៤) សសាមិកា ។

---

១ ឱ. ម. សំសរន្តីហំ ។ ២ ឱ. បូជា ភរិយា សព្វា យោ ។ ម. បូគ. ហុត្វាន សព្វា យោ ។ ៣ ម. ឧបដ្ឋហុំ ។ ៤ ឱ. សំតករម្ហា ។ ម. សំសរិម្ហា ។

## មហាបជាបតិគោតមីថេរីយាបទាន ទី ៧

ខ្ញុំបានទៅកើត ក្នុងពួកទេវតាជាន់តាវត្តិង្ស សម្រេចនូវសេចក្តីប្រាថ្នាទាំងពួង បានគ្រប់សង្កត់ នូវទេវតាទាំងឡាយដទៃ ដោយអង្គ ១០ យ៉ាង គឺដោយរូប សំឡេង ក្លិន រស សម្ផស្ស អាយុ វណ្ណៈ សុខៈ យស ។ មួយទៀត ខ្ញុំឈ្នះឈ្នានរុងរឿង ដោយអធិបតេយ្យ (ជាគំរប់ ១០) ខ្ញុំបានជាមហេសី របស់ព្រះឥន្ទ្រ ក្នុងឋាននោះ ៗ ខ្ញុំត្រូវខ្យល់គឺកម្មបក់ផាត់ទៅ អន្ទោលទៅ ក្នុងសង្សារ បានទៅកើតក្នុងស្រុកទាសគ្រាម ក្នុងដែននៃស្តេចឈ្មោះកាសិកៈ ៗ គ្រានោះ ខ្ញុំប្រុស ៥០០ នាក់ ឥតខ្វះខាត នៅក្នុងស្រុកនោះ ជនណាជាធំជាងជនទាំងពួង ក្នុងស្រុកនោះ ខ្ញុំបានជាប្រពន្ធរបស់ជននោះ ៗ ភិក្ខុប្រាំរយអង្គ របស់ព្រះសយម្ភូ បានចូលទៅកាន់ស្រុកនោះ ដើម្បីបិណ្ឌបាត ខ្ញុំព្រមទាំងញាតិទាំងអស់ ឃើញភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ ខ្ញុំព្រមទាំងប្តី មានចិត្តជ្រះថ្លា បានធ្វើកុដិប្រាំរយខ្នង (ប្រគេន) ចូលទៅបម្រើ អស់ ៤ ខែ ហើយប្រគេននូវត្រៃចីវរ ៗ

តតោ ចុតា សបតិកា(១) តាវតឹសំ គតា មយំ
បច្ឆិមេ ច ភវេ ទានិ ជាតា ទេវទហេ បុរេ ។
បិតា អញ្ជនសក្កោ មេ មាតា មម សុលក្ខណា
តតោ កបិលវត្ថុស្មឹ សុទ្ធោទនឃរំ គតា ។
សញ្ញា(២) សក្យកុលេ ជាតា សក្យានំ(៣) ឃរមាគមុំ
អហំ សេដ្ឋា ច(៤) សព្វាសំ ជិនស្សាបាទិកា អហុំ ។
ស មេ(៥) បុត្តោភិនិក្ខម្ម ពុទ្ធោ អាសិ វិនាយកោ
បច្ឆាហំ បព្វជិត្វាន សតេហិ សហ បញ្ចហិ ។
សាកិយានីហិ វីរាហិ សហ សន្តិសុខំ ផុសឹ
យេ តទា បុព្វជាតិយា អម្ហាកំ អាសុ សាមិនោ ។

១ ម. សព្វបិកា ។ ២ ឱ. ម. សេសា ។ ៣ ឱ. តស្សេវ ។ ៤ ឱ. ម. វិសិដ្ឋា ។
៥ ឱ. ម. មម ។

ខ្ញុំព្រមទាំងប្តី លុះច្យុតចាកអត្តភាពនោះ បានទៅកើតក្នុងឋានតាវត្តិង្ស ឥឡូវនេះ ខ្ញុំកើតក្នុងបុរី ឈ្មោះទេវទហៈក្នុងភពជាទីបំផុត ។ ព្រះបិតារបស់ខ្ញុំជាសាក្យៈ ព្រះនាមអញ្ជនៈ ព្រះមាតារបស់ខ្ញុំ ព្រះនាមសុលក្ខណា លំដាប់នោះ ខ្ញុំបានទៅកាន់ដំណាក់ (អគ្គទេពី) នៃព្រះរាជា ព្រះនាមសុទ្ធោទនៈ ក្នុងក្រុងកបិលពស្តុ ។ ស្ត្រីទាំងអស់ កើតក្នុងសាក្យត្រកូល បានទៅកាន់ដំណាក់ (ស្រីស្នំ) របស់ព្រះបាទសុទ្ធោទនៈនោះ ខ្ញុំប្រសើរជាងស្ត្រីទាំងអស់ បានជាអ្នករក្សាទូវព្រះជិនស្រី ។ ព្រះសម្ពុទ្ធនោះ ជានាយក ជាបុត្ររបស់ខ្ញុំ ទ្រង់ចេញទៅបព្វជ្ជា លុះកាលជាខាងក្រោយ ខ្ញុំក៏ចេញទៅបួសជាមួយនឹងស្ត្រីប្រាំរយនាក់ ។ ខ្ញុំបានពាល់ត្រូវនូវសន្តិសុខ ជាមួយនឹងពួកនាងសាកិយានីទាំងឡាយ ជាស្ត្រីមានព្យាយាម ក្នុងកាលនោះ ជនទាំងឡាយណា ជាស្វាមីរបស់យើង ក្នុងជាតិមុន ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

សហ បុញ្ញស្ស កត្តារេ  មហាសមយការកា
ជុសីសុ អរហត្តន្តេ  សុគតេនានុកម្បិតា ។
តទេតរា ភិក្ខុនីយោ  អារូហឹសុ នភត្តលំ
សង្គតា វិយ តារាយោ  វិរោចឹសុ មហិទ្ធិកា ។
ឥទ្ធី អនេកា ទស្សេសុំ  បិលន្ធិកាតី យថា
កម្មារោ កនកស្សេវ  បុញ្ញកម្មេសុ សុសិក្ខិតា(១) ។
ទស្សេត្វា បាដិហេរានិ  វិវិធានិ(២) ពហូនិ ច
តោសេត្វា វទិន្ទវរំ(៣)  មុនឹ សបរិសំ តទា ។
ឱរោហិត្វា នភត្តលា(៤)  វន្ទិត្វា ឥសិ សត្តមំ
អនុញ្ញាតា នរគ្គេន  យថា ឋានេ និសីទិសុំ ។
អហោនុកម្បិកាម្ហាកំ(៥)  សព្វាសំ វីរ គោតមី
វាសិតា តាយ បុញ្ញេហិ  បត្តា នោ អាសវក្ខយំ ។

---

១ ឱ. កម្មញ្ញស្ស សុសិក្ខិតោ ។ ម. កតកម្មញ្ញស្ស សុសិក្ខិតា ។ ២ ឱ. ម. ចិត្តានិ ប ។
៣ ឱ. ម. វាទិបវរំ ។ ៤ ឱ. ម. នគគា ។ ៥ ឱ. ម. អហោនុកម្បិតា អម្ហំ ។

ជនទាំងនោះ ជាអ្នកធ្វើបុណ្យ អ្នកធ្វើលទ្ធិដ៏ធំ ដែលព្រះសុគតអនុគ្រោះហើយ ក៏បាននូវព្រះអរហត្ត ។

ភិក្ខុនីទាំងឡាយដទៃ ក្រៅអំពីព្រះនាងមហាបជាបតិគោតមីនោះ ហោះទៅកាន់ផ្ទៃអាកាស មានឫទ្ធិច្រើន រុងរឿង ដូចជាផ្កាយប្រជុំគ្នា សម្តែងឫទ្ធិជាអនេក ជាស្ត្រីសិក្សាក្នុងបុញ្ញកម្មទាំងឡាយ ដូចជាជាងមាស ធ្វើនូវគ្រឿងប្រដាប់ដ៏ប្លែកៗ ។ គ្រានោះ ភិក្ខុនីទាំងឡាយ សម្តែងនូវបាដិហារ្យផ្សេងៗ ជាច្រើន ញុំាំងព្រះមុនីដ៏ប្រសើរដូចជាព្រះអាទិត្យព្រមទាំងបរិស័ទឲ្យត្រេកអរ ។ ចុះអំពីផ្ទៃអាកាស មកថ្វាយបង្គំព្រះពុទ្ធ ជាឥសីទី ៧ លុះព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់អនុញ្ញាតហើយ ក៏គង់ក្នុងទីដដែលវិញ រួចទូលថា បពិត្រព្រះមហាវីរៈ ព្រះនាងគោតមី បានអនុគ្រោះខ្ញុំព្រះអង្គទាំងអស់គ្នា ពួកខ្ញុំព្រះអង្គ បានព្រះនាងគោតមីនោះ អប់រំដោយបុណ្យទាំងឡាយ ក៏បានដល់នូវការអស់ទៅនៃអាសវៈ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

កិលេសា ឈាបិតាម្ហាកំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាម អនាសវា ។
ស្វាគតំ វត នោ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥទ្ធិយញ្ច វសី ហោម ទិព្វាយ សោតធាតុយា
ចេតោបរិញ្ញាណស្ស វសី ហោម មហាមុនិ ។
បុព្វេនិវាសំ ជានាម ទិព្វចក្ខុ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថេ ធម្មេ ច នេរុត្តេ បដិភាណេ ច វិជ្ជតិ
ញាណំ អម្ហំ មហាវីរ ឧប្បន្នំ តវ សន្តិកេ ។

កិលេសទាំងឡាយ ពួកខ្ញុំម្ចាស់ដុតបំផ្លាញហើយ ភពទាំងពួង ពួកខ្ញុំម្ចាស់ដកចោលហើយ ពួកខ្ញុំ ជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ពួកខ្ញុំម្ចាស់មកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ពួកខ្ញុំម្ចាស់បានដល់ហើយ សាសនា របស់ព្រះពុទ្ធ ពួកខ្ញុំម្ចាស់បានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ពួកខ្ញុំម្ចាស់បានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ពួកខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បពិត្រព្រះមហាមុនី ពួកខ្ញុំម្ចាស់ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុ និងចេតោបរិយញ្ញាណផង ។ ពួកខ្ញុំម្ចាស់ ដឹងនូវបុព្វេនិវាសៈ ជម្រះនូវទិព្វចក្ខុ អស់អាសវៈទាំងពួងហើយ ឥឡូវនេះភពថ្មីទៀត មិនមានឡើយ ។ បពិត្រព្រះមហាវីរៈ ញាណរបស់ខ្ញុំម្ចាស់ កើតឡើង ក្នុងសំណាក់នៃព្រះអង្គ រមែងមានក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផង ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

អម្ហាហិ(១) បរិចិណ្ណោសិ មេត្តចិត្តាហិ នាយក
អនុជានាហិ សព្វាយោ និព្វានាយ មហាមុនេ ។
និព្វាយិស្សាម ឥច្ចេវំ កឹ វក្ខាមិ វទន្តិយោ
យស្សទានិ ច តេ កាលំ មញ្ញសីតិ ជិនោ ព្រវិ ។
គោតមីអាទិកា តាយោ តទា ភិក្ខុនិយោ ជិនំ
វន្ទិត្វា អាសនា តម្ហា វុដ្ឋាយ អគមីសុ តា ។
មហតា ជនកាយេន សហ លោកគ្គនាយកោ
អនុសំសាវយិ(២) ធីរោ មាតុច្ឆំ យាវ កោដ្ឋកំ ។
តទា និបតិ បាទេសុ គោតមី លោកពន្ធុនោ
សហោតរាហិ(៣) សព្វាហិ បច្ឆិមំ បាទវន្ទនំ ។

---

១ ម. អស្មាភិ ។ ២ ឱ. អនុសំយាយិ សោ ។ ៣ ម. សហេវ តាហិ ។

## មហាបជាបតិគោតមីថេរីយាបទាន ទី ៧

បពិត្រព្រះនាយក ពួកខ្ញុំព្រះអង្គមានមេត្តាចិត្ត បានបម្រើព្រះអង្គហើយ បពិត្រព្រះមហាមុនី សូមព្រះអង្គអនុញ្ញាតពួកខ្ញុំព្រះអង្គទាំងអស់ ដើម្បីបរិនិព្វាន ។ ព្រះជិនស្រីទ្រង់ត្រាស់ថា តថាគតនឹងពោលដូចម្ដេច ចំពោះនាងទាំងឡាយ ដែលចេះតែទទូចនិយាយយ៉ាងនេះថា យើងទាំងឡាយ សុំបរិនិព្វានឥឡូវនេះ (កាលបើយ៉ាងនេះ) នាងទាំងឡាយ ចូរសំគាល់នូវកាលគួរដើម្បីនិព្វានចុះ ។ កាលនោះ ភិក្ខុនីទាំងឡាយនោះ មានព្រះនាងគោតមីជាដើម ថ្វាយបង្គំព្រះជិនស្រី ក្រោកចាកអាសនៈ ហើយដើរទៅ ។ ព្រះលោកនាយក ជាកំពូលនៃលោក ជាអ្នកប្រាជ្ញ មួយអន្លើដោយពួកជនដ៏ច្រើន បានស្ដេចទៅតាមព្រះមាតុច្ឆា ដរាបដល់បន្ទប់ ។ គ្រានោះឯង ព្រះនាងគោតមី ក្រាបចុះទៀបព្រះបាទាទាំងគូ នៃព្រះលោកពន្ធុ ជាមួយនឹងពួកភិក្ខុនីទាំងអស់

+ទុះ នេះឈ្មោះជាការថ្វាយបង្គំនូវព្រះបាទជាទីបំផុត ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ឥទំ បច្ឆិមកំ មយ្ហំ    លោកនាថស្ស ទស្សនំ
ន បុនោ អមតាការំ    បស្សិស្សាមិ មុខំ តវ ។
ន ច មេ វន្ទនំ វីរ    តវ បាទេ សុកោមលេ
សម្ផុសិស្សតិ លោកគ្គ    អជ្ជ គច្ឆាមិ និព្វុតឹ ។
រូបេន កិន្តវានេន    ទិដ្ឋេ ធម្មេ យថាតថេ
សព្វំ សង្ខតមេវេតំ    អនស្សាសិកមិត្តរំ ។
សា សហ តាហិ គន្ត្វាន    ភិក្ខុនុបស្សយំ សកំ
អឌ្ឍបល្លង្កមាភុជ្ជ    និសីទិ បរមាសនេ ។
តទា ឧបាសិកា តត្ថ    ពុទ្ធសាសនវច្ឆលា
តស្សា បវត្តឹ សុត្វាន    ឧបេសុំ បាទវន្ទិកា ។

ការឃើញព្រះលោកនាថនៃខ្ញុំនេះ ជាការឃើញទីបំផុត ខ្ញុំនឹងមិនបានឃើញ នូវព្រះភក្ត្ររបស់ព្រះអង្គ ដែលមានអាការមិនស្ងាប់ទៀតឡើយ ។ បពិត្រព្រះអង្គមានព្យាយាម ការថ្វាយបង្គំរបស់ខ្ញុំ ចំពោះព្រះបាទារបស់ព្រះអង្គដ៏ទន់ល្វន់ នឹងមិនមានទៀតឡើយ បពិត្រព្រះអង្គជាកំពូលនៃលោក ខ្ញុំនឹងទៅកាន់ព្រះនិព្វាន ក្នុងថ្ងៃនេះ ។ (ព្រះសម្ពុទ្ធទ្រង់ត្រាស់តបថា) ព្រះនាងនឹងមានប្រយោជន៍អ្វីដោយរូប ក្នុងបច្ចុប្បន្ននេះ ព្រោះរូបទាំងអស់នុ៎ះ សុទ្ធតែមានបច្ច័យតាក់តែង ជារបស់មិនមាំមួន ជារបស់ស្ងួតស្ងើង ។ ព្រះនាងគោតមីនោះ ទៅកាន់សំណាក់ភិក្ខុនី មួយអន្លើដោយភិក្ខុនីទាំងនោះ អង្គុយបត់ជើង លើអាសនៈប្រសើរ ។ គ្រានោះ ឧបាសិកាទាំងឡាយ ក្នុងទីនោះ ជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនា បានឮដំណឹងព្រះនាងគោតមី ក៏ទៅថ្វាយបង្គំព្រះបាទា ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ការេហិ ខុរំ បហាត្តា ឆិន្នមូលា យថា លតា
រុទន្តា ការុណំ គិរំ សោកដ្ឋា ភូមិបាតិកា(១)។
មា នោ សរណទេ នាថ វិហាយាគមិ និព្វុតឹ
និបតិត្វាន យាចាម សព្វាយោ សិរសា មយំ ។
យា បជានំ គមា តាសំ សទ្ធា បញ្ញា ឧបាសិកា
តស្សា សីសំ បមជ្ជន្តី(២) ឥទំ វចនមព្រវិ ។
អលំ បុត្តា វិលាបេន(៣) មារទាសានុវត្តិនា
អនិច្ចំ សង្ខតំ សព្វំ វិយោគន្តំ ចលាចលំ ។
តតោ សា តា វិសជ្ជិត្វា បឋមជ្ឈានមុត្តមំ
ទុតិយញ្ច តតិយញ្ច សមាបជ្ជិ ចតុត្ថកំ ។
អាកាសាយតនញ្ចេវ វិញ្ញាណាយតនំ តថា
អាកិញ្ចំ នេវសញ្ញញ្ច សមាបជ្ជិ យថាក្កមំ ។

---

១ ឱ. ភរិបាតិកា ។ ម. សុរិបាតិកា ។ ២ ឱ. ម. បបជ្ជន្តី ។ ៣ ឱ. ម. វិសាទេន ។

## មហាបជាបតិគោតមីថេរិយាបទាន ទី ៣

យកដៃគក់ទ្រូង យំស្រែក គួរអាណិត សោយសោកផ្តួលខ្លួនលើផែនដី ដូចជាវល្លិដែលគេកាត់ឰដ៏គល់ ពោលដូច្នេះថា បពិត្រព្រះនាងជាទីពឹងទីរលឹក ព្រះនាងកុំលះបង់នូវយើងទាំងឡាយ ទៅកាន់ព្រះនិព្វានឡើយ យើងទាំងអស់គ្នាក្រាបចុះដោយសិរ្សៈ សូមអង្វរយាត់ ៗ ឧបាសិកាណាមានសទ្ធាមានបញ្ញា ជាប្រធាននៃស្រីទាំងនោះ ព្រះនាងគោតមីបានពោលនូវពាក្យនេះ នឹងឧបាសិកានោះ ដែលកំពុងច្របាច់ព្រះសិររបស់ព្រះនាងថា នែកូនស្រី កុំពិលាបឡើយ ព្រោះការយំសោក ជាហេតុនាំឲ្យប្រព្រឹត្តទៅតាមនូវអន្ទាក់នៃមារទេ រូបទាំងអស់ ដែលមានបច្ច័យប្រជុំតាក់តែងហើយ សុទ្ធតែមិនទៀង មានការព្រាត់ប្រាសជាទីបំផុត ជារបស់នាំឲ្យខ្ចេចលាចល ៗ លំដាប់នោះ ព្រះនាងលះបង់នូវពួកឧបាសិកាទាំងនោះ ចូលកាន់បឋមជ្ឈានដ៏ឧត្តម ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ៗ ចូលកាន់អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញាយតនជ្ឈាន តាមលំដាប់ ៗ

បដិលោមេន ឈានានិ សមាបជ្ជ(១) គោតមី
យាវតា បឋមំ ឈានំ តតោ យាវ ចតុត្ថកំ ។
តតោ វុដ្ឋាយ និព្ពាយិ ទីបច្ចីវ និរាសវា(២)
ភូមិចាលោ មហា អាសិ នភសា វិជ្ជុតា បតិ ។
បនាទិតា(៣) ទុន្ទុភិយោ បរិទេវឹសុ ទេវតា
បុប្ផវុដ្ឋិ ច គគនា អភិវស្សថ មេទនឹ ។
កម្បិតោ មេរុនគាបិ រង្គមជ្ឈេ យថា នដោ
សោកេន នាតិទីនោ ច វិរវោ អាសិ សាគរោ ។
ទេវា នាគាសុរា ព្រហ្មា សំវិគ្គាហំសុ តំខណោ(៤)
អនិច្ចា វត សង្ខារា យថាយំ វិលយំ គតា ។
យា ចេមំ បរិវារឹសុ សត្ថុសាសនការិកា
តាយោបិ អនុបាទានា ទីបសិខា វិយ(៥) និព្វុតា ។

---

១ ម. សមាបជ្ជិត្ថ ។ ២ ឱ. ម. និរាសវា ។ ៣ ឱ. ឃនាទិតា ។ ៤ ឱ. តាវទេ ។
៥ ឱ. ម. ទីបច្ចិ វិយ ។

ព្រះនាងគោតមី ចូលកាន់ឈានទាំងឡាយ ជាបដិលោម តាំងពីចតុត្ថជ្ឈាន មកដល់បឋមជ្ឈាន ។ ព្រះនាងគោតមី មិនមានអាសវៈ ចេញពីចតុត្ថជ្ឈាននោះហើយ ក៏និព្វាន ដូចជាប្រទីបអស់ប្រេង៖ ការកម្រើកផែនដីដ៏ធំ ក៏កើតមានឡើង ផ្គរបន្ទោរ ក៏ភ្លៀងធ្លាក់ធ្លាក់ចុះពីអាកាស ។ ទាំងផ្គរក៏លាន់ឮគគ្រឹកគគ្រេង ទេវតាទាំងឡាយក៏យំខ្សឹកខ្សួល ផ្សៀងផ្កាក៏ធ្លាក់ចុះអំពីអាកាស មកកាន់ផែនដី ។ ស្តេចភ្នំឈ្មោះសិនេរុ ក៏កក្រើកញាប់ញ័រ ដូចអ្នករបាំក្នុងកណ្តាលរឿណរង្គ ទាំងសាគរក៏ស្រែក ហាក់ដូចជាមានសេចក្តីសោកគ្របសង្កត់ ។ ទេវតា នាគ អសុរ ព្រហ្ម មានសេចក្តីសង្វេគបានពោលក្នុងខណៈនោះថា ឧហ្ន៎សង្ខារទាំងឡាយមិនទៀងទេ ដូចយ៉ាងព្រះនាងគោតមីនេះ គង់ដល់នូវការរលាយបាត់ទៅ ។ ស្រីទាំងឡាយណា ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ចោមរោមព្រះនាងគោតមីនេះ ស្រីទាំងនោះមិនមានឧបាទាន និព្វានហើយ ដូចជាអណ្តាតប្រទីបដែលរលត់ ។

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

ហា យោគា វិប្បយោគន្តា ហានិច្ចំ សព្វសង្ខតំ
ហា ជីវិតំ វិនាសន្តំ ឥច្ចាសិ បរិទេវនា ។
តតោ ទេវា ច ព្រហ្មា ច លោកធម្មានុវត្តនំ
កាលានុរូបំ កុព្វន្តិ ឧបេត្វា ឥសិសត្តមំ ។
តទា អាមន្តយិ សត្ថា អានន្ទំ សុតិសាគរំ
គច្ឆានន្ទ និវេទេហិ ភិក្ខូនំ មាតុ និព្វុតឹ ។
តទានន្ទោ និរានន្ទោ អស្សុនា បុណ្ណលោចនោ
គគ្គរេន សរេនាហ សមាគច្ឆន្តុ ភិក្ខវោ ។
បុព្វទក្ខិណបច្ឆាសុ ឧត្តរាយ វសន្តិ យេ(១)
មយ្ហំ សា ភិក្ខុនី មាតា(២) ភិក្ខវោ សុគតោរសា ។
យា វឌ្ឍយិ(៣) បយត្តេន សរីរំ បច្ឆិមំ មុនេ
សា គោតមី គតា សន្តឹ តារាវ សុរិយោទយេ ។

---

១ ម. ឧត្តរាយ ច សន្តិកេ ។ ២ ឱ. សុណន្តុ ភាសិតម្មយ្ហំ ។ ម. សុណន្តុ ភាសិតំ មយ្ហំ ។
៣ ឱ. ម. វឌ្ឍយិ ។

ហើ៎ ការប្រកប មានសេចក្តីព្រាត់ប្រាសជាទីបំផុត ហើ៎ រូបទាំង-ពួងដែលបច្ច័យតាក់តែងហើយ សុទ្ធតែមិនទៀង ហើ៎ ជីវិតមានសេចក្តីវិនាសជាទីបំផុត មានសេចក្តីខ្សឹកខ្សួលដូច្នេះឯង ។ លំ-ដាប់នោះ ទេវតា ព្រហ្ម ចូលទៅគាល់ព្រះពុទ្ធជាឥសីទី ៧ ធ្វើនូវការប្រព្រឹត្តិទៅតាមធម្មតាលោក ដ៏សមគួរតាមកាល ។ គ្រានោះ ព្រះសាស្តា ទ្រង់ត្រាស់ហៅព្រះអានន្ទ ដែលមានវេទដ៏ជ្រៅដូចសាគរថា ម្នាលអានន្ទ អ្នកចូរទៅប្រាប់នូវបរិនិព្វាន របស់ព្រះមាតាដល់ភិក្ខុទាំងឡាយចុះ ។ គ្រានោះ ព្រះអានន្ទមានសេចក្តីទុក្ខ មានភ្នែកពេញដោយទឹកភ្នែក មានសំឡេងអាក់អួល ពោលថា ភិក្ខុទាំងឡាយ ណានៅក្នុងទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ភិក្ខុទាំងឡាយនោះ ចូរប្រជុំគ្នា ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីនោះ ជាព្រះមាតារបស់ខ្ញុំ ជាឱរសរបស់ព្រះសុគត ។ ព្រះនាងគោតមីណា ថ្វាយបង្គំព្រះសរីរៈរបស់ព្រះមុនី ជាទីបំផុតដោយការផ្ចិតផ្ចង់ ព្រះនាងគោតមីនោះ ទៅហើយកាន់ទីស្ងប់រម្ងាប់គឺព្រះនិព្វាន ដូចជាផ្កាយបាត់ទៅ ក្នុងកាលជាទីរះឡើងនៃព្រះអាទិត្យ ។

ពុទ្ធមាតាតិ សញ្ញត្តី(១) ឋបយិត្វា គតា សមំ(២)
ន យត្ថ បញ្ចនេត្តោបិ ឥត្ថ(៣) ឥក្ខតិ នាយកោ ។
យស្សត្ថិ សុគតេ សទ្ធា យោ វា សិស្សោ(៤) មហាមុនេ
ពុទ្ធស្ស មាតុ សក្ការំ ការេតុ សុគតោរសោ ។
សុទុក្ករដ្ឋាបិ តំ សុត្វា សីឃមាគច្ឆ(៥) ភិក្ខវោ
កេចិ ពុទ្ធានុភាវេន កេចិ ឥទ្ធីសុ កោវិទា ។
កូដាគារវរេ រម្មេ សព្វសោណ្ណមយេ សុភេ
មញ្ចកំ សមភេបេសុំ(៦) យត្ថ សុត្តាសិ(៧) គោតមី ។
ចត្តារោ លោកបាលា យេ(៨) អំសេហិ សមធារយុំ
សេសា សក្កាទិកា ទេវា កូដាគារេ សមគ្គហុំ ។
កូដាគារានិ សព្វានិ អាសុំ បញ្ចសតានិ ហិ
សរទាទិច្ចវណ្ណានិ វិស្សុកម្មកតានិ(៩) ហិ ។

---

១ ឱ. បញ្ញត្តិំ ។ ម. បញ្ញត្តំ ។ ២ ឱ. សយំ ។ ៣ ឱ. គតំ ។ ម. គតី ។ ៤ ម. យោ ច បិយោ ។ ៥ ឱ. សីយមាគញ្ញុ ។ ម. សង្ឃមាគញ្ញុ ។ ៦ ម. សហាភបេសុំ ។ ៧ ឱ. សុត្តាបិ ម. វុដ្ឋាសិ ។ ៨ ឱ. ម. តេ ។ ៩ ឱ. វិស្សកម្មកតានិ ។

ព្រះលោកនាយក សូម្បីមានព្រះនេត្រ ៥ មិនឃើញ (នូវគតិរបស់ព្រះនាងបជាបតិគោតមី) ទីស្ងប់រម្ងាប់ណា ព្រះនាងបជាបតិគោតមីភិក្ខុនី តម្កល់ទុកនូវឈ្មោះថាពុទ្ធមាតា ទៅហើយកាន់ទីស្ងប់រម្ងាប់នោះ ៗ បុគ្គលណា មានជំនឿចំពោះព្រះសុគត ម្យ៉ាងទៀត សិស្សណា របស់ព្រះមហាមុនី សិស្សនោះ ជាឱរសរបស់ព្រះសុគត ចូរធ្វើសក្ការៈដល់ព្រះពុទ្ធមាតាចុះ ៗ ភិក្ខុទាំងឡាយ សូម្បីនៅក្នុងទីឆ្ងាយក្រៃពេក លុះឮដំណឹងនោះ ក៏មកដោយរហ័ស ភិក្ខុពួកខ្លះមកដោយពុទ្ធានុភាព ភិក្ខុពួកខ្លះជាអ្នកឈ្លាសក្នុងឫទ្ធិទាំងឡាយ ក៏មកដោយឫទ្ធិ ៗ ព្រះនាងគោតមី ផ្ទំលើគ្រែណា ជនទាំងឡាយលើកនូវគ្រែនោះ ដាក់ក្នុងផ្ទះកំពូលដ៏ប្រសើរ ជាទីរីករាយ ដ៏ស្អាត ជាវិការៈនៃមាសទាំងអស់ ៗ លោកបាលទាំង ៤ ក៏សែងដោយស្មាទាំងឡាយ ទេវតាដ៏សេសមានព្រះឥន្ទ្រជាដើម ក៏បានចាប់កាន់ផ្ទះកំពូល ៗ ផ្ទះកំពូលទាំងអស់មានចំនួន ៥០០ ខ្នង ដែលព្រះវិស្សកម្មទេវបុត្រនិម្មិតហើយ មានពណ៌ដូចជាព្រះអាទិត្យ ក្នុងសរទកាល ៗ

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

សព្វា តហឹ(១) ភិក្ខុនិយោ អាសុំ មញ្ចេសុ សាយិកា(២)
ទេវានំ ខន្ធមារុយ្ហ(៣) និយ្យន្តិ អនុបុព្វសោ ៕
សព្វសោ ឆាទិតំ អាសិ វិតានេន នភត្តលំ
សតារា ចន្ទសុរា ច លញ្ឆិតា(៤) កនកាមយា ៕
បដាកា ឧស្សិតានេកា ចិត្តកា(៥) បុប្ផកញ្ចុកា
ឱកក្កាកាសបទុមា(៦) មហិយា បុប្ផមុគ្គតំ ៕
ទិស្សន្តិ ចន្ទសុរិយោ វិជ្ជលន្តិ(៧) ច តារកា
មជ្ឈន្តិកោ បិចាទិច្ចោ ន តាបេសិ សសី យថា ៕
ទេវា ទិព្វេហិ គន្ធេហិ មាលេហិ សុរភីហិ ច
វាទិតេហិ ច នច្ចេហិ សង្គីតីហិ ច បូជយុំ ៕
នាគាសុរា ច ព្រហ្មានោ យថាសត្តិ យថាពលំ
បូជយឹសុ វិនិយ្យន្តិ(៨) និព្វុតំ ពុទ្ធមាតរំ ៕
សព្វាយោ បុរតោ នីតា និព្វុតា សុគតោរសា
គោតមី និយ្យតេ បច្ឆា សក្កតា ពុទ្ធបោសិកា(៩) ៕

---

១ ម. តាបិ ៕ ២ ម. សាយិកា ៕ ៣ ឱ. ម. ខន្ធមារុឡ្ហ ៕ ៤ ម. លញ្ជិតា ៕ ៥ ឱ. វិតតា ៕
៦ ឱ. ឱគតាកាសច្ចូមារ ៕ ម. ឱគតាកាសបច្ចា ប ៕ ៧ ម. បជ្ជលន្តិ ៕ ៨ ម, ប និយ្យន្តី ៕
៩ ឱ. ពុទ្ធបោសិកា ៕

ភិក្ខុនីទាំងអស់ សិងនៅលើគ្រែក្នុងទីនោះ ទេវតាទាំងឡាយសែងគ្រែលើស្មា នាំចេញទៅតាមលំដាប់ ៗ ផ្ទៃអាកាសបិទបាំង ដោយពិតានទាំងអស់ ព្រះចន្ទ្រព្រះអាទិត្យនិងផ្កាយសឹងមានស្នាមសុទ្ធតែមាសទាំងអស់ ៗ ទង់ទាំងឡាយ ជាអនេក ដ៏វិចិត្រ ដូចជាអាវផ្កា ដែលគេលើកឡើងហើយមានផ្កាឈូកធ្លាក់ចុះអំពីអាកាស ផ្កាផុសឡើងអំពីផែនដី ៗ ព្រះចន្ទ្រនិងព្រះអាទិត្យក៏ប្រាកដ ទាំងផ្កាយក៏រុងរឿង ព្រះអាទិត្យត្រង់ជាក់តែមិនក្តៅដូចព្រះចន្ទ្រ ៗ ទេវតាទាំងឡាយក៏បូជាដោយគ្រឿងក្រអូប កម្រងផ្កាជាទិព្វ មានក្លិនឈ្ងុយឈ្ងប់ផង ដោយគ្រឿងប្រគំផង ដោយការរាំច្រៀងផង ៗ នាគ អសុរ ព្រហ្ម ក៏បូជាសមគួរតាមសេចក្តីអង់អាច សមគួរតាមកម្លាំង នាំចេញទៅនូវពុទ្ធមាតាដែលនិព្វានហើយ ៗ ភិក្ខុនីទាំងអស់ ជាឱរសព្រះសុគតដែលនិព្វានហើយ ជនទាំង-ឡាយ នាំទៅខាងមុខ ឯព្រះនាងគោតមី ដែលចិញ្ចឹមព្រះពុទ្ធ ទេវតាធ្វើនូវសក្ការៈ ហើយនាំចេញទៅខាងក្រោយ ៗ

បុរតោ ទេវមនុជា　　សមាគតា សព្រហ្មកា
បច្ឆា សសាវកោ ពុទ្ធោ　　បូជត្ថំ យាតិ មាតុយា ។
ពុទ្ធស្ស បរិនិព្វានំ　　នេទិសំ អាសិ យាទិសំ
គោតមីបរិនិព្វានំ　　អតិអច្ឆរិយំ(១) អហុ ។
ន ពុទ្ធោ ពុទ្ធនិព្វានេ(២)　　សារីបុត្តាទិ ភិក្ខវោ(៣)
ពុទ្ធោ គោតមិនិព្វានេ　　សារីបុត្តាទិកា យថា ។
ចិតកានិ ការិត្វាន　　សព្វគន្ធមយានិ ច(៤)
គន្ធចុណ្ណាវកិណ្ណានិ(៥)　　ឈាបយឹសុ ច តា តហឹ ។
សេសភាគានិ ឌយ្ហឹសុ　　អដ្ឋិសេសានិ សព្វសោ
អានន្ទោ ច តទាវោច　　សំវេគជនកំ វចោ ។

---

១ ឱ. ម. អតីវច្ឆរិយំ ។ ២ ម. ពុទ្ធោ ពុទ្ធស្ស និព្វានេ ។ ៣ ឱ. នោ បទិស្សតិ ភិក្ខវោ ។ ម. នោ បដិយាទិ ភិក្ខវោ ។ ៤ ឱ. ម. តេ ។ ៥ ឱ. គន្ធបុណ្ណាទិកិណ្ណានិ ។ ម. គន្ធចុណ្ណបកិណ្ណានិ ។

ទេវតា មនុស្ស ព្រមទាំងនាគ អសុរ ព្រហ្ម ដើរខាងមុខ ឯព្រះពុទ្ធព្រមទាំងសាវ័ក យាងទៅខាងក្រោយ ដើម្បីបូជាព្រះមាតា ។ បរិនិព្វានរបស់ព្រះនាងគោតមី ជាការណ៍អស្ចារ្យក្រៃពេក យ៉ាងណា បរិនិព្វានរបស់ព្រះពុទ្ធ មិនដូច្នោះទេ ។ (ព្រោះថា) ក្នុងពុទ្ធបរិនិព្វាន មិនមានព្រះពុទ្ធនិងពួកភិក្ខុមានព្រះសារីបុត្តជាដើម (ជាអធិបតីទេ) ក្នុងគោតមីបរិនិព្វាន មានព្រះពុទ្ធនិងពួកភិក្ខុមានព្រះសារីបុត្តជាដើម (ជាអធិបតី) ទេវតាទាំងឡាយ ធ្វើជើងថ្ករទាំងឡាយជាវិការៈនៃគ្រឿងក្រអូបទាំងអស់ ដេរដាសដោយលំអិតមានក្លិនក្រអូប ហើយបូជាសពភិក្ខុនីទាំងឡាយក្នុងទីនោះ ។ បំណែកនៃសរីរៈរាងសេសសល់ និងឆ្អឹងដែលសេសសល់ ក៏ឆេះសុសអស់ គ្រានោះព្រះអានន្ទ បានពោលនូវវាចា ដែលញ៉ាំងសេចក្តីសង្វេគ

## សត្តមំ មហាបជាបតិគោតមីថេរិយាបទានំ

គោតមី និធនំ យាតា ឧឌ្តញ្ញុស្សា(១) សរីរកំ

សេន្តិំ ពុទ្ធនិញ្ញានំ ន ចិរេន ករិស្សតិ ។

តតោ គោតមិធាតូនិ តស្សា បត្តគតានិ សោ

ឧបនាមេសិ នាថស្ស អានន្ទោ ពុទ្ធចោទិតោ ។

បាណិនា តានិ បគ្គយ្ហ អវោច ឥសិសត្តមោ

មហតោ សារវន្តស្ស យថា រុក្ខស្ស តិដ្ឋតោ ។

យោ សោ មហត្តរោ ខន្ធោ បលុជ្ជេយ្យ អនិច្ចតា

តថា ភិក្ខុនិសង្ឃស្ស គោតមី បរិនិព្វុតា ។

អានន្ទ បស្ស ពុទ្ធស្ស(២) និព្វុតាយបិ មាតុយា

សរីរមត្តសេសាយ ន សោកបរិទេវនា(៣) ។

---

១ ម. ឌយ្ហភូស្សា ។ ២ ឱ. ម. អហោ អច្ឆរិយំ មយ្ហំ ។ ៣ ឱ. ម. នត្ថិ សោកបរិទ្ទវោ ។

## មហាបជាបតិគោតមីថេរិយាបទាន ទី ៣

ឡេកើតថា ព្រះនាងគោតមី ទៅកាន់សេចក្ដីស្លាប់ ទាំងសរីរៈរបស់ព្រះនាង ក៏ឆេះសុសអស់ មិនយូរប៉ុន្មាន ព្រះពុទ្ធនឹងបរិនិព្វាន ជាប្រាកដដែរ ៗ លំដាប់នោះ ព្រះអានន្ទនោះដែលព្រះពុទ្ធទ្រង់ដាស់តឿន ក៏បង្អោនទូវព្រះធាតុ របស់ព្រះនាងគោតមី ដែលតម្កល់ទុកក្នុងបាត្ររបស់ព្រះនាង មកថ្វាយព្រះលោកនាថ ៗ ព្រះពុទ្ធជាឥសីទី៧ ទ្រង់ទទួលទូវព្រះធាតុទាំងឡាយនោះ ដោយព្រះហស្ត ហើយទ្រង់ត្រាស់ដូច្នេះថា ដើមឈើធំមានក្លន កាលនៅរស់ ទាំងទំហំដើមក៏ធំ គប្បីបាក់ទៅ ព្រោះសភាវៈមិនទៀង យ៉ាងណា ព្រះនាងគោតមីជាប្រធាននៃភិក្ខុនីសង្ឃ បរិនិព្វានហើយ ក៏យ៉ាងនោះដែរ ៗ ម្នាលអានន្ទ អ្នកចូរមើលចុះ ព្រះពុទ្ធមាតាដែលបរិនិព្វានហើយ សល់តែសរីរៈទេ អ្នកកុំសោកខ្សឹកខ្សួលឡើយ ៗ

ន សោចិយា បរេសំ សា តិណ្ណសំសារសាគរា
បរិវជ្ជិតសន្តាបា សីតិភូតា សុនិព្វុតា ។
បណ្ឌិតាសិ មហាបញ្ញា សុតបញ្ញា តថេវ ច
រត្តញ្ញូ ភិក្ខុនីនំ សា ឃរំ វិញ្ញាប(១) ភិក្ខវេ ។
ឥទ្ធិយោ ច វសី អាសិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី អាសិ ច គោតមី ។
បុព្វេនិវាសមញ្ញាសិ ទិព្វចក្ខុ វិសោធិតំ
សព្វាសវា បរិក្ខីណា នត្ថិទានិ(២) បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
បរិសុទ្ធំ អហុ ញាណំ តស្មា សោចនិយា ន សា ។
អយោឃនហតស្សេវ ជលតោ ជាតវេទសោ
អនុបុព្វុបសន្តស្ស យថា ន ញាយតេ គតិ ។

---

១ ឱ. ជានាថ ។ ម. ជានេថ ។ ២ ឱ. ប. តស្សា ។

ព្រះនាងគោតមីនោះ ចូលចាកសាគរគឺសង្សារហើយ វៀរចាកសេចក្ដីក្ដៅក្រហាយ មានសេចក្ដីត្រជាក់ មានទុក្ខរលត់ហើយ មិនមែនព្រោះតែសេចក្ដីសោក របស់ពួកជនដទៃឡើយ ។ ព្រះនាងគោតមីភិក្ខុនីនោះ ជាបណ្ឌិត មានបញ្ញាច្រើន មានប្រាជ្ញាក្រាស់ មួយទៀត ព្រះនាងជាអ្នកដឹងនូវរាត្រីវែង គឺអាយុវែង ជាងភិក្ខុនីទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរដឹងយ៉ាងនេះចុះ ។ ព្រះនាងគោតមីស្ទាត់ក្នុងឫទ្ធិផង ស្ទាត់ក្នុងទិព្វសោតធាតុ និងចេតោបរិយញ្ញាណផង ដឹងបុព្វេនិវាសៈ ជម្រះទិព្វចក្ខុ មានអាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ញាណក្នុងអត្ថផង ក្នុងធម៌ផង ក្នុងនិរុត្តិផង ក្នុងបដិភាណផង ដ៏បរិសុទ្ធ ព្រោះហេតុនោះ អ្នកមិនគួរសោកស្ដាយព្រះនាងគោតមីនោះឡើយ ។ គតិរបស់បុគ្គលដែលមានចិត្តស្ងប់រម្ងាប់ តាមលំដាប់ រមែងមិនប្រាកដ ដូចដុំដែកដែលបុគ្គលដំហើយ ក៏ក្ដៅរុងរឿង ដោយសារភ្លើង យ៉ាងណា ។

ឋវំ សម្មាវិមុត្តានំ កាមពង្កាយតារិនំ
បញ្ញាចាតុំ[១] គតិ ឆន្ទិ បត្តានំ អចលំ បទំ[២] ។
អត្តទីបា តតោ ហោថ សតិបដ្ឋានគោចរា
ភាវេត្វា សត្តពោជ្ឈង្គំ[៣] ទុក្ខសន្តំ ករិស្សថាតិ ។
ឥត្ថំ សុទំ អាយស្មា មហាបជាបតិគោតមី ភិក្ខុនី
ឥមា គាថាយោ អភាសិត្ថាតិ ។

មហាបជាបតិគោតមីថេរិយាបទានំ សមត្តំ ។

# អដ្ឋមំ ខេមាថេរិយាបទានំ

(១៨) បទុមុត្តរោ នាម ជិនោ សព្វធម្មេសុ ចក្ខុមា
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
តទាហំ[៤] ហំសវតិយំ ជាតា សេដ្ឋិកុលេ អហុ[៥]
នានារតនបជ្ជោតេ មហាសុខសមប្បិតា ។

---

១.ឱ ម. បញ្ញាបេតុំ ។ ២ ឱ. ម. សុខំ ។ ៣ ឱ. ម. សត្តពោជ្ឈង្គេ ។ ៤ ឱ. នគរេ ។ ៥ ឱ. អហុំ ។

គតិរបស់បុគ្គល មានចិត្តផុតចាកកិលេសហើយ ដោយប្រពៃ ចូលចាកចំណងគឺកាមនិងភវៈ ដល់នូវអចលបទគឺព្រះនិព្វានហើយ ក៏មិនប្រាកដយ៉ាងនោះដែរ ៗ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹងចុះ មានសតិប្បដ្ឋានជាអារម្មណ៍ចុះ ចូរចម្រើននូវសត្តពោជ្ឈង្គៈចុះ ចូរធ្វើនូវទីបំផុតនៃកងទុក្ខចុះ ៗ បានឮថា ព្រះមហាបជាបតិគោតមីភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយបការដូច្នេះ ៗ

ចប់ មហាបជាបតិគោតមីថេរិយាបទាន ។

# ខេមាថេរិយាបទាន ទី ៨

(១៨) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ មានបញ្ញាចក្ខុ ចំពោះធម៌ទាំងពួង ជាលោកនាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ៗ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងនគរហង្សវតី ដែលរុងរឿងដោយរតនៈផ្សេង ៗ ខ្ញុំផ្អែតស្កប់ស្កល់ហើយ ដោយសេចក្តីសុខច្រើន ៗ

ឧបេត្វា តំ មហាវីរំ  អស្សោសឹ ធម្មទេសនំ
តតោ ជាតប្បសាទាហំ  ឧបេសឹ សរណំ ជិនំ ។
មាតរំ បិតរញ្ចាហំ  អាយាចិត្វា វិនាយកំ
និមន្តយិត្វា សត្តាហំ  ភោជយឹ សហ សាវកំ ។
អតិក្កន្តេ ច សត្តាហេ  មហាបញ្ញា នមុត្តមំ
ភិក្ខុនី ឯតទគ្គម្ហិ  ឋបេសិ នរសារថិ ។
តំ សុត្វា មុទិតា ហុត្វា  បុន តស្ស មហេសិនោ
ការំ កត្វាន តំ ឋានំ  បណិបច្ច បណិទហឹ ។
តតោ មំ ស(១) ជិនោ អាហ(២) សិជ្ឈតំ បណិធិ តវ
សសង្ឃេ មេ កតំ ការំ  អប្បមេយ្យផលំ តយា(៣)
សតសហស្សិតោ កប្បេ  ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន  សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា  ឱរសា ធម្មនិម្មិតា
ឯតទគ្គមនុប្បត្តា  ខេមា នាម ភវិស្សតិ ។

---

១ ម. មម ។ ២ ម. សាហ ។ ៣ ឱ. តវ ។

ខ្ញុំចូលទៅគាល់ព្រះមហាវីរបុរស ហើយបានស្តាប់ធម្មទេសនា លំដាប់នោះ ខ្ញុំមានសេចក្តីជ្រះថ្លាកើតឡើង ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ ខ្ញុំសូមអង្វរមាតាបិតា ហើយនិមន្តព្រះពុទ្ធជានាយក ព្រមទាំងព្រះសាវ័កមកឆាន់ អស់ ៧ ថ្ងៃ ។ លុះកន្លង ៧ ថ្ងៃផុតទៅ ព្រះពុទ្ធជានរសារថី ទ្រង់តាំងភិក្ខុនី ដែលឧត្តមជាងពួកភិក្ខុនី មានបញ្ញាច្រើន ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំឮព្រះពុទ្ធវាចានោះហើយ ក៏រីករាយ បានធ្វើសក្ការៈ ចំពោះព្រះពុទ្ធជាមហេសីនោះទៀត ក្រាបចុះហើយប្រាថ្នានូវតំណែងនោះ ។

លំដាប់នោះ ព្រះជិនស្រីទ្រង់ត្រាស់ចំពោះខ្ញុំថា សេចក្តីប្រាថ្នារបស់នាង សម្រេចហើយ សក្ការៈដែលនាងធ្វើហើយចំពោះតថាគត ព្រមទាំងព្រះសង្ឃ ជាសក្ការៈមានផលរាប់មិនបាន ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈ នឹងឧប្បត្តិឡើងក្នុងលោក ។ នាងនឹងបានជាភិក្ខុនីឈ្មោះខេមា ជាធម្មទាយាទជាឱរស ជាធម្មនិម្មិតនៃព្រះសាស្តានោះ ដល់នូវទីជាឯតទគ្គៈ ។

## អដ្ឋមំ ខេមាថេរិយាបទានំ

តេន កាលេន សុកាលេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសូបគា អហំ ។
តតោ ចុតា យាមមគំ តតោហំ តុសិតំ គតា
តតោ ច និម្មានរតឹ វសវត្តិបុរំ គតា ។
យត្ថ យត្ថូបបជ្ជាមិ តស្ស កម្មស្ស វាហសា
តត្ថ តត្ថេវ រាជូនំ មហេសិត្តមការយឹ ។
តតោ ចុតា មនុស្សត្តេ រាជូន ចក្កវត្តិនំ
មណ្ឌលីនញ្ច រាជូនំ មហេសិត្តមការយឹ ។
សម្បត្តឹ អនុភោត្វាន ទេវេសុ មនុស្សេសុ ច(១)
សព្វត្ថ សុខិតា ហុត្វា អនេកកប្បេសុ សំសរឹ ។
ឯកនវុតេ ឥតោ កប្បេ វិបស្សី លោកនាយកោ
ឧប្បជ្ជិ ចារុទស្សនោ(២) សព្វធម្មេ វិបស្សកោ ។

---

១ ឱ. ម. មនុជេសុ ច ។ ២ ឱ. ចារុនយនោ ។

## ខេមាថេរិយាបទាន ទី ៨

ខ្ញុំលះបង់រាងកាយ ជារបស់មនុស្ស ហើយចូលទៅកើតក្នុងឋានតាវត្តិង្ស ដោយបុញ្ញកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនាផង ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះហើយ ទើបទៅកើតក្នុងឋានយាមៈ លុះច្យុតចាកឋានយាមៈនោះហើយ ក៏ទៅកើតក្នុងតុសិត លុះច្យុតចាកឋានតុសិតនោះហើយ ក៏ទៅកើតក្នុងឋាននិម្មានរតី ទៅកើតក្នុងឋានបរនិម្មិតវសវត្តីបុរី ។ ខ្ញុំកើតក្នុងត្រកូលណា ៗ ខ្ញុំបានធ្វើភាពជាមហេសីនៃពួកស្តេចក្នុងត្រកូលនោះ ៗ ព្រោះអានិសង្សនៃបុញ្ញកម្មនោះ ។ លុះច្យុតចាកអត្តភាពនោះហើយ បានធ្វើជាមហេសីនៃពួកស្តេចចក្រពត្តិផង នៃពួកស្តេចមានមណ្ឌលផង ក្នុងអត្តភាពជារបស់មនុស្ស ។ ខ្ញុំបានទទួលសម្បត្តិក្នុងទេវលោកទាំងឡាយផង ក្នុងមនុស្សលោកទាំងឡាយផង ដល់នូវសេចក្តីសុខក្នុងទីទាំងពួង ហើយអន្ទោលទៅក្នុងកប្បទាំងឡាយដ៏ច្រើន ។ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះពុទ្ធវិបស្សី ជាលោកនាយក មានព្រះនេត្រដ៏រុងរឿង ឃើញនូវពួកធម៌ទាំងអស់ ទ្រង់កើតឡើងហើយ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

តមហំ លោកនាយកំ ឧបេត្វា(១) នរសារថឹ
ធម្មំ បណីតំ(២) សុត្វាន បព្វជឹ អនគារិយំ ។
ទសវស្សសហស្សានិ(៣) តស្ស វីរស្ស សាសនេ
ព្រហ្មចរិយំ ចរិត្វាន យុត្តយោគោ ពហុស្សុតោ ។
បច្ចយាការកុសលោ ចតុស្សច្ចវិសារទោ
និបុណោ ចិត្តកថិកោ សត្ថុសាសនការកោ ។
តតោ ចុតាហំ តុសិតំ ឧបបន្នោ យសស្សិនី
អភិភោសឹ(៤) តហឹ អញ្ញេ ព្រហ្មចរិយផលេនហំ ។
យត្ថ យត្ថូបបន្នាហំ មហាភោគោ មហទ្ធនោ
មេធាវិនី រូបវតី(៥) វិនីតបរិសាបិច ។
ភវាមិ តេន កម្មេន យោគេន ជិនសាសនេ
សព្វា សម្បត្តិយោ មយ្ហំ សុលភា មនសោ បិយា ។

---

១ ឱ. ឧបេមិ ។ ២ ម. ភណិតំ ។ ៣ ម. អសីតិវស្សសហស្សានិ ។ ៤ ម. អតិភោមិ ។ ៥ ម. សីលវតី ។

ខ្ញុំចូលទៅគាល់ព្រះលោកនាយកនោះ ព្រះអង្គជានសារថី បានស្តាប់ធម៌ដ៏ប្រសើរ ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំបានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសាសនានៃព្រះពុទ្ធជាវីរបុរសនោះ ប្រកបព្យាយាម ជាពហុស្សូត អស់មួយម៉ឺនឆ្នាំ ។ ខ្ញុំជាអ្នកឈ្លាសវៃ ក្នុងធម៌ជាបច្ចយាការ ក្លៀវក្លាក្នុងចតុរារិយសច្ច មានបញ្ញាដ៏ល្អិត ជាធម្មកថិកាដ៏វិចិត្រ ជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា ។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងឋានតុសិត ជាទេវតាមានយស គ្របសង្កត់ពួកទេវតាដទៃ ក្នុងឋានតុសិតនោះ ដោយផលនៃព្រហ្មចរិយធម៌ ។ ខ្ញុំទៅកើតក្នុងទីណា ៗ ជាស្រីមានភោគៈច្រើន មានទ្រព្យច្រើន មានប្រាជ្ញា មានរូបល្អ ទាំងបរិសទ៍ក៏មានសណ្តាប់ធ្នាប់ ។ ខ្ញុំតែងកើតទាន់សាសនា នៃព្រះជិនស្រី ដោយបុញ្ញកម្មនិងសេចក្តីព្យាយាមនោះ សម្បត្តិទាំងអស់ ខ្ញុំរកបានដោយងាយ ទាំងជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ ។

យោបិ មេ កវតេ កត្តា  យត្ថ យត្ថ គតាយបិ
វិមានេតិ ន មំ កោច  បដិបត្តិផលេន តេ ។
ឥមម្ហិ ភទ្ទកេ កប្បេ  ព្រហ្មពន្ធុ មហាយសោ
នាមេន កោនាគមនោ  ឧប្បជ្ជិ វទតំ វរោ ។
តទា ហិ ពារាណសិយំ  សុសមិទ្ធិកុលប្បជា
ធនញ្ជានី សុមេធា ច  អហិបិច តយោ ជនា ។
សង្ឃារាមំ អទាសិម្ហ  នេកេ សហស្សិកេ មុនេ[១]
សសង្ឃស្ស វិហារំ ហិ[២]  ឧទ្ទិស្ស ការិកា[៣] មយំ ។
តតោ ចុតា មយំ សព្វា  តាវត្តឹសូបគា អហុំ
យសសា អគ្គតំ បត្តា  មនុស្សេសុ តថេវ ច ។
ឥមស្មឹយេវ កប្បម្ហិ  ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន  ឧប្បជ្ជិ វទតំ វរោ ។

---

១ ឱ. ទានំ សហស្សិកំ មុនេ ។ ម. ទានសហាយិកា បុរេ ។ ២ ម. សង្ឃស្ស ច វិហារម្បិ ។
៣ ឱ ទាយិកា ។

ខេមាចេរិយាបទាន ទី ៨

សូម្បីបុរសណា ជាកស្តារបស់ខ្ញុំ ដែលខ្ញុំដើរទៅក្នុងទីណា ៗ កស្តានោះ ៗ មិនដែលមើលងាយខ្ញុំឡើយ ព្រោះផលនៃការប្រតិបត្តិរបស់ខ្ញុំ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកោនាគមនៈ ទ្រង់មានផៅពង្សប្រសើរ មានយសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។ កាលនោះ ជន ៣ នាក់ គឺ នាងធនញ្ជានី ១ សុមេធា ១ ខ្ញទខ្ញុំ ១ កើតក្នុងត្រកូលដ៏ស្តុក-ស្តម្ភ ក្នុងនគរពារាណសី ។ យើងទាំងឡាយ ជាអ្នកកសាងវិហារ ហើយឧទ្ទិសថ្វាយបំពោះព្រះពុទ្ធ ព្រមទាំងព្រះសង្ឃ បានវេរថ្វាយសង្ឃារាមនិងទាន រាប់ដោយពាន់ដ៏ច្រើន បំពោះព្រះមុនី ។ លុះយើងទាំងឡាយគ្រប់គ្នា ច្យុតចាកអត្តភាពនោះហើយ បានទៅកើតឯឋានតាវត្តិង្ស ដល់នូវភាពជាបុគ្គលប្រសើរដោយយស ទាំងក្នុងមនុស្សលោកក៏ដូចគ្នា ។ ក្នុងកប្បនេះដដែល ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សប្រសើរ មានយសធំ ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើង ។

ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។
តស្សាសី ជេដ្ឋិកា ធីតា សមណី ឥតិ វិស្សុតា
ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។
អនុជានិ ន នោ តាតោ អគារេវ តទា មយំ
វីសវស្សសហស្សានិ វិចរិម្ហ អតន្ទិតា ។
កោមារិព្រហ្មចរិយំ(១) រាជកញ្ញា សុខេធិតា
ពុទ្ធោបដ្ឋាននិរតា មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច ភិក្ខុនី ភិក្ខុទាសិកា(២)
ធម្មា ចេវ សុធម្មា ច សត្តមី សង្ឃទាសិកា(៣) ។
អហំ ឧប្បលវណ្ណា ច បដាចារា ច កុណ្ឌលា
កិសាគោតមី ធម្មទិន្នា វិសាខា ហោតិ សត្តមី ។

---

១ ឧ. កោមារព្រហ្មចរិយំ ។ ២ ឧ. ភិក្ខទាយិកា ។ ម. ភិក្ខុទាយិកា ។ ៣ ឧ. ម, សង្ឃទាយិកា ។

គ្រានោះ ព្រះរាជាក្នុងដែនកាសី ព្រះនាមកិកី ជាធំលើប្រជាជន ក្នុងនគរពារាណសី ជាបុរីដ៏ឧត្តម ជាឧបដ្ឋាករបស់ព្រះពុទ្ធជាមហេសី ។ ខ្ញុំត្រូវជាធីតាច្បង របស់ព្រះរាជាអង្គនោះ ដែលគេឮប្រាកដថាឈ្មោះសមណី ខ្ញុំបានស្តាប់ព្រះធម៌របស់ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ព្រះវររាជបិតា ទ្រង់ពុំអនុញ្ញាតដល់យើង គ្រានោះ យើងជាអ្នកមិនខ្ជិលច្រអូសទេ ប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារី អស់ ២០ ពាន់ឆ្នាំក្នុងផ្ទះ ជាព្រះរាជកញ្ញា ឋិតនៅក្នុងសេចក្តីសុខ ត្រេកអរក្រៃពេកក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគំរប់ប្រាំពីរ ។ (ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ធីតាទាំង ៧ នោះ) គឺ ខ្ញុំ ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគំរប់ប្រាំពីរ ។

## អដ្ឋមំ ខេមាថេរិយាបទានំ

កទាចិ សោ នរាទិច្ចោ   ធម្មំ ទេសេតិ អព្ភុតំ

មហានិទានសុត្តន្តំ   សុត្វា តំ បរិយាបុណិំ ។

តេហិ កម្មេហិ សុកតេហិ   ចេតនាបណិធីហិ ច

ជហិត្វា មានុសំ ទេហំ   តាវតឹសំ អគញ្ឆហំ ។

បច្ឆិមេ ច ភវេ ទានិ   សាគលាយំ បុរុត្តមេ

រញ្ញោ មទ្ទស្ស ធីតាសឹ   មនាបា ទយិតា បិយា ។

សហ មេ ជាតមត្តម្ហិ   ខេមំ តម្ហិ បុរេ អហុ

តតោ ខេមាតិ នាមំ មេ   គុណតោ(១) ឧបបជ្ជថ ។

យទាហំ យោព្វនំ បត្តា   រូបវណ្ណវិភូសិតា

តទា អទាសិ មំ តាតោ   ពិម្ពិសារស្ស រាជិនោ ។

តស្សាហំ សុបិយា អាសឹ   រូបកេ លាយនេ រតា

រូបានំ ទោសវាទីតិ   ន ឧបេមិ មហាទយំ ។

---

១ ឱ. គុណិកំ ។

## ខេមាថេរីយាបទាន ទី ៨

ក្នុងកាលមួយ ព្រះអគ្គជាអាទិច្ចវង្សរបស់ជន កំពុងសម្ដែងធម៌ ខ្ញុំបានស្ដាប់មហានិទានសូត្រ ដែលជាសូត្រមិនទាន់ដែលកើតមាន ហើយក៏រៀនយកនូវសូត្រនោះ ។ ខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ ក៏ទៅកើតក្នុងឋានតាវត្តិង្ស ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ លុះដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានជាធីតា ជាទីពេញចិត្ត ជាទីស្រឡាញ់ ជាទីប្រោសប្រាណ របស់ស្ដេចព្រះនាមមទ្ទៈ ក្នុងបុរីដ៏ឧត្តម ឈ្មោះសាគលា ។ ការក្រេមក្សាន្ត កើតមានឡើងក្នុងបុរីនោះ ដំណាលគ្នានឹងការដែលខ្ញុំកើតឡើង ព្រោះហេតុនោះ ពាក្យថានាងខេមា ជាឈ្មោះរបស់ខ្ញុំ កើតឡើងដោយគុណ ។ កាលណា ខ្ញុំដល់នូវវ័យដ៏ចម្រើន ស្អិតស្អាងរូបនិងពណ៌ កាលនោះ ព្រះវរពជបិតា បានប្រទានខ្លួនខ្ញុំទៅព្រះបាទពិម្ពិសារ ។ ខ្លួនខ្ញុំជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ព្រះរាជាអង្គនោះ ជាស្រីត្រេកអរក្នុងការប្រកាន់រូប ខ្ញុំមិនដែលបានចូលទៅគាល់ព្រះពុទ្ធ ព្រះអង្គមានសេចក្ដីអាណិតធំ ដោយខ្ញុំគិតឃើញថា ព្រះពុទ្ធជាអ្នកពោលទោស ចំពោះរូប ។

ពិម្ពិសារោ តទា រាជា    មមានុគ្គហពុទ្ធិយា

វណ្ណយិត្វា វេឡុវនំ    គាយកេ គាយយី មមំ ។

រម្មំ វេឡុវនំ យេន    ន ទិដ្ឋំ សុគតាលយំ

ន តេន នន្ទនំ ទិដ្ឋំ    ឥតិ មញ្ញាមសេ មយំ ។

យេន វេឡុវនំ ទិដ្ឋំ    នរនន្ទននន្ទនំ

សុទិដ្ឋំ នន្ទនំ តេន    អមរិន្ទសុនន្ទនំ ។

វិហាយ នន្ទនំ ទេវា    ឱតរិត្វា មហីតលេ

រម្មំ វេឡុវនំ ទិស្វា    ន តប្បន្តិ សុវិម្ហិតា ។

រាជបុញ្ញេន និព្វត្តំ    ពុទ្ធបុញ្ញេន ភូសិតំ

កោ វត្តា តស្ស និស្សេសំ    វនស្ស គុណសញ្ចយំ ។

គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់ញុំាងអ្នកប្រៀនឲ្យប្រៀន សរសើរវត្តវេឡុវ័នឲ្យខ្ញុំស្តាប់ ដោយឧបាយក្នុងការអនុគ្រោះចំពោះខ្លួនខ្ញុំ ដូច្នេះថា ពួកយើងសំគាល់ថា បុគ្គលណាមិនឃើញ នូវវត្តវេឡុវ័ន ជាទីកកាយ ជាលំនៅនៃព្រះសុគតទេ នន្ទនឧទ្យាន ក៏ឈ្មោះថាបុគ្គលនោះមិនឃើញដែរ ៗ វត្តវេឡុ-វ័ន ជាទីកកាយដ៏ក្រៃលែង របស់ប្រជាជន បុគ្គលណាបានឃើញហើយ ឧទ្យានឈ្មោះនន្ទនៈ ជាទីកកាយដ៏ក្រៃលែង របស់សម្តេចអមរិន្ទ្រាធិរាជ ក៏ឈ្មោះថាបុគ្គលនោះ ឃើញហើយដែរ ៗ ពួកទេវតាលះបង់នន្ទនឧទ្យាន ចុះមកលើផ្ទៃផែនដី បានឃើញវត្តវេឡុវ័នជាទីកកាយហើយ ក៏អស្ចារ្យចំឡែក មិនឆ្អែតក្នុងការមើល ៗ វត្តវេឡុវ័ននេះ កើតឡើងដោយបុណ្យព្រះរាជា ដែលស្អិតស្អាងហើយ ដោយបុណ្យរបស់ព្រះពុទ្ធ នរណាឡើយអាចពោល នូវការសន្សំគុណរបស់វត្តវេឡុវ័ន ដោយសព្វគ្រប់បាន ៗ

## អដ្ឋមំ ខេមាថេរិយាបទានំ

តំ សុត្វា វនសមិទ្ធឹ មម សោតមនោហរំ
ទដ្ឋុកាមា តមុយ្យានំ រញ្ញោ អារោចយឹ តទា ។
មហតា បរិវារេន តទា យំ(១) សោ មហីបតិ
សម្បេសេសិ(២) តមុយ្យានំ ទស្សនាយ សមុស្សុកំ ។
គច្ឆ បស្ស មហាភោគេ វនំ នេត្តរសាយនំ
យំ សទា ភាតិ សិរិយា សុគតាភានុរញ្ជិតំ ។
យទា ច បិណ្ឌាយ មុនិ គិរិព្វជបុរុត្តមំ
បវិដ្ឋោហំ តទា យេវ វនំ ទដ្ឋុមុបាគមឹ ។
តទា តំ សផ្ផុល្លវនំ(៣) នានាភមរកូជិតំ
កោកិលាគីតសហិតំ មយូរគណនច្ចិតំ ។
អប្បសទ្ទមនាកិណ្ណំ នានាចង្កមភូសិតំ
កុដិមណ្ឌបសង្កិណ្ណំ យោគីវរវិភជិតំ(៤) ។

---

១ ម. ប ។ ២ ឱ. សម្បាបេសិ ។ ម. មំ បេសេសិ ។ ៣ ឱ. ផុល្លបវនំ ។ ម. ផុល្លវិបិនំ ។
៤ ឱ. ម. យោគីវររិភជិតំ ។

## ខេមា ថេរិយាបទាន ទី ៨

គ្រានោះ ខ្ញុំឮនូវសមិទ្ធិនៃវត្តវេឡុវ័ន ជារឿងនាំមកដល់ត្រចៀកនិងចិត្តរបស់ខ្ញុំ ខ្ញុំមានប្រាថ្នាចង់ទៅមើលឧទ្យាននោះ ទើបក្រាបទូលព្រះរាជា ៗ គ្រានោះ ព្រះរាជាម្ចាស់ផែនដីអង្គនោះ ទ្រង់បញ្ជូនខ្ញុំដែលកំពុងខ្វល់ខ្វាយ ដើម្បីទៅមើលឧទ្យានដោយបរិវារច្រើន ដោយព្រះបន្ទូលថា ម្នាលនាងមានភោគៈច្រើន ព្រៃណាដែលគេត្រេកអរហើយ ដោយពន្លឺព្រះសុគត រមែងភ្លឺដោយសិរីគ្រប់កាលទាំងពួង ចូរនាងទៅចុះ ចូរនាងមើលព្រៃនោះ ដែលជាទីត្រេកអរនៃភ្នែក ៗ ព្រះមុនីសម្ពុទ្ធ ស្តេចទៅកាន់បុរីដ៏ឧត្តម ឈ្មោះគិរិព្វជៈ ដើម្បីបិណ្ឌបាត ក្នុងកាលណា ខ្ញុំក៏ចូលទៅមើលវត្តវេឡុវ័ន ក្នុងកាលនោះ ៗ គ្រានោះ វត្តវេឡុវ័ននោះ មានដើមឈើរីកផ្កាស្គុះស្គាយ ដែលទ្រហឹងដោយភមរជាតិផ្សេង ៗ ប្រកបដោយចម្រៀងនៃសត្វតាវ៉ៅ ដែលពួកក្ងោកកំពុងពង់ពេន ៗ វត្តវេឡុវ័ន ជាវត្តមានសំឡេងតិច មិនកុះករដោយមនុស្ស ស្អិតស្អាងដោយទីចង្ក្រមផ្សេង ៗ មានកុដិនិងមណ្ឌបរៀបជាជួររៀងរាយ ដែលយោគីវរបុរសគួរត្រេកអរដ៏វិសេស ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

វិចរន្តី អមញ្ញិស្សំ សផលំ នយនំ មមំ(១)
តទាបិ(២) តរុណំ ភិក្ខុំ យុត្តំ ទិស្វា វិចិន្តយឹ ។
ឦទិសេបិ វនេ(៣) រម្មេ ឋិតោយំ នវយោព្វនេ
វសន្តមិវ កាន្តេន រូបេន សុសមន្វិតោ ។
និសិន្នោ រុក្ខមូលម្ហិ មុណ្ឌោ សង្ឃាដិបារុតោ
ឈាយតេ វតយំ ភិក្ខុ ហិត្វា វិសយជំ រតឹ ។
ននុ នាម គហដ្ឋេន កាមំ ភុត្វា យថាសុខំ
បច្ឆា ជិណ្ណេន ធម្មោយំ ចរិតព្វោ សុភទ្ទកោ ។
សុញ្ញកន្តិ វិទិត្វាន គន្ធគេហំ ជិនាលយំ
ឧបេត្វា ជិនមទ្ទក្ខឹ ឧទយន្តំវ ភាករំ ។
ឯកកំ សុខមាសីនំ វីជមានំ វរិត្ថិយា
ទិស្វានេវំ វិចិន្តេសឹ នាយំ លូខោ នរាសភោ ។

១ ឱ. ម. មម ។ ២ ឱ. ម. តត្ថាបិ ។ ៣ ឱ. បវនេ ។ ម. វិបិនេ ។

កាលខ្ញុំដើរទៅ បានសំគាល់ឃើញថា ផ្លែករបស់ខ្ញុំ ប្រកបដោយផល ក្នុងគ្រានោះ ខ្ញុំបានឃើញភិក្ខុកំឡោះមួយរូបជាអ្នកព្យាយាម ខ្ញុំគិតថា ភិក្ខុនេះឋិតនៅក្នុងព្រៃគួរកែកាយបែបនេះ ប្រកបដោយរូបជាទីត្រេកអរ ហាក់ដូចជារូបកាលនៅក្នុងវ័យក្មេង ៗ យី ! ភិក្ខុត្រចៀកនេះ ឃុំសង្វាដីអង្គុយពិនិត្យទៀបគល់ឈើ លះបង់នូវតម្រេកដែលកើតអំពីអារម្មណ៍ ៗ ធម៌នេះ ជាធម៌ដ៏ល្អ ក្រែងគ្រហស្ថចាស់ទុំ បរិភោគកាមសុខតាមសប្បាយ គប្បីប្រព្រឹត្តក្នុងកាលខាងក្រោយទេឬ ៗ ខ្ញុំដឹងច្បាស់ថា ព្រៃនេះស្ងាត់ ហើយចូលទៅកាន់គន្ធកុដិជាលំនៅព្រះជិនស្រី បានឃើញព្រះជិនស្រី ដូចជាព្រះអាទិត្យកំពុងរះឡើង ៗ ខ្ញុំបានឃើញព្រះអង្គ គង់ជាសុខតែមួយព្រះអង្គ ដែលស្រីដ៏ប្រសើរកំពុងបក់ថ្វាយ ហើយគិតយ៉ាងនេះថា ព្រះជិនស្រីនេះ ជាបុគ្គលប្រសើរជាងជន មិនសៅហ្មងទេ ៗ

## អដ្ឋមំ ខេមាថេរិយាបទានំ

សា កញ្ញា កនកាភាសា បទុមាននលោចនា
ពិម្ពោដ្ឋិ កុន្ទទស្សនា មនោនេត្តរសាយនា ។
ហេមទោលា សុវទនា កមលាការសុត្ថនី(១)
វេទិមជ្ឈា វរសោណី រម្ភោរូ(២) ចារុភូសនា ។
រត្តំសកុបសព្យានា(៣) នីលមដ្ឋនិវាសនា
អតប្បនេយ្យរូបេន សព្វាភរណមណ្ឌិតា(៤) ។
ទិស្វា តមេវំ ចិន្តេសី អហោយមភិរូបិនី
ន មយានេន នេត្តេន ទិដ្ឋបុព្វា កុទាចនំ ។
តតោ ជរាភិភូតា សា វិវណ្ណា វិកតាននា
ភិន្នទន្តា(៥) សេតសិរា សលាលា វទនាសុចិ ។

---

១ ឧ. វំសវិទា កលសាការសុត្តនី ។ ម. ភសវិកា កលិកាការសុត្តនី ។ ២ ម. វេធិមជ្ឈា វិសុសោណី រម្ភោរុ ។ ៣ ឧ. រត្តំសកសុសំវិតា ។ ៤ ឧ. ម. ហាសកាវសមន្វិតា ។ ៥ ឧ. សីនទន្តា ។ ម. ភិន្នទន្តា ។

## ខេមាថេរិយាបទាន ទី ៨

នាងកញ្ញានោះ មានរស្មីដូចមាស មានមាត់និងភ្នែក ដូចត្របកផ្កាឈូក មានបបូរមាត់ក្រហម មានមុខស្រស់បស់ជាទីត្រេកអរនៃចិត្តនិងភ្នែក ៗ មានដងខ្លួនល្អ មាសម្បុរដូចមាស មានមាត់ល្អ មានស្តនល្អ មានអាការដូចផ្កាឈូក មានពាក់កណ្តាលដងខ្លួនមូលក្លំ មានត្រគាកល្អ មានភ្លៅគួរជាទីត្រេកអរ មានគ្រឿងស្អិតស្អាងល្អ ៗ មានសំពត់បង់លើស្មាពណ៌ក្រហម មានសំពត់សម្លៀកសាច់ម៉ដ្ឋទាំងមានពណ៌ខៀវ ជាកញ្ញាប្រដាប់ដោយអាភរណៈគ្រប់បែបដោយសភាពគួរមើលមិនចេះឆ្អែត ៗ លុះខ្ញុំឃើញយ៉ាងនេះហើយ ទើបគិតថា ឱហ្ន៎ ស្រីនេះមានរូបល្អណាស់ តាំងពីកាលណាមក អញមិនដែលឃើញ ដោយភ្នែកនេះទេ ៗ លំដាប់នោះ ស្រីនោះត្រូវជរាគ្របសង្កត់ ទៅជាមានសម្បុរប្លែក មានមាត់វៀច មានធ្មេញបាក់ មានក្បាលស្កូវព្រោង មានមាត់កខ្វក់ ប្រកបដោយទឹកមាត់ ហៀរកក្លាក់ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

សន្ឆិត្តកណ្ណា សេតក្ខី លម្ពាសុភបយោធរា
វលីវិតតសព្វង្គី(១) សិរាវិតតទេហិនី ។
នតង្គី(២) ទណ្ឌទុតិយា ឧបណ្ឌុបណ្ឌុកា កិសា(៣)
បវេធមានា បតិតា និស្សសន្តី មុហុំ មុហុំ(៤)។
តតោ មេ អាសិ សំវេគោ អព្ភុតោ លោមហំសនោ
ធិរត្ថុ រូបំ អសុចិ រមន្តេ យត្ថ ពាលិសា(៥)។
តទា មហាការុណិកោ ទិស្វា សំវិគ្គមានសំ
ឧទគ្គចិត្តា សុមនោ(៦) ឥមា គាថា អភាសថ ។
អាតុរំ អសុចឹ បូតឹ បស្ស ខេមេ សមុស្សយំ
ឧគ្ឃរន្តំ បគ្ឃរន្តំ ពាលានំ អភិនន្ទិតំ ។
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ និព្វិទាពហុលា ភវ ។

---

១ ម. វលិវិតចសព្វង្គី ។ ២ ម. នតង្គា ។ ៣ ឱ. ឧប្បាសុឡិកតា កិសា ។ ម. ឧប្ពាសុលិកា កិសិកា ។ ៤ ឱ. ម. មុហុំ មុហុំ ។ ៥ ម ពាលិយា ។ ៦ ម. សុគតោ ។

មានស្លឹកត្រចៀកខ្វរ មានក្លែកសល្អក់ មានស្តនមិនល្អស្វិតយុរ-យារ មានអវយវៈទាំងអស់ជ្រួញជ្រីវ មានសាច់រទុះ មានរាងកាយរាមដោយសរសៃ ៗ មានខ្នងកោង មានឈើច្រត់ជាគំរប់ពីរ មានសម្បុរលឿង ស្លេកស្លាំង ស្គាំងស្គម ញាប់ញ័រចំប្រប់ ដួលដេកស្រតឹក ដកដង្ហើមដ្ដឹត ៗ ៗ លំដាប់នោះ ខ្ញុំមានសេចក្តីសង្វេគដ៏ចំឡែក ជាគ្រឿងព្រឺព្រួចរោមថា ថ្វីយពួកជនពាលតែងរីករាយចំពោះរូបណា រូបនោះជារបស់មិនស្អាត ៗ ក្នុងកាលនោះឯង ព្រះបរមសាស្តា ប្រកបដោយមហាករុណា ឃើញខ្ញុំមានចិត្តសង្វេគ ព្រះអង្គក៏មានព្រះហឫទ័យរីករាយត្រេកអរ បានសម្តែងនូវគាថាទាំងនេះថា ម្នាលនាងខេមា ចូរនាងមើលគ្រោងកាយ ជារបស់ក្តៅ ជារបស់មិនស្អាត ជារបស់ស្អុយរលួយ ដែលហូរខ្ទុរចុះខ្ទុរចេញ ដែលមានតែពួកជនពាលទេត្រេកត្រអាល ៗ នាងចូរអប់រំចិត្ត ដោយអសុភសញ្ញា ឲ្យជាចិត្តមានអារម្មណ៍មូលតែមួយ ឲ្យជាសមាធិចិត្តដ៏ល្អ ចូរនាងមានកាយគតាសតិចុះ ចូរនាងច្រើនដោយនិព្វិទានុបស្សនាចុះ ៗ

## អដ្ឋមំ ខេមាថេរិយាបទានំ

យថា ទធិំ តថា ខីរំ　　យថា ខីរំ តថា ទធិំ

អជ្ឈត្តញ្ច ពហិទ្ធា ច　　កាយេ ឆន្ទំ វិរាជយ ។

អនិមិត្តញ្ច ភាវេហិ　　មានានុសយ បជ្ជហ(១)

តតោ មានាភិសមយា　　ឧបសន្តា ចរិស្សសិ ។

យេ រាគរត្តានុបតន្តិ សោតំ

សយំ កតំ មក្កដកោវ ជាលំ

ឯតម្បិ ឆេត្វាន បរិព្វជន្តិ

អនបេក្ខិនោ កាមសុខំ បហាយ ។

តតោ កល្លិតចិត្តំ មំ　　ញត្វាន នរសារថិ

មហានិទានំ ទេសេសិ　　សុត្តន្តំ វិនយាយ មេ ។

---

១ ឱ.ម មានានុសយមុជ្ជហ ។

## ខេមាថេរិយាបទាន ទី ៨

រូបនេះ យ៉ាងណា សរីរៈនៃនាងនុ៎ះ ក៏យ៉ាងនោះ សរីរៈនៃនាងនុ៎ះ យ៉ាងណា រូបនេះ ក៏យ៉ាងនោះដែរ នាងចូរបន្សាត់នូវសេចក្ដីប្រាថ្នា ក្នុងកាយទាំងខាងក្នុងនិងខាងក្រៅចេញ ។ មួយទៀត ចូរនាងអប់រំនូវអនិមិត្តសមាធិ លះបង់ចោលនូវមានានុស័យ តពីនោះ នាងនឹងបានជាបុគ្គលស្ងប់ ព្រោះយល់ច្បាស់នូវមានានុស័យ ។

ពួកជនណា ដែលត្រេកអរដោយរាគៈ រមែងធ្លាក់
ទៅកាន់ខ្សែគឺតណ្ហា ដូចជាសត្វពីងពាងដែលជាប់នឹង
បណ្ដាញ ដែលខ្លួនឯងធ្វើ លុះតែពួកជនទាំងនោះ ជា
អ្នកមិនមានអាល័យ កាត់នូវខ្សែគឺតណ្ហានុ៎ះ លះបង់នូវ
កាមសុខហើយ ទើបចេញបួសបាន ។

លំដាប់នោះ ព្រះមានព្រះភាគ ជានរសារថី ជ្រាបច្បាស់នូវខ្ញុំថា ជាអ្នកមានចិត្តស្រួល ក៏ទ្រង់សម្ដែងនូវមហានិទានសូត្រ ដើម្បីបន្ទោបង់ (នូវកិលេស) របស់ខ្ញុំ ។

សុត្វា សុត្តន្តសេដ្ឋំ បុព្វសញ្ញមនុស្សរឹ

តត្ថដ្ឋិតាហំ សទ្ធឹ ធម្មចក្ខុំ វិសោធយឹ ។

និបតិត្វា មហេសិស្ស បាទមូលម្ហិ តាវទេ

អច្ចយំ ទេសនត្ថាយ ឥទំ វចនមព្រវឹ ។

នមោ តេ សព្វទស្សាវិ នមោ តេ ការុណាលយ(១)

នមោ តេ តិណ្ណសំសារ នមោ តេ អមតទ្ទទ(២) ។

ទិដ្ឋិគហនបក្ខន្ទា(៣) កាមរាគវិមោហិតា

តយា សម្មា ឧបាយេន វិនីតា វិនយេ រតា ។

អទស្សនេន វិហិតា(៤) តាទិសានំ មហេសិនំ

អនុភោន្តិ មហាទុក្ខំ សត្តា សំសារសាគរេ ។

---

១ ឱ. ករុណាសយ ។ ម. ករុណាករ ។ ២ ឱ. អមតប្បទ ។ ៣ ឱ. ទិដ្ឋិគហនបក្ខន្ទា ។ ម. ទិដ្ឋិគហនបក្ខន្ធា ។ ៤ ឱ. វិភោគា ។ ម. វិយោគា ។

លុះខ្ញុំបានស្តាប់នូវព្រះសូត្រ ដ៏ប្រសើរនោះហើយ ក៏រលឹកឃើញនូវសញ្ញាក្នុងកាលមុន ខ្ញុំឋិតនៅក្នុងទីនោះ បានជម្រះនូវធម្មចក្ខុគឺសោតាបត្តិផល ជាគុណដ៏ស្ងប់ ។ ខ្ញុំក្រាបចុះទៀបបាទមូលនៃព្រះសម្ពុទ្ធជាមហេសី ក្នុងខណៈនោះភ្លាម បានពោលពាក្យនេះ ដើម្បីសម្តែងទោសថា បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុទាំងពួង (ខ្ញុំម្ចាស់) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់មានករុណាជាលំនៅ (ខ្ញុំម្ចាស់) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់មានសង្សារឆ្លងហើយ (ខ្ញុំម្ចាស់) សូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ឲ្យនូវអមតធម៌ (ខ្ញុំម្ចាស់) សូមនមស្ការចំពោះព្រះអង្គ ។ ពួកជនដែលស្ទុះទៅកាន់ព្រៃស្បាត គឺទិដ្ឋិ ដែលវង្វេងឈ្ងប់ក្នុងកាមរាគ ព្រះអង្គបានទូន្មានឲ្យត្រេកអរក្នុងវិន័យ ដោយឧបាយដ៏ប្រពៃ ។ ពួកសត្វដែលឃ្វាង ចាកប្រយោជន៍ព្រោះមិនបានជួបប្រទះ នូវព្រះមហេសី ដែលប្រាកដដូចជាព្រះអង្គទេ រមែងរងសេចក្តីទុក្ខធំ ក្នុងសាគរគឺសង្សារ ។

## អដ្ឋមំ ខេមាថេរិយាបទានំ

យថាហំ លោកសរណំ អរណំ មរណន្តគុំ(១)

នាទ្ទសាមិ មធុរត្ថំ(២) ទេសេស្សាមិ(៣) តមទ្ទយំ ។

មហាហិតំ វរទ្ទទំ(៤) អហិតោតិ វិសង្កិតា

នោបេសី រូបនិរតា ទេសេស្សាមិ តមទ្ទយំ ។

តទា មធុរនិគ្ឃោសោ មហាការុណិកោ ជិនោ

អវោច តិដ្ឋ ខេមេតិ សិញ្ចន្តោ អមតេន មំ ។

តទា បណម្យ សិរសា កត្វា ច នំ បទក្ខិណំ

គន្ត្វា ទិស្វា នរបតី ឥមំ វចនមព្រវិ ។

អហោ សម្មា ឧបាយោ តេ ចិន្តិតោ យមរិន្ទម

វនទស្សនកាមាយ ទិដ្ឋោ និព្វនតោ(៥) មុនិ ។

---

១ ម. អរណន្តគុំ ។ ២ ឱ. មធូរដ្ឋំ ។ ម. អធូរដ្ឋំ ៣ ឱ. ទេសយាមិ ។ ៤ ឱ. មហាហិតំ តំ វរទំ ។ ម. មហាហិតំ វរទនំ ។ ៥ ម. និព្វានតោ ។

## ខេមាថេរីយាបទាន ទី ៨

ក្នុងកាលណា ខ្ញុំមិនបានឃើញព្រះពុទ្ធជាទីពឹងរបស់សត្វលោក ព្រះអង្គមិនមានកងកិលេស ដល់នូវទីបំផុតនៃមរណៈ ខ្ញុំនឹងសំម្តែងទោសនោះ មានអត្ថដ៏ពីរោះ ក្នុងកាលនោះ ៗ ខ្ញុំព្រះអង្គឥតមានរង្កៀស បំពោះព្រះពុទ្ធ ព្រះអង្គមានប្រយោជន៍ធំ ឲ្យនូវគុណដ៏ប្រសើរថា ព្រះអង្គឥតប្រយោជន៍ ដូច្នេះឡើយ ខ្ញុំជាអ្នកត្រេកអរក្នុងរូប ទើបមិនបានចូលមកគាល់ព្រះអង្គ ខ្ញុំនឹងសូមសម្តែង នូវទោសនោះ ៗ កាលនោះ ព្រះពុទ្ធជិនស្រីមានសម្លេងពីរោះ ប្រកបដោយមហាករុណា ស្រោចខ្ញុំដោយទឹកគឺអម្រឹត ហើយបានត្រាស់ថា ម្នាលនាងខេមា ចូរនាងឈប់សិន ៗ ក្នុងកាលនោះ ខ្ញុំអោនប្រណម្យដោយត្បូង ធ្វើប្រទក្សិណបំពោះព្រះអង្គហើយ ទើបដើរចេញទៅ លុះខ្ញុំឃើញព្រះនរបតីហើយ ខ្ញុំពោលពាក្យនេះថា បពិត្រព្រះអង្គទូន្មាននូវសត្រូវ ឱហ្ន៎ ! ឧបាយនេះ ព្រះអង្គទ្រង់ព្រះចិន្តាហើយ ដោយប្រពៃ បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ការរំលត់ (កិលេស) ដែលខ្ញុំម្ចាស់ ប្រាថ្នាដើម្បីមើលនូវវត្តវេឡុវ័ន ក៏បានឃើញហើយ ៗ

យទិ តេ រុច្ចតេ រាជ សាសនេ តស្ស តាទិនោ
បព្វជិស្សាមិ រ្វបេហំ និព្វុតា មុនិ ភាណិតា(១) ។

## ទុតិយំ ភាណវារំ ។

អញ្ជលឹ បគ្គហេត្វាន តទាហ ស មហីបតិ
អនុជានាមិ តេ ភទ្ទេ បព្វជ្ជា តវ សិជ្ឈតុ ។
បព្វជិត្វា តទា ចាហំ សត្តមាសេ ឧបដ្ឋិតេ
ទីបោទយញ្ច ភេទញ្ច ទិស្វា សំវិគ្គមានសា ។
និព្វិន្ទា សព្វសង្ខារេ បច្ចយាការកោវិទា
ចតុរោឃេ អតិក្កម្ម អរហត្តំ អបាបុណឹ ។
ឥទ្ធិយា(២) ច វសី អាសឹ ទិព្វាយ សោតធាតុយា
ចេតោបរិយញ្ញាណស្ស វសី ចាបិ ភវាមហំ ។

---

១ ម. និព្វុតា មុនិ ពាទិតា ។ ២ ម. ឥទ្ធីសុ ។

បពិត្រព្រះរាជា បើព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ចំពោះសាសនារបស់ព្រះពុទ្ធ ជាបុគ្គលទីងទាំងនោះ បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់ជាអ្នកនឿយណាយក្នុងរូប ដោយព្រះរាជា នឹងសូមបួសក្នុងកាលឥឡូវនេះ ។

ចប ភាណវារៈ ទី ២ ។

កាលនោះ ព្រះរាជា ជាម្ចាស់ផែនដី ផ្គងអញ្ជលីត្រាស់ថា ម្នាលនាងដ៏ចម្រើន ខ្ញុំអនុញ្ញាតឲ្យនាង សូមបព្វជ្ជារបស់នាងសម្រេចចុះ ។ ក្នុងកាលនោះ ខ្ញុំបួសរួចហើយ លុះដល់ ៧ ថ្ងៃ ប្រាកដហើយ ខ្ញុំបានឃើញនូវការកើតឡើង និងការបែកធ្លាយនៃប្រទីប ហើយក៏មានចិត្តតក់ស្លុតរន្ធត់ ។ ខ្ញុំជាអ្នកនឿយណាយ ក្នុងសង្ខារទាំងពួង ទៀវខ្លាសក្នុងបច្ចយាការ ក៏ខ្ញុំផុតនូវឱឃៈទាំង ៤ ហើយបាននូវភាពនៃខ្លួនជាព្រះអរហន្ត ។ ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។

## អដ្ឋមំ ខេមាថេរិយាបទានំ

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវា បរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
បរិសុទ្ធំ មមំ ញាណំ ឧប្បន្នំ ពុទ្ធសាសនេ ។
កុសលាហំ វិសុទ្ធីសុ កថាវត្ថុវិសារទា
អភិធម្មនយញ្ញូ ច វសិប្បត្តាម្ហិ សាសនេ ។
តតោ តោរណវត្ថុស្មឹ រញ្ញោ កោសលសាមិនោ
បុច្ឆិតា និបុណេ បញ្ហេ ព្យាករោន្តី យថាកថំ(១) ។
តទា ស រាជា សុគតំ ឧបសង្កម្ម បុច្ឆថ
តថេវ ពុទ្ធោ ព្យាកាសិ យថា តេ ព្យាកតា មយា ។
ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
មហាបញ្ញានមគ្គាតិ ភិក្ខុនីនំ នរុត្តមោ ។

---

១ ម. តថំ ។

## ខេមាថេរីយាបទាន ទី ៨

ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុក៏ខ្ញុំបានជម្រះហើយ អាសវៈទាំងអស់របស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទេ ញាណរបស់ខ្ញុំ ដ៏បរិសុទ្ធ ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ កើតឡើងហើយក្នុងពុទ្ធសាសនា ។ ខ្ញុំជាស្រីវាងវៃក្នុងវិសុទ្ធិទាំងឡាយផង ក្លៀវក្លាក្នុងកថាវត្ថុទាំងឡាយផង ស្គាល់ន័យក្នុងអភិធម្មផង ដល់នូវការស្ទាត់ក្នុងសាសនាផង ។ លំដាប់នោះ ខ្ញុំដែលព្រះរាជាម្ចាស់ដែនកោសលទ្រង់សាកសួរទៀបទីក្លោងទ្វារ ក៏ដោះនូវប្រស្នាទាំងឡាយដ៏ល្អិត តាមសេចក្តីពិត ។ គ្រានោះ ព្រះរាជានោះ ទ្រង់ចូលទៅគាល់ព្រះសុគតហើយទូលសួរ ឯព្រះពុទ្ធ ក៏ទ្រង់ដោះស្រាយ ដូចខ្ញុំបានដោះស្រាយប្រស្នាទាំងនោះដែរ ។ ព្រះជិនស្រី ព្រះអង្គជាបុគ្គលឧត្តមជាងជន ត្រេកអរចំពោះគុណនោះ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា ខេមាភិក្ខុនីនេះប្រសើរផុតជាងភិក្ខុនីទាំងឡាយ ដែលមានប្រាជ្ញាច្រើន ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ខេមា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ខេមាថេរិយាបទានំ សមត្តំ ។

## នវមំ ឧប្បលវណ្ណាថេរិយាបទានំ

(១៩) ភិក្ខុនី ឧប្បលវណ្ណា ឥទ្ធិយា បារមី គតា
វន្ទិត្វា សត្ថុនោ បាទេ ឥទំ វចនមព្រវិ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវខ្នោង ។ ខុ ។ ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខេមាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ខេមាថេរិយាបទាន ។

# ឧប្បលវណ្ណាថេរិយាបទាន ទី ៩

(១៩) ឧប្បលវណ្ណាភិក្ខុនី ដល់នូវត្រើយនៃឫទ្ធិ បានថ្វាយបង្គំព្រះបាទាព្រះសាស្តា ហើយពោលនូវពាក្យនេះថា

ឧរិម៉ ឧប្បលវណ្ណាថេរិយាបទានំ

និតិណ្ណា ជាតិសំសារំ បត្តាហំ អចលំ បទំ
សព្វទុក្ខំ មយា ខីណំ អារោចេមិ មហាមុនិ ។
យាវតា បរិសា អត្ថិ បសន្នា ជិនសាសនេ
យេសញ្ច(១) មេបរាធោត្ថិ ខមន្តុ ជិនសម្មុខា ។
សំសារេ សំសរន្តា មេ ខលិតំ មេ សចេ ភវេ
អារោចេមិ មហាវីរ អបរាធំ ខមស្សុ មេ(២) ។
ឥទ្ធិញ្ចាបិ និទស្សេហិ មម សាសនការិកេ
ចតស្សោ បរិសា អជ្ជ កង្ខំ ឆិន្ទាហិ យាវតា ។
ធីតា តុយ្ហំ មហាវីរ បញ្ញវន្ត ជុតិន្ធរ
ពហុញ្ច ទុក្ករំ កម្មំ កតំ មេ អតិទុក្ករំ ។

---

១ ឱ. យេសញ្ចោ ។ ២ ឱ. តំ ។

## ឧប្បលវណ្ណាថេរិយាបទាន ទី ៩

បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ឆ្លងផុត នូវជាតិសង្សារហើយ ដល់នូវព្រះនិព្វាន ជាទីមិនកម្រើក ខ្ញុំម្ចាស់សូមក្រាបទូលនូវទុក្ខទាំងពួង របស់ខ្ញុំម្ចាស់ដែលអស់ហើយ ៗ ពួកបរិស័ទទាំងប៉ុន្មាន ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី កំហុសរបស់ខ្ញុំម្ចាស់ មានចំពោះពួកជនណា សូមពួកជននោះ អត់ទោសក្នុងទីចំពោះព្រះភក្ត្រនៃព្រះជិនស្រីឲ្យទាន ៗ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់កំពុងអន្ទោលទៅក្នុងសង្សារ បើខ្ញុំម្ចាស់មានសេចក្តីភ្លាត់ភ្លាំង ខ្ញុំម្ចាស់សូមអង្វរ សូមព្រះអង្គអត់ទោសចំពោះកំហុសនៃខ្ញុំម្ចាស់នោះ ៗ ម្នាលនាងអ្នកធ្វើតាមសាសនារបស់តថាគត បើដូច្នោះ ចូរនាងសម្តែងនូវឫទ្ធិចុះ ចូរនាងញុំាងបរិស័ទទាំង ៤ ឲ្យកាត់នូវសេចក្តីសង្ស័យទាំងប៉ុន្មាន ក្នុងថ្ងៃនេះចុះ ៗ បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង ខ្ញុំម្ចាស់ជាធីតារបស់ព្រះអង្គ បំណែកខាងអំពើដ៏ច្រើន ដែលគេកម្រធ្វើបាន ខ្ញុំព្រះអង្គបានធ្វើឲ្យជាអំពើ រឹតតែកម្រក្រៃលែង ៗ

ឧប្បលស្សេវ មេ វណ្ណោ នាមេនុប្បលនាមិកា
សា ធីតា តេ មហាវីរ បាទេ វន្ទាមិ ចក្ខុម ។
រាហុលោ ច អហញ្ចេវ- នេកជាតិសតេ ពហូ
ឯកស្មឹ សម្ភវេ ជាតា សមានឆន្ទចេតសា ។
និព្វត្តិ ឯកតោ ហោតិ ជាតិយា នាបិ ឯកតោ
បច្ឆិមេ ភវសម្បត្តេ ឧភយោ(១) នាមសម្ភវា ។
បុត្តោ ច រាហុលោ នាម ធីតា ឧប្បលសវ្ហយា
បស្ស វីរ មម ឥទ្ធឹ ពលំ ទស្សេមិ សត្ថុនោ ។
មហាសមុទ្ទេ ចតុរោ បក្ខិបិ ហត្ថបាណិយំ(២)
តេលំ ហត្ថគតញ្ចេវ(៣) វិជ្ជោ(៤) កោមារកោ យថា ។
ឧព្វត្តយិត្វា បថវឹ បក្ខិបិ ហត្ថបាណិយំ(២)
ចិត្តមុញ្ជំ(៥) យថា នាម លុញ្ចិ កោមារកោ យុវា ។

---

១ ឱ. ឧភោបិ ។ ២ ម. ហត្ថបាតិយំ ។ ៣ ឱ. វត្តិគតញ្ចេវ ។ ៤ ឱ. វេជ្ជោ ។ ៥ ឱ. ចិត្តបុញ្ជំ ។

បពិត្រព្រះអង្គជាមហាវីរបុរស ទ្រង់មានបញ្ញាចក្ខុ សម្បុរ របស់ខ្ញុំម្ចាស់ដូចជាសម្បុរនៃផ្កាឧប្បល ខ្ញុំម្ចាស់មានឈ្មោះជា ឧប្បលវណ្ណា ជាធីតារបស់ព្រះអង្គ សូមថ្វាយបង្គំព្រះបាទា ។ ព្រះរាហុលត្ថេរនិងខ្ញុំម្ចាស់ ធ្លាប់កើតក្នុងភពតែមួយ អស់រយ នៃជាតិជាច្រើន ជាអ្នកមានចិត្តនិងឆន្ទៈស្មើគ្នា ។ ការកើត ឡើងក្នុងទីជាមួយគ្នាក៏មាន ក្នុងជាតិជាមួយគ្នាក៏មាន លុះដល់ បច្ឆិមភព ជនទាំងពីរនាក់កើតដោយឈ្មោះ (ផ្សេងគ្នា) ។ ព្រះរាជបុត្រ បានមកជាកុមារឈ្មោះរាហុល ខ្ញុំម្ចាស់បានមក ជាធីតាឈ្មោះឧប្បលវណ្ណា បពិត្រព្រះអង្គជាវីរបុរស សូម ព្រះអង្គទតឫទ្ធិនៃខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់នឹងសម្ដែងកម្លាំងថ្វាយ ព្រះសាស្ដា ។ នាងឧប្បលវណ្ណា ដាក់មហាសមុទ្រទាំង៤ លើផ្ទៃបាតដៃ ហាក់ដូចកូនក្មេងលេងប្រេង ដែលតាំង នៅលើបាតដៃ ។ នាងឧប្បលវណ្ណា ក្កិះផែនដីដាក់លើ ផ្ទៃបាតដៃ ដូចជាក្មេងជំទង់ ដកនូវស្មៅយាបូងដ៏វិចិត្រ ។

### នវមំ ឧប្បលវណ្ណាថេរិយាបទានំ

ចក្កវាឡសមំ ពាណឹ ឆាទយិត្វាន មត្ថកេ
វស្សាបេត្វាន ផុសិតំ នានាវណ្ណំ បុនប្បុនំ ។
ភូមឹ ឧទុក្ខលំ កត្វា ធញ្ញំ កត្វាន សក្ខរំ
សិនេរុំ មុសលំ កត្វា មទ្ទិ កោមារិកា(១) យថា ។
ធីតាហំ ពុទ្ធសេដ្ឋស្ស នាមេនុប្បលសវ្ហយា
អភិញ្ញាសុ វសីភូតា តវ សាសនការិកា ។
នានាវិកុព្វនំ កត្វា ទស្សេត្វា លោកនាយកំ
នាមគោត្តំ បកាសេត្វា(២) ពាទេ វន្ទាមិ ចក្ខុមា ។
ឥទ្ធិយា ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវា បរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។

---

១ ឱ. បទកោមារិកា ។ ២ ឱ. ម. សំសាវេត្វា ។

## ឧប្បលវណ្ណាថេរីយាបទាន ទី ៩

នាងឧប្បលវណ្ណា ប៉ាំងនូវបាតដៃស្មើបក្រវាឡ លើក្បាល ហើយញុំាងគ្រាប់ភ្លៀង មានពណ៌ផ្សេងៗ ឲ្យធ្លាក់ចុះ ៗ នាងធ្វើផែនដីជាត្បាល់ ធ្វើគ្រួសជាស្រូវ ធ្វើភ្នំសិនេរុជាអង្រែ ដូចក្មេងស្រីបុកស្រូវ ៗ ខ្ញុំម្ចាស់ឈ្មោះឧប្បលវណ្ណា ជាធីតា របស់ព្រះពុទ្ធដ៏ប្រសើរ ជាអ្នកស្ទាត់ក្នុងអភិញ្ញាទាំងឡាយ ជា អ្នកធ្វើតាមសាសនារបស់ព្រះពុទ្ធអង្គ ៗ បពិត្រព្រះអង្គមាន បញ្ញាចក្ខុ ខ្ញុំម្ចាស់សូមធ្វើនូវវិកុព្វនឫទ្ធិផ្សេង ៗ សម្ដែងថ្វាយ ព្រះលោកនាយក ហើយប្រកាសនូវនាមនិងគោត្រ ទើប ថ្វាយបង្គំព្រះបាទាព្រះអង្គ ៗ បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ ជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងទិព្វសោតធាតុឫទ្ធិផង ជាអ្នក ស្ទាត់ក្នុងចេតោបរិយញ្ញាណផង ៗ ខ្ញុំម្ចាស់ដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុក៏ខ្ញុំម្ចាស់ជម្រះហើយ អាសវៈទាំងអស់ ក៏អស់ រលីងហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានទៀតទេ ៗ

អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច

ញាណំ មេ វិបុលំ សុទ្ធំ សភាវេន(១) មហេសិនោ ។

បុរិមានំ ជិនគ្គានំ សង្កាមន្តេន ទស្សិតំ(២)

អធិការំ ពហុ មយ្ហំ តុយ្ហត្ថាយ មហាមុនិ ។

យំ មយា បុរិមំ កម្មំ កុសលំ សរ មេ(៣) មុនិ

តវត្ថាយ មហាវីរ បុញ្ញំ ឧបចិតំ មយា ។

អកព្ពដ្ឋានេ វជ្ជេត្វា បរិចារេន្តា(៤) អនាចារំ

តវត្ថាយ មហាវីរ ចត្តំ មេ(៥) ជីវិតុត្តមំ ។

ទសកោដិសហស្សានិ អទាសិំ មម ជីវិតំ

បរិចត្តា ច មេ ហោមិ តវត្ថាយ មហាមុនិ ។

---

១ ឱ. បភាវេន ។ ២ ឱ. សង្កមន្តេ និទស្សិតំ ។ ម. សង្កមន្តេន ទស្សិតំ ។ ៣ ឱ. សំសរេ ។ ៤ ម. ភារយន្តី ។ ៥ ឱ. វត្តម្មេ ។

ញាណរបស់ខ្ញុំម្ចាស់ ដ៏ទូលាយស្អាតក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ តាមសភាពរបស់ព្រះពុទ្ធជាមហេសី ។ បពិត្រព្រះមហាមុនី ព្រះអង្គផ្ចាញ់សម្តែងនូវសង្គ្រាម ចំពោះព្រះជិនស្រីដ៏ប្រសើរទាំងឡាយក្នុងកាលមុន កិច្ចការដ៏ក្រៃលែងច្រើនយ៉ាងរបស់ខ្ញុំម្ចាស់ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី អំពើណាមានក្នុងកាលមុន ដែលខ្ញុំម្ចាស់ធ្វើហើយ សូមព្រះអង្គ រលឹកនូវអំពើជាកុសលរបស់ខ្ញុំម្ចាស់នោះ បពិត្រព្រះមហាវីរបុរស បុណ្យដែលខ្ញុំម្ចាស់ សន្សំទុកហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះអង្គជាមហាវីរបុរស ខ្ញុំម្ចាស់វៀរ ( នូវអំពើ ) ក្នុងទីមិនគួរ ហើយបានទាត់ចោលនូវអនាចារ ជីវិតដ៏ឧត្តម ដែលខ្ញុំម្ចាស់លះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានជីវិតដល់ខ្ញុំម្ចាស់ អស់ ១០ ពាន់កោដិ ទាំងខ្លួនខ្ញុំម្ចាស់ដែលខ្ញុំម្ចាស់បានលះបង់ហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។

## នវមំ ឧប្បលវណ្ណាថេរិយាបទានំ

តទាតិវិម្ហិតា សព្វា  សិរសាវ កតញ្ជលី
អវោចេយ្យ កតំ(១) អាសិ  អតុលិទ្ធិ បរក្កមា ។
សតសហស្សេ ឥតោ កប្បេ  នាគកញ្ញា អហំ តទា
វិមលា នាម នាមេន  កញ្ញានំ សាធុសម្មតា ។
មហោរគោ មហានាគោ  បសន្នោ ជិនសាសនេ
បទុមុត្តរំ មហាតេជំ  និមន្តេសិ សសាវកំ ។
រតនមយញ្ច មណ្ឌបំ  បល្លង្កំ រតនាមយំ
រតនវាលុកាកិណ្ណំ  ឧបភោគំ រតនាមយំ ។
មគ្គញ្ច បដិយាទេសិ(២)  រតនធជភូសិតំ
បច្ចុគ្គន្ត្វាន សម្ពុទ្ធំ  វជ្ជន្តោ តុរិយេហិ សោ ។
បរិសាហិ ច ចតូហិ  ឧរេត(៣) លោកនាយកោ
មហោរគស្ស ភវនេ  និសីទិ បរមាសនេ ។

---

១ ម. កថំ ។ ២ ឱ. បដិញាទេសិ ។ ៣ ឱ. បរិសាហិ ច ចតូហិ បរេតោ ។ ម. បរិសាហិ ចតស្សាហិ បរិតោ ។

## ឧប្បលវណ្ណាថេរិយាបទាន ទី ៩

គ្រានោះ បរិស័ទទាំងអស់ ស្ញប់ស្ញែងក្រៃលែង ធ្វើអញ្ជលី ដោយត្បូងពោលថា បពិត្រនាងម្ចាស់ សេចក្ដីព្យាយាម មានឫទ្ធិថ្លឹងមិនបាន ដែលនាងធ្វើហើយ តើដូចម្ដេច ៗ

ក្នុងកប្បទីមួយសែន អំពីកប្បនេះ កាលនោះខ្ញុំកើត ជាកញ្ញានៃនាគ ឈ្មោះនាងវិមលា ដែលគេសន្មតហៅថា ស្រីល្អ ជាងនាគកញ្ញាទាំងឡាយ ៗ ពស់ធំឈ្មោះមហា-នាគ ជ្រះថ្លាក្នុងសាសនានៃព្រះជិនស្រី បានទិមន្ដព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់មានតេជៈច្រើន ព្រមទាំងសាវ័ក ៗ មហានាគនោះ បានរៀបចំនូវមណ្ឌប ជាវិការៈនៃកែវផង នូវបល្ល័ង្កជាវិការៈនៃកែវផង នូវគ្រឿងឧបភោគជាវិការៈនៃកែវ ដែលលាយដោយខ្សាច់ជាវិការៈនៃកែវផង នូវផ្លូវ ដែលស្អិតស្អាងដោយទង់ជ័យ ជាវិការៈនៃកែវផង ហើយ ប្រគំដោយតូរ្យតន្ត្រី ទទួលព្រះសម្ពុទ្ធ ៗ ចំណែកខាងព្រះលោកនាយក ដែលបរិស័ទទាំង ៤ បានហែហមហើយ ទ្រង់គង់លើអាសនៈដ៏ប្រសើរ ក្នុងលំនៅនៃមហានាគ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

អន្នបានំ ខាទនីយំ ភោជនញ្ច(១) មហារហំ
វរំ វរញ្ច ទទាសិ នាគរាជា មហាយសំ(២) ។
ភុញ្ជិត្វាន សសម្ពុទ្ធោ បត្តេ(៣) ធោវិត្វា យោនិសោ
អនុមោទនិយំ កាសិ នាគកញ្ញា មហិទ្ធិកា ។
សព្វញ្ញុំ ផុល្លិតំ ទិស្វា នាគកញ្ញា មហាយសំ
បសន្នំ សត្ថុនោ ចិត្តំ សុនិវិទ្ធញ្ច(៤) មានសំ ។
មមញ្ច ចិត្តមញ្ញាយ ជលជុត្តមនាមកោ
តស្មឹ ខណេ មហាវីរោ ភិក្ខុនី ទស្សយិទ្ធិយា ។
ឥទ្ធី អនេកា ទស្សេសិ ភិក្ខុនី សា វិសារទា
បមោទិតា វេទជាតា សត្ថារំ ឯតទព្រវី ។
អទ្ទសាហំ ឥមា ឥទ្ធី(៥) សុមិតា ឥតរាយបិ
កាជំ អហោសិ សា ធីរ ឥទ្ធិយា សុវិសារទា ។

---

១ ឱ. ភោជនីយំ ។ ២ ឱ. មហាយសោ ។ ៣ ម. បត្តំ ។ ៤ ឱ. ម. សុនិពទ្ធញ្ច ។
៥ ឱ. ម. ឥមំ ឥទ្ធិំ ។

ស្តេចនាគបានថ្វាយនូវបាយទឹកផង នូវភោជនដែលគួរបរិភោគមានថ្លៃច្រើនផង នូវពរដ៏ប្រសើរផង ចំពោះព្រះពុទ្ធទ្រង់មានយសធំ ៗ លុះព្រះសម្ពុទ្ធនោះទ្រង់សោយហើយ ទ្រង់លាងបាត្រ ហើយធ្វើអនុមោទនា ដោយឧបាយនៃប្រាជ្ញាថា ចូរនាងនាគកញ្ញា មានឫទ្ធិច្រើនចុះ ៗ នាងនាគកញ្ញាបានឃើញព្រះសព្វញ្ញុពុទ្ធដែលទ្រង់ស្រស់បស់ មានយសច្រើន ចិត្តក៏ជ្រះថ្លាចំពោះព្រះសាស្តាផង ចិត្តក៏ប្រតិព័ទ្ធចំពោះព្រះសាស្តាផង ៗ ក្នុងខណៈនោះ ព្រះសម្ពុទ្ធ ជាមហាវីរបុរស ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវចិត្តរបស់ខ្ញុំ ទ្រង់បង្ហាញនូវភិក្ខុនីដោយឫទ្ធិ ៗ ភិក្ខុនីនោះ ក្លៀវក្លា សម្តែងនូវឫទ្ធិច្រើនប្រការ ខ្ញុំក៏រីករាយ ត្រេកអរ បានពោលពាក្យនេះ ចំពោះព្រះសាស្តាថា បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ខ្ញុំម្ចាស់បានឃើញឫទ្ធិទាំងនេះ ដែលរាប់ថាក្រៃលែងជាងឫទ្ធិឯទៀត ភិក្ខុនីនោះក្លៀវក្លាដោយឫទ្ធិខ្លាំងម៉្លេះ តើដោយប្រការដូចម្តេច ៗ

## ឥទំ ឧប្បលវណ្ណាថេរិយាបទានំ

ឱរសា មុខតោ ជាតា ធីតា មម មហិទ្ធិកា
មមានុសាសនីករា ឥទ្ធិយា សុវិសារទា ។
បុទ្ធស្ស វចនំ សុត្វា តុដ្ឋា ឃរំ អវេចយឹ(១)
អហំបិ តាទិសា ហោមិ ឥទ្ធិយា សុវិសារទា ។
បមោទិតាហំ សុមនា បត្តឧត្តមមានសា
អនាគតម្ហិ អទ្ធានេ ឦទិសា ហោមិ នាយក ។
មណិមយញ្ច បល្លង្កំ មណ្ឌបញ្ច បកស្សវំ
អន្នបានេន(២) តប្បេត្វា សសង្ឃំ លោកនាយកំ
នាតានំ បវំ បុប្ផំ អរុណំ នាម ឧប្បលំ
វណ្ណំ មេ ឦទិសំ ហោតុ បូជេសឹ លោកនាយកំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគញ្ឆហំ ។

---

១ ឱ. តុដ្ឋា ឯវ បត្ថេសហំ ។ ម. ឯវ មហោសហំ តទា ។ ២ ឱ. ម. មហាជនេន ។

## ឧប្បវណ្ណាថេរិយាបទាន ទី ៨

ភិក្ខុនីនេះ ជាធីតា ជាឱរសកើតអំពីមាត់របស់តថាគត ទើបជាភិក្ខុនីមានឫទ្ធិច្រើន ជាអ្នកធ្វើតាមអនុសាសនីរបស់តថាគត បានជាមានសេចក្ដីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ។

លុះខ្ញុំស្ដាប់ព្រះវាចានៃព្រះពុទ្ធហើយ ក៏ត្រេកអរពោលនូវពាក្យយ៉ាងនេះថា សូមឲ្យខ្ញុំម្ចាស់ជាស្ត្រីក្លៀវក្លាក្រៃលែងដោយឫទ្ធិ ប្រាកដដូចជាភិក្ខុនីនោះ ។ បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់មានចិត្តអរសប្បាយ រីករាយ មានចិត្តខ្ពង់ខ្ពស់ សូមឲ្យបានដូចភិក្ខុនីនេះ ក្នុងកាលអនាគត ពុំខាន ។ (ខ្ញុំបានថ្វាយ) នូវបល្ល័ង្កជាវិការៈនៃកែវមណីផង នូវមណ្ឌបដ៏ភ្លឺផ្លេកផង ហើយញុំាងព្រះពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។ ខ្ញុំបូជាផ្កាឧប្បលឈ្មោះអរុណ ជាផ្កាដ៏ប្រសើរ របស់ពួកនាគចំពោះព្រះពុទ្ធ ជាលោកនាយក ហើយសូមឲ្យពណ៌សម្បុររបស់ខ្ញុំដូចផ្កានេះ ។ ដោយអំពើ ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុក នូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

តតោ ចុតាហំ មនុជេ     ឧបបន្នា សយម្ភុនោ
ឧប្បលេហិ បដិច្ឆន្នំ     បិណ្ឌបាតមទាសហំ ។
ឯកនវុតេ ឥតោ កប្បេ     វិបស្សី នាម នាយកោ
ឧប្បជ្ជិ ចារុនយនោ(១)     សព្វធម្មេសុ ចក្ខុមា ។
សេដ្ឋិធីតា តទា ហុត្វា     ពារាណសិបុរុត្តមេ
និមន្តេត្វាន សម្ពុទ្ធំ     សសង្ឃំ លោកនាយកំ ។
មហាទានំ ទទិត្វាន     ឧប្បលេហិ វិនាយកំ
បូជយិត្វា ច តជេហោរ(២)     វណ្ណសោភំ អបត្ថយឹ ។
ឥមម្ហិ ភទ្ទកេ កប្បេ     ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន     ឧប្បជ្ជិ វទតំ វរោ ។
ឧបដ្ឋាកោ មហេសិស្ស     តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម     ពារាណសិបុរុត្តមេ ។

---

១ ម. ចារុទស្សនា ។ ២ ម បេតសារំ ។

លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងឋានមនុស្ស បានថ្វាយបិណ្ឌបាតដែលបិទបាំងដោយផ្កាឧប្បលទាំងឡាយ ចំពោះព្រះពុទ្ធជាសយម្ភូ ។ ក្នុងកប្បទី៩១ អំពីកប្បនេះ ព្រះពុទ្ធជានាយកព្រះនាមវិបស្សី មានព្រះនេត្រដ៏ភ្លឺថ្លា មានបញ្ញាចក្ខុក្នុងធម៌ទាំងពួង ទ្រង់កើតឡើង ។ ក្នុងកាលនោះ ខ្ញុំបានកើតជាសេដ្ឋីធីតា ក្នុងបុរីដ៏ឧត្តម ឈ្មោះពារាណសី បាននិមន្តព្រះសម្ពុទ្ធជាលោកនាយក ព្រមទាំងព្រះសង្ឃ ខ្ញុំថ្វាយមហាទាន បូជាព្រះពុទ្ធជានាយក ដោយផ្កាឧប្បលទាំងឡាយ ហើយប្រាថ្នាឲ្យមានពណ៌សម្បុរល្អដូចផ្កាឧប្បលទាំងនោះ ។ ក្នុងភទ្ទកប្បនេះ ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសច្រើន ប្រសើរជាងពួកជនអ្នកពោល ទ្រង់កើតឡើង ។ គ្រានោះ ព្រះរាជាដែនកាសី ព្រះនាមកិកី ជាឥស្សរៈលើប្រជាជន ក្នុងពារាណសីបុរីដ៏ប្រសើរ បានជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ។

## នវមំ ឧប្បលវណ្ណាថេរិយាបទានំ

តស្សាសឹ ទុតិយា ធីតា   សមណីគុត្តសវ្ហយា(១)
ធម្មំ សុត្វា ជិនគ្គស្ស   បព្វជ្ជំ សមរោចយឹ ។
អនុជានិ ន នោ តាតោ   អគារេវ តទា មយំ
វីសំ វស្សសហស្សានិ   វិចរិម្ហ អតន្ទិតា ។
កោមារិព្រហ្មចរិយំ   រាជកញ្ញា សុខេដ្ឋិតា
ពុទ្ធោបដ្ឋាននិរតា   មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច   ភិក្ខុនី ភិក្ខុទាសិកា(២)
ធម្មា ចេវ សុធម្មា ច   សត្តមី សង្ឃទាសិកា(៣) ។
អហំ ខេមា ច សប្បញ្ញា   បដាចារា ច កុណ្ឌលា
កិសា.គោតមី ធម្មទិន្នា   វិសាខា ហោតិ សត្តមី ។
តេហិ កម្មេហិ សុកតេហិ   ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ   តាវត្តឹសំ អគច្ឆហំ ។

---

១ ឱ. ម. សមគុត្តស្វ្ហយា ។ ២ ឱ. ភិក្ខទាយិកា ។ ម. ភិក្ខុទាយិកា ។ ៣ ឱ. ម. សង្ឃ-ទាយិកា ។

## ឧប្បលវណ្ណាថេរិយាបទាន ទី ៩

ខ្ញុំជាធីតាទីពីរ របស់ព្រះរាជាអង្គនោះ ឈ្មោះនាងសមណគុត្តា បានស្តាប់ធម៌របស់ព្រះពុទ្ធជិនស្រី ជាបុគ្គលប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ ក្នុងគ្រានោះ ព្រះវររាជបិតារបស់យើងទ្រង់មិនអនុញ្ញាត យើងក៏មិនខ្ជិលច្រអូសប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារី អស់ ២០ ពាន់ឆ្នាំ នៅក្នុងផ្ទះ ជាព្រះរាជកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាព្រះរាជធីតា ៧ អង្គ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគំរប់ប្រាំពីរ ។ (ក្នុងពុទ្ធុប្បាទព្រះសមណគោតមនេះ ធីតាទាំងនោះ បានមកជា) ខ្លួនខ្ញុំ ១ នាងខេមាមានប្រាជ្ញា ១ បដាចារា ១ កុណ្ឌលកេសី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគំរប់ប្រាំពីរ ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។

តតោ ចុតា មនុស្សេសុ ឧបបន្នា មហាកុលេ
បីតមដ្ឋវំ ទុស្សំ អទំ អរហតោ អហំ ។
តតោ ចុតា អរិដ្ឋបុរេ ជាតា វិប្បកុលេ អហំ
ធីតា តិរិដិវច្ឆស្ស(១) ឧម្មាទន្តី មនោហរា ។
តតោ ចុតា ជនបទេ កុលេ អញ្ញតរេ អហំ
បសុតា នាតិផីតម្ហិ សាលើ តោបេមហន្តកា ។
ទិស្វា បច្ចេកសម្ពុទ្ធំ បញ្ចលាជសតានហំ
ទត្វា បទុមឆន្នានិ បញ្ច បុត្តសតានិបិ(២) ។
បត្ថយឹ តេសុ បុត្តេសុ(៣) មធុំ ទត្វា សយម្ភុនោ
តតោ ចុតា អរញ្ញេហំ អជាយឹ បទុមោទរេ ។
កាសិរញ្ញោ មហេសីហំ ហុត្វា សក្កតបូជិតា
អជនឹ រាជបុត្តានិ អនូន សតបញ្ចកំ ។

១ ឱ. តិរីដិវច្ឆស្ស ។ ២ ឱ. បុត្តសតានហំ ។ ម. បុត្តសតានិហំ ។ ៣ ឱ. តេសុ បត្ថេ-សុ ។ ម. តេបិ បត្ថេសុំ ។

លុះច្យុតចាកឋានតាវត្តិង្សនោះហើយ ក៏មកកើតក្នុងមនុស្ស ត្រកូលធំ បានថ្វាយនូវសំពត់សាប់ម៉ដ្ឋមានពណ៌លឿងដល់ព្រះអរហន្ត ។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងអរិដ្ឋបុរី ក្នុងត្រកូលព្រាហ្មណ៍ ជាធីតានៃតិរិដិវច្ឆសេដ្ឋី ឈ្មោះនាងឧម្មាទន្តី ជាទីពេញចិត្ត (របស់ជន) ។ លុះខ្ញុំច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងជនបទ ក្នុងត្រកូលមួយ ជាអ្នកខ្វល់ខ្វាយ មិនជាអ្នកស្ដុកស្ដម្ភណាស់ណាទេ ។ គ្រានោះ ខ្ញុំថែរក្សានូវស្រូវសាលី ខ្ញុំបានឃើញព្រះបច្ចេកសម្ពុទ្ធ ហើយថ្វាយលាជប្រាំរយកន្លោង ដែលគ្របដោយផ្កាឈូក ហើយប្រាថ្នានូវកូនប្រាំរយរូប ខ្ញុំថ្វាយទឹកឃ្មុំដល់ព្រះពុទ្ធជាសយម្ភូ ព្រោះតែកូនទាំងនោះ លុះច្យុតចាកអត្តភាពនោះហើយ បានមកកើតក្នុងត្របកផ្កាឈូក នៅក្នុងព្រៃ ។ ខ្ញុំបានជាមហេសីរបស់ស្ដេចដែនកាសី ដែលគេធ្វើសក្ការបូជា បានបង្កើតព្រះរាជបុត្រចំនួនប្រាំរយឥតខ្វះ ។

## នវមំ ឧប្បលវណ្ណាថេរិយាបទានំ

យទា តេ យោព្ពនប្បត្តា កីឡន្តា ជលកីឡិតំ
ទិស្វាន ឱបត្តបទុមំ អាសុំ បច្ចេកនាយកា ។
សាហំ តេហិ វិនាភូតា សុតវរេហិ(១) សោកិនី
ចុតា ឥសិគិលិបស្សេ គាមកម្ហិ អជាយិហំ ។
យទា ពុទ្ធា សុតមតិ សុតានំ អគ្គតោបិ ច
យាតុំ អានាយ គច្ឆន្តិ អជ្ជ បច្ចេកនាយកេ ។
ភិក្ខាយ គាមំ គច្ឆន្តេ ទិស្វា បុត្តេ អនុស្សរី
ចីវរាភ វិនិក្ខញ្ញិ តទា មេ បុត្តបេមសា ។
តតោ តេសំ អទំ យាតុំ បសន្នា សេហិ បាណិភិ
តតោ ចុតាហំ តិទសំ នន្ទនំ ឧបបជ្ជហំ ។

---

១ ឱ. សុតវីរេហិ ។ ម. សុតវិនាភិ ។

## ឧប្បលវណ្ណាថេរិយាបទាន ទី ៤

កាលណា ព្រះរាជបុត្រទាំងនោះ ដល់នូវវ័យចំរើនឡើង កំពុងលេងល្បែងក្នុងទឹក បានឃើញស៊ឹកទិនផ្កាឈូកសំយុងចុះ (មានចិត្តនឿយណាយក្នុងសង្ខារ ក៏ចេញបួស) បានជាព្រះបច្ចេកពុទ្ធ ជានាយក ក្នុងកាលនោះ ៗ ខ្ញុំនោះជាអ្នកព្រាត់ប្រាសចាករាជបុត្រដ៏ប្រសើរទាំងនោះ ក៏មានសេចក្តីសោកស្តាយ លុះច្យុត (ចាកអត្តភាពនោះហើយ) បានមកកើតក្នុងស្រុកតូចមួយ ទៀបភ្នំឥសិគិលិ ៗ កាលណាខ្ញុំមានចិត្តភ្នកទឹកដល់កូន ដែលជាព្រះបច្ចេកពុទ្ធ ក៏នាំយកបបរដើរទៅដើម្បីកូនទាំងឡាយផង ដើម្បីខ្លួនផង ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធជានាយក ៨ ព្រះអង្គ ដែលកំពុងដើរទៅកាន់ស្រុក ដើម្បីភិក្ខា ក៏នឹករលឹកកូនទាំងឡាយ កាលនោះ ទរនៃទឹកដោះរបស់ខ្ញុំក៏ខ្ពរចេញ ព្រោះសេចក្តីស្រឡាញ់ចំពោះកូន ៗ លំដាប់នោះ ខ្ញុំជ្រះថ្លាបានប្រគេនបបរដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដោយដៃរបស់ខ្លួន លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកើតឯឧទ្យាន ឈ្មោះនន្ទនៈ ក្នុងឋានត្រៃត្រឹង្ស ៗ

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

អនុភោត្វា សុខទុក្ខំ សំសរិត្វា ភវាភវេ
តវត្ថាយ មហាវីរ បរិច្ចត្តញ្ច ជីវិតំ ។
ឃរំ ពហុវិធំ ទុក្ខំ សម្បត្តិ ច ពហុវិធា(១)
បច្ឆិមេ ភវសម្បត្តេ ជាតា សាវត្ថិយំ បុរេ ។
មហាធនេ សេដ្ឋិកុលេ សុខិតេ សជ្ឈិតេ តថា
នានារតនបជ្ជោតេ សព្វកាមសមិទ្ធនេ ។
សក្កតបូជិតា ចេវ មានិតាបចិតា តថា
រូបសិរី អនុប្បត្តា កុលេសុ អតិសក្កតា ។
អតីវ បត្ថិតា ចាសឹ រូបភោគសិរីហិ ច
បត្ថិតា សេដ្ឋិបុត្តេហិ អនេកេហិ សតេហិ ច ។
អគារំ បជហិត្វាន បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ ចតុសច្ចំ អបាបុណឹ ។
ឥទ្ធិយា អភិនិម្មិត្វា ចតុរស្សំ រថំ អហំ
ពុទ្ធស្ស បាទេ អវន្ទឹ(២) លោកនាថសិរីមតោ(៣) ។

---

១ ម. សម្បត្តិញ្ច ពហុវិធំ ។ ២ ឱ. វន្ទិស្សំ ។ ៣ ម. លោកនាថស្ស តាទិនោ។

បពិត្រព្រះអង្គ ជាមហាវីរបុរស ខ្ញុំម្ចាស់បានទទួលសុខទុក្ខ អន្ទោលទៅក្នុងភពតូចភពធំ ទាំងជីវិតក៏ខ្ញុំលះបង់ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ សេចក្តីទុក្ខផ្សេង ៗ ជាច្រើនយ៉ាងក្តី សម្បត្តិផ្សេង ៗ ជាច្រើនក្តី (របស់ខ្ញុំ) រមែងមានយ៉ាងនេះឯង លុះដល់បច្ឆិមភព ខ្ញុំមកកើតក្នុងសាវត្ថីបុរី ។ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋីមានទ្រព្យច្រើន ដល់នូវសេចក្តីសុខ ជាត្រកូលបាត់បែងល្អហើយ រុងរឿងដោយរតនវត្ថុផ្សេង ៗ សម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ។ ខ្ញុំត្រូវគេធ្វើសក្ការបូជាផង រាប់អានកោតក្រែងដូច្នោះផង ដល់នូវរូបសិរី ត្រូវគេធ្វើសក្ការៈក្រៃលែងក្នុងត្រកូលទាំងឡាយ ។ ខ្ញុំជាស្ត្រីដែលពួកជនអ្នកមានសិរីដោយរូបនិងភោគៈប្រាថ្នាលើសលុបផង ដែលពួកកូនសេដ្ឋីជាច្រើនរយនាក់ប្រាថ្នាហើយផង ។ ខ្ញុំលះបង់នូវផ្ទះហើយចូលទៅកាន់ផ្នួស កាលមិនទាន់ដល់កន្លះខែនៅឡើយ ក៏បានលុះនូវសច្ចៈ ៤ ។ ខ្ញុំនិម្មិតនូវរថមានជ្រុង ៤ ដោយឫទ្ធិ ហើយថ្វាយបង្គំ នូវព្រះបាទនៃព្រះពុទ្ធ ព្រះអង្គជាទីពឹងដ៏មានសិរី របស់សត្វលោក ។

## នវមំ ឧប្បលវណ្ណាថេរិយាបទានំ

សុបុប្ផិតគ្គំ ឧបគម្ម បាទបំ(១)
ឯកា តុវំ តិដ្ឋសិ សាលមូលេ
ន ចាបិ តុយ្ហំ ទុតិយត្ថិ កោចិ(២)
ពាលេ ន ត្វំ ភាយសិ ធុត្តកានំ ។
សតំ សហស្សានិបិ ធុត្តកានំ(៣)
ឥធាគតា ឯទិសកា(៤) ភវេយ្យុំ
លោមំ ន ឥញ្ជេ នបិ សម្បវេធេ(៥)
កឹ មេ តុវំ មារ ករិស្សសេកោ(៦) ។

ឯសា អន្តរធាយាមិ   កុច្ឆឹ វា បវិសាមិ តេ
ភមុកន្តរិកាយម្បិ   តិដ្ឋន្តឹ មំ ន ទក្ខសិ ។
ចិត្តម្ហិ វសិភូតាហំ(៧)   ឥទ្ធិបាទា សុភាវិតា
សព្វពន្ធនមុត្តាម្ហិ   ន តំ ភាយាមិ អាវុសោ ។

---

១ ឱ. ម. ភិក្ខុនី ។ ២ ឱ. ម. ន បត្ថិ តេ ទុតិយោ វណ្ណធាតុ ។ ៣ ឱ. សតំ សហស្សានម្បិ ធុត្តកានំ ។ ម. សតំ សហស្សានិបិ ធុត្តកានិ ។ ៤ ម. ឥទិសកា ។ ៥ ឱ. ម. លោមំ ន ឥញ្ជាមិ ន សន្តសាមិ ។ ៦ ឱ. មារំ ន ភាយាមិ តំ ឯកសី ។ ម. ន មារំ ភាយាមិ តមេកិកាបិ ។ ៧ ឱ. ចិត្តស្មឹ វសិភូតស្មឹ ។ ម. ចិត្តស្មឹ វសិភូតាម្ហិ ។

## ឧប្បលវណ្ណាថេរិយាបទាន ទី ៨

(មារពោលថា) នាងអាស្រ័យនូវដើមឈើដែល មានចុងរីកផ្កាស្គុះស្គាយ ឋិតនៅទៀបគល់រាំងតែម្នាក់ឯង ទាំងអ្នកណាមួយ ជាគំរប់ពីរនឹងនាង ក៏មិនមាន តើនាងមិនខ្លាចពួកជនពាល ឬពួកអ្នកលេងទេឬ ។

(ខ្ញុំឆ្លើយថា) ពួកជនអ្នកលេង ចំនួនមួយរយក្តី មួយពាន់ក្តី ដែលប្រាកដដូច្នោះ មកក្នុងទីនេះ យើងក៏ឥតព្រឺរោម ឥតញាប់ញ័រ ម្នាលមារ អ្នកជាបុគ្គលម្នាក់ឯង តើនឹងធ្វើម្តេចដល់យើង ។

យើងនុ៎ះ អាចបំបាត់ខ្លួនក៏បាន ចូលទៅក្នុងពោះអ្នកឯងក៏បាន កាលយើងឋិតនៅត្រង់ប្រជុំចិញ្ចើម ក៏អ្នកមើលមិនឃើញ ។ យើងជាស្រីស្ទាត់ក្នុងផ្លូវចិត្ត ទាំងឥទ្ធិបាទទាំងឡាយ យើងក៏បានចម្រើនល្អហើយ យើងជាស្រីរួចចាកបំណាងទាំងអស់ហើយ នែអាវុសោ យើងមិនខ្លាចអ្នកទេ ។

សត្តិសូលូបមា កាមា ខន្ធាបិ(១) អធិកុដ្ដកា(២)
យត្ថ(៣) កាមរតឹ ព្រូសិ អរតិ ទានិ សា មម ។
សព្វត្ថ វិហតា នន្ទិ តមោក្ខន្ធោ បទាលិតា
ឯវំ ជានាហិ បាបិម និហតោ ត្វមសិ អន្តក ។
ជិនោ តស្មឹ(៤) គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
សេដ្ឋា(៥) ឥទ្ធិមតីនន្តិ បរិសាសុ វិនាយកោ ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។

---

១ ម. ខន្ធាសំ ។ ២ ឱ. ម. អធិកុដ្ដនា ។ ៣ ឱ. ម. យំ ត្វំ ។ ៤ ឱ. ម. តស្មិំ ។ ៥ ម. អគ្គា ។

អ្នកពោលនូវសេចក្ដីត្រេកអរក្នុងកាម ចំពោះគំនរកាមណា គំនរកាមនោះ ឧបមាដូចមុខលំពែង ដ៏មុតក្រៃលែង ឥឡូវនេះ យើងមិនមានសេចក្ដីត្រេកអរ ក្នុងកាមនោះទៀតទេ ។ សេចក្ដីរីករាយ ក្នុងអារម្មណ៍ទាំងអស់ យើងបានកំចាត់បង់ហើយ ទាំងគំនរនៃសេចក្ដីងងឹត យើងក៏ទំលាយចេញហើយ ម្នាលមារមានចិត្តបាប អ្នកចូរដឹងយ៉ាងនេះចុះ ខ្លួនអ្នកត្រូវយើងកំចាត់បានហើយ ។ ព្រះជិនស្រីជានាយក ត្រេកអរចំពោះគុណនោះ តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ក្នុងបរិស័ទទាំង-ឡាយថា នាងឧប្បលវណ្ណា ជាស្រីប្រសើរបំផុតជាងភិក្ខុនីដែលមានឫទ្ធិទាំងឡាយ ។ ព្រះសាស្ដាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនរបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំក៏ទំលាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ ដល់គុណវិសេសណា ប្រយោជន៍ គឺគុណវិសេសនោះឯង ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងអស់ ខ្ញុំបានក៏ដល់ជាលំដាប់ហើយ ។

### នវមំ ឧប្បលវណ្ណាថេរិយាបទានំ

ចីវរំ បិណ្ឌបាតញ្ច   បច្ចយំ សយនាសនំ
ខណេន ឧបនាមេន្តិ   សហស្សានិ សមន្តតោ ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧប្បលវណ្ណា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ឧប្បលវណ្ណាថេរិយាបទានំ សមត្តំ ។

## ឧប្បលវណ្ណាថេរិយាបទាន ទី [illegible]

ចំនួនពាន់នៃពួកជនដោយជុំវិញ រមែងបង្អោនមកនូវបច្ច័យ គឺចីវរ បិណ្ឌបាត សេនាសនៈ ដោយកាលក្ដាម ៗ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ! ខ្ញុំមកល្អហើយក្នុងសំណាក់ព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧប្បលវណ្ណាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧប្បលវណ្ណាថេរិយាបទាន ។

# ទសមំ បដាចារាថេរិយាបទានំ

(២០) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
តទាហំ ហំសវតិយំ ជាតា សេដ្ឋិកុលេ អហុ
នានារតនបជ្ជោតេ មហាសុខសមប្បិតា ។
ឧបេត្វា តំ មហាវីរំ អស្សោសឹ ធម្មទេសនំ
តតោ ជាតប្បសាទាហំ ឧបេសឹ សរណំ ជិនំ ។
តតោ វិនយធារីនំ អគ្គំ វណ្ណេសិ នាយកោ
ភិក្ខុនឹ លជ្ជិនឹ តាទឹ កប្បាកប្បវិសារទំ ។
តទា មុទិតចិត្តាហំ តំ ឋានំ អភិកង្ខយឹ
និមន្តេត្វា ទសពលំ សសង្ឃំ លោកនាយកំ ។
ភោជយិត្វាន សត្តាហំ ទទិត្វា បត្តចីវរំ(១)
និបច្ច សិរសា បាទេ ឥទំ វចនមព្រវឹ ។

១ ឱ. ទទិត្វា ប តិចីវរំ ។ ម. ទទិត្វាវ តិចីវរំ ។

# បដាចារាថេរិយាបទាន ទី ១០

(២០) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ ក្នុងគ្រានោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងនគរហង្សវតី រុងរឿងដោយរតនៈផ្សេង ៗ ជាស្រីឆ្អែតស្កប់ស្កល់ដោយសេចក្តីសុខច្រើនយ៉ាង ។ ខ្ញុំបានចូលទៅគាល់ព្រះអង្គ ជាមហាវីរបុរសនោះ បានស្តាប់ធម្មទេសនា លំដាប់នោះ ខ្ញុំកើតសេចក្តីជ្រះថ្លា ហើយដល់នូវព្រះជិនស្រីជាទីពឹង ។ លំដាប់នោះ ព្រះពុទ្ធជានាយក ទ្រង់សរសើរភិក្ខុនីជាអ្នកអៀនខ្មាស មានចិត្តនឹងធឹង ក្លៀវក្លាក្នុងហេតុគួរនិងមិនគួរ ជាភិក្ខុនីខ្ពង់ខ្ពស់ជាងភិក្ខុនីទាំងឡាយ អ្នកទ្រទ្រង់នូវវិន័យ ។ ក្នុងកាលនោះ ខ្ញុំមានចិត្តរីករាយ ប៉ុនប៉ង់ចំពោះតំណែងនោះ ហើយនិមន្តព្រះទសពល ជាលោកនាយក ព្រមទាំងព្រះសង្ឃ ឲ្យឆាន់អស់ ៧ ថ្ងៃ ហើយបានថ្វាយបាត្រនិងចីវរ ក្រាបទៀបព្រះបាទាដោយត្បូង ហើយពោលពាក្យនេះថា

## ទសមំ បដាចារាថេរិយាបទានំ

យា តយា វណ្ណិតា វីរ  ឥតោ អដ្ឋមកេ មុនិ(១)
តាទិសាហំ ភវិស្សាមិ  យទិ សិជ្ឈតិ នាយក ។
តទា អវោច មំ សត្ថា  ភទ្ទេ មា ភាយិ អស្សស
អនាគតម្ហិ អទ្ធានេ  លទ្ធសេតំ មនោរថំ ។
សតសហស្សេ ឥតោ កប្បេ  ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន  សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា  ឱរសា ធម្មនិម្មិតា
បដាចារាតិ នាមេន  ហេស្សតិ សត្ថុសាវិកា ។
តទាហំ មុទិតា ហុត្វា  យាវជីវំ តទា ជិនំ
មេត្តចិត្តា បរិចរឹ  សសង្ឃំ លោកនាយកំ ។
តេន កម្មេន សុកតេន  ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ  តាវតឹសំ អគច្ឆហំ ។

---

១ ឱ. មុនេ ។

បពិត្រព្រះមុនីជាធីរបុរស ភិក្ខុនីណា ដែលព្រះអង្គសរសើរហើយ បពិត្រព្រះអង្គជានាយក ខ្ញុំម្ចាស់សូមឲ្យបានដូចភិក្ខុនីនោះ ក្នុងកប្បទី ៨ អំពីកប្បនេះ បើសេចក្តីប្រាថ្នា នឹងសម្រេច ។ ក្នុងកាលនោះ ព្រះសាស្តាបានត្រាស់នឹងខ្ញុំថា ម្នាលនាងដ៏ចម្រើន នាងកុំខ្លាច ចូរនាងត្រេកអរចុះ ក្នុងកាលអនាគត នាងនឹងបានតំណែងនុ៎ះដូចចិត្តប្រាថ្នា ។ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រឱក្កាកៈ នឹងមានក្នុងលោក ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ នាងនឹងបានជាផៅពង្សក្នុងធម៌ទាំងឡាយ នៃព្រះសាស្តាអង្គនោះ ជាឱរសជាធម្មនិម្មិត មានឈ្មោះថានាងបដាចារា ជាសាវិការបស់ព្រះសាស្តា ។ ក្នុងគ្រានោះ ខ្ញុំមានចិត្តរីករាយ មានមេត្តាចិត្តបម្រើព្រះជិនស្រី ជាលោកនាយក ព្រមទាំងព្រះសង្ឃ ដរាបអស់ជីវិត ។ ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។

ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។
តស្សាសឹ តតិយា ធីតា ភិក្ខុនី ឥតិ វិស្សុតា
ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។
អនុជានិ ន នោ តាតោ អគារេវ តទា មយំ
វីសំ វស្សសហស្សានិ វិចរិម្ហ អតន្ទិតា[១] ។
កោមារិព្រហ្មចរិយំ រាជកញ្ញា សុខេដ្ឋិតា
ពុទ្ធោបដ្ឋាននិរតា មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច ភិក្ខុនី ភិក្ខុទាសិកា[២]
ធម្មា ចេវ សុធម្មា ច សត្តមី សង្ឃទាសិកា[៣] ។
អហំ ឧប្បលវណ្ណា ច ខេមា ភទ្ទា ច ភិក្ខុនី
កិសាគោតមី ធម្មទិន្នា វិសាខា ហោតិ សត្តមី ។

---

១ ម. អតន្ទិកា ។ ២ ឱ. ភិក្ខទាយិកា ។ ម. ភិក្ខុទាយិកា ។ ៣ ឱ. ម. សង្ឃទាយិកា ។

ព្រះពុទ្ធព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងពួកជនអ្នកពោល ទ្រង់កើតឡើងក្នុងកប្បនេះ ។ ក្នុងកាលនោះ ព្រះរាជាក្នុងដែនកាសីព្រះនាមកិកី ជាឧបដ្ឋាករបស់ព្រះពុទ្ធជាមហេសី ជាឥស្សរៈលើប្រជាជនក្នុងក្រុងពារាណសីបុរីដ៏ឧត្តម ។ ខ្ញុំបានជាធីតាទី ៣ នៃព្រះបាទកិកីនោះ ដែលប្រាកដជាភិក្ខុនី បានស្តាប់ធម៌របស់ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងបព្វជ្ជា ។ តែក្នុងកាលនោះ ព្រះបិតារបស់យើងទ្រង់ពុំអនុញ្ញាត យើងក៏ជាស្ត្រីមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយៈសម្រាប់កុមារីអស់ ២០ ពាន់ឆ្នាំ នៅក្នុងផ្ទះ ជាព្រះរាជកញ្ញាឋិតនៅក្នុងសេចក្តីសុខ ត្រេកអររីករាយក្នុងការបម្រើព្រះពុទ្ធ ជាធីតា ៧ អង្គ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគំរប់ប្រាំពីរ ។ (រាជកញ្ញាទាំងនោះ លុះបេរិលវឹងមក ក្នុងពុទ្ធុប្បាទនេះ) បានមកជា ខ្ញុំ ១ ឧប្បលវណ្ណា ១ ខេមា ១ ភទ្ទាភិក្ខុនី ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគំរប់ប្រាំពីរ ។

## ទសមំ បដាចារាថេរិយាបទានំ

តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគញ្ឆហំ(១) ។
បច្ឆិមេ ច ភវេ ទានិ ជាតា សេដ្ឋិកុលេ អហំ
សាវត្ថិយំ បុរវរេ ឥទ្ធេ ផីតេ មហទ្ធនេ ។
យទា ច យោព្វនុបេតា វិតក្កវសគា អហំ ។
នរញ្ញានបតិំ(២) ទិស្វា តេន សទ្ធឹ អគញ្ឆហំ ។
ឯកបុត្តប្បសុតាហំ ទុតិយោ កុច្ឆិយា មម
តទាហំ មាតាបិតរោ ឱក្កាមីតិ(៣) សុនិច្ឆិតា ។
នារោចេសឹ បតឹ មយ្ហំ តទា តម្ហិ បវាសិតេ
ឯកិកា និគ្គតា គេហា គន្តុំ សាវត្ថិមុត្តមំ ។
តតោ មេ សាមិ អាគន្ត្វា សម្ភាវេសិ បថេ មមំ
តទា មេ កម្មជា វាតា ឧប្បន្នា អតិទារុណា ។

---

១ ឱ. អគម្ហ ស្រេ ។ ម. អគញ្ឆហំ ។ ២ ម. នរំ ជារបតឹ ។ ៣ ឱ. ឱក្កាមីតិ ។ ម. ឧក្កាមីតិ ។

បដាចារាថេរិយាបទាន ទី ១០

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយ ជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តឹង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរមាំមួនស្ដុកស្ដម្ភ មានធនធានច្រើន ។ ខ្ញុំកំពុងប្រកបដោយវ័យដ៏ចម្រើន លុះក្នុងអំណាចនៃវិតក្កៈ ខ្ញុំបានឃើញនូវបុរសអ្នកនៅក្នុងជនបទហើយ ក៏បានទៅនៅជាមួយនឹងបុរសនោះ ។ ខ្ញុំមានបុត្រប្រុស ១ នាក់ ប្រសូតហើយ បុត្រទី ២ នៅក្នុងផ្ទៃរបស់ខ្ញុំ ក្នុងកាលនោះ ខ្ញុំកាត់ចិត្តថា អញត្រូវទៅរកជួបមាតាបិតាវិញ ។ គ្រានោះ ខ្ញុំមិនបានប្រាប់ស្វាមីរបស់ខ្ញុំទេ លុះស្វាមីនោះឃ្លាតចេញទៅ ខ្ញុំជាស្ត្រីតែម្នាក់ឯងរត់ចេញចាកផ្ទះ ដើរទៅកាន់ក្រុងសាវត្ថីដ៏ឧត្តម ។ លំដាប់នោះ ប្ដីរបស់ខ្ញុំមកតាមទាន់ក្នុងផ្លូវ បបួលខ្ញុំទៅវិញ ក្នុងគ្រានោះ ខ្យល់កម្មជវាត ( ខ្យល់កើតអំពីកម្ម ) ដ៏អាក្រក់ពន់ពេក កើតឡើងដល់ខ្ញុំ ។

ឧទិតោ(១) មហាមេឃោ   បសូតិសមយេ មម

ឧដ្ឋាយ តទា គន្ត្វា   សាមិំ សប្បេន មារិតោ។

តទា វិជាតទុក្ខេន   អនាថា កបណា អហំ

កុន្នទឹ បូរិតំ ទិស្វា   គច្ឆន្តី សកុលាលយំ។

ពាលំ អាទាយ ឱតរឹ(២)   បារកូលេ ច ឯកិកា

បាយេត្វា(៣) ពាលកំ បុត្តំ   ឥតរំ តារណាយហំ(៤)។

និវត្តា ឧក្កុសោ ហាសិ   តរុណំ វិលបន្តកំ

ឥតរញ្ច វហិ សោតោ   សាហំ សោកសមប្បិតា។

សាវត្ថិនគរំ គន្ត្វា   អស្សោសឹ សជនេ មតេ

តទា អវោច សោកដ្ដា   មហាសោកសមប្បិតា។

ឧភោ បុត្តា កាលកតា   បថេ(៥) មយ្ហំ បតិ មតោ

មាតា បិតា ច ភាតា ច   ឯកចិត្តម្ហិ ឌយ្ហរេ។

---

១ ម. ឧដ្ឋិតោ។ ២ ឱ.ម. អតរឹ។ ៣ ម. ឋបេត្វា។ ៤ ម. តរណាយហំ។ ៥ ឱ.ម បន្ថេ។

ស្រាប់តែភ្លៀងធំតាំងឡើង ក្នុងសម័យជាទីប្រសូតិ នូវកូននៃខ្ញុំ គ្រានោះ ប្តី (របស់ខ្ញុំ) ទៅដើម្បីប្រយោជន៍ដល់ឧស ត្រូវពស់ចឹកស្លាប់ទៅ ។ គ្រានោះ ខ្ញុំជាស្រីកំព្រាមិនមានទីពឹង ដោយសេចក្តីទុក្ខ ព្រោះសម្រាលកូន ខ្ញុំដើរទៅកាន់លំនៅនៃត្រកូលរបស់ខ្លួន ឃើញនូវស្ទឹងតូច មានទឹកពេញព្រៀប ។ ខ្ញុំជាស្រីម្នាក់ឯង នាំយកកូនតូច ឆ្លងទៅដាក់ឯច្រាំងត្រើយនាយ ហើយញុំាងកូនតូចឲ្យបៅ វិលត្រឡប់មកចម្លងកូនបង ។ មានសត្វខ្លែងមួយឆាបយកកូនតូចដែលកំពុងយំ ទាំងខ្សែទឹកក៏កួចយកកូនបងទៅទៀត ខ្ញុំជាស្រីចុកណែនដោយសេចក្តីសោក ។ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី បានឮថាពួកជនរបស់ខ្លួន គឺមាតា-បិតាត្រូវស្លាប់អស់ហើយ គ្រានោះ ខ្ញុំមានសេចក្តីសោកគ្របសង្កត់ ចុកណែនដោយសេចក្តីសោកដ៏ធំ ហើយបានពោលថា កូនទាំងពីរធ្វើមរណកាលហើយ ទាំងប្តីរបស់ខ្ញុំក៏ស្លាប់ក្នុងព្រៃ មាតាបិតានិងបងប្រុស ក៏ត្រូវគេដុតលើជើងថ្ករជាមួយគ្នា ។

## ទសមំ បដាចារាថេរិយាបទានំ

តទា កិសា ច បណ្ឌូ ច អនាថា ទិនមានសា
ឥតោ តតោ គច្ឆន្តីហំ(១) អទ្ទសំ នរសារថឹ ។
តតោ ឧបេច្ច មំ សត្ថា បុត្តិ មា សោចិ អស្សស
អត្តានំ តេ គវេសស្សុ កឹ និរត្ថំ វិហញ្ញសិ ។
ន សន្តិ បុត្តា តាណាយ ន ញាតិ នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។
តំ សុត្វា មុនិនោ វាក្យំ បឋមំ ផលមជ្ឈគំ
បព្វជិត្វាន ន ចិរំ អរហត្តំ អបាបុណឹ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
បរចិត្តានិ ជានាមិ សត្ថុ សាសនការិកា ។

១ ឱ. ភមន្តីហំ ។ ម. គមេន្តីហំ ។

## បដាចារិយាបទាន ទី ១០

កាលនោះ ខ្ញុំជាស្រីស្គាំងស្គមផង កើតរោគលឿងផង ឥតមានទីពឹង មានចិត្តប្រកបដោយសេចក្ដីទុក្ខ លំដាប់នោះ ខ្ញុំដើរចេញទៅអំពីទីនេះ បានឃើញព្រះពុទ្ធ ព្រះអង្គជាសារថីរបស់ប្រជាជន ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ត្រាស់ចំពោះខ្ញុំថា នាងចូរកុំសោកស្ដាយចំពោះកូនទាំងឡាយឡើយ ចូរនាងស្រស់ស្រាយឡើង ចូរនាងស្វែងរកខ្លួនរបស់នាងវិញ នាងព្រួយឥតប្រយោជន៍សោះទេ ។ កូនទាំងឡាយពឹងពុំបាន ញាតិក៏ពឹងពុំបាន ទាំងផៅពង្សក៏ពឹងពុំបាន បុគ្គលដែលត្រូវសេចក្ដីស្លាប់គ្របសង្កត់ ទីពឹងចំពោះញាតិពុំបានឡើយ ។ លុះខ្ញុំបានស្ដាប់ព្រះវាចានោះរបស់ព្រះមុនី ក៏បាននូវផលទី ១ ខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានសម្រេចនូវព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនានៃព្រះសាស្ដា រមែងដឹងនូវចិត្តនៃបុគ្គលដទៃផង ។

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
ខេបេត្វា អាសវេ សព្វេ វិសុទ្ធាសី សុនិម្មលា ។
តតោហំ វិនយំ សព្វំ សន្តិកេ សព្វទស្សិនោ
ឧគ្គហឹ សព្វវិត្ថារំ ព្យាហរឹ ច យថាតថំ ។
ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
អគ្គំ វិនយធារីនំ បជាធាភវ ឯកិកា ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុ ខ្ញុំបានជម្រះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធឥតមានមន្ទិល ព្រោះបានញ៉ាំងអាសវៈទាំងពួងឲ្យអស់ហើយ ។ លំដាប់នោះ ខ្ញុំបានរៀនវិន័យទាំងអស់ក្នុងសំណាក់ របស់ព្រះពុទ្ធ ព្រះអង្គឃើញហេតុទាំងអស់ផង ខ្ញុំឆ្លើយដោះស្រាយ នូវសេចក្តីពិស្តារគ្រប់យ៉ាងតាមពិតផង ។ ព្រះជិនស្រីត្រេកអរ ចំពោះគុណនោះ ហើយតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា នាងបដាចារា ជាភិក្ខុនីឯក ប្រសើរជាងពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យ ។ ព្រះសាស្តា ខ្ញុំបានប្រព្រឹត្តតាមហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចេញហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានគាស់រំលើងចេញហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍ គឺគុណធម៌នោះរបស់ខ្ញុំ ជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ខ្ញុំក៏បានសម្រេចហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។

### ឧទ្ទានំ

ស្វាគតំ វត មេ អាសិ  ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា  កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ  វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា  កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បដាចារា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

បដាចារាថេរិយាបទានំ សមត្តំ ។

### ឧទ្ទានំ

ឯកូបោសថិកា ចេវ  សលឡា ចាថ មោទកា(១)
ឯកាសនា បញ្ចទីបា(២)  នឡមាលី ច គោតមី ។
ខេមា ឧប្បលវណ្ណា ច  បដាចារា ច ភិក្ខុនី
គាថាសតានិ បញ្ចេវ  នវ ចាបិ តទុត្តរិ(៣) ។

ឯកូបោសថវគ្គោ ទុតិយោ ។

---

១ ឱ. ម. សលទ្ទា ប តិមោទកា ។ ម. សឡ្ឡា ប តិមោទកី ។ ២ ឱ. ម. ឯកាសនបទា ទីបា ។ ៣ ឱ. ចត្តារិ នវុតិ សត្តមេវច ។

ឧទ្ទាន

ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបដាចារាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បដាចារាថេរិយាបទាន ។

## ឧទ្ទាន

ឯកុបោសថិកាថេរិយាបទាន ១ សឡលបុប្ផិកាថេរិយាបទាន ១ មោទកទាយិកាថេរិយាបទាន ១ ឯកាសនទាយិកាថេរិយាបទាន ១ បញ្ចទីបទាយិកាថេរិយាបទាន ១ នឡមាលិកាថេរិយាបទាន ១ បជាបតិគោតមីថេរិយាបទាន ១ ខេមាថេរិយាបទាន ១ ឧប្បលវណ្ណាថេរិយាបទាន ១ បដាចារាថេរិយាបទាន ១ មានគាថា ៥០៩ គាថា ។

ចប់ ឯកុបោសថវគ្គ ទី ២ ។

## តតិយោ កុណ្ឌលកេសិវគ្គោ

### បឋមំ កុណ្ឌលកេសីថេរិយាបទានំ

(២១) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ

ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។

តទាហំ ហំសវតិយំ ជាតា សេដ្ឋិកុលេ អហុ(១)

នានារតនបជ្ជោតេ មហាសុខសមប្បិតា ។

ឧបេត្វា តំ មហាវីរំ អស្សោសឹ ធម្មុត្តមំ(២)

តតោ ជាតប្បសាទាហំ ឧបេសឹ សរណំ ជិនំ ។

តទា មហាការុណិកោ បទុមុត្តរនាយកោ

ខិប្បាភិញ្ញានមគ្គន្តិ(៣) ឋបយិ(៤) ភិក្ខុនឹ សុភំ ។

តំ សុត្វា មុទិតា ហុត្វា ទានំ ទត្វា មហេសិនោ

និបច្ច សិរសា បាទេ តំ ឋានំ អភិបត្ថយឹ ។

---

១ ឱ. ម. អហុំ ។ ២ ឱ. ម. ធម្មទេសនំ ។ ៣ ឱ. ខិប្បាភិញ្ញានមគ្គន្តេ ។ ៤ ឱ. ឋបេសិ ។ ម. ថបេសិ ។

# កុណ្ឌលកេសវគ្គ ទី ៣

## កុណ្ឌលកេសីថេរិយាបទាន ទី ១

(២១) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ព្រះអង្គដល់នូវត្រើយនៃធម៌ទាំងពួង ជានាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋី ក្នុងក្រុងហង្សវតី ជាត្រកូលរុងរឿងដោយរតនវត្ថុផ្សេង ៗ ខ្ញុំជាស្រីស្កប់ស្កល់ដោយសេចក្ដីសុខច្រើនប្រការ ។ ខ្ញុំចូលទៅរកព្រះពុទ្ធជាមហាវីរបុរសអង្គនោះ ហើយបានស្ដាប់ធម៌ដ៏ឧត្ដម លំដាប់នោះ ខ្ញុំមានសេចក្ដីជ្រះថ្លាកើតឡើងហើយ បានដល់ព្រះជិនស្រីជាទីពឹង ។ ក្នុងកាលនោះឯង ព្រះពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ប្រកបដោយមហាករុណា ទ្រង់តាំងសុភាភិក្ខុនី ថាជាភិក្ខុនីប្រសើរជាងពួកភិក្ខុនី ដែលត្រាស់ដឹងឆាប់រហ័ស ។ លុះខ្ញុំបានស្ដាប់ព្រះពុទ្ធវាចានោះហើយ ខ្ញុំមានសេចក្ដីរីករាយ បានថ្វាយទានដល់ព្រះពុទ្ធជាមហេសី ហើយក្រាបចុះទៀបព្រះបាទាដោយត្បូង ប្រាថ្នានូវតំណែងនោះ ។

## បឋមំ កុណ្ឌលកេសីថេរិយាបទានំ

អនុមោទិ មហាវីរោ　　ភទ្ទេ យន្តេភិបត្ថិតំ
សមិជ្ឈិស្សតិ តំ សព្វំ　　សុខិនី ហោហិ និព្វុតា ។
សតសហស្សិតោ កប្បេ　　ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន　　សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា　　ឱរសា ធម្មនិម្មិតា
ភទ្ទា កុណ្ឌលកេសាតិ　　ហេស្សតិ សត្ថុសាវិកា ។
តេន កម្មេន សុកតេន　　ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ　　តាវតឹសំ អគច្ឆហំ ។
តតោ ចុតា យាមមគំ　　តតោហំ តុសិតំ គតា
តតោ ច និម្មានរតឹ　　វសវត្តិបុរំ គតា ។

## កុណ្ឌលកេសីថេរីអបទាន ទី ១

ព្រះពុទ្ធជាមហាវីរបុរស ទ្រង់អនុមោទនាថា ម្នាលនាងដ៏ចម្រើន តំណែងណា ដែលនាងប្រាថ្នាហើយ តំណែងទាំងអស់នោះ នឹងសម្រេចពុំខាន ចូរនាងបានសេចក្តីសុខ រំលត់ទុក្ខចុះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម ទ្រង់សម្ភពក្នុងត្រកូលក្សត្រ ឈ្មោះឱក្កាកៈ នឹងកើតឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌របស់ព្រះសាស្តាអង្គនោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តា ឈ្មោះនាងកុណ្ឌលកេសីដ៏ចម្រើន ។

ដោយអំពើដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ ទៅកើតក្នុងឋានយាមៈ ច្យុតចាកឋានយាមៈនោះ បានទៅកើតក្នុងឋានតុសិត ច្យុតចាកឋានតុសិតនោះ ក៏បានទៅកើតក្នុងឋាននិម្មានរតី រួចទៅកើតក្នុងបរនិម្មិតវសវត្តីបុរី ។

យត្ថ យត្ថូបបជ្ជាមិ    តស្ស កម្មស្ស វាហសា
តត្ថ តត្ថេវ ភវនំ    មហេសិត្តមការយឹ ។
តតោ ចុតា មនុស្សេសុ    ភវនំ ចក្កវត្តិនំ
មណ្ឌលីនញ្ច ភវនំ    មហេសិត្តមការយឹ ។
សម្បត្តឹ អនុភោត្វាន    ទេវេសុ មានុសេសុ ច
សព្វត្ថ សុខិតា ហុត្វា    នេកកប្បេសុ សំសរឹ ។
ឥមម្ហិ ភទ្ទកេ កប្បេ    ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន    ឧប្បជ្ជិ វទតំ វរោ ។
ឧបដ្ឋាកោ មហេសិស្ស    តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម    ពារាណសិបុរុត្តមេ ។
តស្ស ធីតា ចតុត្ថាសឹ    ភិក្ខុទាសីតិ[១] វិស្សុតា
ធម្មំ សុត្វា ជិនគ្គស្ស    បព្វជ្ជំ សមរោចយឹ ។

---

១ ឱ. ភិក្ខទាយីតិ ។ ម. ភិក្ខុទាយីតិ ។

ខ្ញុំកើតក្នុងទីណា ៗ ខ្ញុំបានទូវភាពជាមហេសីរបស់ស្តេចទាំង ឡាយ ក្នុងទីនោះ ៗ ព្រោះអានិសង្សនៃបុញ្ញកម្មនោះឯង ៗ ខ្ញុំច្យុតចាកអត្តភាពនោះ ហើយបានមកកើតក្នុងមនុស្សលោក បានទូវភាពជាមហេសី របស់ស្តេចចក្រពត្តិទាំងឡាយផង របស់ស្តេចក្នុងមណ្ឌលទាំងឡាយផង ៗ ខ្ញុំបានទូវសម្បត្តិ ក្នុងទេវលោកផង ក្នុងមនុស្សលោកផង ហើយជាស្រីដល់ នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅក្នុងកប្បដ៏ច្រើន ៗ ព្រះពុទ្ធព្រះនាមកស្សបៈ ព្រះអង្គមានផៅពង្សដ៏ប្រសើរ មាន យសច្រើន ប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់កើតឡើងក្នុង ភទ្ទកប្បនេះ ៗ គ្រានោះ ព្រះរាជាក្នុងដែនកាសីព្រះនាម កិកី ក្នុងពារាណសីបុរីដ៏ឧត្តម ជាឥស្សរៈលើប្រជាជន បាន ជាឧបដ្ឋាកនៃព្រះពុទ្ធជាមហេសី ៗ ខ្ញុំជាធីតាទី ៤ របស់ព្រះ រាជាអង្គនោះ ដែលប្រាកដជាភិក្ខុទាសី បានស្តាប់ធម៌របស់ ព្រះជិនស្រីដ៏ប្រសើរ ហើយក៏ពេញចិត្តចំពោះបព្វជ្ជា ៗ

## បឋមំ កុណ្ឌលកេសីថេរិយាបទានំ

អនុញាតិ ន នោ តាតោ អគារេវ តទា មយំ
វីសំ វស្សសហស្សានិ វិចរិម្ហ អតន្ទិតា ។
កោមារិព្រហ្មចរិយំ រាជកញ្ញា សុខេធិតា
ពុទ្ធោបដ្ឋាននិរតា មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច ភិក្ខុនី ភិក្ខុទាសិកា(១)
ធម្មា ចេវ សុធម្មា ច សត្តមី សង្ឃទាសិកា(២) ។
ខេមា ឧប្បលវណ្ណា ច បដាចារា អហន្តទា
កិសាគោតមី ធម្មទិន្នា វិសាខា ហោតិ សត្តមី ។
តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ គិរិព្វជបុរុត្តមេ
ជាតា សេដ្ឋិកុលេ ផីតេ យទាហំ យោព្វនេ ឋិតា ។

---

១ ឱ. ភិក្ខុទាយិកា ។ ម. ភិក្ខុទាយិកា ។ ២ ឱ. ម. សង្ឃទាយិកា ។

ព្រះបិតាយើងទ្រង់មិនអនុញ្ញាតឲ្យបួសទេ កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយសម្រាប់កុមារីអស់ពីរម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញាឋិតនៅក្នុងសេចក្ដីសុខ ត្រេកអររីករាយ ក្នុងការបម្រើព្រះពុទ្ធ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ នាងសង្ឃទាសិកា ជាគំរប់ប្រាំពីរ ។ កាលនោះ (ព្រះរាជធីតាទាំង ៧ នាក់នោះបេរវិលវិញមក) បានជានាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ ខ្ញុំ ១ កិសាគោតមី ១ ធម្មទិន្នា ១ វិសាខា ជាគំរប់ប្រាំពីរ ។ ដោយអំពើដែលខ្ញុំបានធ្វើល្អនោះផង ដោយការតម្កល់ទុកនូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយជារបស់មនុស្សហើយ បានទៅកើតក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋីដ៏ស្តុកស្តម្ភក្នុងបុរីដ៏ឧត្តម ឈ្មោះគិរិព្វជៈ បិតានៅក្នុងវ័យដ៏ចម្រើន ។

ចោរំ វធត្ថំ និយន្តំ ទិស្វា រត្តា តហឹ អហំ
បិតា មេ តំ សហស្សេន មោចយិត្វា វធា តតោ ។
អទាសិ តស្ស មំ តាតោ វិទិត្វាន មនំ មម
តស្សាហមាសិ វិស្សដ្ឋា អតិវ ទយិតា ហិតា ។
សោ មេ ភូសនលោភេន ពលឹ បក្ខាហរិំ(១) ទិសោ
ចោរប្បបាតំ នេត្វាន បព្វតេ ចេតយិ វធំ ។
តទាហំ បណមិត្វាន សត្តុកំ សុកតញ្ជលី
រក្ខន្តី អត្តនោ បាណំ ឥទំ វចនមព្រវឹ ។
ឥទំ សុវណ្ណកាយុរំ(២) មុត្តា វេឡុរិយា ពហូ
សព្វំ(៣) ហរស្សុ ភទ្ទន្តេ មញ្ច ទាសីតិ សាវយ ។
ឱរោបយស្សុ កល្យាណ មា ពាឡ្ហំ បរិទេវសិ(៤)
ន តាហំ អភិជានាមិ អហន្ត្វា ធនមាភតំ(៥) ។

---

១ ឱ. មាលបក្ខាហតំ ។ ម. ពលិមជ្ឈាសយោ ។ ២ ឱ ម. សុវណ្ណកេយុរំ ។ ៣ ឱ. សព្វំ ។ ៤ ឱ. មា ពហុំ បរិទេវយិ ។ ៥ ឱ. ម. ធនមាភតំ ។

ខ្ញុំឃើញនូវចោរដែលគេកំពុងបណ្តើរ យកទៅដើម្បីសម្លាប់ ហើយស្រឡាញ់ចំពោះចោរនោះ លំដាប់នោះ បិតារបស់ខ្ញុំ ដោះចោរនោះ ចេញអំពីទោសដែលត្រូវសម្លាប់ ដោយកហាបណៈមួយពាន់ ។ បិតាបានឲ្យខ្ញុំទៅចោរនោះ ព្រោះដឹងច្បាស់នូវចិត្តខ្ញុំ ខ្លួនខ្ញុំជាស្រីឥតវៀស ជាអ្នកអាណិតអនុគ្រោះក្រៃពេក ចំពោះចោរនោះ ។ ឯចោរនោះ នាំមកនូវគ្រឿងបូជា ហើយនាំខ្ញុំទៅកាន់ជ្រោះ សម្រាប់ទំលាក់ចោរ ហើយគិតសម្លាប់ខ្ញុំ លើក្ន ដោយសេចក្តីចង់បាននូវគ្រឿងប្រដាប់របស់ខ្ញុំ ។ គ្រានោះ ខ្ញុំធ្វើអញ្ជលីដ៏ល្អ ប្រណម្យចំពោះចោរ ឈ្មោះសត្តុកៈ រក្សានូវជីវិតរបស់ខ្លួនទុកសិន ហើយពោលពាក្យនេះថា បពិត្រអ្នកដ៏ចម្រើន អ្នកចូរនាំយកនូវសង្វាជាវិការនៃមាស ព្រមទាំងកែវមុក្តា កែវពៃទូរ្យដ៏ច្រើន ទាំងអស់នេះទៅចុះ រួចសូមឲ្យអ្នកប្រាប់គេឲ្យដឹងថា ខ្ញុំជាទាសីចុះ ។ ម្នាលនាងកល្យាណី នាងចូរដាក់នូវគ្រឿងប្រដាប់ មកឲ្យអញចុះ នាងកុំខ្សឹកខ្សួលខ្លាំងឡើយ អញមិនដែលថាមិនសម្លាប់ នូវមនុស្សដែលមកក្នុងព្រៃនោះទេ ។

## បឋមំ កុណ្ឌលកេសីថេរិយាបទានំ

យតោ សរាមិ អត្តានំ យតោ បត្តាស្មិ វិញ្ញុតំ
ន ចាហំ អភិជានាមិ អញ្ញំ បិយតរំ តយា ។
ឯហិ តំ ឧបគុយ្ហិស្សំ(១) កត្វាន តំ បទក្ខិណំ
តំ វន្ទាមិ បុន នត្ថិ(២) មម តុយ្ហញ្ច សង្គមោ ។
ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។
ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ លហុំ អត្ថំ វិចិន្តិតា(៣) ។
លហុញ្ច វត ខិប្បញ្ច នេកដ្ឋេ សមចេតយិ
ចិត្តបណ្ណាយតានេវ(៤) តទាហំ សត្តុកំ វធិ ។

---

១ ឱ. ម. ឧបគូហិស្សំ ។ ២ ឱ. ម. ន បីតនិ បុនោ អត្ថិ ។ ៣ ឱ. ម. អត្ថវិចិន្តិកា ។
៤ ឱ. មិគំ បុណ្ណាយ តេនេវ ។

អញនឹកគេមើលនូវខ្លួនអញ ចាប់តាំងពីអញដល់នូវភាពជាអ្នកដឹងក្តីមក អញមិនដែលស្គាល់អ្នកដទៃឡជាទីស្រឡាញ់ជាងនាងឡើយ ។ អ្នកចូរមកនេះ ខ្ញុំនឹងបានកៀកកើយអ្នកសិន ហើយសូមធ្វើប្រទក្សិណអ្នក ថ្វាយបង្គំអ្នក ព្រោះថាការរួបរួមគ្នារវាងខ្ញុំនឹងអ្នកមិនមានទៀតទេ ។ (ទេវតាពោលថា) ប្រុសមិនមែនឈ្មោះថាបណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះ តែជាអ្នកមានឧបាយវាងវៃ ក្នុងហេតុនោះៗ ក៏ឈ្មោះថាបណ្ឌិតបាន ។ ប្រុសមិនមែនឈ្មោះថាបណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បីស្រីសោះ តែជាអ្នកគិតឃើញនូវប្រយោជន៍រហ័ស ក៏ឈ្មោះថាបណ្ឌិតដែរ ។ បុគ្គលណា ត្រិះរិះឃើញនូវប្រយោជន៍ច្រើនដ៏រហ័សផង ឆាប់ផង ដូចជាបុគ្គលកាលឃើញតាមហេតុនៃសំបុត្រ ឬត្រម្រាដ៏វិចិត្រ បុគ្គលនោះឈ្មោះបណ្ឌិត គ្រានោះ ខ្ញុំបានសម្លាប់នូវចោរឈ្មោះសត្តុកៈ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

យោ ច ឧប្បតិតំ អត្ថំ ន ខិប្បំ អនុពុជ្ឈតិ
សោ ហញ្ញតេ មន្ទមតិ ចោរោវ គិរិគព្ភរេ ។
យោ ច ឧប្បតិតំ អត្ថំ ខិប្បមេវ និពោធតិ
មុច្ចតេ សត្តុសម្ពាធា តទាហំ សត្តុកា យថា ។
តទាហំ បាតយិត្វាន គិរិទុគ្គម្ហិ សត្តុកំ
សន្តិកំ សេតវ្ហានំ ឧបេតា បព្វជឹ អហំ ។
សណ្ឌាសេន ច កោសេ មេ លុញ្ចិត្វា សព្វសោ តទា
បព្វជិត្វាន សមយំ អាចិក្ខឹសុ និរន្តរំ ។
តតោ តំ ឧគ្គហេត្វាន និសីទិត្វា ឯកិកា
សមយំ តំ វិចិន្តេសឹ សុវាណោ មានុសំ ករំ ។
ឆិន្នំ គយ្ហ សមីបេ មេ បាតយិត្វា អបក្កមិ
ទិស្វា និមិត្តំ អលភឹ ហត្ថំ បុឡវាកុលំ ។

បុគ្គលណា មិនយល់ដាច់នូវប្រយោជន៍ ដែលកើតឡើង ហើយ បុគ្គលនោះ ឈ្មោះថាមានគំនិតទន់ រមែងទុក្ខព្រួយ ដូចជាចោរដែលធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ។ បុគ្គលណា យល់ច្បាស់ដាច់ នូវប្រយោជន៍ដែលកើតឡើងហើយ បុគ្គលនោះ រមែងរួចអំពីការបៀតបៀនដោយសត្រូវ ដូចជាខ្ញុំរួចចាកបុរសឈ្មោះសត្តុកៈ ក្នុងកាលនោះឯង ។ ខ្ញុំច្រានបុរសឈ្មោះសត្តុកៈ ទៅក្នុងជ្រោះភ្នំ រួចហើយចូលទៅកាន់សំណាក់ពួកតាបស អ្នកស្លៀកពាក់សំពត់សហើយបួស ។ ក្នុងកាលនោះ ខ្ញុំទុកសក់របស់ខ្ញុំដោយចន្លាស ដោយប្រការទាំងពួងហើយ ទើបបួស ពួកតាបសក៏ប្រាប់នូវលទ្ធិឥតមានចន្លោះឡើយ ។ លំដាប់នោះ ខ្ញុំរៀននូវលទ្ធិនោះ ហើយអង្គុយតែម្នាក់ឯង គិតនូវលទ្ធិនោះ (គាប់ចួន) ឆ្កែក៏ពាំយកដៃរបស់មនុស្ស ។ ឆ្កែពាំដៃរបស់មនុស្ស ដែលដាច់មកទំលាក់ចោល ក្នុងទីជិតខ្ញុំ ហើយចៀសចេញទៅ ខ្ញុំបានឃើញហើយ ក៏បាននូវនិមិត្ត ចំពោះត្រកូលនៃដង្កូវដែលឋិតនៅ (ក្នុងសាកសពនោះ) ។

## បឋមំ កុណ្ឌលកេសីថេរិយាបទានំ

តតោ ឧដ្ឋាយ សំវិគ្គា អាបុច្ឆឹ សហធម្មិកេ
តេ អវោចុំ វិជានន្តិ តំ អត្ថំ សក្យភិក្ខវោ ។
សាហំ តមត្ថំ បុច្ឆិស្សំ ឧបេត្វា ពុទ្ធសាវកេ
តេ មមាទាយ គច្ឆឹសុ ពុទ្ធសេដ្ឋស្ស សន្តិកេ ។
សោ មេ ធម្មមទេសេសិ ខន្ធាយតនធាតុយោ
អសុភានិច្ចំ ទុក្ខាតិ អនត្តាតិ ច នាយកោ ។
តស្ស ធម្មំ សុណិត្វាហំ ធម្មចក្ខុំ វិសោធយឹ
តតោ វិញ្ញាតសទ្ធម្មា បព្វជ្ជំ ឧបសម្បទំ ។
អាយាចិតោ(១) តទា អាហ ឯហិ ភទ្ទេតិ នាយកោ
តទាហំ ឧបសម្បន្នា បរិត្តំ តោយមទ្ទសំ ។
បាទបក្ខាលនេនាហំ ញត្វា សឧទយព្វយំ
តថា សព្វេបិ សង្ខារ ឥតិ សំចិន្តយឹ(២) តទា ។

---

១ ឱ. អាយាចិ សោ ។ ២ ឱ. ឥតិ សញ្ចិន្តយឹ ។ ម. ឦទិសំ ចិន្តយឹ ។

## កុណ្ឌលកេសីថេរិយាបទាន ទី ១

លំដាប់នោះ ខ្ញុំតក់ស្លុត ហើយក្រោកទៅសួរពួកសហធម្មិក ឯពួកសហធម្មិកទាំងនោះប្រាប់ថា ពួកភិក្ខុជាសក្យបុត្រ ទើបដឹងច្បាស់នូវសេចក្តីនោះបាន ៗ ខ្ញុំនោះបានចូលទៅរកពួកសាវ័ករបស់ព្រះពុទ្ធ ហើយសួរសេចក្តីនោះ ពួកសាវ័កទាំងនោះ ក៏នាំខ្ញុំទៅក្នុងសំណាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ ៗ ព្រះពុទ្ធជានាយកនោះ ទ្រង់សម្តែងនូវព្រះធម៌ ចំពោះខ្ញុំថា ខន្ធ អាយតនៈ ធាតុ ជាធម្មជាតិមិនស្អាតផង មិនទៀងផង ជាទុក្ខផង ជាអនត្តាផង ៗ លុះខ្ញុំបានស្តាប់នូវធម៌របស់ព្រះអង្គហើយ បានជម្រះធម្មចក្ខុ គឺសោតាបត្តិផល លំដាប់នោះ ខ្ញុំបានដឹងច្បាស់នូវព្រះសទ្ធម្មហើយ ក៏សូមនូវបព្វជ្ជានិងឧបសម្បទា ៗ កាលនោះ ព្រះពុទ្ធជានាយក ដែលខ្ញុំសូមហើយ ទើបទ្រង់ត្រាស់ថា ម្នាលនាងដ៏ចម្រើន នាងចូរមកចុះ កាលនោះ ខ្ញុំក៏បានឧបសម្បទា ហើយបានឃើញទឹកបន្តិច ៗ ខ្ញុំដឹងនូវរូបប្រកបដោយការកើតឡើង និងការសូន្យទៅ ដោយគ្រាន់តែលាងជើង ហើយគិតក្នុងកាលនោះថា សង្ខារទាំងឡាយទាំងពួង មានសភាពដូចគ្នា ៗ

តតោ ចិត្តំ វិមុច្ចិ មេ អនុបាទាយ សព្វសោ
ខិប្បាភិញ្ញានមគ្គេម្ហ តទា បញ្ញាបយិ ជិនោ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
បរចិត្តានិ ជានាមិ សត្ថុសាសនការិកា(១)។
បុព្វេនិវាសំ ជានាមិ(២) ទិព្វចក្ខុំ វិសោធិតំ
ខេបេត្វា អាសវេ សព្វេ វិសុទ្ធាសី សុនិម្មលា ។
បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។
យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មេ វិបុលំ(៣) សុទ្ធំ ពុទ្ធសេដ្ឋស្ស វាហសា ។

---

១ ម. សត្ថុសាសនការិកាតិ ន ទិស្សតិ ។ ២ ម. បុព្វេនិវាសំ ជានាមីតិ ឥមេ បាឋា ន ទិស្សន្តិ ។ ៣ ឱ. ម. វិមលំ ។

លំដាប់នោះ ចិត្តរបស់ខ្ញុំក៏រួចស្រឡះចាកអាសវៈ ព្រោះមិនប្រកាន់ដោយប្រការទាំងពួង គ្រានោះ ព្រះជិនស្រីទ្រង់តាំងខ្ញុំថា ប្រសើរលើសជាងពួកភិក្ខុនី ដែលត្រាស់ដឹងឆាប់ហ័ស ខ្ញុំជាស្រីស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ក្នុងសោតធាតុជាទិព្វផង ខ្ញុំជាអ្នកធ្វើតាមសាសនារបស់ព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃផង ៗ ខ្ញុំដឹងនូវបុព្វេនិវាសៈ ទាំងទិព្វចក្ខុខ្ញុំបានជំរះហើយ ខ្ញុំជាភិក្ខុនីបរិសុទ្ធមិនមានមន្ទិល ព្រោះញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ៗ ព្រះសាស្តាខ្ញុំបានប្រព្រឹត្តតាមហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំដាក់ចេញហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភពថ្មី ខ្ញុំគាស់រំលើងចេញហើយ ៗ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់គុណធម៌ណា ប្រយោជន៍គឺគុណធម៌នោះរបស់ខ្ញុំ ជាទីអស់ទៅនៃសញ្ញោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ៗ ញាណរបស់ខ្ញុំ ដ៏ទូលាយស្អាត ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណក៏ដូចគ្នា ព្រោះហេតុនៃព្រះពុទ្ធជាបុគ្គលប្រសើរ ៗ

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភទ្ទា កុណ្ឌលកេសា ភិក្ខុនី
ឥមា គាថាយោ អភាសិត្ថាតិ ។

កុណ្ឌលកេសីថេរិយាបទានំ សមត្តំ ។

## ទុតិយំ កិសាគោតមីថេរិយាបទានំ

(២២) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចេញហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកុណ្ឌលកេសីភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កុណ្ឌលកេសីថេរិយាបទាន ។

## កិសាគោតមីថេរិយាបទាន ទី ២

[៤២] ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែន គិតអំពីកប្បនេះទៅ ។

តទាហំ ហំសវតិយំ ជាតោ អញ្ញតរេ កុលេ
ឧបេត្វា តំ នរវរំ សរណំ សមុបាគមឹ ។
ធម្មញ្ច តស្ស អស្សោសឹ ចតុសច្ចូបសញ្ហិតំ
មធុរំ បរមស្សាទំ ចិត្តសន្តិសុខាវហំ ។
តទាបិ(១) ភិក្ខុនី ធីរេ(២) លូខចីវរធារិកំ
បាបេន្តោ ឯតទគ្គម្ហិ វណ្ណយិ បុរិសុត្តមោ ។
ជនេត្វានប្បកំ បីតឹ សុត្វា ភិក្ខុនិយា គុណំ
ការំ កត្វាន ពុទ្ធស្ស យថាសត្តិ យថាពលំ ។
និបច្ច មុនិធីរន្តំ តំ ឋានំ អភិបត្ថយឹ
តទានុមោទិ សម្ពុទ្ធោ ឋានលាភាយ នាយកោ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។

---

១ ឱ. កទាចិ ។ ម. តទា ច ។ ២ ឱ. ម. វីរេ ។

កាលនោះ ខ្ញុំកើតក្នុងត្រកូលមួយ នៅក្នុងក្រុងហង្សវតី បាន ចូលទៅគាល់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ប្រសើរជាងនរជននោះ ហើយយកព្រះអង្គជាទីពឹង ។ ខ្ញុំបានស្តាប់ធម៌ពីរោះរបស់ព្រះអង្គ ជាធម៌ប្រកបដោយសច្ចៈ ៤ មានអាទិ-សង្ស៊ើក្រៃលែង នាំមកនូវសេចក្តីស្ងប់និងសេចក្តីសុខ ក្នុងចិត្ត ។ កាលនោះ ព្រះពុទ្ធជាអ្នកប្រាជ្ញ ជាបុរសដ៏ខ្ពង់ខ្ពស់ ទ្រង់សរសើរតាំងភិក្ខុនី អ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ក្នុងទីជាឯតទគ្គៈ ។ ខ្ញុំញុំាងបីតិមានប្រមាណច្រើនឲ្យកើត ស្តាប់នូវគុណនៃភិក្ខុនី ខ្ញុំធ្វើនូវគ្រឿងសក្ការៈដល់ព្រះពុទ្ធ តាមគួរដល់សេចក្តីអង់អាច តាមគួរដល់កម្លាំង ។ ខ្ញុំបានក្រាបចុះជិតព្រះអង្គ ជាអ្នកប្រាជ្ញ មានប្រាជ្ញាខ្ជាប់ខ្ជួននោះ ហើយប្រាថ្នានូវតំណែងនោះ កាលនោះ ព្រះសម្ពុទ្ធ ជានាយកទ្រង់អនុមោទនា ចំពោះការបាននូវតំណែងនោះថា ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្តា ព្រះនាមគោតម ទ្រង់កើតក្នុងឧក្កាកត្រកូល នឹងត្រាស់ឡើង ក្នុងលោក ។

## ទុតិយំ កិសាគោតមីថេរិយាបទានំ

តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
កិសាគោតមិ នាម នាមេន ហេស្សតិ សត្ថុសាវិកា ។
តំ សុត្វា មុទិតា ហុត្វា យាវជីវំ តទា ជិនំ
មេត្តចិត្តា បរិចរឹ បច្ចយេហិ វិនាយកំ ។
តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគច្ឆហំ
ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។
បញ្ចមី តស្ស ធីតាហំ(១) ធម្មា នាមេន វិស្សុតា
ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។

---

១ ឱ. ម. ធីតាសឹ ។

នាងនេះនឹងបានជាព្រះញាតិ ក្នុងធម៌ទាំងឡាយនៃព្រះគោតមនោះ ជាឱរស ជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្តា មានឈ្មោះថាកិសាគោតមី ។ កាលនោះ ខ្ញុំស្តាប់នូវពុទ្ធព្យាករណ៍នោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តា បានបម្រើព្រះជិនស្រីជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ មានផៅពង្សដ៏ប្រសើរ មានយសធំប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងហើយ ក្នុងភទ្ទកប្បនេះ ។ កាលនោះ ព្រះរាជាក្នុងដែនកាសី ទ្រង់ព្រះនាមកិកី ព្រះអង្គជាធំជាងនរជន ក្នុងក្រុងពារាណសីដ៏ឧត្តម ទ្រង់ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ៗ ខ្ញុំជាធីតាទី ៥ នៃព្រះរាជានោះ មានឈ្មោះប្រាកដថាធម្មា បានស្តាប់ធម៌ព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងផ្នួស ។

អនុជានិ ន នោ តាតោ   អគារេវ តទា មយំ
វីសវស្សសហស្សានិ   វិចរិម្ហ អតន្ទិតា(១) ។
កោមារិព្រហ្មចរិយំ   រាជកញ្ញា សុខេធិតា
ពុទ្ធោបដ្ឋាននិរតា   មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច   ភិក្ខុនី ភិក្ខុទាសិកា
ធម្មា ចេវ សុធម្មា ច   សត្តមី សង្ឃទាសិកា ។
ខេមា ឧប្បលវណ្ណា ច   បដាចារា ច កុណ្ឌលា
អហញ្ច ធម្មទិន្នា ច   វិសាខា ហោតិ សត្តមី ។
តេហិ កម្មេហិ សុកតេហិ ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ   តាវតឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ   ជាតា សេដ្ឋិកុលេ អហំ
ទុក្កតេ អជនេ ផីចេ   គតា ច សជនំ កុលំ ។
បតិដ្ឋបេត្វាន(២) សេសា មេ   ទិស្សន្តិ អជណា ឥតិ
យទា ច បសុតា អាសី   សព្វេសំ ទយិតា តទា ។

---

១ ម. អតន្ទិកា ។ ២ ឱ. ម. បតឹ ឋបេត្វា ។

ព្រះបិតានៃយើង មិនទ្រង់អនុញ្ញាតឲ្យបួសទេ កាលនោះយើង ជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយធម៌ សម្រាប់កុមារី អស់ ២ ម៉ឺនឆ្នាំក្នុងផ្ទះ ។ យើងជាព្រះរាជធីតា ៧ នាក់ ជាកញ្ញានៃស្តេច ឋិតនៅក្នុងសេចក្តីសុខ ត្រេកអរ រីករាយ ក្នុងការបម្រើព្រះពុទ្ធ គឺ នាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគំរប់ ៧ ។ (ព្រះរាជធីតា ៧ អង្គនោះ បើវិលវិញមកបានជា) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ ខ្ញុំ ១ ធម្មទិន្នា ១ វិសាខា ជាគំរប់ ៧ ។ ដោយកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដែលជាអ្នកធ្លាក់ខ្លួន កំសត់ឥតទ្រព្យ ជាត្រកូលទន់ទាបវិញ តែខ្ញុំបានមានប្តីត្រកូលសម្បូណ៌ ដោយទ្រព្យសម្បត្តិ ។ ជនទាំងឡាយ ដ៏សេស វៀរលែងតែប្តីរបស់ខ្ញុំចេញ សុទ្ធតែជាអ្នកឥតទ្រព្យ ខ្ញុំប្រសូតកូនក្នុងកាលណា ជនទាំងពួងក៏អាណិតខ្ញុំ ក្នុងកាលនោះ ។

## ទុតិយំ កិសាគោតមីថេរិយាបទានំ

យទា សោ តរុណោ បុត្តោ កោមារកោ(១) សុខេឌ្ឍិតា
សបាណមិវ កន្តោ មេ តទា យមវសំ គតោ ។

សោកដ្ដា ទីនវទនា អស្សុនេត្តា រុទម្មុខា
មតំ កុណបមាទាយ វិលបន្តី គមាមហំ ។

តទា ឯកេន សន្ទិដ្ឋា ឧបេតា ភិសក្កុត្តមំ
អវោចំ ទេហិ ភេសជ្ជំ បុត្តសញ្ជីវន្តិ ភោ ។

ន វិជ្ជន្តេ មតា យស្មឹ គេហេ សិទ្ធត្ថកំ តតោ
អាហាភតិ ជិនោ អាហ វិនយោបាយកោវិទោ ។

តទា គមិត្វា សាវត្ថឹ ន លភឹ តាទិសំ ឃរំ
កុតោ សិទ្ធត្ថកំ តស្មា តតោ លទ្ធា សតឹ អហំ ។

---

១ ឱ. ភទ្ទោ កោមលង្គោ ។ ម. ភទ្រោ កោមលកោ ។

## កិសាគោតមីថេរិយាបទាន ទី ២

កាលណា កូនខ្ចីរបស់ខ្ញុំនោះ ជាកុមារតូច ឋិតនៅក្នុងសេចក្តីសុខ ជាទីស្រឡាញ់របស់ខ្ញុំ ដូចជាជីវិតរបស់ខ្លួន កាលនោះ កូននោះ ក៏លុះអំណាចនៃសេចក្តីស្លាប់ទៅ ។ ខ្ញុំមានសេចក្តីសោកគ្របសង្កត់ មានមុខប្រែកបដោយសេចក្តីទុក្ខ មានភ្នែកពេញដោយទឹកភ្នែក មានមាត់យំ ពសាកសពដែលស្លាប់នោះ ដើរយំខ្សុញខ្សែរ ។ កាលនោះ ខ្ញុំបានជួបបុរសម្នាក់ ក៏ចូលទៅរកព្រះពុទ្ធជាគ្រូពេទ្យដ៏ប្រសើរ ហើយពោលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គឲ្យថ្នាំព្រោះកូនឲ្យរស់ ។ ព្រះជិនស្រីព្រះអង្គជាអ្នកឈ្លាសវៃ ក្នុងឧបាយនៃការទូន្មាន ទ្រង់ត្រាស់ថា ជនទាំងឡាយដែលស្លាប់ហើយមិនមានក្នុងផ្ទះណា ចូរនាងយកគ្រាប់ស្ពៃ អំពីផ្ទះនោះមក (ឲ្យតថាគត) ។ កាលនោះ ខ្ញុំដើរទៅកាន់ក្រុងសាវត្ថី រកមិនបានផ្ទះប្រាកដដូច្នោះ ព្រោះហេតុនោះ ទឹងរកគ្រាប់ស្ពៃអំពីផ្ទះណាបាន លំដាប់នោះ ខ្ញុំក៏បាននូវស្មារតីឡើង ។

កុណបំ ឆឌ្ឌយិត្វាន ឧបេសឹ លោកនាយកំ
ទូរតោ ច មមំ ទិស្វា អវោច មធុរស្សរោ ។
យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

ន តាវ ធម្មោ និគមស្ស ធម្មោ
ន ចាបិយំ ឯកកុលស្ស ធម្មោ
សព្វស្ស លោកស្ស សទេវកស្ស
ឯសោវ(១) ធម្មោ យទិទំ អនិច្ចតា ។

សាហំ សុត្វានិមា គាថា ធម្មចក្ខុំ វិសោធយឹ
តតោ វិញ្ញាតសទ្ធម្មា បព្វជឹ អនគារិយំ ។
តថាបិ បព្វជិតា សន្តី យុញ្ជន្តី ជិនសាសនេ
ន ចិរេនេវ កាលេន អរហត្តំ អបាបុណឹ ។

---

១ ម. ឯសេវ ។

ខ្ញុំបោលនូវសាកសព ហើយចូលទៅគាល់ព្រះពុទ្ធ ជាលោកនាយក ចំណែកខាងព្រះអង្គមានសម្ដេងពីពោះ ទ្រង់ទតឃើញខ្ញុំអំពីចម្ងាយ ហើយត្រាស់ថា បុគ្គលណា កាលមិនបានឃើញនូវការកើតនិងការសូន្យទៅ (នៃបញ្ចក្ខន្ធ) ទេ ហើយរស់នៅមួយរយឆ្នាំក៏ដោយ ជីវិតរបស់បុគ្គល អ្នកឃើញនូវការកើតឡើង និងការសូន្យទៅ (នៃបញ្ចក្ខន្ធ) សូម្បីរស់នៅតែមួយថ្ងៃ ក៏ប្រសើរជាង ។

អនិច្ចតាធម៌នេះ នឹងថាជាធម៌សម្រាប់ស្រុកមួយក៏ទេ ជាធម៌សម្រាប់និគមមួយក៏ទេ ជាធម៌សម្រាប់ត្រកូលមួយក៏ទេ ធម៌នុ៎ះឯងសម្រាប់លោក ព្រមទាំងទេវលោកទាំងអស់ ។

ខ្ញុំនោះ បានស្ដាប់នូវគាថាទាំងឡាយនេះ ហើយជម្រះនូវធម្មចក្ខុ គឺសោតាបត្តិមគ្គ លំដាប់នោះ ខ្ញុំក៏ដឹងច្បាស់នូវព្រះសទ្ធម្ម ហើយចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសរួចហើយ ក៏មានចិត្តស្ងប់ ប្រកបក្នុងសាសនាព្រះជិនស្រី អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានសម្រេចនូវព្រះអរហត្ត ។

## ទុតិយំ កិសាគោតមីថេរិយាបទានំ

ឥទ្ធីសុ ច វសី ហោមិ   ទិព្វាយ សោតធាតុយា
បរចិត្តានិ ជានាមិ   សត្ថុសាសនការិកា ។
បុព្វេនិវាសំ ជានាមិ   ទិព្វចក្ខុំ វិសោធិតំ
ខេបេត្វា អាសវេ សព្វេ   វិសុទ្ធាសិំ សុនិម្មលា ។
បរិចិណ្ណោ មយា សត្ថា   កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ   ភវនេត្តិ សមូហតា ។
យស្សត្ថាយ បព្វជិតា   អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ   សព្វសំយោជនក្ខយោ ។
អត្ថធម្មនិរុត្តីសុ   បដិភាណេ តថេវ ច
ញាណំ មេ វិមលំ សុទ្ធំ   ពុទ្ធសេដ្ឋស្ស វាហសា ។
សង្ការកូដា អាហរិត្វា   សុសានា រថិយាបិ ច
តតោ សង្ឃាដិកំ កត្វា   លូខំ ធារេមិ ចីវរំ ។
ជិនោ តស្មឹ គុណេ តុដ្ឋោ   លូខចីវរធារណេ
ឋបេសិ ឯតទគ្គម្ហិ   បរិសាសុ វិនាយកោ ។

## កិសាគោតមីថេរិយាបទាន ទី ២

ខ្ញុំជាអ្នកធ្វើនូវសាសនានៃព្រះសាស្ដា ស្ទាត់ក្នុងឫទ្ធិទាំងឡាយ ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុ ខ្ញុំក៏បានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួងឲ្យអស់ទៅ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ ព្រះសាស្ដា ខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាដែលជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំគាស់រំលើងចោលហើយ ។ ខ្ញុំចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺកិរិយាអស់ទៅនៃសំយោជនៈទាំងពួងនោះ ខ្ញុំបានសម្រេចហើយ ។ ញាណរបស់ខ្ញុំ ដ៏ធំទូលាយស្អាត ក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ ព្រោះអំណាចនៃព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំនាំសំពត់អំពីគំនរសម្រាមផង អំពីព្រៃស្មសានផង អំពីច្រកផង ហើយធ្វើជាសង្ឃាដី ទ្រទ្រង់នូវចីវរដ៏សៅហ្មង ។ ព្រះជិនស្រី ជានាយក ទ្រង់ត្រេកអរក្នុងគុណរបស់ខ្ញុំ គឺការទ្រទ្រង់នូវចីវរដ៏សៅហ្មងនោះ បានតាំងខ្ញុំក្នុងទីជាឯតទគ្គៈ ក្នុងពួកបរិស័ទ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា កិសាគោតមី ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

កិសាគោតមីថេរិយាបទានំ សមត្តំ ។

## តតិយំ ធម្មទិន្នាថេរិយាបទានំ

(២៣) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីដ៏ប្រសើរ កាត់ផ្ដាច់នូវចំណង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះកិសាគោតមីភិក្ខុនី មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ កិសាគោតមីថេរិយាបទាន ។

# ធម្មទិន្នាថេរិយាបទាន ទី ៣

(៤៣) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ជាអ្នកដឹកនាំសត្វលោក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។

## តតិយំ ធម្មទិន្នាថេរិយាបទានំ

តទាហំ ហំសវតិយា  កុលេ អញ្ញតរេ អហុ
បរកម្មំ ការី អាសឹ  និបកា សីលសំវុតា ។
បទុមុត្តរស្ស ពុទ្ធស្ស  សុជាតោ អគ្គសាវកោ
វិហារា អភិនិក្ខម្ម  បិណ្ឌបាតាយ[១] គច្ឆតិ ។
ឃដំ គហេត្វា គច្ឆន្តី  តទា ឧទកហារិកា
តំ ទិស្វា អទទឹ បូវំ[២]  បសន្នា សេហិ បាណិភិ ។
បដិគ្គហេត្វា តត្ថេវ  និសិន្នោ បរិភុញ្ជិ សោ
តតោ នេត្វា តំ គេហំ  អទាសឹ តស្ស ភោជនំ ។
តតោ មេ អយ្យកោ តុដ្ឋោ អការសិ[៣] សុណិសំ សកំ
សស្សុយា សហ គន្ត្វាន  សម្ពុទ្ធំ អភិវាទយឹ ។
តទា សោ ធម្មកថិកំ  ភិក្ខុនឹ បរិកិត្តយំ
ឋបេសិ ឯតទគ្គម្ហិ  តំ សុត្វា មុទិតា អហំ ។
និមន្តយិត្វា សុគតំ  សសង្ឃំ លោកនាយកំ
មហាទានំ ទទិត្វាន  តំ ឋានំ អភិបត្ថយឹ ។

---
១ ម. បត្តមាទាយ ។ ២ ឱ. សូបំ ។ ម. បូបំ ។ ៣ ឱ. អករិ ។ ម. អករី ។

## ធម្មទិន្នាថេរិយាបទាន ទី ៣

កាលនោះ ខ្ញុំកើតក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី ជាអ្នកធ្វើនូវការងារនៃជនដទៃ ខ្ញុំមានប្រាជ្ញាចាស់ សង្រួមក្នុងសីល ។ ព្រះថេរឈ្មោះសុជាត ជាអគ្គសាវ័ក នៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ចេញអំពីវត្តទៅដើម្បីបិណ្ឌបាត ។ កាលនោះ ខ្ញុំចេញទៅដងទឹក កាន់ក្អមដើរទៅ បានឃើញព្រះថេរៈនោះ ក៏មានសេចក្តីជ្រះថ្លា បានប្រគេននំ ដោយដៃរបស់ខ្លួន ។ ព្រះថេរៈនោះ ទទួលនំហើយ ក៏គង់ឆាន់ក្នុងទីនោះ លំដាប់នោះ ម្ចាស់របស់ខ្ញុំមានចិត្តត្រេកអរនឹងខ្ញុំ បានយកខ្ញុំធ្វើជាកូនប្រសារបស់ខ្លួន ខ្ញុំទៅជាមួយនឹងម្តាយក្មេក ថ្វាយបង្គំព្រះសម្ពុទ្ធ ។ គ្រានោះ ព្រះអង្គទ្រង់តាំងភិក្ខុនីមួយរូប ជាធម្មកថិកា អ្នកសម្តែងធម៌ដល់បរិស័ទក្នុងទីជាឯតទគ្គៈ ខ្ញុំបានស្តាប់ពុទ្ធតម្រាស់នោះហើយ ក៏មានចិត្តរីករាយខ្លាំង ។ ខ្ញុំនិមន្តព្រះសុគត ជាលោកនាយក ព្រមទាំងភិក្ខុសង្ឃ ថ្វាយមហាទាន ហើយប្រាថ្នានូវតំណែងនោះ ។

តតោ មំ សុគតោ អាហ ឃននិន្នាទសុស្សរោ(១)
មមុបដ្ឋាននិរតា សសង្ឃបរិវេសិកា ។
សទ្ធម្មសវនេ យុត្តា គុណវឌ្ឍិតមានសា
ភទ្ទេ ភវស្សុ មុទិតា លច្ឆសេតំ(២) បណិធិផលំ ។
សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
ធម្មទិន្នាតិ នាមេន ហេស្សតិ សត្ថុ សាវិកា ។
តំ សុត្វា មុទិតា ហុត្វា យាវជីវំ មហាមុនិំ
មេត្តចិត្តា បរិចរឹ បច្ចយេហិ វិនាយកំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។

---

១ ឱ. ឃននិន្នាទសុស្សរោ ។ ម. ឃននិន្នាទសុស្សរេ ។ ២ ឱ. ម. លច្ឆសេ ឥតិ ទិស្សតិយេវ ។

លំដាប់នោះ ព្រះសុគត ព្រះអង្គមានសម្លេងណែនរំពងពីរោះ ត្រាស់នឹងខ្ញុំថា នាងជាស្រីត្រេកអរ ក្នុងការបម្រើតថាគត ជាអ្នកអង្គាសតថាគត ព្រមទាំងភិក្ខុសង្ឃ ។ នាងជាអ្នកប្រកបក្នុងការស្ដាប់នូវព្រះសទ្ធម្ម មានចិត្តចម្រើនដោយគុណ ម្នាលនាងដ៏ចម្រើន នាងចូររីករាយចុះ នាងនឹងបានផលដែលនាងតាំងប្រាថ្នាទុះ ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិ ក្នុងធម៌នៃព្រះពុទ្ធអង្គនោះ ជាឱរស ជាធម្មនិម្មិត បានជាសាវិកានៃព្រះសាស្ដា មានឈ្មោះថាធម្មទិន្នា ។ ខ្ញុំបានស្ដាប់ពាក្យនោះ ក៏រីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះមហាមុនី ជានាយក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

## តតិយំ ធម្មទិន្នាថេរិយាបទានំ

ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។

ឧបដ្ឋាកោ មហេសិស្ស តទា អាសិ នរិស្សរោ
កាសិរាជា កិកី នាម ពារាណសិបុរុត្តមេ ។

ឆដ្ឋា តស្ស អហំ ធីតា សុធម្មា ឥតិ វិស្សុតា
ធម្មំ សុត្វា ជិនគ្គស្ស បព្វជ្ជំ សមរោចយឹ ។

អនុជានិ ន នោ តាតោ[1] អគារេវ តទា មយំ
វីសំ វស្សសហស្សានិ វិចរិម្ហ[2] អតន្ទិតា ។

តតិយំ ភាណវារំ ។

---

១ ម. នានុ ជានាសិ មំ តាតោ ឥតិ ទិស្សតិ ។ ២ ឱ. វិចរិម្ហា ។

## ធម្មទិន្នាថេរិយាបទាន ទី ៣

ព្រះពុទ្ធមានផៅពង្សដ៏ប្រសើរ មានយសធំ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញ ទ្រង់ព្រះនាមកស្សបៈ កើតឡើងហើយក្នុងកប្បនេះ ៗ កាលនោះ ព្រះរាជាក្នុងដែនកាសី ព្រះនាមកិកី ជាឥស្សរៈនៃនរៈ ក្នុងក្រុងពារាណសីដ៏ឧត្តម ជាឧបដ្ឋាកនៃព្រះពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ ៗ ខ្ញុំជាធីតាទី ៦ នៃព្រះរាជាអង្គនោះ មានឈ្មោះប្រាកដថានាងសុធម្មា បានស្តាប់ធម៌នៃព្រះជិនស្រីដ៏ប្រសើរ ហើយពេញចិត្តនឹងផ្នួស ៗ ព្រះបិតារបស់យើងទ្រង់មិនអនុញ្ញាត កាលនោះ យើងជាអ្នកមិនខ្ជិលច្រអូស បានប្រព្រឹត្តព្រហ្មចរិយធម៌សម្រាប់កុមារី អស់ ២ ម៉ឺនឆ្នាំ ក្នុងផ្ទះ ៗ

ចប់ ភាណវារៈ ទី ៣ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

កោមារិព្រហ្មចរិយំ    រាជកញ្ញា សុខេដ្ឋិតា
ពុទ្ធោបដ្ឋាននិរតា    មុទិតា សត្ត ធីតរោ ។
សមណី សមណគុត្តា ច    ភិក្ខុនី ភិក្ខុទាសិកា
ធម្មា ចេវ សុធម្មា ច    សត្តមី សង្ឃទាសិកា ។
ខេមា ឧប្បលវណ្ណា ច    បដាចារា ច កុណ្ឌលា
គោតមី ច អហំ ចេវ    វិសាខា ហោតិ សត្តមី ។
តេហិ កម្មេហិ សុកតេហិ    ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ    តាវត្តឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ    គិរិព្វជបុរុត្តមេ
ជាតា សេដ្ឋិកុលេ ផីតេ    សព្វកាមសមិទ្ធនេ ។
យទា រូបគុណូបេតា    បឋមេ យោព្វនេ ឋិតា
តតោ បរកុលំ គន្ត្វា    វសឹ សុខសមប្បិតា ។

ធីតា ៧ អង្គ ជាកញ្ញានៃស្តេច តាំងនៅក្នុងសេចក្តីសុខ ត្រេកអររីករាយ ក្នុងការបម្រើព្រះពុទ្ធ គឺនាងសមណី ១ សមណគុត្តា ១ ភិក្ខុនី ១ ភិក្ខុទាសិកា ១ ធម្មា ១ សុធម្មា ១ សង្ឃទាសិកា ជាគំរប់ ៧ ។ (ធីតា ៧ អង្គនោះ ចេរវិលវឹងមកបានជា) នាងខេមា ១ ឧប្បលវណ្ណា ១ បដាចារា ១ កុណ្ឌលា ១ គោតមី ១ ខ្ឈនខ្ញុំ ១ វិសាខា ជាគំរប់ ៧ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តឹង្ស ។ ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដ៏ស្តុកស្តម្ភ ក្នុងក្រុងគិរិព្វជៈ ដ៏ឧត្តម អាចសម្រេចសេចក្តីប្រាថ្នាទាំងពួងបាន ។ កាលណា ខ្ញុំប្រកបដោយគុណគឺរូបសម្បត្តិ តាំងនៅក្នុងបឋមវ័យហើយ កាលនោះឯង ខ្ញុំបានទៅកាន់ត្រកូលនៃបុរសដទៃ (មានប្តី) ហើយនៅស្កប់ស្កល់ដោយសេចក្តីសុខ ។

## តតិយំ ធម្មទិន្នាថេរិយាបទានំ

ឧបេត្វា លោកសរណំ  សុណិត្វា ធម្មទេសនំ
អនាគាមិផលំ បត្តោ  សាមិកោ មេ សុពុទ្ធិមា ។
តទា តំ(១) អនុជានេត្វា  បព្វជឹ អនគារិយំ
ន ចិរេនេវ កាលេន  អរហត្តំ អបាបុណឹ ។
តទា ឧបាសកោ សោ មំ  ឧបគន្ត្វា អបុច្ឆថ
គម្ភីរេ និបុណេ បញ្ហេ  តេ សព្វេ ព្យាករឹ អហំ ។
ជិនោ តស្មឹ គុណេ តុដ្ឋោ  ឯតទគ្គេ ឋបេសិ មំ
ភិក្ខុនឹ ធម្មកថិកំ  នាញ្ញំ បស្សាមិ ឯទិសំ ។
ធម្មទិន្នា យថា ធីរា  ឯវំ ធារេថ ភិក្ខវេ
ឯវាហំ បណ្ឌិតា នាម  នាយកេនានុកម្បិតា ។
បរិចិណ្ណោ មយា សត្ថា  កតំ ពុទ្ធស្ស សាសនំ
ឱហិតោ គរុកោ ភារោ  ភវនេត្តិ សមូហតា ។

---

១ ឱ. ម. តទាហំ ។

## ធម្មទិន្នាថេរីយាបទាន ទី ៣

ឯស្វាមីរបស់ខ្ញុំនោះមានប្រាជ្ញាល្អ បានចូលទៅគាល់ព្រះពុទ្ធ ជាទីពឹងនៃសត្វលោក ស្តាប់ធម៌ទេសនាហើយ ក៏បានដល់នូវអនាគាមិផល ។ កាលនោះ ខ្ញុំបានញុំាងស្វាមីនោះ ឲ្យអនុញ្ញាតហើយ ចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានដល់ព្រះអរហត្ត ។ កាលនោះ ឧបាសកនោះ ចូលមករកខ្ញុំហើយ សួរនូវប្រស្នាទាំងឡាយដ៏ជ្រាលជ្រៅ ខ្ញុំក៏បានព្យាករប្រស្នាទាំងអស់នោះ ។ ព្រះជិនស្រីត្រេកអរក្នុងគុណនោះហើយ បានតាំងខ្ញុំក្នុងទីជាឯតទគ្គៈថា តថាគតមិនឃើញភិក្ខុនីជាធម្មកថិកាដទៃ ប្រាកដដូចភិក្ខុនីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកយ៉ាងនេះថា នាងធម្មទិន្នា ជាអ្នកប្រាជ្ញ ។

ខ្ញុំឈ្មោះថាជាស្រីបណ្ឌិត ដែលព្រះលោកនាយកអនុគ្រោះ ដោយប្រការយ៉ាងនេះឯង ។ ព្រះសាស្តា ខ្ញុំបានបម្រើដោយគោរពហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានរំលើងចោលហើយ ។

យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ
សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
បរចិត្តានិ ជានាមិ ពុទ្ធសាសនការិកា (១) ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
ខេបេត្វា អាសវេ សព្វេ វិសុទ្ធាសិំ សុនិម្មលា ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឧ. ម. សត្ថុសាសនការិកា ។

ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ គឺការអស់ទៅនៃសំយោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ។ ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមពុទ្ធសាសនា ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុខ្ញុំបានជម្រះហើយ ខ្ញុំញុំាងអាសវៈទាំងពួងឲ្យអស់ហើយ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលសោះឡើយ ។ កិលេសទាំងឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលអស់ហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ អាយស្មា ធម្មទិន្នា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ធម្មទិន្នាថេរិយាបទានំ សមត្តំ ។

## បត្ថុំ សកុលាថេរិយាបទានំ

(២៤) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
ហិតាយ សព្វសត្តានំ សុខាយ វទតំ វរោ
អត្ថាយ បុរិសាជញ្ញោ បដិបន្នោ សទេវកេ ។
យសគ្គប្បត្តោ សិរិមា កិត្តិវណ្ណគតោ ជិនោ
បូជិតោ សព្វលោកស្ស ទិសា សព្វា សុវិស្សុតោ ។
ឧត្តិណ្ណវិចិកិច្ឆោ សោ វីតិវត្តកថំកថោ
សម្បុណ្ណមនសង្កប្បោ បត្តោ សម្ពោធិមុត្តមំ ។

បានឮថា ព្រះធម្មទិន្នាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ធម្មទិន្នាថេរិយាបទាន ។

## សកុលាថេរិយាបទាន ទី ៤

(៤៤) ព្រះជិនស្រីព្រះនាមទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះអង្គប្រសើរ ជាងអ្នកប្រាជ្ញទាំងឡាយ ជាបុរសអាជានេយ្យ ប្រតិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីសេចក្តីចម្រើន ដល់សព្វសត្វ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ ព្រះជិនស្រីទ្រង់ដល់នូវយសដ៏ប្រសើរ មានសិរី ពេញពោរដោយកេរ្តិ៍ឈ្មោះនិងសេចក្តីសរសើរ ដែលលោកទាំងពួងបូជាហើយ ប្រាកដក្នុងទិសទាំងពួង ។ ព្រះអង្គមានសេចក្តីសង្ស័យឆ្លងហើយ មានសេចក្តីងឿងឆ្ងល់កន្លងបង់ហើយ មានសេចក្តីត្រិះរិះក្នុងព្រះទ័យបរិបូណ៌ហើយ ទ្រង់ដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា នរុត្តមោ
អនក្ខាតញ្ច អក្ខាសិ អសញ្ជាតញ្ច សញ្ជនី ។
មគ្គញ្ញូ ច មគ្គវិទូ មគ្គក្ខាយី នរាសភោ
មគ្គស្ស កុសលោ សត្ថា សារថីនំ វរុត្តមោ ។
មហាការុណិកោ នាថោ(១) ធម្មំ ទេសេតិ នាយកោ
និមុគ្គេ កាមបង្កម្ហិ សមុទ្ធរតិ ចាណិនោ ។
តទាហំ ហំសវតិយំ ជាតា ខត្តិយនន្ទនា
សុរូបា សធនា ចាបិ ទយិតា ច សិរីមតី ។
អានន្ទស្ស មហារញ្ញោ ធីតា បរមសោភនា
វេមាតា ភគិនី ចាបិ បទុមុត្តរនាមិនោ ។
រាជកញ្ញាហិ សហិតា សព្វាភរណភូសិតា
ឧបគម្ម(២) មហាវីរំ អស្សោសិ ធម្មទេសនំ ។

១ ឱ. ម សត្ថា ។ ២ ម. ឧបាគម្ម ។

ព្រះសម្ពុទ្ធប្រសើរជាងនរជន ទ្រង់ញ៉ាំងមគ្គ ដែលមិនទាន់កើត ឲ្យកើតឡើងផង សម្តែងនូវមគ្គដែលមិនទាន់សម្តែងផង បណ្តុះនូវមគ្គដែលមិនទាន់បណ្តុះផង ។ ព្រះសម្ពុទ្ធ ជាអ្នកអង់អាចជាងនរជន ព្រះអង្គជ្រាបនូវមគ្គ ត្រាស់ដឹងនូវមគ្គ ប្រាប់នូវមគ្គ ជាគ្រូប្រៀនប្រដៅដ៏ឧត្តម ប្រសើរជាងសារថីទាំងឡាយ ។ ព្រះសម្ពុទ្ធ ព្រះអង្គប្រកបដោយព្រះទ័យករុណាដ៏ធំ ជាទីពឹងនៃសត្វលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់សម្តែងធម៌ ស្រោចស្រង់នូវសត្វទាំងឡាយ ដែលមុជចុះក្នុងភក់គឺកាម ។ កាលនោះ ខ្ញុំកើតក្នុងក្រុងហង្សវតី ឈ្មោះខត្តិយនន្ទា ជាស្រីមានរូបល្អ ប្រកបដោយទ្រព្យ មានចិត្តអាណិតអាសូរចំពោះអ្នកដទៃ ជាស្រីមានសិរី ។ ខ្ញុំជាធីតានៃមហារាជព្រះនាមអានន្ទ ជាស្រីមានលំអដ៏ប្រសើរ ជាប្អូនស្រីមាតាផ្សេងគ្នា នៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។ ខ្ញុំស្អិតស្អាង ដោយគ្រឿងអាភរណៈទាំងពួង ជាមួយនឹងព្រះរាជកញ្ញាទាំងឡាយ ហើយចូលទៅគាល់ព្រះពុទ្ធ ទ្រង់មានព្យាយាមធំ ហើយស្តាប់ធម៌ទេសនា ។

## បត្តុំ សកុលាថេរិយាបទានំ

តទា ហិ សោ លោកវិទូ(១) កិត្តឹ និព្វុតត្តិំ
ចតុបរិសាយ(២) មជ្ឈេ អគ្គដ្ឋានេ ឋបេសិ តំ ។
សុណិត្វា តមហំ ហដ្ឋា ទានំ ទត្វាន(៣) សត្ថុនោ
បូជេត្វាន ច សម្ពុទ្ធំ និព្វុតត្តិំ អបត្ថយឹ ។
តតោ អវោច មំ សត្ថា នន្ទេ លច្ឆសិ បត្ថិតំ
បទីបធម្មទានំ ផលមេតំ សុនិច្ឆិតំ ។
សតសហស្សិតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
សកុលាភតិ ច(៤) នាមេន ហេស្សតិ សត្ថុសាវិកា ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគច្ឆហំ ។

---

១ ឱ លោកគុរុ ។ ម. លោកគរុ ២ ឱ. កិត្តយើ បរិសា ។ ម. កិត្តយំ បរិសា ។
៣ ម ភិន្ទិត្វាន ។ ៤ ឱ. ម. សកុលា នាម ។

## សកុលាថេរិយាបទាន ទី ៤

គ្រានោះ ព្រះអង្គជ្រាបច្បាស់នូវលោក ទ្រង់តាំងភិក្ខុនីនោះ ដែលមានចក្ខុដូចជាទិព្វ ក្នុងឋានៈដ៏ប្រសើរ ក្នុងកណ្ដាលនៃបរិស័ទ ៤ ។ ខ្ញុំបានស្ដាប់ព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ ថ្វាយទានដល់ព្រះសាស្ដា បូជាព្រះសម្ពុទ្ធ ហើយប្រាថ្នានូវទិព្វចក្ខុ ។ លំដាប់នោះ ព្រះសាស្ដាបានត្រាស់នឹងខ្ញុំថា ម្នាលនាងនន្ទា នាងនឹងបានតំណែងដែលនាងប្រាថ្នា ឋានៈដែលនាងប្រាថ្នាដោយប្រពៃនុះ ជាផលនៃធម្មទានដូចជាប្រទីប ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឧក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបានជាព្រះញាតិ ក្នុងធម៌ទាំងឡាយនៃព្រះសាស្ដានោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកាព្រះសាស្ដា មានឈ្មោះថាសកុលា ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។

ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
បរិព្វាជិកិនី អាសឹ តទាហំ ឯកចារិនី
ភិក្ខាយ វិចរិត្វាន អលភឹ តេលមត្តកំ ។
តេន ទីបំ បទីបេត្វា ឧបដ្ឋឹ សព្វសំវរំ
ចេតិយំ ទិបទគ្គស្ស វិប្បសន្នេន ចេតសា ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
យត្ថ យត្ថូបបជ្ជាមិ តស្ស កម្មស្ស វាហសា
សញ្ជលន្តិ(១) មហាទីបា តត្ថ តត្ថ(២) គតាយ មេ ។
តិរោកុឌ្ឌំ តិរោសេលំ សមតិគ្គយ្ហ បព្វតំ
បស្សាមហំ យទិច្ឆាមិ ទីបទានស្សិទំ ផលំ ។
វិសុទ្ធនយនា ហោមិ យសសា ជលិតាមហំ
សទ្ធា បញ្ញវតី ចេវ ទីបទានស្សិទំ ផលំ ។

---

១ ឱ. សញ្ចរន្តិ ។ ម. សំជរហន្តិ ។ ២ ឱ. យត្ថ ។

ព្រះពុទ្ធព្រះនាមកស្សបៈ ព្រះអង្គមានផៅពង្សដ៏ប្រសើរ មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើងក្នុងភទ្ទកប្បនេះ ។ កាលនោះ ខ្ញុំបួសជានាងបរិព្វាជិកា ប្រព្រឹត្តម្នាក់ឯង ត្រាច់ទៅដើម្បីភិក្ខា ហើយបាននូវវត្ថុត្រឹមតែប្រេងប៉ុណ្ណោះ ។ ខ្ញុំមានចិត្តជ្រះថ្លា បានអុជប្រទីបដោយប្រេងនោះ បម្រើព្រះចេតិយប្រសើរសមរម្យជាងចេតិយទាំងពួងនៃព្រះពុទ្ធប្រសើរជាងសត្វមានជើងពីរ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ដោយផលនៃកម្មនោះ ខ្ញុំកើតក្នុងទីណា ៗ ប្រទីបដ៏ធំទាំងឡាយ បំភ្លឺដល់ខ្ញុំដែលនៅក្នុងទីនោះ ៗ ។ ខ្ញុំប្រាថ្នារបស់ណា ខ្ញុំឃើញ (របស់នោះ) ធ្លុះរហូតខាងក្រោយជញ្ជាំង ធ្លុះរហូតខាងក្រោយនៃភ្នំថ្ម នេះជាផលនៃការឲ្យប្រទីប ។ ខ្ញុំជាអ្នកមានភ្នែកស្អាត រុងរឿងដោយយស មានសទ្ធា មានប្រាជ្ញា នេះជាផលនៃការឲ្យប្រទីប ។

## ចតុត្ថំ សកុណាថេរិយាបទានំ

បច្ឆិមេ ច ភវេ ទានិ ជាតា វិប្បកុលេ អហំ
បហូតធនធញ្ញម្ហិ មុទិតេ រាជបូជិតេ ។
អហំ សព្វង្គសម្បន្នា សព្វាភរណភូសិតា
បុរប្បវេសេ សុគតំ វាតបានេ ឋិតា អហំ ។
ទិស្វា ជលន្តំ យសសា ទេវមនុស្សសក្កតំ
អនុព្យញ្ជនសម្បន្នំ លក្ខណេហិ វិភូសិតំ ។
ឧទគ្គចិត្តា សុមនា បព្វជ្ជំ សមរោចយឹ
ន ចិរេនេវ កាលេន អរហត្តំ អបាបុណឹ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
បរចិត្តានិ ជានាមិ សត្ថុសាសនការិកា ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
ខេបេត្វា អាសវេ សព្វេ វិសុទ្ធាសឹ សុនិម្មលា ។

## សកុណបេរិយាបទាន ទី ៤

ឥឡូវនេះ មកដល់បច្ឆិមភព ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ មានទ្រព្យនិងស្រូវច្រើន ជាត្រកូលរីករាយ ដែលស្តេចរាប់អានបូជាហើយ ។ ខ្ញុំបរិបូណ៌ដោយអវយវៈគ្រប់យ៉ាង ស្អិតស្អាងដោយអាការៈទាំងពួង ខ្ញុំឈរនៅត្រង់បង្អួច ឃើញព្រះសុគត ត្រង់ប្រទេសជាទីចូលទៅកាន់បុរី ។ ខ្ញុំឃើញព្រះពុទ្ធរុងរឿងដោយយស ដែលទេវតានិងមនុស្សធ្វើសក្ការៈហើយ ទ្រង់បរិបូណ៌ដោយអនុព្យញ្ជនៈ ស្អិតស្អាងដោយលក្ខណៈទាំងឡាយ ។ ខ្ញុំមានចិត្តអណ្តែតឡើង មានចិត្តល្អ ពេញចិត្តនឹងផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានដល់ព្រះអរហត្ត ។ ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ដឹងនូវចិត្តនៃបុគ្គលដទៃ ដោយសោតធាតុដ៏ជាទិព្វ ។ ខ្ញុំដឹងនូវបុព្វេនិវាសញ្ញាណ ទិព្វចក្ខុ ខ្ញុំបានជម្រះហើយ ខ្ញុំបានញុំាងអាសវៈទាំងពួង ឲ្យអស់ហើយ ជាអ្នកបរិសុទ្ធស្អាត មិនមានមន្ទិលឡើយ ។

បរិចិណ្ណោ មយា សត្ថា កតំ ពុទ្ធស្ស សាសនំ

ឱហិតោ គរុកោ ភារោ ភវនេត្តិ សមូហតា ។

យស្សត្ថាយ បព្វជិតា អគារស្មា អនគារិយំ

សោ មេ អត្ថោ អនុប្បត្តោ សព្វសំយោជនក្ខយោ ។

តតោ មហាការុណិកោ ឯតទគ្គេ ឋបេសិ មំ

ទិព្វចក្ខុកានំ អគ្គា សកុលាតិ នរុត្តមោ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

ព្រះសាស្តាខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈដ៏ធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំសត្វទៅកាន់ភព ខ្ញុំបានដកចោលហើយ ។ ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ណា ប្រយោជន៍នោះគឺការអស់ទៅនៃសំយោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ ។ លំដាប់នោះ ព្រះពុទ្ធប្រសើរជាងនរជន ព្រះអង្គប្រកបដោយមហាករុណា ទ្រង់តាំងខ្ញុំជាឯតទគ្គៈ ដោយព្រះពុទ្ធដីកាថា នាងសកុលាថេរី ជាក្សត្រីប្រសើរផុត ជាងថេរីទាំងឡាយដែលមានទិព្វចក្ខុ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងហើយ ខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សកុលា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

សកុលាថេរិយាបទានំ សមត្តំ ។

## បញ្ចមំ នន្ទាថេរិយាបទានំ

(២៨) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។

នន្ទាថេរិយាបទាន ទី ៥

បានឮថា ព្រះសកុលាភិក្ខុនី មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សកុលាថេរិយាបទាន ។

## នន្ទាថេរិយាបទាន ទី ៥

(២៥) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយ នៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ ព្រះពុទ្ធទ្រង់ទូន្មានសត្វលោក ញុំាងសត្វលោកឲ្យដឹងច្បាស់ ចម្លងសត្វទាំងពួង ឈ្លាសវៃក្នុងទេសនា ទ្រង់ញុំាងប្រជុំជន ជាច្រើន ឲ្យឆ្លងហើយ ។ ព្រះអង្គជាអ្នកអនុគ្រោះ ប្រកបដោយករុណា ស្វែងរកនូវប្រយោជន៍ ដល់សត្វទាំងពួង ទ្រង់ញុំាងតិត្ថិយទាំងពួង ដែលមកដល់ហើយ ឲ្យតាំងនៅក្នុងសីល ៥ ។

ឃរំ និភកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ ច
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិភិ ។

រតនានដ្ឋបញ្ញាសំ ឧគ្គតោ សោ មហាមុនិ
បញ្ចនគ្ឃិយសង្កាសោ ទ្វត្តឹសវរលក្ខណោ ។

វស្សសតសហស្សានិ អាយុ វិជ្ជតិ(១) តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

តទាហំ ហំសវតិយំ ជាតា សេដ្ឋិកុលេ អហុ
នានារតនបជ្ជោតេ មហាសុខសមប្បិតា ។

ឧបេត្វា តំ មហាវីរំ អស្សោសឹ ធម្មទេសនំ
អមតំ បរមស្សាទំ បរមត្ថំ និវេទកំ ។

តទា និមន្តយិត្វាន សសង្ឃំ លោកនាយកំ(២)
ទត្វា តស្ស មហាទានំ បសន្នា សេហិ បាណិភិ ។

---

១ ឱ. តិដ្ឋតិ ។ ២ ឱ. តិភវន្តគំ ។

សីល ៥ ជារបស់មិនរិករ យ៉ាងនេះ ជារបស់សូន្យពួកតិត្ថិយ ជារបស់ដែលព្រះអរហន្តទាំងឡាយ អ្នកមានសេចក្ដីស្អាតជំនាញ ប្រកបដោយតាទិគុណវិចិត្រ ហើយ ។ ព្រះពុទ្ធព្រះនាមបទុមុត្តរៈនោះ ជាអ្នកប្រាជ្ញធំ មានកំពស់ ៥៨ ហត្ថ មានទ្រង់ទ្រាយដូចចេតិយមាស មានលក្ខណៈ ៣២ ដ៏ប្រសើរ ។ ព្រះអង្គមានព្រះជន្មមួយសែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅអស់កាលប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លងហើយ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ជាត្រកូលរុងរឿងដោយកែវផ្សេង ៗ ជាអ្នកស្កប់ស្កល់ដោយសេចក្ដីសុខដ៏ធំ នៅក្នុងក្រុងហង្សវតី ។ ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ព្រះអង្គមានព្យាយាមធំ ខ្ញុំបានស្ដាប់នូវធម៌ទេសនា គឺអមតនិព្វាន ជាធម៌មានអានិសង្សក្រៃលែង មានប្រយោជន៍យ៉ាងល្អិតល្អន់ ជាធម៌ដែលព្រះអង្គសំដែងហើយ ។ គ្រានោះ ខ្ញុំមានចិត្តជ្រះថ្លាខ្លាំង បាននិមន្តព្រះលោកនាយក ព្រមទាំងភិក្ខុសង្ឃ ហើយថ្វាយមហាទានដល់ព្រះអង្គ ដោយដៃរបស់ខ្លួន ។

## បញ្ចមំ នន្ទាថេរិយាបទានំ

ឈាយិនីនំ ភិក្ខុនីនំ អគ្គដ្ឋានំ អបត្ថយឹ
និបច្ច សិរសា វីរំ សសង្ឃំ លោកនាយកំ ។
តទា អនន្តទមតោ តិលោកសរណោ បភូ
ព្យាកាសិ នរសុភោ(១) លច្ឆសេ តំ សុបត្ថិតំ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
នន្ទាតិ នាម នាមេន ហេស្សតិ សត្ថុសាវិកា ។
តំ សុត្វា មុទិតា ហុត្វា យាវជីវំ តទា ជិនំ
មេត្តចិត្តា បរិចរឹ បច្ចយេហិ វិនាយកំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។

---

១ ឱ. នរសទ្ទូលោ ។ ម. នរសារថិ ។

## នន្ទាថេរិយាបទាន ទី ៥

ខ្ញុំក្រាបជិតព្រះលោកនាយក ព្រះអង្គមានព្យាយាម ព្រមទាំងព្រះសង្ឃដោយត្បូង ហើយប្រាថ្នានូវតំណែងដ៏ប្រសើរជាងពួកភិក្ខុនីដែលមានឈាន ។ កាលនោះ ព្រះអង្គទូន្មានសត្វដែលមិនទាន់ទូន្មានហើយ ជាទីពឹងនៃលោកទាំង ៣ មានរស្មី ព្រះអង្គជានាយសារថីរបស់ពួកនរជន ទ្រង់ព្យាករណ៍ថា នាងនឹងបាននូវតំណែង ដែលនាងប្រាថ្នាហើយដោយប្រពៃ +នុះ ។ ក្នុងមួយសែនកប្ប អំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម សម្ភពក្នុងឧក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ នាងនឹងបានជាញាតិក្នុងធម៌ទាំងឡាយ របស់ព្រះសាស្តាអង្គនោះ ជាឱរសជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្តា មានឈ្មោះថានាងនន្ទា ។ កាលនោះ ខ្ញុំបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តាបម្រើព្រះជិនស្រី ព្រះអង្គជានាយក ដោយបច្ច័យទាំងឡាយដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

តតោ ចុតា យាមមគំ តតោហំ តុសិតំ គតា(១)
តតោ ច និម្មានរតឹ វសវត្តិបុរំ គតា ។
យត្ថ យត្ថូបបជ្ជាមិ តស្ស កម្មស្ស វាហសា
តត្ថ តត្ថេវ រាជូនំ មហេសិត្តមការយឹ ។
តតោ ចុតា មនុស្សត្តេ រាជូនំ ចក្កវត្តិនំ
មណ្ឌលីនញ្ច រាជូនំ មហេសិត្តមការយឹ ។
សម្បត្តឹ អនុភោត្វាន ទេវេសុ មនុជេសុ ច
សព្វត្ថ សុខិតា ហុត្វា នេកកប្បេសុ សំសរឹ ។
បច្ឆិមេ ភវសម្បត្តេ បុរស្មឹ(២) កបិលវ្ហយេ
រញ្ញោ សុទ្ធោទនស្សាហំ ធីតា អាសឹ អនិន្ទិតា ។
រូបសិរិ(៣) រូបិនឹ ទិស្វា នន្ទិតំ អាសិ តំ កុលំ
តេន នន្ទាតិ មេ នាមំ សុន្ទរ បវរ អហំ(៤) ។

---

១ ឱ. ម. អគំ ។ ២ ឱ. ម. សុរម្មេ ។ ៣ ឱ. ម. សិរិយា ។ ៤ ឱ. សុន្ទរំ បវរំ អតុំ ។ ម. សុន្ទរំ បវរំ អហុ ។

លុះខ្ញុំច្យុតចាកឋានតាវត្តិង្សនោះ បានទៅកើតឯឋានយាមៈ ច្យុតចាកឋានយាមៈនោះ បានទៅកាន់ឋានតុសិត ច្យុតចាកឋានតុសិតនោះ បានទៅកាន់និម្មានរតី ច្យុតចាកនិម្មានរតីនោះហើយ បានទៅកាន់បរនិម្មិតវសវត្តីបុរី ។ ដោយផលនៃកុសលកម្មនោះ ខ្ញុំកើតក្នុងទីណា ៗ តែងបានជាមហេសីនៃស្តេចទាំងឡាយក្នុងទីនោះៗ ។ ខ្ញុំច្យុតចាកទីនោះហើយ កើតជាមនុស្ស បានជាមហេសី នៃស្តេចចក្រពត្តិទាំងឡាយផង នៃស្តេចមានមណ្ឌលទាំងឡាយផង ។ ខ្ញុំសោយនូវសម្បត្តិក្នុងទេវតានិងមនុស្ស ហើយដល់នូវសេចក្តីសុខក្នុងទីទាំងពួង អន្ទោលទៅអស់កប្បច្រើន ។ លុះដល់មកក្នុងបច្ឆិមភព ខ្ញុំកើតជាធីតា នៃព្រះបាទសុទ្ធោទនៈ មិនមានអ្នកណាមួយតិះដៀលបាន ក្នុងបុរីឈ្មោះកបិលពស្តុ ។ ត្រកូលនោះក៏ដល់នូវសេចក្តីត្រេកអរ ព្រោះបានឃើញខ្ញុំជាស្រីមានរស្មី ព្រោះហេតុនោះ ឈ្មោះរបស់ខ្ញុំថានាងនន្ទា ខ្ញុំជាស្រីល្អប្រសើរ ។

## បញ្ចមំ ឧត្តរាថេរិយាបទានំ

យុវតី ច សមានា កល្យាណីតិ ច វិស្សុតា
តស្មឹ នគរេ រម្មេ ឋបេត្វា តំ យសោធរំ ។
ជេដ្ឋា ភាតា តិលោកគ្គោ បច្ឆិមោ អរហា តថា
ឯកាកិនី គហដ្ឋាហំ មាតុយា បរិរោទិតា ។
សាកិយម្ហិ កុលេ ជាតា បុត្តេ ពុទ្ធានុជា តុវំ
នន្ទេនបិ វិនា ភូតា អគារេ កឹ ន លច្ឆសិ ។
ជរាវសានំ យោព្វញ្ញំ រូបំ អសុចិសម្មតំ
រោគន្តមបិចារោគ្យំ ជីវិតំ មរណន្តិកំ ។
ឥទំបិ តេ សុភំ រូបំ សសិកន្តំ(១) មនោហរំ
ភូសនានំ អលង្ការំ សិរិសង្កេតសន្និភំ(២) ។
បូជិតំ លោកសករំវ នយនានំ រសាយនំ
បុញ្ញានំ កិត្តិជននំ ឧក្កាកកុលនន្ទនំ ។

---

១ ឱ. បស្សូរកន្តំ ។ ២ ឱ. សិរីសង្ខតសន្និភំ ។ ម. សិរិសង្ឃាជសន្និភំ ។

## នន្ទាថេរិយាបទាន ទី ៥

មួយទៀត ខ្ញុំប្រាកដជាស្រីមានលំអ ជាងស្រីក្រមុំទាំងអស់ វៀរលែងតែព្រះនាងយសោធរា ក្នុងនគរជាទីរីករាយនោះ បេញ ៗ បងប្រុសច្បង (របស់ខ្ញុំ) បានជាកំពូលនៃលោក ទាំង ៣ បងប្រុសបន្ទាប់ខាងក្រោយ ជាព្រះអរហន្តដូចគ្នា ខ្ញុំនៅជាគ្រហស្ថតែម្នាក់ឯង ដែលមានមាតាតែងដាស់តឿនថា នាងជាព្រះអនុជានៃព្រះពុទ្ធ កើតក្នុងត្រកូលសក្យបុត្រ នាងបើវៀរចាកសេចក្តីត្រេកអរក្នុងធម៌ហើយ តើនឹងបាននូវអ្វីក្នុងផ្ទះ ៗ សេចក្តីចម្រើនមានជរាជាទីបំផុត រូបជារបស់ដែលសន្មតថាមិនស្អាត ការមិនមានរោគ មានរោគជាទីបំផុត ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ៗ រូបរបស់នាងនេះល្អ គួររមិលមើល គួររីករាយ ជាគ្រឿងប្រដាប់របស់អ្នកស្ទិតស្ទាងទាំង-ឡាយ ដូចជាទីលំនៅដែលមានសិរី ៗ (រូបរបស់នាង) ដែលគេបូជាហើយ ដូចជាវត្ថុមានខ្ទឹមក្នុងលោក ជាទីនាំមកនូវរសដល់ភ្នែកទាំងឡាយ ជាទីញ៉ាំងកិត្តិស័ព្ទ ឲ្យកើតដល់ជនអ្នកមានបុណ្យទាំងឡាយ ជាទីញ៉ាំងឧក្កាកត្រកូលឲ្យត្រេកអរ ៗ

ន ចិរេនេវ កាលេន ជរា សមភិភោស្សតិ(១)
បហាយ(២) គេហំ តារុញ្ញំ(៣) ចរ(៤) ធម្មមនិន្ទិតេ ។
សុត្វាហំ មាតុ វចនំ បព្វជឹ អនគារិយំ
ទេហេន ន តុ ចិត្តេន រូបយោព្វនលោលិតា ។
មហតា ច បយត្តេន ឈានជ្ឈេន សរំ មមំ(៥)
កាតុញ្ច វទតេ មាតា ន ចាហំ តត្ថ ឧស្សុកា ។
តតោ មហាការុណិកោ ទិស្វា មំ កាមលានសំ(៦)
និព្វិន្ទនត្ថំ រូបស្មឹ មម ចក្ខុបថេ ជិនោ ។
សកេន អានុភាវេន ឥត្ថឹ មាបេសិ សោភនំ
ទស្សនីយំ សុរុចិរំ មមតោបិ សុរូបិនឹ ។
តមហំ វិម្ហិតា ទិស្វា អតិវិម្ហិតទេហិនឹ(៧)
ចិន្តយឹ សផលំ មេតិ នេត្តលាភញ្ច មានុសំ ។

---

១ ឱ. សមធិហេស្សតិ ។ ម. សមភិសេស្សតិ ។ ២ ឱ. ម. វិហាយ ។ ៣ ឱ. តារុញ្ញោ ។ ម. តារុញ្ញោ បរ ។ ៤ ឱ. វរ ។ ៥ ម. បរំ មម ។ ៦ ឱ. ម. កាមលាលសំ ។ ៧ ឱ. អវិនិច្ចិតទេហិនី ។

អស់កាលមិនយូរប៉ុន្មាន ជកទឹងគ្របសង្កត់ (នូវរូបរបស់នាង) មិនខាន នាងគួរលះបង់ផ្ទះ ដែលអ្នកប្រាជ្ញគប្បីតិះដៀល ហើយប្រព្រឹត្តធម៌ ដែលអ្នកប្រាជ្ញមិនតិះដៀលវិញ ។ ខ្ញុំបានស្តាប់ពាក្យរបស់មាតា ជាអ្នកមានចិត្តមិនរលោរលោំ ដោយកងកាយ និងរូបនិងវ័យ ហើយចូលទៅកាន់ផ្នួស ។ មាតារបស់ខ្ញុំ ពោលដើម្បីធ្វើនូវសេចក្តីរំពុក ដោយការរៀនឈានដ៏ធំ ជាធម្មជាតស្អាត តែខ្ញុំមិនបានខ្វល់ខ្វាយ ក្នុងការរៀនឈាននោះទេ ។ លំដាប់នោះ ព្រះជិនស្រី ប្រកបដោយមហាករុណា ឃើញខ្ញុំមានមុខដូចផ្កាឈូក ទ្រង់និម្មិតស្រីល្អគួររមិលមើល រុងរឿងក្រៃពេក មានរូបល្អជាងខ្ញុំ ក្នុងវង្វង់ចក្ខុរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំនឿយណាយក្នុងរូប ដោយអានុភាពនៃព្រះអង្គ ។ ខ្ញុំឃើញស្រីនោះមានរាងកាយអស្ចារ្យក្រៃពេក ក៏ស្ញើចគិតថា ក្អែករបស់អញប្រកបដោយផល ព្រោះរូបជារបស់មនុស្សនេះ ជាលាភនៃក្អែក ។

## បញ្ចមំ នត្ថាបេរិយាបទានំ

តមហំ ឃហិ សុកណោ(១) យេនត្ថោ តំ វទេហិ មេ
កុលវេត្ត នាមគោត្តញ្ច វទ មេ យទិ តេ បិយំ ។
ន បណ្ណាការោ(២) សុកណោ ឧច្ឆង្គេ មំ និវេសយ(៣)
សីទន្តិ(៤) មមន្តានិ បសុប្បយ(៥) មុហុត្តកំ ។
តតោ សីសំ មមង្កេ(៦) សា កត្វា សយិ សុសោភណា(៧)
តស្សា លលាតេ(៨) បតិតា លុទ្ធា(៩) បរមទារុណា ។
សហ តស្សា និបាតេន បិឡកា ឧបបជ្ជថ
បក្ខរីសុ បភិន្នា ច កុណបា បុព្វលោហិតា ។
សភិន្នំ(១០) វណញ្ចាបិ កុណបំ បូតិគន្ធិកំ
ឧទុមាតំ វិនីលញ្ច សព្វញ្ចាបិ(១១) សរីរកំ ។

---

១ ឱ. ម. សុភគេ ។ ២ ម. ន វិញ្ញាណោ ។ ៣ ម. និភិសយ ។ ៤ ឱ. និសីទន្តិ ។ ៥ ឱ. បស្សេនិស្សំ ។ ៦ ម មមង្គេ ។ ៧ ឱ. ម. សុលោបត ។ ៨ ឱ. ម. នលាដេ ។ ៩ ឱ. លុទ្ធា ។ ១០ ម. បភិន្នំ ។ ១១ ម. បុព្វញ្ចាបិ ។

## ឧត្តរាថេរិយាបទាន ទី ៥

ខ្ញុំនិយាយនឹងស្រីនោះថា ម្នាលស្រីល្អល្អ នាងចូរមក នាងមានសេចក្តីត្រូវការ ដោយវត្ថុណា នាងចូរប្រាប់វត្ថុនោះដល់ខ្ញុំ បើ (ពាក្យរបស់ខ្ញុំ) ជាទីស្រឡាញ់នៃនាង ចូរនាងប្រាប់ខ្ញុំនូវត្រកូល នាម និងគោត្ររបស់នាង ។ ម្នាលស្រីល្អ (កាលនេះ) មិនមែនជាកាលគួរដោះស្រាយប្រស្នាទេ នាងចូរឲ្យខ្ញុំបិតនៅលើភ្លៅ អវយវៈទាំងឡាយរបស់ខ្ញុំស្រុតចុះ នាងចូរឲ្យខ្ញុំដេកមួយរំពេច ។ លំដាប់នោះ ស្រីដែលព្រះពុទ្ធនិមិត្តដ៏ល្អនោះ ដេកកើយក្បាលលើភ្លៅនៃខ្ញុំ ខ្ញុំជាស្រីអាក្រក់យ៉ាងក្រៃលែង ក៏ដួលទៅលើថ្ងាសស្រីនោះ ។ ពកក៏កើតឡើងដល់ស្រីនោះ ដំណាលគ្នានឹងការដួលចុះ ខ្ទុះនិងឈាមទាំងឡាយ ហូរចេញចាកសាកសព ដែលបែកធ្លាយហើយផង មាត់មានក្លិនស្អុយ ដូចសាកសពបែកធ្លាយហើយផង សរីរៈទាំងមូល ហើមប៉ោងឡើង មានសម្បុរខៀវផង ។

សា បវេធិតសព្វង្គី និស្សសន្តី មុហុំ មុហុំ
វេទយន្តី សកំ ទុក្ខំ ករុណំ បរិទេវយិ ។
ទុក្ខេន ទុក្ខិតា ហោមិ ដុសយន្តី ច វេទនា
មហាទុក្ខេ និមុគ្គម្ហិ សរណំ ហោមិ(១) មេ សខិ ។
កុហឹ វទនសោភន្តេ កុហិន្តេ តុង្គនាសិកា
តម្ពពិម្ពវរោដ្ឋន្តេ វទនន្តេ កុហឹ គតំ ។
កុហឹ សសិនិភំ វណ្ណំ(២) កម្ពុគិវា កុហឹ គតា
ទាមាមាលញ្ច(៣) តេ កណ្ណំ វេណ្ណំ សមុទាគតំ ។
មកុលបទុមាការា(៤) កលសាវ បយោធរា
បភិន្នា បូតិកុណបា ទុដ្ឋគន្ធមាគតា(៥) ។
វេទិមជ្ឈា បុថុស្សោណិ(៦) សុណាវ និតកិព្វិសា
ជាតា អមជ្ឈករិតា(៧) អហោ រូបំ អសស្សតំ ។

---

១ ឱ. ម. ហោហិ ។ ២ ឱ. សសី និភំ វត្តំ ។ ៣ ឱ. ទោណាលោហាប ។ ម. ទោណោលុណ្ឌវ ។
៤ ឱ. ម. មកុឡាករកាការ ។ ៥ ឱ. ទុដ្ឋគន្ធិត្វមាគតា ។ ។ ម. ទុដ្ឋគន្ធិត្តមាគតា ។ ៦
ម. វេធិមេជ្ឈាវ សុស្សោណី ។ ៧ ឱ. អភេជ្ជករិតា ។ ម. អមេជ្ឈករិតា ។

ស្រីនោះ មានអវយវៈទាំងពួងញ័ររន្ធត់ ដកដង្ហើមចេញម្ហប ៗ ទទួលរងទុក្ខរបស់ខ្លួន ខ្សឹកខ្សួល (ព្រោះអាស្រ័យ)នូវសេចក្ដីករុណាថា អាត្មាអញលំបាក ដោយសេចក្ដីទុក្ខ ប៉ះពាល់នូវវេទនា ជ្រមុជចុះក្នុងទុក្ខធំ អាត្មាអញមានសំឡាញ់ជាទីពឹងនៃអាត្មាអញ ៗ ឱ ! លំអមុខរបស់នាង បាត់ទៅឯណាទៅ ច្រមុះគោងរបស់នាង បាត់ទៅឯណាទៅ បបូរមាត់ដ៏ប្រសើរដូចជាផ្លែបាសទុំរបស់នាង បាត់ទៅឯណាទៅ មាត់របស់នាង បាត់ទៅឯណាទៅ ៗ សម្បុររបស់នាងប្រហែលដោយព្រះចន្ទ្រ បាត់ទៅឯណាទៅ កដ៏ប្រដាប់ដោយមាសរបស់នាង បាត់ទៅឯណាទៅ ចង្កោមផ្កានិងកម្រងផ្កានិងត្របៀករបស់នាង ប្រកបដោយសម្បុរខុសគ្នា ៗ ដោះរបស់នាងក្សំ មានអាការដូចផ្កាឈូកក្ដោប សាកសពមានក្លិនស្អុយបែកធ្លាយហើយ មានក្លិនអាក្រក់ក្រៃពេក ៗ នាងមានចង្កេះរលេ មានទ្រគាកធំ មានខ្លួនអាក្រក់ក្រៃលែង ដូចជ្រញ់ ពេញដោយវត្ថុមិនស្អាត ឱហ្ន៎ ! រូបមិនទៀងទេតើ ៗ

## បញ្ចមំ នន្ទាថេរិយាបទានំ

សព្វំ សរីរសញ្ញាតំ   បូតិកំ ភយានកំ

សុសានមិវ ជេគុច្ឆំ(១)   រមន្តេ យត្ថ ពាលិយា(២)។

តទា មហាការុណិកោ   ភាតា មេ លោកនាយកោ

ទិស្វា សំវិគ្គចិត្តំ មំ   ឥមា គាថា អភាសថ ។

អាតុរំ កុណបំ បូតឹ   បស្ស នន្ទេ សមុស្សយំ

អសុភាយ ចិត្តំ ភាវេហិ   ឯកគ្គំ សុសមាហិតំ ។

យថា ឥទំ តថា ឯតំ   យថា ឯតំ. តថា ឥទំ

ទុគ្គន្ធំ បូតិកំ វាតិ   ពាលានំ អភិនន្ទិតំ ។

ឯវមេតំ អវេក្ខន្តិ   រត្តិន្ទិវមតន្ទិតា

តតោ សកាយ បញ្ញាយ   អភិនិព្វិជ្ជ ទក្ខសិ ។

---

១ ម. ជេគុច្ឆំ ។ ២ ឱ. ពាលិសា ។

## ឧត្តរាថេរីយាបទាន ទី ៥

ពួកពាលតែងត្រេកអរក្នុងរូបណា រូបទាំងអស់នោះ ដែលកើតហើយ ជាសរីរៈមានក្លិនស្អុយ គួរខ្លាច ជាទីខ្ពើមរអើម ដូចជាព្រៃស្មសាន ៗ កាលនោះ ព្រះសាស្តាជាបងរបស់ខ្ញុំ ប្រកបដោយមហាករុណា ជានាយកនៃសត្វលោក ទ្រង់ឃើញខ្ញុំមានចិត្តតក់ស្លុត ទ្រង់បានត្រាស់នូវគាថាទាំងនេះថា ម្នាលនាងនន្ទា នាងចូរមើលនូវសាកសព ដែលឈឺជានិច្ច មានក្លិនស្អុយ មានឆ្អឹង ៣០០ កំណាត់លើកឡើងហើយ នាងចូរចំរើនចិត្ត ដោយអសុភកម្មដ្ឋាន ឲ្យជាចិត្តមានអារម្មណ៍តែមួយ តាំងនៅមាំដោយប្រពៃចុះ ៗ រូបរបស់នាងនេះ យ៉ាងណា រូបរបស់ស្រីនុ៎ះ ក៏យ៉ាងនោះដែរ រូបរបស់ស្រីនុ៎ះយ៉ាងណា រូបរបស់នាងនេះ ក៏យ៉ាងនោះដែរ រូបនេះមានក្លិនអាក្រក់ ស្អុយ ផ្សាយទៅ តែពួកពាលប្រាថ្នាក្រៃពេក ៗ ជនទាំងឡាយ ដែលមិនខ្ជិលទាំងយប់ទាំងថ្ងៃ រមែងពិចារណាឃើញរូបនុ៎ះ យ៉ាងនេះឯង នាងនឿយណាយចាករូបនោះ ហើយឃើញដោយប្រាជ្ញារបស់ខ្លួនចុះ ៗ

តតោហំ អាសិ សំវិគ្គា(១) សុត្វា គាថា សុភាសិតា
តត្រដ្ឋិតាហំ សន្តី អរហត្តំ អបាបុណឹ ។
យត្ថ យត្ថ និសិន្នាហំ តទា(២) ឈានបរាយណា
ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា នន្ទា ភិក្ខុនី ជនបទ-
កល្យាណី ឥមា គាថាយោ អភាសិត្ថាតិ ។

នន្ទាថេរិយាបទានំ សមត្តំ ។

---

១ ម. អតិសំវិគ្គា ។ ២ ម. សទា ។

លំដាប់នោះ ខ្ញុំបានស្តាប់នូវគាថាជាសុភាសិត ក៏មានចិត្តតក់ស្លុត ខ្ញុំឋិតនៅក្នុងទីនោះ មានចិត្តស្ងប់ បានដល់នូវព្រះអរហត្ត ។ កាលនោះ ខ្ញុំអង្គុយក្នុងទីណា ៗ ក៏មានឈានជាទីប្រព្រឹត្តទៅខាងមុខ ព្រះជិនស្រី ត្រេកអរក្នុងគុណនោះហើយ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណាង ដូចមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនន្ទាភិក្ខុនីជនបទកល្យាណី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នន្ទាថេរិយាបទាន ។

## ឆដ្ឋំ សោណាថេរិយាបទានំ

(២៦) បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។
តទា សេដ្ឋិកុលេ ជាតា សុខិតា សជ្ជិតា(១) បិយា
ឧបេត្វា តំ មុនិវរំ អស្សោសឹ មធុរំ វចំ ។
អារទ្ធវីរិយានគ្គំ វណ្ណេតិ ភិក្ខុនឹ ជិនោ(២)
តំ សុត្វា មុទិតា ហុត្វា ការំ កត្វាន សត្ថុនោ ។
អភិវាទិយ សម្ពុទ្ធំ ឋានំ បត្ថយឹ តទា
អនុមោទិ មហាវីរោ សិជ្ឈតំ បណិធី តវ ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
សោណាតិ នាម នាមេន ហេស្សតិ សត្ថុសាវិកា ។

---

១ ម. បូជិតា ។ ២ ឱ. ម. វណ្ណេន្តំ ភិក្ខុនិំ ជិនំ ។

# សោណាថេរិយាបទាន ទី ៦

(២៦) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយក ទ្រង់កើតឡើងហើយក្នុងកប្បទីមួយសែនអំពីកប្បនេះ ។ កាលនោះ ខ្ញុំកើតក្នុងត្រកូលសេដ្ឋី ដល់នូវសេចក្ដីសុខ ជាស្រីមានគេជាប់ចិត្ត ជាទីស្រឡាញ់ (នៃជនដទៃ) ខ្ញុំបានចូលទៅគាល់ព្រះពុទ្ធអង្គនោះ ជាអ្នកប្រាជ្ញដ៏ប្រសើរ បានស្ដាប់តម្រាស់ដ៏ពីរោះ ។ ព្រះជិនស្រីទ្រង់សរសើរភិក្ខុនី អ្នកមានព្យាយាមលើសលុប ជាងភិក្ខុនីទាំងឡាយអ្នកមានព្យាយាមប្រារព្ធ ខ្ញុំបានស្ដាប់ព្រះពុទ្ធតម្រាស់នោះ ក៏មានចិត្តរីករាយ ហើយធ្វើនូវសក្ការៈចំពោះព្រះសាស្ដា ។ កាលនោះ ខ្ញុំថ្វាយបង្គំព្រះសម្ពុទ្ធ ហើយប្រាថ្នានូវតំណែងនោះ ព្រះមហាវីរបុរស ទ្រង់អនុមោទនាថា សេចក្ដីប្រាថ្នានៃនាងនឹងសម្រេច ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ដឹងឡើងក្នុងលោក ។ នាងនឹងបានជាញាតិ ក្នុងធម៌ទាំងឡាយនៃព្រះសាស្ដានោះ ជាឱរស ជាធម្មនិម្មិត ជាសាវិកានៃព្រះសាស្ដា មានឈ្មោះថាសោណា ។

តំ សុត្វា មុទិតា ហុត្វា យាវជីវំ តទា ជិនំ
មេត្តចិត្តា បរិចរឹ បច្ចយេហិ វិនាយកំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេ ទានិ ជាតា សេដ្ឋិកុលេ អហំ
សាវត្ថិយំ បុរវរេ ឥទ្ធេ ផីតេ មហទ្ធនេ ។
យទា ច យោព្វនំ បត្តា គន្ត្វា បតិកុលំ អហំ
ទស បុត្តានិ អជនឹ សុរូបានិ វិសេសតោ ។
សុខេ ឋិតា ច តេ សព្វេ ជនេនេត្តមនោហរា
អមិត្តានម្បិ រុចិតា មម បគេវ តេ បិយា ។

កាលនោះ ខ្ញុំបានស្តាប់ពុទ្ធព្យាករណ៍នោះហើយ ក៏មានចិត្តរីករាយ មានចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រី ជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលនៃសេដ្ឋី ជាត្រកូលស្តុកស្តម្ភ ធំទូលាយ មានទ្រព្យច្រើន ក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរ ។ កាលណា ខ្ញុំដល់នូវវ័យ ទៅត្រកូលប្តី បានបង្កើតកូន ១០ នាក់ មានរូបល្អប្លែក ៗ គ្នា ។ កូនទាំងអស់នោះ ឋិតនៅក្នុងសេចក្តីសុខ ជាទីគាប់ភ្នែកនិងចិត្តនៃជន សូម្បីសត្រូវទាំងឡាយក៏គង់គាប់ចិត្តដែរ នឹងបាច់និយាយទៅថ្វី ដល់កូនទាំងនោះដែលជាទីស្រឡាញ់នៃខ្ញុំ ។

## ឆដ្ឋ សោណាថេរិយាបទានំ

តតោ មយ្ហំ អកាមាយ  ទសបុត្តបុរក្ខតោ
បព្វជិត្ថ ស មេ កន្តា  ទេវទេវស្ស សាសនេ ។
តទេកិកា វិចិន្តេសឹ  ជីវិតេនាលមត្ថុ មេ
ជិនាយ បតិបុត្តេហិ  ពុទ្ធាយបិ(១) វរាកិយា ។
អហំបិ តត្ថ គច្ឆិស្សំ  សម្បត្តោ យត្ថ មេ បតិ
ឯវាហំ ចិន្តយិត្វាន  បព្វជឹ អនគារិយំ ។
តតោ មមំ(២) ភិក្ខុនិយោ  ឯកំ ភិក្ខុនុបស្សយេ
វិហាយ គច្ឆុមោវាទំ  តាបេហិ ឧទកំ ឥតិ ។
តទា ឧទកមានេត្វា  ឱកិរិត្វាន កុម្ភិយា
ចុល្លេ ឋបេត្វា អាសិនា  តតោ ចិត្តំ សមាទហឹ ។
ខន្ធេ អនិច្ចតោ ទិស្វា  ទុក្ខតោ ច អនត្តតោ
ខេបេត្វា អាសវេ សព្វេ  អរហត្តំ អបាបុណឹ ។
តទាគន្ត្វា ភិក្ខុនិយោ  ឧណ្ហោទកមបុច្ឆិសុំ
តេជោធាតុំ អធិដ្ឋាយ  ខិប្បំ សន្តាបយឹ ជលំ ។

---

១ ឱ. ម. វុឌ្ឍាយ ប ។ ២ ឱ. ម. គតោ ប មំ ។

សោណកថេរិយាបទាន ទី ៦

លំដាប់នោះ ប្ដីរបស់ខ្ញុំនោះ មានកូន ១០ នាក់ចោមរោម ទៅបួសក្នុងសាសនាព្រះពុទ្ធ ជាទេវតាក្នុងទេវតា ដោយខុសបំណងរបស់ខ្ញុំ ៗ គ្រានោះ ខ្ញុំតែម្នាក់ឯង បានគិតថា ជីវិតមិនគួរដល់អញ ដែលជាស្រីចាស់កំព្រាព្រាត់ប្រាស់ចាកប្ដីនិងកូនទាំងឡាយឡើយ ដូច្នេះ ប្ដីរបស់អញនៅក្នុងទីណា អញនឹងទៅក្នុងទីនោះ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ចូលទៅកាន់ផ្នួស ៗ លំដាប់នោះ ភិក្ខុនីទាំងឡាយលះបង់ខ្ញុំម្នាក់ឯងក្នុងលំនៅនៃភិក្ខុនី ហើយក៏ទៅឲ្យឱវាទថា នាងចូរដាំទឹក ៗ គ្រានោះ ខ្ញុំនាំទឹកមកហើយចាក់អំពក្អម តម្កល់ទុកក្នុងកាដន៍តូចហើយអង្គុយ តម្កល់ចិត្តមាំ ក្នុងខណៈនោះ ៗ ខ្ញុំឃើញនូវខន្ធទាំងឡាយ ជាមិនទៀងផង ជាទុក្ខផង ជាអនត្តាផង បានញ៉ាំងអាសវៈទាំងពួងឲ្យអស់ ហើយដល់ព្រះអរហត្ត ៗ គ្រានោះ មានភិក្ខុនីទាំងឡាយ មកសួររកទឹកក្ដៅ ខ្ញុំក៏បានអធិដ្ឋានតេជោធាតុ ហើយញ៉ាំងទឹកឲ្យក្ដៅយ៉ាងរហ័ស ៗ

វិម្ហិតា តា ជិនវរំ ឯតមត្ថមសាវយុំ
តំ សុត្វា មុទិតោ នាថោ ឥមំ គាថំ អភាសថ ។
យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វីរិយារភតោ ទឡ្ហំ ។
អារាធិតោ មហាវីរោ មយា(១) សុប្បដិបត្តិយា
អារទ្ធវីរិយានក្កំ មមាហ ស មហាមុនិ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. មម ។

ភិក្ខុនីទាំងនោះស្ងៀម ហើយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះ
ជិនស្រីដ៏ប្រសើរ ព្រះពុទ្ធជាទីពឹងនៃសត្វលោក ទ្រង់ព្រះ
សណ្ដាប់សេចក្ដីនោះហើយ ក៏រីករាយ ត្រាស់គាថានេះថា
បុគ្គលណាមួយ ជាអ្នកខ្ជិលច្រអូស មានព្យាយាមថោកថយ
គប្បីរស់នៅអស់មួយរយឆ្នាំ ជីវិតរបស់បុគ្គលដែលមានព្យា-
យាមប្រារព្ធមាំ រស់នៅតែមួយថ្ងៃ ប្រសើរជាង ។ ព្រះ
មហាមុនី មានព្យាយាមធំ ខ្ញុំបានធ្វើឲ្យរីករាយហើយ ដោយ
សេចក្ដីប្រតិបត្តិដ៏ប្រពៃ ហើយទ្រង់ត្រាស់ថា ខ្ញុំជាស្រីប្រសើរ
ផុត ជាងភិក្ខុនីទាំងឡាយ អ្នកមានព្យាយាមប្រារព្ធហើយ ។
កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំ
គាស់រំលើងចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបាន
កាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់ទន្លីង ។ ឱ! ខ្ញុំមកល្អ
ហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ ខ្ញុំ
បានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សោណា ភិក្ខុនី ឥមា គាថា-
យោ អភាសិត្ថាតិ ។

សោណាថេរីយាបទានំ សមត្តំ ។

## សត្តមំ ភទ្ទកាបិលានីថេរីយាបទានំ

[២៧] បទុមុត្តរោ នាម ជិនោ សព្វធម្មាន បារគូ(១)

ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ។

តទា ហិ(២) ហំសវតិយំ វិទេហោ នាម នាមតោ

សេដ្ឋី បហូតរតនោ តស្ស ជាយា អហោសហំ ។

កទាចិ សោ នរាទិច្ចំ ឧបេច្ច សបរិជ្ជនោ

ធម្មំ អស្សោសិ ពុទ្ធស្ស សព្វទុក្ខក្ខយាវហំ ។

---

១ ឱ. ម. សព្វធម្មេសុ បក្កុមា ។ ២ ឱ. ម. តទាហុ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសោណាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោណាថេរិយាបទាន ។

## ភទ្ទកាបិលានីថេរិយាបទាន ទី ៧

(២៧) ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កើតឡើងក្នុងកប្បទីមួយសែន អំពីកប្បនេះ ។ កាលនោះ សេដ្ឋីឈ្មោះវិទេហៈ មានកេរ្តិ៍ច្រើន នៅក្នុងក្រុងហង្សវតី ខ្ញុំជាប្រពន្ធនៃសេដ្ឋីនោះ ។ ក្នុងកាលមួយ សេដ្ឋីនោះ ព្រមទាំងជនជាបរិស័ទចូលទៅគាល់ព្រះពុទ្ធ ជាព្រះអាទិត្យរបស់នរជន ហើយស្តាប់ធម៌របស់ព្រះពុទ្ធ ជាទីនាំមកនូវការអស់ទៅ នៃទុក្ខទាំងពួង ។

សាវកំ ធុតវាទានំ អគ្គំ កិត្តេសិ នាយកោ
សុត្វា សត្តាហិកំ ទានំ ទត្វា ពុទ្ធស្ស តាទិនោ ។
និបច្ច សិរសា បាទេ តំ ឋានំ អភិបត្ថយឹ
ស ហាសយន្តោ បរិសំ តទា ហិ(១) នរបុង្គវោ ។
សេដ្ឋោ អនុកម្បាយ ឥមា គាថា អភាសថ
លច្ឆសេ បត្ថិតំ ឋានំ និព្ពុតោ ហោហិ បុត្តក ។
សតសហស្សេ ឥតោ កប្បេ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា ឱរសា ធម្មនិម្មិតា
កស្សបោ នាម នាមេន ហេស្សតិ សត្ថុសាវកោ ។
តំ សុត្វា មុទិតោ ហុត្វា យាវជីវំ តទា ជិនំ
មេត្តចិត្តោ បរិចរិ បច្ចយេហិ វិនាយកំ ។

---

១ ឱ. ម. តទាហ ។

ព្រះពុទ្ធជានាយក ទ្រង់សរសើរនូវសាវ័ក ថាជាអ្នកប្រសើរជាងភិក្ខុទាំងឡាយ អ្នកពោលពាក្យជាគ្រឿងកំចាត់បង់ នូវកិលេស ។ ខ្ញុំបានស្តាប់ហើយ ថ្វាយទានដល់ព្រះពុទ្ធជាតាទិបុគ្គល អស់ ៧ ថ្ងៃ ។ ខ្ញុំក្រាបទៀបព្រះបាទាដោយសិរ្សៈ ប្រាថ្នាតំណែងនោះ គ្រានោះ ព្រះអង្គជាអ្នកធ្លើមជាងនរៈ ទ្រង់ញុំាងបរិស័ទឲ្យរីករាយ ហើយទ្រង់ត្រាស់គាថាទាំងនេះ ដើម្បីអនុគ្រោះសេដ្ឋីថា ម្នាលកូន អ្នកនឹងបានតំណែងដែលអ្នកប្រាថ្នាហើយ អ្នកចូរបានរំលត់ទុក្ខចុះ ។ ក្នុងកប្បទីមួយ សែនអំពីកប្បនេះ ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងត្រាស់ឡើងក្នុងលោក ។ សេដ្ឋីនោះ នឹងបានជាញាតិក្នុងធម៌ទាំងឡាយ នៃព្រះសាស្តានោះ ជាឱរស ជាធម្មនិម្មិត ជាសាវ័កនៃព្រះសាស្តា មានឈ្មោះថាកស្សប ។ កាលនោះ ខ្ញុំបានស្តាប់ព្យាករណ៍នោះហើយ ក៏រីករាយមានចិត្តប្រកបដោយមេត្តា បម្រើព្រះជិនស្រី ព្រះអង្គជានាយកនៃសត្វលោក ដោយបច្ច័យទាំងឡាយ ដរាបដល់អស់ជីវិត ។

## សត្តមំ ភទ្ទកាបិលានីថេរិយាបទានំ

សាសនំ ជោតយិត្វាន សោ មទ្ទិត្វា កុតិត្ថិយេ
វេនេយ្យំ វិនយិត្វាន(១) និព្វុតោ សោ សសាវកោ ។
និព្វុតេ តម្ហិ លោកគ្គេ បូជនត្ថាយ សត្ថុនោ
ញាតិមិត្តេ សមានេត្វា សហ តេន អការយិ ។
សត្តយោជនិកំ ថូបំ ឧព្វេធំ រតនាមយំ
ជលន្តំ សតរំសីវ សាលរាជំវ ផុល្លិតំ ។
សត្តសតសហស្សានិ បាតិយោ(២) សត្ត ការយឹ
នឡគ្គិ វិយ ជោតន្តេ រតនេហេវ សត្តហិ ។
គន្ធតេលេហិ បូរេត្វា ទីបានុជ្ជលយឹ តហឹ
បូជនត្ថាយ មហេសិស្ស សព្វសត្តានុកម្បិនោ ។
សត្តសតសហស្សានិ បុណ្ណកុម្ភានិ ការយឹ
រតនេហេវ បុណ្ណានិ បូជនត្ថាយ មហេសិនោ ។
មជ្ឈេ អដ្ឋដ្ឋកុម្ភីនំ ឧស្សិតា កញ្ចនគ្ឃិយោ
អតិរោចន្តិ វណ្ណេន សារទេវ ទិវាករេ ។

---

១ ឱ. វេនេយ្យេ វិនយិត្វា សោ ប ។ ម. វេនេយ្យំ វិនយិត្វា ប ។ ២ ឱ. ម. បាតិយោ ។

## ភទ្ទាកាបិលានីថេរិយាបទាន ទី ៣

ព្រះពុទ្ធវង្គនោះ ញុំាងសាសនាឲ្យរុងរឿង ញាំញីនូវតិរ្ថិយ អាក្រក់ទាំងឡាយ ទូន្មាននូវវេនេយ្យសត្វ ព្រះអង្គព្រមទាំង សាវ័កបរិនិព្វានហើយ ។ កាលព្រះមានព្រះភាគ ជាកំពូល នៃសត្វលោកនោះនិព្វានហើយ មហាជនបានប្រជុំញាតិនិង មិត្ត មួយអន្លើដោយសាវ័កទាំងឡាយនោះ បានញុំាងជនឲ្យ ធ្វើព្រះស្តូបជាវិការៈនៃកែវ កម្ពស់ ៧ យោជន៍ ដ៏រុងរឿង ដូចព្រះអាទិត្យ ឬដូចស្តេចឈើមានផ្ការីក ដើម្បីបូជាព្រះ សាស្តា ។ ខ្ញុំបានឲ្យគេសាងកាជន៍ ៧ អស់ទ្រព្យ ៧ សែន កាជន៍ទាំងនោះ រុងរឿងដោយកែវ ៧ ដូចភ្លើងឆេះបបុះ ។ ខ្ញុំញុំាងប្រទីបទាំងនោះឲ្យពេញដោយប្រេងក្រអូប ហើយអុជ បំភ្លឺក្នុងទីនោះ ដើម្បីបូជាព្រះពុទ្ធ ទ្រង់ស្វែងរកគុណធំ ទ្រង់ អនុគ្រោះដល់សត្វទាំងពួង ។ ខ្ញុំសាងក្អមដ៏ពេញចំនួន ៧ សែន ដ៏ពេញដោយកែវ ៧ ដើម្បីបូជាដល់ព្រះពុទ្ធ ទ្រង់ ស្វែងរកគុណដ៏ធំ ។ គ្រឿងបូជាជាវិការៈនៃមាស ដែល បុគ្គលលើកឡើងហើយ ក្នុងកណ្តាលនៃក្អមប្រាំបី ៗ ដ៏រុង រឿងដោយសម្បុរ ដូចជាព្រះអាទិត្យ ក្នុងសរទសម័យ ។

ចតុទ្វារេសុ សោភន្តិ តោរណា រតនាមយា
ឧស្សិតា ជលកា រម្មា សោភន្តិ រតនាមយា ។
វិរោចន្តិ បរិក្ខាយោ(១) អវដំសា សុនិម្មិតា
ឧស្សិតានិ បដាកានិ រតនានិ វិរោចរេ ។
សុវត្តំ សុកតញ្ចេតំ ចេតិយំ រតនាមយំ
អតិរោចតិ វណ្ណេន សសដ្ឋាវ ទិវាករោ ។
ថូបស្ស មេ ទិសា តិស្សោ ហរិតាលេន បូរយឹ
ឯកា មនោសិលាយេកា អញ្ជនេន ច ឯកិកា ។
បូជំ ឯតាទិសំ រម្មំ ការេត្វា វរវាទិនោ
អទាសឹ ទានំ សង្ឃស្ស យាវជីវំ យថាពលំ ។
សហាហំ(២) សេដ្ឋិនា តេន តានិ បុញ្ញានិ សព្វសោ
យាវជីវំ ករិត្វាន សហាវ សុគតឹ គតា(៣) ។

១ ឱ ម. បរិក្ខិត្តា ។ ២ ម. សហាវ ។ ៣ ឱ. អហំ ។

ក្លោងទ្វារជាវិការៈនៃកែវល្អក្នុងទ្វារទាំង ៤ ផែនក្តារជាវិការៈនៃកែវជាទីរីកពាយ ដែលបុគ្គលលើកឡើងហើយក៏ល្អ ៗ របងទាំងឡាយមានកំពូល ដែលបុគ្គលតាក់តែងល្អរុងរឿង ទង់ទាំង-ឡាយជាវិការៈនៃកែវ ដែលបុគ្គលលើកឡើងហើយក៏រុងរឿង ៗ ចេតិយនេះ ជាវិការៈនៃកែវ មានសម្បុរក្រហមល្អ ដែលបុគ្គលធ្វើហើយដោយប្រពៃ រុងរឿងដោយសម្បុរ ដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃល្ងាច ៗ ខ្ញុំបានញុំាងទិសទាំង ៣ នៃព្រះស្តូបរបស់ខ្ញុំ ឲ្យពេញ គឺទិសមួយ ពេញដោយថ្មហរិតាល ទិសមួយ ពេញដោយថ្មមនោសិលា ទិសមួយ ពេញដោយថ្មមានពណ៌ខៀវ ៗ ខ្ញុំបានញុំាងជនឲ្យធ្វើនូវការបូជា ជាទីរីកពាយប្រាកដដូចទុំ ដល់ព្រះពុទ្ធមានវាទៈដ៏ប្រសើរ ហើយឲ្យទានដល់ព្រះសង្ឃ តាមសមគួរដល់កម្លាំង ដរាបដល់អស់ជីវិត ៗ ខ្ញុំធ្វើបុណ្យទាំងនោះ ដោយសព្វគ្រប់ ជាមួយនឹងសេដ្ឋីនោះ ដរាបដល់អស់ជីវិត ហើយក៏បានទៅកាន់សុគតិ ជាមួយគ្នា ៗ

## សត្តមំ ភទ្ទកាបិលានីថេរិយាបទានំ

សម្បត្តិយោនុភុត្វាន[១]    ទេវត្តេ អថ មានុសេ
ឆាយា វិយ សរីរេន    សហ តេនេវ សំសរឹ ។
ឯកនវុតេ ឥតោ កប្បេ    វិបស្សី នាម នាយកោ
ឧប្បជ្ជិ ចារុនយនោ    សព្វធម្មវិបស្សកោ ។
តទា ហិ ពន្ធុមតិយា    ព្រាហ្មណោ សាធុសម្មតោ
អឌ្ឍោ សន្តោ គុណោ ចាសិ    ធនេន ច សុទុគ្គតោ ។
តទាបិ[២] តស្សាហំ អាសិ    ព្រាហ្មណី សមចេតសា
កទាចិ សោ ទិជវរោ    សង្គមេសិ មហាមុនឹ ។
និសិន្នំ ជនកាយម្ហិ    ទេសេន្តំ អមតំ បទំ
សុត្វា ធម្មំ បមុទិតោ    អទាសិ ឯកសាដកំ ។
ឃរំ ឯកេន វត្ថេន    គន្ត្វានេតំ មមព្រវិ[៣]
អនុមោទ មហាបុញ្ញ    ទិន្នំ ពុទ្ធស្ស សាដកំ ។

---

១ ឱ. ម. សម្បត្តិយោនុភោត្វាន ។ ២ ឱ. តទា ហិ ។ ៣ ម. ស មព្រវិ ។

## កន្ទុកាបិណ្ឌិយត្ថេរិយាបទាន ទី ៣

ខ្ញុំបានសោយសម្បត្តិទាំងឡាយ ក្នុងអត្តភាពជាទេវតា និងមនុស្ស អន្ទោលទៅជាមួយនឹងសេដ្ឋីនោះ ដូចជាស្រមោលអន្ទោលទៅតាមសរីរៈ ។ ក្នុងកប្បទី៩១អំពីកប្បនេះ ព្រះពុទ្ធជានាយក ទ្រង់ព្រះនាមវិបស្សី មានព្រះនេត្រដូចមាសពិចារណាឃើញច្បាស់នូវធម៌ទាំងពួង ទ្រង់កើតឡើង ។ គ្រានោះ មានព្រាហ្មណ៍ម្នាក់ក្នុងក្រុងពន្ធុមតី គេសន្មតថាជាសប្បុរស ជាអ្នកមាំមួន ស្ងប់ស្ងាត់ដោយគុណ តែជាអ្នកខ្វះត្រទ្រព្យក្រៃពេក ។ កាលនោះ ខ្ញុំជាព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មានចិត្តស្មើគ្នា ជូនកាលព្រាហ្មណ៍ ប្រសើរនោះបានគប់រកព្រះមហាមុនី ដែលគង់សម្តែងអមតនិព្វានក្នុងពួកជន គាត់បានស្តាប់ធម៌ ក៏មានចិត្តរីករាយ បានថ្វាយសំពត់សាដកមួយ ហើយទៅកាន់ផ្ទះដោយសំពត់មួយ ហើយពោលពាក្យនេះនឹងខ្ញុំថា ម្នាលនាងមានបុណ្យធំ នាងចូររីករាយចំពោះសំពត់សាដក ដែលបងបានថ្វាយ ដល់ព្រះពុទ្ធចុះ ។

តទាហំ អញ្ជលឹ កត្វា អនុមោទឹ សុវិទិតា(១)
សុទិន្នា សាដកោ សាមិ ពុទ្ធសេដ្ឋស្ស តាទិនោ ។

សុខិតោ សជ្ជិតោ ហុត្វា សំសរន្តោ ភវាភវេ
ពារាណសីបុរេ រម្មេ រាជា អាសិ មហីបតិ ។

តទា តស្ស មហេសីហំ ឥត្ថី កុម្ពស្ស ឧត្តមា
តស្សាបិ ទុតិយិកា អាសិ បុត្វសិនេហេន ឧត្តរិ(២) ។

បិណ្ឌាយ វិចរន្តោ សោ អដ្ឋ បច្ចេកនាយកោ
ទិស្វា បមុទិតោ ហុត្វា ទត្វា បិណ្ឌំ មហារហំ ។

ពុទ្ធេ(៣) និមន្តយិត្វាន កត្វា រតនមណ្ឌបំ
កម្មារេហិ កតមដ្ឋំ(៤) សោវណ្ណំ សតហត្ថកំ(៥) ។

---

១ ឱ. ម. សុបីណិតា ។ ២ ឱ. បុត្តស្នេហេន ឧត្តរឹ ។ ម. បុត្ត ស្នេហេន ពុត្តរិ ។ ៣ ឱ. បុនោ ។ ម. បុន ។ ៤ ឱ. ម. កតំ បត្តំ ។ ៥ ឱ. ម. វិត តត្តកំ ។

កាលនោះ ខ្ញុំដឹងច្បាស់ បានធ្វើអញ្ជលីអនុមោទនាថា បពិត្រស្វាមី ខ្ញុំសូមអនុមោទនាសាដកដែលអ្នកថ្វាយហើយដោយប្រពៃដល់ព្រះពុទ្ធដ៏ប្រសើរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។ ប្តីនៃខ្ញុំនោះ ដល់ហើយនូវសេចក្តីសុខ ត្រូវបុញ្ញកម្មបាត់បែង កាលអន្ទោលទៅ ក្នុងភពតូច និងភពធំ បានកើតជាស្តេចម្ចាស់ផែនដីក្នុងក្រុងពារាណសី ជាទីរីករាយ ។ កាលនោះ ខ្ញុំជាមហេសីនៃស្តេចនោះ ជាអ្នកខ្ពង់ខ្ពស់ជាងពួកស្រី ហើយជាអគ្គមហេសី ដ៏ប្រសើរក្រៃលែងជាងសេចក្តីស្រឡាញ់នៃស្តេចនោះ ដែលមានក្នុងភពមុន ។ ស្តេចនោះ ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ និមន្តទៅដើម្បីបិណ្ឌបាត ក៏មានចិត្តរីករាយ ប្រគេនចង្ហាន់បិណ្ឌបាតមានថ្លៃច្រើន ។ ស្តេចនោះ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ហើយធ្វើបាំងកែវជាវិការៈនៃមាស មានប្រមាណ ១០០ ហត្ថ មានសណ្ឋានរលីង ដែលពួកជាងធ្វើហើយ ។

## សត្តមំ ភទ្ទកាបិលានីថេរីយាបទានំ

សមានេត្វាន តេ សព្វេ តេសំ ធនមទាសិ សោ
សោធាសនេ(១) បរិដ្ឋានំ បសន្នោ សេហិ បាណិភិ
តំបិ ធនំ សមាទាសឹ កាសិកោ ជនបទ្ទធា
បុធាហំ(២) ពារាណសិយំ ជាតា កាសិកគាមកេ(៣)
កុដុម្ពិកកុលេ ផីតេ សុខិតោ សោ សភាតុកោ
ជេដ្ឋស្ស ភាតុនោ ជាយា អហោសឹ សុបតិព្វតា ។
បច្ចេកពុទ្ធំ ទិស្វាន មម ភត្តកនិយសោ(៤)
ភាតុ ភត្តំ(៥) តស្ស ទត្វា(៦) អាគតេ តម្ហិ ចាវទិ(៧) ។
នាភិនន្ទិ សោ ទានំ តតោ តស្ស អទាសហំ
ពុទ្ធាធានិយ(៨) តំ អន្នំ បុនោ តស្សេវ សោ អទា ។
តំ ធានំ(៩) ឆឌ្ឌយិត្វាន ទុដ្ឋា ពុទ្ធស្សហំ តទា
បត្តំ កលលបុណ្ណំ អទាសិ តស្ស តាទិនោ ។

---

១ ឱ សោវណ្ណសនេ ។ ម. សោណ្ណសនេ ។ ២ ឱ. បុគោបិ ។ ៣ ឱ. អជាយឹ ទ្វារគាមកេ ។ ម. ភជាបិ ទ្វារគាមកេ ។ ៤ ឱ. ភាតុកនិយសោ ។ ម ភត្តាទនិយសោ ។ ៥ ឱ. ភាតំ តំ ។ ម. ភាគានំ ។ ៦ ឱ. ទត្វាហំ ។ ម. ទត្វាន ។ ៧ ឱ. ម. បាវទី ។ ៨ ម. ឧទាអានិយ ។ ៩ ឱ. ម. តទន្នំ ។

## ភទ្ទកាបិលានីថេរិយាបទាន ទី ៣

ព្រះរាជានោះ ទ្រង់រាប់អានព្រះបច្ចេកពុទ្ធទាំងអស់នោះ មានសេចក្តីជ្រះថ្លា ហើយបានថ្វាយទាន ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ដែលចូលទៅកាន់ទីសេនាសនៈ ដោយព្រហស្តនៃព្រះអង្គ ។ កាលនោះ ខ្ញុំបានឲ្យទាននោះ ជាមួយនឹងស្តេចក្នុងដែនកាសី ខ្ញុំកើតក្នុងកាសិកគ្រាម ជិតក្រុងពារាណសីម្តងទៀត ។ ស្តេចនោះ កើតក្នុងត្រកូលកុដុម្ពិកៈដ៏ធំទូលាយ ដល់នូវសេចក្តីសុខ ព្រមទាំងបងប្អូន ខ្ញុំជាប្រពន្ធនៃបងច្បង ជាស្រីមានវត្តដល់ប្តីដោយប្រពៃ ។ ប្អូនរបស់ប្តីខ្ញុំ បានឃើញព្រះបច្ចេកពុទ្ធហើយ ប្រគេនភត្តរបស់បងដល់ព្រះបច្ចេកពុទ្ធនោះ កាលបើបងនោះត្រឡប់មក ខ្ញុំបាននិយាយប្រាប់សព្វគ្រប់ ។ បងនោះ មិនត្រេកអរចំពោះទាន លំដាប់នោះ ខ្ញុំបានឲ្យភត្តដល់ប្តីនោះ ប្តីនោះ នាំបាយនោះ ហើយថ្វាយដល់ព្រះពុទ្ធនោះទៀត ។ កាលនោះ ខ្ញុំចោលនូវទាននោះហើយ ប្រទុស្តចំពោះព្រះពុទ្ធ ខ្ញុំបានឲ្យបាត្រដ៏ពេញដោយភក់ដល់ព្រះពុទ្ធនោះ ទ្រង់មិនញាប់ញ័រដោយលោកធម៌ ។

ទានេ ច គហណេ ចេវ  អបរេ បទុសេបិច
សមចិត្តមុខំ ទិស្វា  តទាហំ សំវិធី(១) កុសំ ។
បុនោ បត្តំ គហេត្វាន  សោធយិត្វា សុគន្ធិនា
បសន្នចិត្តា បូរេត្វា  សយតំ សក្ការំ អទំ ។
យត្ថ យត្ថុបបជ្ជាមិ  សុរូបា ហោមិ ទានតោ
ពុទ្ធស្ស អបការេន  ទុគ្គា មទនេន(២) ច ។
បុនោ កស្សបវីរស្ស  និដ្ឋាបិតម្ហិ(៣) ចេតិយេ
សោវណ្ណំ ឥដ្ឋកំ វរំ(៤)  អទាសិំ មុទិតា អហំ ។
ចតុជ្ជាតេន គន្ធេន  តេមយិត្វា(៥) តមិដ្ឋកំ
មុត្តា ទុគ្គន្ធទោសម្ហា  សព្វង្គសុសមាគតា ។
សត្តទាតិសហស្សានិ  រតនេហិ ច(៦) សត្តហិ
ការេត្វា យតប្បភានិ  វដ្ដីនិ ច សហស្សសោ(៧) ។
បក្ខិបេត្វា បទីបេត្វា  ឋបយឹ សត្ថុ បន្តិយោ
បូជនត្ថំ លោកនាថស្ស  វិប្បសន្នេន ចេតសា ។

---

១ ឱ. មហាសត្ថុំ បធឹ ។ ២ ឱ. ម. វិវនេន ។ ៣ ឱ. និដ្ឋាយន្តម្ហិ ។ ម. និដ្ឋាយន្តម្ហិ ។ ៤ ម. សោវណ្ណឥដ្ឋកាមយំ ។ ៥ ឱ. ម. និបយិត្វា ។ ៦ ឱ. ម. រតនេហេវ ។ ៧ ឱ. ម. សហស្សយោ ។

កាលនោះ ខ្ញុំឃើញព្រះពុទ្ធមានព្រះទ័យស្មើ ក្នុងការឲ្យទានផង ក្នុងការទទួលផង ក្នុងសេចក្តីកោតក្រែងផង ក្នុងសេចក្តីប្រទូស្តផង ហើយសង្កេតក្រៃលែង ។ ខ្ញុំកាន់យកបាត្រមួយទៀត ជំរះដោយគ្រឿងក្រអូប មានចិត្តជ្រះថ្លាញុំាងបាត្រឲ្យពេញ ហើយឲ្យស្អាតព្រមទាំងទឹកដោះថ្លា ។ ខ្ញុំកើតក្នុងទីណា ៗ ជាស្រីមានរូបល្អព្រោះទាននោះ ខ្ញុំជាស្រីមានក្លិនអាក្រក់ ព្រោះប្រទូស្តចំពោះព្រះពុទ្ធផង ព្រោះសេចក្តីស្រវឹងផង ។ កាលចេតិយនៃព្រះពុទ្ធ ព្រះនាមកស្សប ជាអ្នកប្រាជ្ញ គេឲ្យសម្រេចហើយ ខ្ញុំមានចិត្តរីករាយ បានឲ្យឥដ្ឋជាវិការៈនៃមាសដ៏ប្រសើរទៀត ។ ខ្ញុំជ្រលក់ឥដ្ឋនោះឲ្យទទឹកដោយគ្រឿងក្រអូប មានជាតិ ៤ យ៉ាង ក៏បានរួចស្រឡះចាកទោសមានក្លិនអាក្រក់ ប្រកបដោយអវយវៈទាំងពួងដ៏ល្អ ។ ខ្ញុំឲ្យធ្វើភាជន៍ ៧ ពាន់ ដោយកែវ ៧ ប្រការផង ប្រដេះមួយពាន់ដ៏ពេញដោយខ្លាញ់ផង ។ ខ្ញុំមានចិត្តជ្រះថ្លាបានដាក់ប្រេងអុជបំភ្លឺតម្កល់ទុក ៧ ជួរ ដើម្បីបូជាព្រះលោកនាថ ។

## សត្តមំ ភទ្ទកាបិលានីថេរិយាបទានំ

តទាបិ តស្មឹ បុញ្ញស្មឹ ភាគិនីហំ វិសេសតោ
បុនោ កាសីសុ សញ្ជាតោ សមិត្តោ(១) ឥតិ វិស្សុតោ ។
តស្សាហំ ភរិយា អាសឹ សុខិតា សជ្ជិតា បិយា
តទា បច្ចេកមុនិនោ(២) អទាសិ ឃនវេឋនំ ។
តស្សាបិ ភាគិនី អាសឹ មោទិត្វា ញាតមុត្តមំ
បុនាបិ កាសិរដ្ឋម្ហិ ជាតា កោលិយជាតិយា ។
តតោ កោលិយបុត្តានំ សតេហិ សហ បញ្ចហិ
បញ្ច បច្ចេកពុទ្ធានំ សតានិ សមុបដ្ឋហិ(៣) ។
តេមាសំ វាសយិត្វាន(៤) អទាសិ ច តិចីវរំ(៥)
ជាយា តស្ស តទា អាសឹ បុញ្ញកម្មបថានុគា ។
តតោ ចុតា អហុ រាជា នន្ទោ នាម មហាយសោ
តស្សាបិ មហេសី អាសឹ សព្វកាមសមិទ្ធិនី ។

---

១ ឱ. សុមិត្តោ ។ ម. សុមិត្តា ។ ២ ឱ. ម. តទាបិ បច្ចេកមុនេ ។ ៣ ឱ. សមុបដ្ឋហឹ ។
៤ ឱ. តប្បយិត្វាន ។ ៥ ឱ. ម. អទំសុ ច តិចីវរេ ។

## កដុកាបិណ្ឌីថេរិយាបទាន ទី ៧

គ្រានោះ ខ្ញុំជាស្រីមានចំណែកក្នុងបុណ្យនោះ ដោយវិសេស (បុរសនោះ) កើតក្នុងដែនកាសីទៀត ប្រាកដដោយឈ្មោះ ជាសមិទ្ធបុរស ។ កាលនោះ ខ្ញុំជាភរិយាបុរសនោះ ជាអ្នកដល់នូវសេចក្តីសុខ មានគេជាប់ចិត្ត ជាទីស្រឡាញ់នៃជន ឯប្តីខ្ញុំបានប្រគេនឈ្នួតមានសាច់ក្រាស់ ដល់ព្រះបច្ចេកមុនី ។ ម្យ៉ាងទៀត ខ្ញុំជាស្រីមានចំណែកដោយបុណ្យ ត្រេកអរនូវទានដ៏ឧត្តមរបស់ប្តីនោះ ឯបុរសនោះកើតក្នុងជាតិកោលិយ-ជន ក្នុងដែនកាសីទៀត ។ កាលនោះ សមិទ្ធបុរសនោះ បម្រើព្រះបច្ចេកពុទ្ធ ៥០០ អង្គ មួយអន្លើដោយកោលិយបុត្រ ៥០០ នាក់ ។ រួចហើយ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយ ឲ្យគង់នៅអស់ ៣ ខែ ហើយប្រគេនត្រៃចីវរ កាលនោះ ខ្ញុំជាប្រពន្ធនៃសមិទ្ធបុរសនោះ ជាអ្នកប្រព្រឹត្តទៅតាមគន្លងនៃបុញ្ញកម្ម ។ សមិទ្ធបុរសនោះ ច្យុតចាកអត្តភាពនោះ បានកើតជាស្តេចព្រះនាមនន្ទៈ មានយសធំ ខ្ញុំជាមហេសីនៃស្តេចនោះ ជាអ្នកសម្រេចនូវសេចក្តីប្រាថ្នាទាំងពួង ។

តតោ អហុ ចវិត្វាន(១) ព្រហ្មទត្តោ មហីបតិ
បទុមាវតិបុត្តានំ បច្ចេកមុនិនំ តទា ។
សតានិ បញ្ចន្នានិ យាវជីវំ ឧបដ្ឋហឹ
រម្មុយ្យានេ និវាសេត្វា និព្វានានិ ច បូជយឹ ។
ចេតិយានិ ច ការេត្វា បព្វជិត្វា ឧភោ មយំ
ភាវេត្វា អប្បមញ្ញាយោ ព្រហ្មលោកំ អគម្ហសេ ។
តតោ ចុតោ មហាតិត្ថេ សុជាតោ បិប្ផលាយនោ
មាតា សុមនទេវី ច កោសិគោត្តោ ទិជោ បិតា ។
អហំ មទ្ទេ ជនបទេ សាកលាយំ(២) បុរុត្តមេ
កបិលស្ស ទិជស្សាសឹ ធីតា មាតា សុចិមតិ ។
ឃនកញ្ចនពិម្ពេន និម្មិនិត្វាន មំ បិតា ។
អទា កស្សបធីរស្ស កាមេហិ វជ្ជិតស្ស ច(៣)
កទាចិ សោ ការុណិកោ គន្ត្វា កម្មន្តបេក្ខកោ
កាកាទិកេហិ ខជ្ជន្តេ បាណេ ទិស្វាន សំវិជិ ។

---

១ ឱ, តតោ ចុតោ ភវិត្វាន ។ ម. តតោ រាជា ភវិត្វាន ។ ២ ឱ. សាគលាយំ ។ ម. សាកលាយ ។ ៣ ឱ. កាមាសា វជ្ជិតស្ស មេ ។ ៤ ឱ. ម. ការុណិកោ ។

លុះច្យុតអំពីអត្តភាពនោះហើយ បានកើតជាស្តេចព្រហ្មទត្ត ជាម្ចាស់ផែនដី កាលនោះ ខ្ញុំបម្រើព្រះបច្ចេកមុនី ជាបុត្រនៃនាងបទុមាវតី ។ ខ្ញុំបម្រើព្រះបច្ចេកមុនី ៥០០ អង្គ ដរាបដល់អស់ជីវិត ហើយនិមន្តព្រះបច្ចេកមុនីទាំងឡាយ ឲ្យនៅក្នុងឧទ្យាននៃស្តេច ហើយបូជានូវព្រះបច្ចេកមុនីទាំងឡាយ ដែលនិព្វានហើយ ។ យើងទាំងពីរនាក់ បានឲ្យជាងធ្វើចេតិយទាំងឡាយ ហើយបួសចម្រើនអប្បមញ្ញាទាំងឡាយ ក៏បានទៅកើតក្នុងព្រហ្មលោក ។ លុះច្យុតចាកព្រហ្មលោក ប្តីកើតក្នុងមហាតិត្ថៈ ជាកូនចៅនៃបិប្ផលគោត្រ ឯមាតាឈ្មោះសុមនទេវី បិតាជាព្រាហ្មណ៍កោសិគោត្រ ។ ខ្ញុំ (កើត) ក្នុងក្រុងសាគលា ជាបុរីដ៏ឧត្តម ក្នុងជនបទឈ្មោះមទ្ទៈ ។ ខ្ញុំជាធីតានៃកបិលព្រាហ្មណ៍ មាតាឈ្មោះសុចិមតី បិតាស្អិតស្អាងខ្ញុំ ដោយរូបភាពជាវិការៈនៃមាសតាន់ បានឲ្យខ្ញុំដល់កស្សបបណ្ឌិត ជាអ្នកវៀរចាកកាមទាំងឡាយ កាលដែលកស្សបបណ្ឌិតនោះ នៅក្មេង បានទៅមើលការងារ ឃើញសត្វតូច ៗ ត្រូវពួកសត្វមានក្អែកជាដើមចំពាស៊ី ក៏សង្វេគ ។

## សត្តមំ ភទ្ទកាបិលានីថេរិយាបទានំ

ឃរេ ចាហំ តិលេ ជាតេ ទិស្វានាតបតាបនេ
កិមិ កាកេហិ ខជ្ជន្តេ សំវេគមលភិំ តទា ។
តទា សោ បព្ពជី ធីរោ អហំ តំ អនុបព្ពជឹ
បញ្ចវស្សានិ និវសឹ បរិព្ពាជមតេ[១] អហំ ។
យទា បព្ពជិតា អាសិ គោតមី ជិនបោសិកា
តទាហំ តមុបាគន្ត្វា ពុទ្ធេន អនុសាសិតា ។
ន ចិរេនេវ កាលេន អរហត្តំ អបាបុណឹ
អហោ កល្យាណមិត្តត្តំ កស្សបស្ស សិរីមតោ ។
បុត្តោ[២] ពុទ្ធស្ស ទាយាទោ កស្សបោ សុសមាហិតោ
បុព្វេនិវាសំ សោ វេទិ សគ្គាបាយញ្ច បស្សតិ ។
អថោ ជាតិក្ខយំ បត្តោ អភិញ្ញាវោសិតោ មុនិ
ឯតាហិ តីហិ វិជ្ជាហិ តេវិជ្ជោ ហោតិ ព្រាហ្មណោ ។

---

១ ម. បរិព្ពាជវតេ ។ ២ ម. លុពោ ។

## ភទ្ទាកាបិលានីថេរីយាបទាន ទី ៣

ខ្ញុំឃើញគ្រាប់ល្ងទាំងឡាយ ដែលគេហាលក្នុងកំដៅថ្ងៃជិតផ្ទះ ត្រូវពួកជន្លេនិងក្អែកទំពាស៊ី បានទទួលសេចក្ដីសង្វេគ ក្នុងកាលនោះ ។ កាលនោះ កស្សបបណ្ឌិតនោះបួសហើយ ខ្ញុំក៏បួសតាមកស្សបបណ្ឌិតនោះដែរ ខ្ញុំនៅអាស្រ័យក្នុងគន្លងនៃបរិព្វាជកវត្ត អស់ ៥ វស្សា ។ កាលណា នាងគោតមីជាអ្នកចិញ្ចឹមព្រះជិនស្រីបួសហើយ កាលនោះ ខ្ញុំក៏ចូលទៅរកនាងគោតមីនោះ ដែលព្រះពុទ្ធប្រៀនប្រដៅហើយ ។ អស់កាលមិនយូរប៉ុន្មាន ខ្ញុំក៏បានដល់ព្រះអរហត្ត ឱហ្ន៎ ! ព្រះកស្សបមានសិរីជាមិត្តល្អ ។ ព្រះកស្សបជាកូន ជាញាតិនៃព្រះពុទ្ធ មានចិត្តតម្កល់ខ្ជាប់ហើយ ដោយប្រពៃ លោកដឹងនូវបុព្វេនិវាសផង ឃើញនូវឋានសួគ៌និងអបាយផង ។ ម្យ៉ាងទៀត ព្រះកស្សបនោះ ជាអ្នកប្រាជ្ញ មានអភិញ្ញានៅរួចហើយ បានដល់នូវការអស់ទៅនៃជាតិ ជាខីណាសវ-ព្រាហ្មណ៍ មានវិជ្ជា ៣ ដោយវិជ្ជាទាំង ៣ នេះ ។

តថេវ ភទ្ទកាបិលានី តេវិជ្ជា មច្ចុហាយិនី
ធារេន្តី អន្តិមំ ទេហំ ជេត្វា មារំ សវាហនំ ។
ទិស្វា អាទីនវំ លោកេ ឧភោ បព្ពជិតា មយំ
តយម្ហា(១) ខីណាសវា ទន្តា សីតិភូតាម្ហ និព្វុតា ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភទ្ទកាបិលានី ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

ភទ្ទកាបិលានីថេរិយាបទានំ សមត្តំ ។

---

១ ឱ. អម្ហ ។ ម. ត្យម្ហិ ។

## សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

ភទ្ទកាបិលានី មានវិជ្ជា ៣ លះបង់មច្ចុ ទ្រទ្រង់រាងកាយ មានក្នុងទីបំផុត ឈ្មោះមារព្រមទាំងពាហនៈ ដូចគ្នាដែរ ។ យើងទាំងពីរនាក់ ឃើញទោសក្នុងលោកហើយបួស យើងទាំងពីរនាក់នោះ មានអាសវៈអស់ហើយ មានខ្លួនទូន្មានហើយ មានសេចក្តីត្រជាក់កើតហើយ មានទុក្ខរំលត់ហើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំនង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភទ្ទកាបិលានីភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភទ្ទកាបិលានីថេរិយាបទាន ។

# អដ្ឋមំ យសោធរាថេរិយាបទានំ

(២៨) បុរក្ខតា ភិក្ខុនីហិ សតេហិ សហស្សេហិ សា(១)
មហិទ្ធិកា មហាបុញ្ញា សម្ពុទ្ធំ ឧបសង្កមិ ។
សម្ពុទ្ធំ អភិវាទេត្វា សត្ថុនោ ចក្កលក្ខណោ
និសិន្នា ឯកមន្តម្ហិ ឥទំ វចនមព្រវី ។
អដ្ឋសត្តតិវស្សាហំ បច្ឆិមា វត្តយិ វយា
បព្ភារម្ហិ(២) អនុប្បត្តា អារោចេមិ មហាមុនិ ។
បរិបក្កា វយោ មយ្ហំ បរិត្តំ មម(៣) ជីវិតំ
បហាយ វោ គមិស្សាមិ កតំ មេ(៤) សរណមត្តនោ ។
វយម្ហិ(៥) បច្ឆិមេ កាលេ មរណំ ឧបរុន្ធតិ
អជ្ជ រត្តឹ មហាវីរ បាបុណិស្សាមិ និព្ពុតឹ ។
នត្ថិ ជាតិ ជរា ព្យាធិ មរណញ្ច មហាមុនេ
អជរាមរាភយបុរំ(៦) គមិស្សាមិ អសង្ខតំ ។
យាវតា បរិសា នាម សមុទាសន្តិ(៧) សត្ថុនោ
អបរាធំ បជានន្តិ ខមន្តុ សម្មុខា មុនេ ។

---

១ ឱ. សហ បញ្ចហិ ។ ២ ឱ. បព្ភារម្ហិ ។ ៣ ឱ. អថ ។ ៤ ម. មេ សរៈត្តា នត្ថិ ។ ៥ ឱ. វយោ ប ។ ៦ ឱ. ម. អជរា មរណំ បុរំ ។ ៧ ឱ. សមុបយាតិ ។

# យសោធរាថេរីយាបទាន ទី ៨

(៦៨) ខ្ញុំជាអ្នកមានឫទ្ធិច្រើន មានប្រាជ្ញាច្រើន មាននាងភិក្ខុនីទាំងឡាយ មួយសែនអង្គ ហោមរោមហើយ ចូលទៅគាល់ព្រះសម្ពុទ្ធ ៗ ថ្វាយបង្គំព្រះសម្ពុទ្ធនិងលក្ខណៈគឺចក្រនៃព្រះសាស្តា អង្គុយក្នុងទីសមគួរ ហើយពោលពាក្យនេះថា ខ្ញុំមានវស្សា ៧៨ ក្នុងបច្ឆិមវ័យ ខ្ញុំមកដល់ញកហើយ ក្រាបទូលព្រះមហាមុនីថា វ័យរបស់ខ្ញុំ ចាស់ណាស់ហើយ ជីវិតរបស់ខ្ញុំតិចណាស់ ខ្ញុំនឹងលះបង់ព្រះអង្គហើយទៅ ទីពឹងរបស់ខ្លួនខ្ញុំបានធ្វើហើយ ៗ ក្នុងកាលជាបច្ឆិមវ័យ សេចក្តីស្លាប់កាន់តែកៀកចូលមកជិត បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំម្ចាស់នឹងដល់នូវនព្វានក្នុងវេលាយប់ថ្ងៃនេះ ៗ បពិត្រព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ មិនមាន ខ្ញុំនឹងដល់ នូវបុរីដែលជាទីឥតមានជរា ឥតមានមរណៈ ឥតមានភ័យមិនមានបច្ច័យតាក់តែងឡើយ ៗ បពិត្រព្រះមហាមុនី ធម្មតាបរិស័ទទាំងឡាយ តែងចូលទៅអង្គុយជិតព្រះសាស្តា ដឹងច្បាស់នូវកំហុស និងសេចក្តីគួរក្នុងទីចំពោះព្រះភក្ត្រ ៗ

សំសរិត្វា ច(១) សំសារេ   ខលិតញ្ច មមន្តយិ(២)
អាកោចេមិ មហាវីរ   អបកជំ ខមស្សុ មេ ។
ឥទ្ធិញ្ចាបិ និទស្សេហិ   មម សាសនការិកា(៣)
បរិសានញ្ច សព្វាសំ   កង្ខំ ឆិន្ទស្សុ សាសនេ(៤) ។
យសោធរា អហំ វីរ   អគារេ តេ បជាបតិ
សាកិយម្ហិ កុលេ ជាតា   ឥត្ថី អង្គេ បតិដ្ឋិតា ។
ជីនំ សតសហស្សានំ   ឆវុតីនំ ឆឡុត្តរិ(៥)
អគារេ តេ អហំ វីរ   ធាមោក្ខា សព្វិស្សរា ។
រូបាចារគុណូបេតា   យោព្វនដ្ឋាបិ សព្វទា
សព្វា មំ អបចាយន្តិ   ទេវតា វិយ មានុសា ។
កញ្ញាសហស្សបមុខា   សក្យបុត្តនិវេសនេ
សមានសុខទុក្ខា តា   ទេវតា វិយ នន្ទនេ ។

---

១ ឱ. សំសរន្តញ្ច ។ ២ ឱ. តរំ មយិ ។ ៣ ឱ. ម. សាសនការិកេ ។ ៤ ម. យាវតា ។
៥ ម. ឆទុត្តរិ ។

បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គអន្ទោលទៅ ក្នុងសំសារ សូមក្រាបទូលនូវការភ្លាំងភ្លាត់របស់ខ្ញុំ ចំពោះព្រះអង្គ សូមព្រះអង្គអត់នូវកំហុសនោះ ដល់ខ្ញុំព្រះអង្គ ។ នាងជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃតថាគត ចូរនាងសម្តែងនូវឫទ្ធិ ចូរកាត់នូវសេចក្តីសង្ស័យ នៃបរិស័ទទាំងពួង ក្នុងសាសនា ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំឈ្មោះយសោធរា ជាភរិយានៃព្រះអង្គ (កាលនៅ) ក្នុងផ្ទះកើតក្នុងត្រកូលសក្យៈ តាំងនៅក្នុងអង្គជាស្ត្រី ។ បពិត្រព្រះអង្គមានព្យាយាម ខ្ញុំជាប្រធាននៃស្ត្រីទាំងឡាយមួយសែន ៩៦ ជាធំជាងស្ត្រីទាំងពួងក្នុងផ្ទះនៃព្រះអង្គ ។ ស្ត្រីទាំងពួងប្រកបដោយគុណគឺរូបនិងមារយាទ តាំងនៅក្នុងបឋមវ័យសព្វៗកាល គោរពកោតក្រែងខ្ញុំ ដូចជាមនុស្សទាំងឡាយគោរពកោតក្រែងទេវតា ។ ស្ត្រីទាំងនោះមានពួកនាងកញ្ញាមួយពាន់ជាប្រធាន មានសុខនិងទុក្ខស្មើគ្នា ក្នុងដំណាក់នៃសក្យបុត្រ ដូចជាពួកទេវតា ក្នុងនន្ទនវ័ន ។

## អដ្ឋមំ យសោធរាថេរិយាបទានំ

កាមធាតុមតិក្កន្តា បណ្ឌិតា(១) រូបធាតុយា
រូបេន សទិសា នត្ថិ ឋបេត្វា លោកនាយកំ ។
សម្ពុទ្ធំ អភិវាទេត្វា ឥទ្ធី ទស្សេសិ សត្ថុនោ
នេកា នានាវិធាការា មហាឥទ្ធីបិ ទស្សយិ ។
ចក្កវាឡសមំ កាយំ សីសំ ឧត្តរតោ កុរុ
ឧភោ បក្ខា ទុវេ ទីបា ជម្ពុទីបំ សរីរតោ ។
ទក្ខិណញ្ច សរំ បិញ្ឆំ នានាសាខា តុ បត្តិកា
ចន្ទញ្ច សូរិយញ្ចក្ខី មេរុបព្ពតតោ សិខំ ។
ចក្កវាឡគិរី តុណ្ឌំ ជម្ពុរុក្ខំ សមូលកំ
វីជមានា ឧបគន្ត្វា វន្ទតេ លោកនាយកំ ។
ហត្ថិវណ្ណំ តថេវស្សំ បព្ពតំ ជលជន្តជា
ចន្ទញ្ច សូរិយំ មេរុំ សក្កវណ្ណញ្ច ទស្សយិ ។
យសោធរា អហំ វីរ បាទេ វន្ទាមិ ចក្ខុម
សហស្ស លោកធាតូនំ ផុល្លបទ្មេន(២) ឆាទយិ
ព្រហ្មវណ្ណញ្ច មាបេត្វា ធម្មំ ទេសេតិ សុញ្ញតំ(៣)
យសោធរា អហំ វីរ បាទេ វន្ទាមិ ចក្ខុម ។

---

១ ឱ. ម. សណ្ឋិតា ។ ២ ឱ. ផុល្លបច្មេន ។ ៣ ឱ. បុញ្ញតំ ។

## យសោធរាថេរីយាបទាន ទី ៨

បណ្ឌិតទាំងឡាយ កន្ទង់នូវកាមធាតុ ប្រាកដស្មើដោយរូបក្ខន្ធ រូបធាតុ វៀរលែងតែព្រះលោកនាយកចេញ មិនមានទេ ។

យសោធរាថេរី ថ្វាយបង្គំព្រះសម្ពុទ្ធហើយ សំដែងឫទ្ធិចំពោះព្រះសាស្តាទាំងសម្តែងឫទ្ធិច្រើន មានអាការៈផ្សេងៗច្រើនយ៉ាង ។ គឺធ្វើកាយជាភ្នំចក្រវាឡ ក្បាលជាឧត្តរកុរុទ្វីប ទ្វីបទាំងពីរជាស្លាបទាំងពីរ ជម្ពូទ្វីបជាសរីរៈ ។ សមុទ្រខាងត្បូងជាសំណុំកន្ទុយ ស្លឹកជាលំពង់ស្លាប ព្រះចន្ទ្រនិងព្រះអាទិត្យ ជាភ្នែក ភ្នំមេរុជាកំប៉ោយ ។ ភ្នំចក្រវាឡជាចំពុះ ដើមព្រីងជាទីប្រជុំ ហើយចូលទៅជិតថ្វាយបង្គំ អង្គុយបក់ព្រះលោកនាយក ។ សម្តែងនូវភេទនៃដំរី សេះ ភ្នំ ផលជាត ព្រះចន្ទ្រព្រះអាទិត្យ ភ្នំមេរុ ភេទនៃព្រះឥន្ទ្រក៏ដូចគ្នា ។ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គ ឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា គ្របនូវលោកធាតុមួយពាន់ ដោយផ្ការីក ។ ខ្ញុំនិម្មិតភេទជាព្រហ្មហើយសម្តែងធម៌ដ៏សូន្យ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ ខ្ញុំព្រះអង្គ ឈ្មោះយសោធរា សូមក្រាបថ្វាយបង្គំព្រះបាទា ។

ឥទ្ធីសុ ច វសី ហោមិ   ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស   វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ   ទិព្វចក្ខុំ វិសោធិតំ
សព្វាសវា បរិក្ខីណា   នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ   បដិភាណេ តថេវ ច
ញាណំ មយ្ហំ មហាវីរ   ឧប្បន្នំ តវ សន្តិកេ ។
តុម្ហានំ លោកនាថានំ   សង្គមំ តេ សុទស្សិតំ
អធិការំ ពហុំ មយ្ហំ   តុយ្ហត្ថាយ មហាមុនេ ។
យំ មយ្ហំ បុរិមំ កម្មំ   កុសលំ សរសេ មុនេ
តុយ្ហត្ថាយ មហាវីរ   បុញ្ញំ ឧបចិតំ មយា ។
អភព្វដ្ឋានេ វជ្ជិត្វា   វារយិត្វា អនាចរំ(១)
តុយ្ហត្ថាយ មហាវីរ   សញ្ចត្តំ(២) ជីវិតំ មយា ។

---

១ ឱ. បាបយន្តី អនាចរំ ។ ២ ឱ. សមត្តំ ។

បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំង-ឡាយ ទាំងស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណ ដោយសោត-ធាតុជាទិព្វ ។ ខ្ញុំព្រះអង្គដឹងនូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំព្រះអង្គបានជម្រះហើយ អាសវៈទាំងពួងអស់រលីងហើយ ឥឡូវនេះភពថ្មីទៀត មិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថ ធម៌ និរុត្តិ និងបដិភាណ កើតឡើងហើយដល់ខ្ញុំ ក្នុងសំណាក់នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី ការគប់រកព្រះលោកនាថទាំងឡាយ ព្រះអង្គបានសម្តែងហើយ ដោយប្រពៃ សេចក្តីកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បីប្រយោជន៍ ដល់ព្រះអង្គ ។ បពិត្រព្រះមុនី សូមព្រះអង្គរលឹកកុសលកម្មរបស់ខ្ញុំដែលមានក្នុងកាលមុន បពិត្រព្រះអង្គមានព្យាយាមធំ បុណ្យខ្ញុំបានសន្សំហើយ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំបានលះបង់នូវអកព្វដ្ឋាន ហាមឃាត់នូវអនាចារៈ ហើយលះបង់ជីវិតដើម្បីប្រយោជន៍ដល់ព្រះអង្គ ។

## អដ្ឋមំ យសោធរាថេរិយាបទានំ

នេកកោដិសហស្សានិ ភរិយត្ថាយ ទាសិ មំ
ន តត្ថ វិនា ហោមិ តុយ្ហត្ថាយ មហាមុនេ ។
នេកកោដិសហស្សានិ ឧបកាភយ ទាសិ មំ
ន តត្ថ វិមនា ហោមិ តុយ្ហត្ថាយ មហាមុនេ ។
នេកកោដិសហស្សានិ ជីវិតានិ បរិច្ចជី
នេកកោដិសហស្សានិ ភោជនត្ថាយ ទាសិ មំ ។
ន តត្ថ វិមនា ហោមិ តុយ្ហត្ថាយ មហាមុនេ
ភយមោក្ខំ ករិស្សន្តិ តទាមិ(១) មម ជីវិតំ ។
អង្គគតេ(២) អលង្ការេ វត្ថេ នានាវិធេ ពហូ
ឥត្ថីភណ្ឌេ ន គុយ្ហាមិ(៣) តុយ្ហត្ថាយ មហាមុនេ ។

---

១ ឱ. បជាមិ ។ ២ ម. អង្គេ ឯវំ ។ ៣ ឱ. ឥត្ថីភណ្ឌេន គូហាមិ ។

យសោធរាថេរិយាបទាន ទី ៨

បពិត្រព្រះមហាមុនី ព្រះអង្គទ្រង់ប្រទានខ្ញុំម្ចាស់ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន ដើម្បីជាភរិយា (នៃជនដទៃវិញ) ខ្ញុំមិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន ដើម្បីជាឧបការៈ (នៃជនដទៃ) ខ្ញុំក៏មិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គបានប្រទានខ្ញុំម្ចាស់អស់ជាតិ មានពាន់នៃកោដិដ៏ច្រើន ដើម្បីការប្រើប្រាស់ (នៃជនដទៃ) ខ្ញុំមិនតូចចិត្តក្នុងរឿងនោះ ព្រោះជាប្រយោជន៍ដល់ព្រះអង្គ ។ ខ្ញុំបានលះបង់ជីវិត មានពាន់នៃកោដិដ៏ច្រើន ជនទាំងឡាយនឹងធ្វើការរួចចាកភ័យ ខ្ញុំឲ្យនូវជីវិតរបស់ខ្ញុំ ។ បពិត្រព្រះមហាមុនី ខ្ញុំមិនលាក់ទុក នូវគ្រឿងប្រដាប់សម្រាប់អវយវៈ គ្រឿងអលង្ការ សំពត់ដ៏ច្រើន មានប្រការផ្សេង ៗ និងកណ្ឋៈរបស់ស្រីប្រុស ដើម្បីជាប្រយោជន៍ ដល់ព្រះអង្គ ។

ធនធញ្ញបរិច្ចាគំ គាមានិ និគមានិ ច
ខេត្តំ បុត្តា ច ធីតា ច បរិចត្តំ មហាមុនិ ។
ហត្ថី អស្សំ គវញ្ចាបិ ទាសិយោ បរិចារិកា
តុយ្ហត្ថាយ មហាវីរ បរិចត្តា អសង្ខិយា ។
យំ មយ្ហំ បដិមន្តេសិ ទានំ ទស្សាមិ យាចកេ
វិមនំ មេ ន បស្សាមិ ទទតោ ទានមុត្តមំ ។
នានាវិធំ ពហុំ ទុក្ខំ សំសារេ ច ពហុវិធេ
តុយ្ហត្ថាយេ មហាវីរ អនុភុត្តំ[1] អសង្ខិយំ ។
សុខប្បត្តានុមោទាមិ ន ច ទុក្ខេសុ ទុម្មនា
សព្វត្ថ តុសិតា ហោមិ តុយ្ហត្ថាយ មហាមុនិ ។
អនុមគ្គេន សម្ពុទ្ធោ យំ ធម្មំ អភិនីហរិ
អនុភោត្វា សុខទុក្ខំ បត្តោ ពោធឹ មហាមុនិ ។

១ ឱ. បរិភុត្តំ ។

បពិត្រព្រះមហាមុនី ការបរិច្ចាគទ្រព្យធននិងស្រូវ ទាំងស្រុក និគម ស្រែ បុត្រនិងធីតា ខ្ញុំក៏បានលះបង់ហើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ ដំរី សេះ គោ និងខ្ញុំស្រី អ្នកបម្រើ មានចំនួនរាប់មិនបាន ខ្ញុំក៏បានលះបង់ហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ ព្រះអង្គប្រឹក្សា នូវទានណានឹងខ្ញុំ ខ្ញុំឲ្យនូវទាននោះ ដល់ស្មូមទាំងឡាយ កាលព្រះអង្គឲ្យទានដ៏ឧត្តម ខ្ញុំមិនឃើញសេចក្តីតូចចិត្ត របស់ខ្ញុំទេ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំរងទុក្ខដ៏ច្រើន មានប្រការផ្សេងៗ មានចំនួនរាប់មិនបាន ក្នុងសំសារដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កាលព្រះអង្គដល់នូវសេចក្តីសុខ ខ្ញុំក៏ត្រេកអរ មួយទៀត ខ្ញុំមិនតូចចិត្ត ព្រោះទុក្ខទាំងឡាយរបស់ខ្ញុំ ខ្ញុំជាអ្នកត្រេកអរក្នុងទីទាំងពួង ដើម្បីជាប្រយោជន៍ នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះអង្គសោយសុខនិងទុក្ខ ត្រាស់ដឹងតាមលំដាប់មគ្គ ហើយដល់នូវពោធិញ្ញាណ រូបនាំមកនូវធម៌ ។

## អដ្ឋមំ យសោធរាថេរីយាបទានំ

ព្រហ្មទេវញ្ច សម្ពុទ្ធំ គោតមំ លោកនាយកំ
អញ្ញេសំ លោកនាថានំ សង្គមន្តេ ពហុំ មយា ។
អធិការំ ពហុំ មយ្ហំ តុយ្ហត្ថាយ មហាមុនិ
គវេសន្តី ពុទ្ធធម្មំ អរហន្តេ បរិចារិកា ។
កប្បសតសហស្សេ ច ចតុរោ ច អសង្ខេយេ
ទីបង្ករោ មហាវីរោ ឧប្បជ្ជិ លោកនាយកោ ។
បច្ចន្តទេសវិសយេ និមន្តេត្វា តថាគតំ
តស្ស អាគមនំ មគ្គំ សោធេន្តិ តុដ្ឋមានសា ។
តេន កាលេន សោ អាសិ សុមេធោ នាម
ព្រាហ្មណោ
មគ្គញ្ច បដិយាទេសិ អាយតោ សព្វទស្សិនោ ។
តេន កាលេនហំ អាសឹ កញ្ញា ព្រាហ្មណសម្ភវា
សុមិត្តា នាម នាមេន ឧបគច្ឆឹ សមាគមំ ។
អដ្ឋ ឧប្បលហត្ថានិ បូជនត្ថាយ សត្ថុនោ
អាទាយ ជនស្ស មជ្ឈេ[1] អទ្ទសំ ឥសិមុត្តមំ[2] ។

---

១ ឱ. ជនសម្មជ្ឈេ ។ ម. ជនសំមជ្ឈេ ។ ២ ម. ឥសិមុគ្គតំ ។

## យសោធរាថេរិយាបទាន ទី ៨

ខ្ញុំមានការគប់រកព្រះលោកនាថ ដទៃច្រើនអង្គ (ព្រោះអា-ស្រ័យ) នូវព្រះសម្ពុទ្ធ ជាព្រះលោកនាយក ព្រះនាមគោតម ជាទេវតាប្រសើរ ។ បពិត្រព្រះមហាមុនី ការកសាងដ៏ច្រើនរបស់ខ្ញុំ ដើម្បីប្រយោជន៍នៃព្រះអង្គ ខ្ញុំជាអ្នកបំរើព្រះអង្គ ដែលស្វែងរកនូវពុទ្ធធម៌ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្យាយាមធំ ជានាយកនៃសត្វលោក កើតហើយ ក្នុងកប្បទីបួនអសង្ខេយ្យ និងមួយសែន ។ ជនទាំងឡាយនៅក្នុងបច្ចន្ត-ប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគត ហើយជំរះផ្លូវ ជាទីស្តេចមកនៃព្រះទីបង្ករនោះ ។ កាលនោះ ព្រះអង្គជាព្រាហ្មណ៍ ឈ្មោះសុមេធៈ តាក់តែងផ្លូវសម្រាប់ថ្វាយព្រះពុទ្ធទីបង្ករ ទ្រង់ឃើញធម៌ទាំងពួង កាលស្តេចមកដល់ ខ្ញុំជាកញ្ញា កើតក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះនាងសុមិត្តា បានចូលទៅកាន់ទីប្រជុំ ។ ខ្ញុំយកផ្កាឧប្បល ៨ ក្តាប់ ដើម្បីបូជាព្រះសាស្តា បានឃើញឥសីដ៏ឧត្តម ក្នុងកណ្តាលនៃជន ។

ជិគុច្ឆិតំ ឧយិតំ(១) អតិក្កន្តំ មនោហរំ

ទិស្វា តទា អមញ្ញិស្សំ សកលំ ជីវិតំ មម ។

បរក្កមន្តំ សកលំ អទ្ទសំ ឥសិនោ តទា

បុព្វកម្មេន សម្ពុទ្ធេ ចិត្តញ្ចាបិ បសីទិ មេ ។

ភិយ្យោ ចិត្តំ បសាទេសឹ ឥសេ ឧទគ្គមានសេ

ទេយ្យំ អញ្ញំ ន បស្សាមិ ទេមិ បុប្ផានិ តេ ឥសេ(២) ។

បញ្ច ហត្ថា តវ ហោន្តុ តយោ ហោន្តុ មមំ ឥសេ

តេន សទ្ធឹ សមា ហោន្តុ ពោធិត្ថាយ តវ(៣) ឥសេ ។

ចតុត្ថំ ភាណវារំ ។

---

១ ឱ. ឧស្សិតំ ។ ២ ឱ. ឥសី ។ ៣ ឱ. ពោធនត្ថាយ តវំ ។

កាលនោះ ខ្ញុំបានឃើញព្រះសម្ពុទ្ធ ទ្រង់ខានយានមកអស់កាលយូរ ទ្រង់មានព្រះទ័យប្រកបដោយករុណា ក៏បណ្តាលឲ្យចិត្តត្រេកអរក្រៃលែង ហើយសំគាល់ថា ជីវិតរបស់អាត្មាអញប្រកបដោយផល ។ កាលនោះ ខ្ញុំបានឃើញសេចក្តីព្យាយាមប្រកបដោយផល របស់ឥសីនោះ ទាំងចិត្តរបស់ខ្ញុំ ក៏ជ្រះថ្លាក្នុងព្រះពុទ្ធ ដោយកុសលកម្ម មានក្នុងកាលមុន ។ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង ក្នុងឥសីមានចិត្តខ្ពង់ខ្ពស់ ហើយទូលថា បពិត្រឥសី ខ្ញុំមិនឃើញវត្ថុដទៃដែលគួរថ្វាយទេ ខ្ញុំសូមថ្វាយផ្កាទាំងឡាយដល់លោក ។ បពិត្រឥសី ផ្កា ៥ ក្តាប់ ចូរមានដល់លោក ផ្កា ៣ ក្តាប់ ចូរមានដល់ខ្ញុំ បពិត្រឥសី ផ្កាទាំងឡាយ ចូរជារបស់ស្មើគ្នាមួយអន្លើដោយឥសីនោះ ដើម្បីប្រយោជន៍ដល់ពោធិញាណរបស់ព្រះអង្គ ។

ចប់ ភាណវារៈ ទី ៤ ។

## អដ្ឋមំ យសោធរាថេរីយាបទានំ

ឥសិ គហេត្វា បុប្ផានិ　　អាគច្ឆន្តំ មហាយសំ
បូជេសិ ជនស្ស មជ្ឈេ[១]　　ពោធិត្ថាយ មហាឥសី ។
បស្សិត្វា ជនស្ស មជ្ឈេ　　ទីបង្ករមហាមុនិ
វិយាកាសិ មហាវីរោ　　ឥសិមុគ្គតមានសំ ។
អបរិមេយ្យេ ឥតោ កប្បេ　　ទីបង្ករមហាមុនិ
មម កម្មំ វិយាកាសិ　　ឧជុភាវំ មហាមុនិ ។
សមចិត្តា សមកម្មា　　សមការី ភវិស្សតិ
បិយា ហេស្សតិ កម្មេន　　តុយ្ហត្ថាយ មហាឥសេ ។
សុទស្សនា សុបិយា ច　　មនាបា[២] បិយវាទិនី
តស្ស ធម្មេសុ ទាយាទា　　វិហរិស្សតិ[៣] ឥទ្ធិកា ។
យថាបិ ភណ្ឌសាមុគ្គំ　　អនុរក្ខន្តិ សាមិនោ
ឯវំ កុសលធម្មានំ　　អនុរក្ខិស្សតេ[៤] អយំ ។

---

១ ឱ. ម. ជនសម្មជ្ឈេ · ២ ឱ. មនសា ។ ៣ ឱ. បិយា ហេស្សតិ ។ ៤ ឱ. អនុរក្ខិយតេ ។

ឥសីយកផ្កាទាំងឡាយ បូជាព្រះពុទ្ធជាមហាឥសី មានយសធំ ដែលមកក្នុងកណ្ដាលនៃពួកជន ដើម្បីប្រយោជន៍ដល់ពោធិញ្ញាណ ។ ព្រះមហាមុនី ព្រះនាមទីបង្ករ មានព្យាយាមធំ ឃើញឥសីមានចិត្តខ្ពង់ខ្ពស់ ទ្រង់ព្យាករក្នុងកណ្ដាលនៃជន ។

ព្រះមហាមុនី ព្រះនាមទីបង្ករៈ ជាអ្នកប្រាជ្ញ ទ្រង់ព្យាករ នូវអំពើរបស់ខ្ញុំ ដែលជាស្រីមានភាពត្រង់ ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះថា ម្នាលមហាឥសី ស្រីនេះ នឹងជាអ្នកមានចិត្តស្មើគ្នា មានការងារស្មើគ្នា ជាអ្នកធ្វើការស្មើគ្នា ជាទីស្រឡាញ់ដោយការងារស្មើគ្នានឹងអ្នក ដើម្បីប្រយោជន៍នៃអ្នក ។ មួយទៀត ស្រីនេះ នឹងជាអ្នកមានរូបគួរឲ្យរមិលមើលក្រៃលែង គួរឲ្យស្រឡាញ់ ពេញចិត្តក្រៃលែង ពោលពាក្យជាទីស្រឡាញ់ ជាអ្នកមានឫទ្ធិ នឹងបានជាញាតិក្នុងធម៌ នៃព្រះពុទ្ធនោះ ។ ប្រៀបដូចជនជាម្ចាស់ទ្រព្យរមែងរក្សាស្មុគ្រ សម្រាប់ដាក់នូវភណ្ឌៈ យ៉ាងណា ស្រីនេះ នឹងរក្សាធម៌ជាកុសលទាំងឡាយ ក៏យ៉ាងនោះដែរ ។

តស្ស តំ អនុកម្បន្តី បូរយិស្សតិ បារមី
សីហោវ បញ្ជរំ ហិត្វា បាបុណិស្សតិ ពោធិយំ ។
អបរិមេយ្យេ ឥតោ កប្បេ យំ មំ ពុទ្ធោ វិយាករិ(១)
តំ វាចំ អនុមោទន្តី ឃរំការី ករី អហំ ។
តស្ស កម្មស្ស សុកតស្ស តត្ថ ចិត្តំ បសាទយឹ
ទេវមានុសកំ យោនឹ អនុភោត្វា អសង្ខិយំ ។
សុខទុក្ខំ អនុភោត្វា ទេវេសុ មានុសេសុ ច
បច្ឆិមេ ភវសម្បត្តេ អជាយឹ សាកិយេ កុលេ ។
រូបវតី ភោគវតី យសសីលវតី តតោ
សព្វង្គសម្បទា ហោមិ កុលេសុ បតិសក្កតា(២) ។
លាភសិ លោកសក្ការំ លោកធម្មសមាគមំ
ចិត្តញ្ច ទុក្ខិតំ នត្ថិ វសាមិ អកុតោភយា ។

---

១ ឱ. យំ ពុទ្ធោ វិយាការិតំ ។ ២ ឱ. អតិសក្កតា ។

ស្រីនេះកាលអនុគ្រោះនូវកុសលធម៌នោះ របស់ព្រះពុទ្ធនោះ នឹងញុំាងបារមីទាំងឡាយឲ្យពេញ នឹងដល់នូវពោធិញ្ញាណ ដូចសត្វសីហៈលះបង់ទ្រុងដូច្នោះ ។

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះពុទ្ធទ្រង់ព្យាករខ្ញុំដោយវាចាណា ខ្ញុំត្រេកអរចំពោះវាចានោះ ជាអ្នកធ្វើយ៉ាងនោះ កាលកុសលកម្មដែលខ្ញុំធ្វើល្អហើយនោះ ខ្ញុំញុំាងចិត្តឲ្យជ្រះថ្លា ក្នុងកុសលនោះ ហើយបានកំណើតជារបស់នៃទេវតានិងមនុស្ស រាប់មិនអស់ ។ លុះទទួលនូវសេចក្តីសុខនិងទុក្ខ ក្នុងទេវតានិងមនុស្សហើយ ដល់មកក្នុងបច្ឆិមភព បានកើតក្នុងត្រកូលសក្យៈ ។ លំដាប់នោះ ខ្ញុំជាអ្នកមានរូបល្អ មានភោគៈ មានយសនិងសីល បរិបូណ៌ដោយអវយវៈទាំងពួង ជាអ្នកគោរពចំពោះប្តី ក្នុងត្រកូលទាំងឡាយ ។ ឯចិត្តរបស់ខ្ញុំ ដែលប្រជុំចុះ ក្នុងលោកធម៌មានលាភៈ សេចក្តីសរសើរ និងសក្ការៈជាដើម ជាចិត្តមិនដល់នូវសេចក្តីទុក្ខទេ តើខ្ញុំនឹងមានភ័យអំពីណា ។

## អដ្ឋមំ យសោធរាថេរិយាបទានំ

វត្តំ ហោតំ ភគវតោ    រញ្ញោ អន្តេបុរេ តទា
ខត្តិយានំ បុរេ វីរ    ឧបការញ្ច និទ្ទិសិ ។
ឧបការក ច យោ នារី    យា ច នារី សុខេ ទុក្ខេ
អត្ថក្ខាយី ច យា នារី    យា នារី នានុកម្បិកា ។
បញ្ចកោដិសតា ពុទ្ធា    នវកោដិសតានិ ច
ឯតេសំ ទេវទេវានំ    មហាទានំ បវត្តយឹ ។
អធិការំ មហា[1] មយ្ហំ    មហាភជ[2] សុណោហិ មេ
ឯកាទសកោដិសតា ហោន្តិ លោកគ្គនាយកា[3] ។
ឯតេសំ ទេវទេវានំ    មហាទានំ បវត្តយឹ
អធិការំ មហា មយ្ហំ    មហាភជ[2] សុណោហិ មេ ។
វីសកោដិសតា ពុទ្ធា    តឹសកោដិសតានិ ច
ឯតេសំ ទេវទេវានំ    មហាទានំ បវត្តយឹ ។

---

១ ឱ. សទាតិ ទិស្សតិយេវ ។ ២ ម. ធម្មាជាតិ ទិស្សតិយេវ ។ ៣ ឱ. ឯការសំ កោដិសតា បញ្ចកោដិសតានិ ច ។ ម. ឯកាទសកោដិសតា ពុទ្ធា ទ្វាទសកោដិយោ ។

## យសោធរាថេរិយាបទាន ទី ៨

សមដូចជាព្រះមានព្រះភាគ បានត្រាស់ចំពោះព្រះរាជាខាងក្នុងបុរីដូច្នេះថា បពិត្រព្រះអង្គមានព្យាយាម ព្រះអង្គសម្តែងឧបការគុណរបស់នារី នៃពួកក្សត្រិយ៍ក្នុងបុរីនោះ គឺ នារីធ្វើសេចក្តីទំនុកបំរុង នារីដឹងសុខនិងទុក្ខ នារីប្រាប់ប្រយោជន៍ និងនារីជាអ្នកអនុគ្រោះ ៗ (ដោយសារនារីនោះ) តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធប្រាំរយកោដិ និងប្រាំបួនរយកោដិ ជាទេវតាក្រៃលែង ជាងទេវតា ៗ បពិត្រមហារាជ សេចក្តីកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ព្រះពុទ្ធទាំងឡាយជានាយក ជាកំពូលនៃលោក ដប់មួយរយកោដិ ៗ តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហារាជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ៗ ព្រះពុទ្ធទាំងឡាយពីរពាន់កោដិផង បីពាន់កោដិផង តថាគតបានញុំាងមហាទាន ឲ្យប្រព្រឹត្តទៅដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ៗ

អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ

ចត្តាឡីសកោដិសតា បញ្ចកោដិសតានិ ច ។

ឃតេសំ ទេវទេភកំ មហាទានំ បវត្តយឹ

អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ ។

សដ្ឋិកោដិសតា បុណ្ណា សត្តតិកោដិសតានិ ច

ឃតេសំ ទេវទេភកំ មហាទានំ បវត្តយឹ ។

អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ

អសីតិកោដិសតា បុណ្ណា នវុតិកោដិសតានិ ច ។

ឃតេសំ ទេវទេភកំ មហាទានំ បវត្តយឹ ។

អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ ។

បពិត្រមហាពជ សេចក្តីកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ព្រះពុទ្ធទាំងឡាយ បួនពាន់កោដិផង ប្រាំរយកោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងឡាយនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ។ ព្រះពុទ្ធទាំងឡាយ ប្រាំមួយពាន់កោដិផង ប្រាំពីរពាន់កោដិផង តថាគត បានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្តាប់តថាគត ព្រះពុទ្ធទាំងឡាយ ប្រាំបីពាន់កោដិផង ប្រាំបួនពាន់កោដិផង តថាគតបានញុំាងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែង ជាងទេវតា ។ បពិត្រមហាពជ ការកសាងដ៏ធំ របស់តថាគត សូមព្រះអង្គស្តាប់តថាគត ។

## អដ្ឋមំ យសោធរាថេរិយាបទានំ

កោដិសតហស្សានិ ហោន្តិ លោកគ្គនាយកា
ឯតេសំ ទេវទេវានំ មហាទានំ បវត្តយឹ ។
អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ
នវកោដិសហស្សានិ អបរេ លោកនាយកា ។
ឯតេសំ ទេវទេវានំ មហាទានំ បវត្តយឹ
អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ ។
កោដិសតសហស្សានិ បញ្ចាសីតិ មហេសិនំ
បញ្ចាសីតិកោដិសតា សត្តវីសតិកោដិយោ(១) ។
ឯតេសំ ទេវទេវានំ មហាទានំ បវត្តយឹ
អធិការំ មហា មយ្ហំ មហារាជ សុណោហិ មេ ។

---

១ ឱ. សត្តតិសហស្សកោដិយោ ។ ម. សត្តតីសាប កោដិយោ ។

## យសោធរាថេរីយាបទាន ទី ៨

ព្រះពុទ្ធទាំងឡាយ ជានាយកដ៏ប្រសើរក្នុងលោក មួយសែនកោដិ តថាគតបានញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ព្រះពុទ្ធទាំងឡាយ ជានាយកនៃសត្វលោកដទៃទៀត ប្រាំបួនពាន់កោដិ ។ តថាគតបានញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ។ ព្រះពុទ្ធជាមហេសី ៨៥ សែនកោដិផង ១ សែនកោដិផង ៨៥ កោដិផង ២៧ កោដិផង តថាគតបានញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅ ដល់ព្រះពុទ្ធទាំងនុ៎ះ ដែលជាទេវតាក្រៃលែងជាងទេវតា ។ បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត សូមព្រះអង្គស្ដាប់តថាគត ។

បច្ចេកពុទ្ធា វីតរាគា[១] អឌ្ឍមឌ្ឍកកោដិយោ[២]
អធិការំ មហា មយ្ហំ មហាភាគ សុណោហិ មេ ។
ខីណាសវា វីតមលា អសង្ខេយ្យា ពុទ្ធសាវកា
អធិការំ មហា មយ្ហំ មហាភាគ សុណោហិ មេ ។
ឃរំ ធម្មេសុ ចិណ្ណានំ សទា សទ្ធម្មចារិនោ
ធម្មចារី សុខំ សេតិ អស្មិំ លោកេ បរម្ហិ ច ។
ធម្មញ្ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ អស្មិំ លោកេ បរម្ហិ ច ។
និព្ពិន្ទិត្វាន សំសារេ បព្វជឹ អនគារិយំ
សហស្សបរិវារេន បព្វជិត្វា អកិញ្ចនា ។
អគារំ វិជហិត្វាន បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ ចតុសច្ចំ អបាបុណឹ ។

---

១ ឱ. ម. ធុតរាគា ។ ២ ឱ. អឌ្ឍអឌ្ឍមកោដិយោ ។ ម. អឌ្ឍឌ្ឍមកកោដិយោ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលប្រាសចាកពាគៈ ចំនួនប្រាំបីៗ កោដិ បពិត្រមហាពជ ការកសាងដ៏ធំរបស់តថាគត (ចំពោះព្រះបច្ចេកពុទ្ធទាំងនុ៎ះ) សូមព្រះអង្គស្តាប់តថាគត ។ ព្រះខីណាស្រពទាំងឡាយ ជាសាវ័កនៃព្រះពុទ្ធ មានប្រមាណពប់មិនបាន មានមន្ទិលអស់ហើយ បពិត្រព្រះមហាពជ ការកសាងដ៏ធំរបស់តថាគត (ចំពោះព្រះខីណាស្រពទាំងនុ៎ះ) សូមព្រះអង្គស្តាប់តថាគត ។ កាលបុគ្គលអ្នកសន្សំកុសលធម៌ទាំងឡាយ កាលបុគ្គលអ្នកប្រព្រឹត្ត នូវព្រះសទ្ធម្មទាំងឡាយ សព្វៗកាល បុគ្គលអ្នកប្រព្រឹត្តធម៌យ៉ាងនេះ តែងដេកជាសុខ ក្នុងលោកនេះនិងលោកខាងមុខ ។ បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យជាសុចរិត មិនគប្បីប្រព្រឹត្តធម៌នោះ ឲ្យជាទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌ តែងដេកជាសុខ ក្នុងលោកនេះនិងលោកខាងមុខ ។ ខ្ញុំនឿយណាយក្នុងសង្សារ ហើយចូលទៅកាន់ផ្នួស ដោយបរិវារមួយពាន់ លុះបួសហើយមិនមានសេចក្តីក្រវល់ក្រវាយ ។ ខ្ញុំលះបង់ផ្ទះហើយចូលទៅកាន់ផ្នួស មិនទាន់ដល់កន្ទះខែផង ក៏បានដល់សច្ចៈ ៤ ។

## អដ្ឋមំ យសោធរាថេរិយាបទានំ

ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
ឧបនេន្តិ ពហូនេកេ(១) សាគរេយេវ ឧម្មិយោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឃរំ ពហុវិធំ ទុក្ខំ សម្បត្តិ ច ពហុវិធំ
វិសុទ្ធភាវសម្បត្តា លភាមិ សព្វសម្បទា ។
យោ ទទាតិ សក្កត្តានំ បុញ្ញត្ថាយ មហេសិនោ
សហាយសម្បទា ហោន្តិ និព្វានបទមសង្ខតំ ។
បរិក្ខីណំ អតីតញ្ច បច្ចុប្បន្នំ អនាគតំ
សព្វកម្មំ មម ខីណំ បាទេ វន្ទាមិ ចក្ខុមាតិ ។

---

១ ម. ពហូ ជនា ។

## យសោធរាថេរីយាបទាន ទី ៨

ជនទាំងឡាយជាច្រើន នាំចីវរ បិណ្ឌបាត និងទីដេក ទីអង្គុយ ចូលមក ដូចជារលកក្នុងសាគរ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។ ខ្ញុំដល់នូវសេចក្តីទុក្ខច្រើនប្រការផង នូវសម្បត្តិច្រើនប្រការផង នូវការវិនាស្អាតផង ហើយបាននូវសម្បទាទាំងពួង ។ បុគ្គលណា ឲ្យខ្លួនរបស់ខ្លួនដល់ព្រះពុទ្ធមហេសី ដើម្បីប្រយោជន៍ដល់បុណ្យ សហាយសម្បទា និងចំណែកនៃព្រះនិព្វាន មិនមានបច្ច័យតាក់តែង រមែងមានដល់បុគ្គលនោះ ។ កិលេសជាតជាអតីតក្តី ជាបច្ចុប្បន្នក្តី ជាអនាគតក្តី អស់រលិងហើយ កម្មទាំងពួងរបស់ខ្ញុំអស់ហើយ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ខ្ញុំសូមក្រាបថ្វាយបង្គំព្រះបាទា ។

ឥត្ថំ សុទំ អាយស្មា យសោធរា ភិក្ខុនី ភគវតោ
សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ។

យសោធរាថេរិយាបទានំ សមត្តំ ។

## នវមំ ទសសហស្សថេរីនមបទានំ

(២៩) កប្បេ សតសហស្សេ ច ចតុរោ ច សង្ខ្យេ
ទីបង្ករោ នាម ជិនោ ឧប្បជ្ជិ លោកនាយកោ ។
ទីបង្ករោ មហាវីរោ វិយាកាសិ វិនាយកោ
សុមេធញ្ច សុមិត្តញ្ច សមានសុខទុក្ខតំ ។
សទេវកញ្ច បស្សន្តា វិចរន្តា សទេវកំ
តេសំ បតិត្តេន អម្ហេ ឧបគម្ម សមាគមំ ។
អម្ហំ សញ្ញបតិ ហោតិ(១) អនាគតសមាគមេ
សញ្ញាវ តុយ្ហំ ករិយា មនាបា បិយវាទិកា ។

---

១ ឱ. សញ្ញាបតី ហោន្តិ ។

បានឮថា ព្រះយសោធរាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

**ចប់ យសោធរាថេរិយាបទាន ។**

# ទសសហស្សថេរីអបទាន ទី ៩

[២៧] ក្នុងកប្បទី ៤ អសង្ខេយ្យ និងមួយសែន ព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយក ទ្រង់កើតឡើង ។ ព្រះពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ទ្រង់ព្យាករ នូវសុមេធតាបសផង នាងសុមិត្តាផង ដែលរួមសុខទុក្ខជាមួយគ្នា ។ ព្រះមហាមុនី ព្រះអង្គឃើញមនុស្សលោក ព្រមទាំងទេវលោក ទាំងទ្រង់ស្តេចទៅកាន់មនុស្សលោក ព្រមទាំងទេវលោក ហើយចូលមកកាន់ទីប្រជុំនៃយើងខ្ញុំ ដែលកំពុងសរសើរជនទាំងនោះ ។ ប្តីទាំងអស់របស់យើងខ្ញុំ មានក្នុងទីសមាគមជាអនាគត ប្រពន្ធទាំងអស់របស់ព្រះអង្គ ជាទីពេញព្រះទ័យនៃព្រះអង្គ ជាអ្នកពោលពាក្យជាទីស្រឡាញ់ ។

## ធម៌ ទសសហស្សថេរីអបទាន

ទានំ សីលមយំ(១) សព្វំ ភាវនា ច សុភាវិតា(២)

ទីឃរត្តមិទំ(៣) សព្វំ បរិចត្តំ មហាមុនេ ។

គន្ធមាលំ វិលេបនំ ទីបញ្ច រតនាមយំ

យង្កិញ្ចិ បត្ថិតំ សព្វំ បរិចត្តំ មហាមុនិ ។

អញ្ញំ វាបិ កតំ កម្មំ បរិភោគញ្ច មានុសំ

ទីឃរត្តំ ហិ នោ សព្វំ បរិចត្តំ មហាមុនេ ។

អនេកជាតិសំសារំ ពហុបុញ្ញំ ហិ(៤) នោ កតំ

ឥស្សរំ អនុភោត្វាន សំសរិត្វា ភវាភវេ ។

បច្ឆិមេ ភវសម្បត្តេ សក្យបុត្តនិវេសនេ

នានាកុលុបបន្នាយោ អច្ឆរា កាមវណ្ណិនី ។

---

១ ម. សីលំ មយ្ហំ ។ ២ ឱ. ភាវនំ ច សុភាវិតំ ។ ៣ ឱ. ទីឃរត្តំ មយំ ។ ៤ ម. បិ ។

ទាន សីល ការនោទាំងអស់ យើងខ្ញុំបានអប់រំដោយល្អ ហើយ បពិត្រព្រះមហាមុនី វត្ថុទាំងអស់នេះ ខ្ញុំបានលះបង់ចោល អស់កាលជាយូរអង្វែងហើយ ៗ វត្ថុណាមួយ គឺគ្រឿងក្រអូប កម្រងផ្កា គ្រឿងលាប និងប្រទីបជាវិការៈនៃកេរ ដែលយើងខ្ញុំបានតម្កល់ទុកហើយ បពិត្រព្រះមហាមុនី វត្ថុទាំងអស់ (នោះ) យើងខ្ញុំបានលះបង់ចោលហើយ ៗ ន័យមួយទៀត អំពើដទៃ និងគ្រឿងបរិភោគជារបស់មនុស្ស ដែលយើងបានធ្វើហើយ បពិត្រព្រះមហាមុនី របស់ទាំងអស់នុ៎ះ យើងខ្ញុំបានលះបង់ចោល អស់កាលយូរអង្វែងហើយ ៗ បុណ្យមានប្រមាណច្រើន ដែលយើងបានធ្វើហើយ បានសោយនូវភាពជាឥស្សរៈ ត្រាច់រង្គាត់ក្នុងភពតូចភពធំ អស់សំសារវដ្ដមានជាតិច្រើន ៗ លុះដល់មកក្នុងបច្ឆិមភព យើងខ្ញុំបានកើតក្នុងត្រកូលផ្សេង ៗ គ្នា ក្នុងលំនៅនៃព្រះសក្យបុត្រ ជាស្រីមានពណ៌សម្បុរជាទីប្រាថ្នា បីដូចជាស្រីទេពអប្សរ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

លាភគ្គេន យសំ បត្តា   បូជិតា សព្វសក្កតា
លាភិយោ អន្នបានានំ   សទា សម្មានិតា មយំ ។
អគារំ បជហិត្វាន   បព្វជិម្ហនគារិយំ
អឌ្ឍមាសេ អសម្បត្តេ   សព្វា បត្តាម្ហ និព្វុតឹ ។
លាភិយោ អន្នបានានំ   វត្ថសេនាសនានិ ច
ឧបេន្តិ បច្ចយា សព្វេ   សទា សក្កតបូជិតា ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា   វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

បានដល់នូវយស ដែលជនទាំងពួង ធ្វើសក្ការបូជាហើយ ដោយលាភដ៏ប្រសើរ បាននូវបាយនិងទឹក ដែលពួកជនរាប់អានសព្វ ៗ កាល ។ យើងខ្ញុំលះបង់នូវផ្ទះ ហើយចូលទៅកាន់ផ្នួស មិនទាន់បានដល់កន្ទះខែ ក៏បានដល់សេចក្តីរំលត់ទុក្ខទាំងអស់គ្នា ។ យើងខ្ញុំជាអ្នកបាននូវបាយនិងទឹកផង នូវសំពត់និងសេនាសនៈផង បច្ច័យទាំងពួង រមែងមានគ្រប់គ្រាន់ យើងខ្ញុំត្រូវគេធ្វើសក្ការបូជា សព្វកាល ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំគាស់រំលើងហើយ យើងខ្ញុំជាអ្នកមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្ទឹង ។ ឱ! យើងខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

ឥត្ថំ សុទំ យសោធរីបមុខានិ ទស ភិក្ខុនីសហស្សានិ
ភគវតោ សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ។

ទសសហស្សថេរីនមបទានំ សមត្តំ ។

## ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

(៣០) អដ្ឋារសសហស្សានិ   ភិក្ខុនី សាកិយសម្ភវា
យសោធរីបមុខានិ   សត្ថុំ ឧបសង្កមុំ ។
អដ្ឋារសសហស្សានិ(១)   សព្វា ហោន្តិ មហិទ្ធិកា
វន្ទិត្វា មុនិនោ បាទេ   អាកោចេន្តិ យថាពលំ ។
ជាតិ ខីណា ជរា ព្យាធិ   មរណញ្ច មហាមុនេ
អនាសវំ បទំ សន្តំ   អមតំ យាម នាយកំ ។
ខលិតញ្ច បុរេ អត្ថិ   សព្វាសម្បំ មហាមុនិ
អបរាធំ បជានន្តិ   ខម អម្ហំ វិនាយកា ។

១ ឱ. យសោធរីយសហស្សានិ ។

អដ្ឋារសថេរីសហស្សានមបទាន ទី ១០

បានឮថា ព្រះភិក្ខុនី មួយម៉ឺនរូប មានព្រះនាងយសោធរាភិក្ខុនី ជាប្រធាន មានអាយុ បានសម្តែងនូវគាថាទាំងនេះ បំពោះព្រះភ័ក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ទសសហស្សថេរីនមបទាន ។

# អដ្ឋារសថេរីសហស្សានមបទាន ទី ១០

[ ៣០ ] ភិក្ខុនី ១៨ ពាន់ មាននាងយសោធរាជាប្រធាន ដែលកើតក្នុងត្រកូលសាក្យៈ បាននាំគ្នាចូលទៅគាល់ព្រះសម្ពុទ្ធ ។ ភិក្ខុនីទាំង ១៨ ពាន់នោះ សឹងមានឫទ្ធិច្រើន នាំគ្នាចូលទៅថ្វាយបង្គំព្រះបាទាព្រះមុនី ក្រាបទូលតាមសមគួរដល់កម្លាំងថា បពិត្រព្រះមហាមុនី ជាតិ ជរា ព្យាធិ និងមរណៈ (នៃយើងខ្ញុំ) អស់ហើយ បពិត្រព្រះអង្គជានាយក យើងខ្ញុំទាំងឡាយនឹងទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ដែលមិនមានអាសវៈ ជាផ្លូវដ៏ស្ងប់រម្ងាប់ ។ បពិត្រព្រះមហាមុនី កាលពីដើម ពួកភិក្ខុនីទាំងអស់ មានសេចក្តីភាំងភាំត់ ពួកភិក្ខុនីដឹងច្បាស់នូវកំហុស បពិត្រព្រះអង្គជានាយក សូមព្រះអង្គអត់ទោសដល់យើងខ្ញុំ ។

ឥទ្ធិញ្ចាបិ និទស្សេថ មម សាសនការិកា
បរិសានញ្ច សព្វាសំ កង្ខំ ឆិន្ទថ យាវតា ។
យសោធរា(១) មហាវីរ មណាចា បិយទស្សិនា
សព្វា តុយ្ហំ មហាវីរ អគារស្មិំ បជាបតិ ។
ជីនំ សតសហស្សានំ នវុតីនំ ឆឡុត្តរិ(២)
អគារេ តេ មយំ វីរ ចាមោក្ខា សព្វឥស្សរា ។
រូបាចារគុណូបេតា យោព្វនដ្ឋា បិយំវទា
សព្វាយោ អបចាយន្តិ ទេវតា វិយ មានុសា ។
អដ្ឋារសសហស្សានិ សព្វា សាកិយសម្ភវា
យសោធរី(៣) សហស្សានិ ចាមោក្ខា ឥស្សរា តទា ។

---

១ ឱ. ម. យសោធរី ។ ២ ម. តីណិ សតសហស្សានិ នវុតិ ច ឆទុត្តរីតិ ទិស្សតិ ។ ៣ ឱ. យសោវតី ។

នាងទាំងឡាយ ជាអ្នកធ្វើតាមសាសនា របស់តថាគត ចូរសម្តែងនូវឫទ្ធិ ឲ្យទាល់តែកាត់សេចក្តីសង្ស័យ របស់ពួកបរិស័ទទាំងអស់ ។

បពិត្រព្រះមហាវីរៈ ខ្ញុំម្ចាស់យសោធរា ជាទីពេញព្រះហឫទ័យ ជាទីស្រឡាញ់ គួរមើលមើល បពិត្រព្រះមហាវីរៈ ស្ត្រីទាំងពួងជាព្រះជាយាក្នុងដំណាក់ របស់ព្រះអង្គ ។ បពិត្រព្រះអង្គមានព្យាយាម បណ្តាពួកស្រីមួយសែន ៩៦ រូប ខ្ញុំម្ចាស់ជាប្រធាន ជាឥស្សរៈ លើស្រីទាំងពួង ក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ ពួកស្រីទាំងអស់ ជាអ្នកបរិបូណ៌ដោយគុណ គឺរូបនិងអាចារៈ ឋិតនៅក្នុងបឋមវ័យ ពោលពាក្យជាទីស្រឡាញ់ តែងគោរពកោតក្រែងខ្ញុំម្ចាស់ ដូចពួកមនុស្សគោរពកោតក្រែងពួកទេវតា ។ ពួកស្រីទាំង ១៨ ពាន់ កើតក្នុងត្រកូលសាក្យៈ ក្នុងកាលនោះ ស្រីមួយពាន់ ទ្រទ្រង់យស ជាប្រធាន ជាធំ ។

## ទសមំ អដ្ឋារសបេរីសហស្សានមបទានំ

កាមធាតុមតិក្កន្តា សណ្ឋិតា រូបធាតុយា
រូបេន សទិសា នត្ថិ សហស្សានំ មហាមុនេ ។
សម្ពុទ្ធំ អភិវាទេត្វា ឥទ្ធី ទេសេសុ សត្ថុនោ
នេកា នានាវិធាការា មហាឥទ្ធីបិ ទស្សយុំ ។
ចក្កវាឡសមំ កាយំ សីសំ ឧត្តរតោ កុរុ
ឧភោ បក្ខា ទុវេ ទីបា ជម្ពុទីបំ សរីរតោ ។
ទក្ខិណញ្ច សរំ បិញ្ជំ(១) នានាសាខា តុ បត្តកា(២)
ចន្ទញ្ច សុរិយញ្ចក្ខិ មេរុបព្វតតោ សិខំ ។
ចក្កវាឡគិរី តុណ្ឌំ ជម្ពុរុក្ខំ សមូលកំ(៣)
វីជមានា ឧបាគន្ត្វា វន្ទេន្ត(៤) លោកនាយកំ ។
ហត្ថិវណ្ណំ តថេវស្សំ បព្វតំ ជលជន្តា(៥)
ចន្ទញ្ច សុរិយំ មេរុំ សក្កវណ្ណញ្ច ទស្សយុំ ។
យសោធរ(៦) មយំ វីរ បាទេ វន្ទាម ចក្ខុម
តវ ចិរប្បភាវេន(៧) និប្ផន្នា នរនាយក ។

---

១ ឱ. បិញ្ជំ ។ ២ ម. សុបត្តកា ។ តុ-សទ្ទោ នត្ថិ ។ ៣ ម. សមូហកំ ។ ៤ ឱ. ម. វន្ទន្តិ ។
៥ ឱ. ជលជំ តថា ។ ម. លធំ តថា ។ ៦ ឱ. យសោវណ្ណា ។ ឱ. វីរប្បភាវេន ។

បពិត្រព្រះមហាមុនី ស្រីទាំងឡាយកន្លងនូវកាមធាតុ ឋិតនៅក្នុងរូបធាតុ ប្រាកដស្មើដោយរូប នៃស្រីទាំងមួយពាន់គ្មានទេ ៗ ថេរីទាំងឡាយ មានឫទ្ធិច្រើន លុះថ្វាយបង្គំព្រះសម្ពុទ្ធហើយ សម្តែងឫទ្ធិថ្វាយព្រះសាស្តា សម្តែងនូវមហិទ្ធិ-ឫទ្ធិមានអាការផ្សេង ៗ ដ៏ច្រើន ៗ គឺ សម្តែងកាយស្មើនឹងចក្រវាឡ ឧត្តរកុរុទ្វីបជាក្បាល ទ្វីបទាំងពីរជាស្លាបទាំងពីរខាង ជម្ពូទ្វីបជាសរីរៈ ៗ ស្រះខាងត្បូង ជាសំណុំកន្ទុយ ស្លឹងផ្សេង ៗ ជាបំពង់ស្លាប ព្រះចន្ទ្រនិងព្រះអាទិត្យជាភ្នែក ភ្នំមេរុជាសិរ ៗ ភ្នំចក្រវាឡនិងដើមព្រីងព្រមទាំងឫស ជាចំពុះ កាលបក់ហើយចូលមក ថ្វាយបង្គំព្រះលោកនាយក ៗ កាលនោះ បានសម្តែងភេទ នៃដំរី សេះ ភ្នំ ផលជាតិ ព្រះចន្ទ្រ ព្រះអាទិត្យ ភ្នំមេរុ និងភេទព្រះឥន្ទ្រ ៗ បពិត្រព្រះអង្គមានព្យាយាម មានចក្ខុ យើងខ្ញុំនិងនាងយសោធរា សូមថ្វាយបង្គំព្រះបាទា បពិត្រព្រះអង្គជានាយកនៃជន យើងខ្ញុំសម្រេចហើយ ដោយអានុភាពរបស់ព្រះអង្គ អស់កាលដ៏យូរ ៗ

ឥទ្ធីសុ ច វសី ហោម   ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស   វសី ហោម មហាមុនេ ។
បុព្វេនិវាសំ ជានាម   ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា   នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ   បដិភានេ តថេវ ច
ញាណំ អម្ហំ មហាវីរ   ឧប្បន្នំ តវ សន្តិកេ ។
ពុទ្ធានំ(១) លោកនាថានំ   សង្គមំ នោ និទស្សិតំ
អធិការា ពហូ អម្ហេ   តុយ្ហត្ថាយ មហាមុនេ ។
យំ អម្ហំ បុរិមំ កម្មំ   កុសលំ សរិសេ មុនេ
តុយ្ហត្ថាយ មហាវីរ   បុញ្ញានុបចិតានិ នោ ។

---

១ ឱ. ម. បុញ្ញានំ ។

បពិត្រព្រះមហាមុនី យើងខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំង-ឡាយផង ក្នុងសោតធាតុជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ យើងខ្ញុំដឹងបុព្វេនិវាសៈ ទិព្វចក្ខុយើងខ្ញុំជម្រះស្អាតហើយ យើងខ្ញុំមានអាសវៈទាំងពួង អស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិ-សម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទានៃយើងខ្ញុំ កើតឡើងហើយក្នុងសំណាក់របស់ព្រះអង្គ ។ ការគប់រកនូវព្រះពុទ្ធទាំងឡាយ ដែលជាទីពឹងរបស់សត្វលោក យើងខ្ញុំបានសម្ដែងហើយ បពិត្រព្រះមហាមុនី ការកសាងជាច្រើនយើងខ្ញុំបានធ្វើហើយ ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមុនី កុសលកម្មណា ដែលជាកម្មចាស់របស់ខ្ញុំ សូមព្រះអង្គនឹកនូវកុសលកម្មនោះ បពិត្រព្រះអង្គមានព្យាយាមធំ បុណ្យទាំងឡាយយើងខ្ញុំសន្សំហើយ ដើម្បីប្រយោជន៍ព្រះអង្គ ។

## ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

អគ្ឃដ្ឋានេ វេឌ្ឍន្តា ភរិយម្ហ អនាចរំ[១]

ពុទ្ធត្ថាយ មហាវីរ សញ្ចត្តំ ជីវិតម្បិ[២] នោ ។

នេកកោដិសហស្សានិ ភរិយត្តាយ ទាសិ នោ

ន តត្ថ វិមនា ហោម ពុទ្ធត្ថាយ មហាមុនេ ។

នេកកោដិសហស្សានិ ឧបការាយ ទាសិ នោ

ន តត្ថ វិមនា ហោម ពុទ្ធត្ថាយ មហាមុនេ ។

នេកកោដិសហស្សានិ ភោជនត្ថាយ ទាសិ នោ

ន តត្ថ វិមនា ហោម ពុទ្ធត្ថាយ មហាមុនេ ។

---

១ ឱ. ឋាបយិម្ហ អនាវរំ ។ ២ ឱ. ម. បត្តានិ ជីវិតានិ ។

អដ្ឋារសបេរីសហស្សាគមបទាន ទី ១០

បពិត្រព្រះអង្គ មានព្យាយាមធំ យើងខ្ញុំបានវៀរក្នុងទីមិនគួរ ហើយហាមឃាត់នូវអនាចារៈ សូម្បីជីវិត យើងខ្ញុំ ក៏បានលះបង់ ដើម្បីប្រយោជន៍ព្រះអង្គ ៗ ព្រះអង្គទ្រង់ប្រទានយើងខ្ញុំ ដើម្បីប្រយោជន៍ជាភរិយា នៃបុគ្គលដទៃវិញ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្តក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ៗ ព្រះអង្គបានប្រទាន នូវយើងខ្ញុំ ដើម្បីទំនុកបម្រុង (ជនដទៃ) អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំឥតមានតូចចិត្ត ក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ៗ ព្រះអង្គទ្រង់ព្រះរាជទាន នូវយើងខ្ញុំ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់នៃជនដទៃ អស់ជាតិមានពាន់នៃកោដិដ៏ច្រើន បពិត្រព្រះមហាមុនី យើងខ្ញុំទាំងឡាយ ឥតមានតូចចិត្ត ក្នុងរឿងនោះទេ ដើម្បីប្រយោជន៍ព្រះអង្គ ៗ

នេកកោដិសហស្សានិ ជីវិតានិ ចជិម្ហសេ(១)
ភយមោក្ខំ ករិស្សាម ជីវិតានិ ចជិម្ហសេ(១) ។
អង្គគតេ អលង្ការេ វត្ថេ នានាវិធេ ពហូ
ឥត្ថិភណ្ឌេ ច គុយ្ហាម តុយ្ហត្ថាយ មហាមុនេ ។
ធនធញ្ញបរិច្ចាគំ គាមានិ និគមានិ ច
ខេត្តំ បុត្តញ្ច ធីតញ្ច បរិចត្តំ មហាមុនេ ។
ហត្ថិអស្សំ គវញ្ចាបិ ទាសិយោ បរិចារិកា
តុយ្ហត្ថាយ មហាវីរ បរិចត្តំ(២) អសង្ខិយំ ។
យំ អម្ហេ បដិមន្តេសិ ទានំ ទស្សាម យាចកេ
វិមនំ នោ ច បស្សាម ទទតោ ទានមុត្តមំ ។
នានាវិធំ ពហុំ ទុក្ខំ សំសារេ ច ពហុព្ពិធេ
តុយ្ហត្ថាយ មហាវីរ អនុភុត្តំ(៣) អសង្ខិយំ ។

---

១ ឱ. ម. បជិម្ហសេ ។ ២ ម. បរិវិត្តំ ។ ៣ ឱ. បរិបត្តំ ។ ម. បរិភុត្តំ ។

យើងខ្ញុំបានលះបង់ជីវិតទាំងឡាយ មានពាន់នៃកោដិដ៏ច្រើន គឺធ្វើឲ្យគេប្រហារកទុក្ខភ័យ ស៊ូលះបង់ជីវិតនៃខ្លួន ៗ បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលលាក់ទុក នូវគ្រឿងប្រដាប់ដែលជាប់នឹងអង្គ ដូចយ៉ាងសំពត់ផ្សេង ៗ ជាច្រើន កណ្ឋៈរបស់ស្រី ដើម្បីប្រយោជន៍ព្រះអង្គ ៗ បពិត្រព្រះមហាមុនី យើងខ្ញុំបានបរិច្ចាគទ្រព្យនិងស្រូវ បានបរិច្ចាគស្រុក និគមស្រែ កូនប្រុស កូនស្រី ៗ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំបានបរិច្ចាគដំរី សេះ គោ ខ្ញុំស្រី អ្នកបម្រើរាបមិនអស់ ដើម្បីប្រយោជន៍ព្រះអង្គ ៗ ព្រះអង្គបានប្រឹក្សា នឹងយើងខ្ញុំដោយទានណា យើងខ្ញុំក៏បានឲ្យទាននោះ ដល់សូមទាំងឡាយ យើងខ្ញុំមិនបានឃើញ នូវសេចក្ដីតូចចិត្តចំពោះព្រះអង្គ កាលដែលឲ្យទានដ៏ឧត្ដមនោះសោះឡើយ ៗ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំទាំងឡាយ បានទទួលនូវសេចក្ដីទុក្ខ មានចំណែកច្រើនចំពូកណាស់ រាប់មិនអស់ក្នុងសំសារមានចំណែកច្រើន ដើម្បីប្រយោជន៍ព្រះអង្គ ៗ

## ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

សុខំ បត្តានុមោទាន  ន ច ទុក្ខេសុ ទុម្មនា
សព្វត្ថ តុសិតា(១) ហោម  តុយ្ហត្ថាយ មហាមុនេ ។
អនុមគ្គេន សម្ពុទ្ធោ  យំ ធម្មំ អភិនីហរិ
អនុភោត្វា សុខទុក្ខំ  បត្តោ ពោធឹ មហាមុនេ ។
ព្រហ្មទេវញ្ច សម្ពុទ្ធំ  គោតមំ លោកនាយកំ
អញ្ញាសិំ លោកនាថានំ  សទ្ធមន្តេហិ នោ ពហុ ។
អធិការំ ពហុំ អម្ហំ  តុយ្ហត្ថាយ មហាមុនេ
គវេសតោ ពុទ្ធធម្មំ  មយន្តេ បរិចារិកា ។
កប្បេ ច សតសហស្សេ  ចតុរោ ច អសង្ខយេ
ទីបង្ករេ មហាវីរេ  ឧប្បជ្ជិ លោកនាយកោ ។
បច្ចន្តទេសវិសយេ  និមន្តេត្វា តថាគតំ
តស្ស អាគមនំ មគ្គំ  សោធេន្តិ តុដ្ឋមានសា ។

---

១ ឱ. ម. តុលិតា ។

បពិត្រព្រះមហាមុនី យើងខ្ញុំបានរីករាយ តាមចំណែកបុណ្យ ដែលនាំមកនូវសេចក្តីសុខ ទាំងមិនតូចចិត្ត ចំពោះទុក្ខទាំងឡាយ ជាអ្នកត្រេកអរក្នុងទីទាំងពួង ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី ព្រះសម្ពុទ្ធទ្រង់សោយនូវសុខទុក្ខ ហើយដល់នូវការត្រាសដឹង នាំមកនូវធម៌ដោយលំដាប់មគ្គ ។ ការគប់រកព្រះសម្ពុទ្ធព្រះនាមគោតម ជាលោកនាយក ដែលជាទេវតាប្រសើរផង ព្រះលោកនាថទាំងឡាយដទៃផង យើងខ្ញុំ (បានសម្តែងហើយ) ជាច្រើនដង ។ សេចក្តីកសាងដ៏ច្រើន នៃយើងខ្ញុំរមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ព្រះអង្គ បពិត្រព្រះមហាមុនី យើងខ្ញុំ ជាស្រីបម្រើរបស់ព្រះអង្គ កាលដែលទ្រង់ស្វែងរកនូវពុទ្ធធម៌ ។ ក្នុងកប្បទី៤ អសង្ខេយ្យនិង ១ សែន ព្រះសម្ពុទ្ធព្រះនាមទីបង្ករ ជាមហាវីរបុរស ជាលោកនាយកទ្រង់កើតឡើង ។ ជនទាំងឡាយនៅបច្ចន្តប្រទេស និមន្តព្រះតថាគត មានចិត្តត្រេកអរ នាំគ្នាជម្រះផ្លូវសម្រាប់យាងមក នៃព្រះតថាគតនោះ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

តេន កាលេន សោ អាសិ សុមេធោ នាម ព្រាហ្មណោ

មគ្គញ្ច បដិយាទេសិ អាយតោ សព្វទស្សិនោ ។

តេន កាលេន អហុម្ហា សព្វ ព្រាហ្មណសម្មតា

ជលុកជាតិបុប្ផានិ(១) អាហរិម្ហ សមាគមំ ។

តស្មឹ សោ សមយេ ពុទ្ធោ ទីបង្ករោ មហាយសោ

វិយាកាសិ មហាវីរោ ឥសិមុគ្គតមានសំ ។

ចលតិ រវតិ បឋវី សង្កម្បតិ សទេវកោ

តស្ស កម្មំ បកិត្តេន្តោ ឥសិមុគ្គតមានសំ ។

ទេវកញ្ញា មនុស្សា ច មយញ្ចាបិ សទេវកា

នានាបូជនីយំ ភណ្ឌំ បូជយិត្វាន បត្ថយុំ ។

តេសំ ពុទ្ធោ វិយាកាសិ ជោតិទីបសនាមកោ(២)

អជ្ជ យេ បត្ថិតា អត្ថិ តេ ភវិស្សន្តិ សម្មុខា ។

---

១ ម. ជលូទជានិ បុប្ផានិ ។ ២ ឱ. ជោតិទីបីសនាមកោ ។

ក្នុងកាលនោះ ព្រះអគ្គជាព្រាហ្មណ៍ ឈ្មោះសុមេធៈ បានចាត់ចែងរៀបចំផ្លូវ ដើម្បីព្រះសម្ពុទ្ធទីបង្ករ ទ្រង់ឃើញហេតុទាំងពួង ទ្រង់យាងមក ។ ក្នុងកាលនោះ យើងខ្ញុំទាំងអស់គ្នា កើតក្នុងត្រកូលព្រាហ្មណ៍ បានទៅនាំយកផ្កាផលុកជាតិមកកាន់ទីប្រជុំ ។ ក្នុងសម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករ មានយសធំ មានព្យាយាមធំនោះ ទ្រង់បានព្យាករនូវសុមេធតាបស ជាឥសីមានចិត្តរីករាយ ។ កាលព្រះពុទ្ធទីបង្ករ ទ្រង់ប្រកាសកម្ម របស់សុមេធតាបសនោះថា ជាឥសីមានចិត្តរីករាយ ផែនដីកក្រើក រំភើបញាប់ញ័រ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ។ ពួកទេវកញ្ញា ពួកមនុស្ស ទាំងយើងខ្ញុំព្រមទាំងទេវតា សឹងនាំគ្នាបូជាគ្រឿងប្រដាប់ដែលគួរបូជាផ្សេង ៗ ហើយតាំងប្រាថ្នា ។ ព្រះពុទ្ធជាម្ចាស់ មានព្រះនាមទីបង្ករ ទ្រង់បានព្យាករដល់ពួកជនទាំងនោះថា ជនទាំងឡាយណា មានសេចក្ដីប្រាថ្នាក្នុងថ្ងៃនេះ ជនទាំងនោះ ឈ្មោះថា មានក្នុងទីចំពោះមុខ (នៃព្រះពុទ្ធ) ។

## ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

អបរិមេយ្យេ ឥតោ កប្បេ  យំ សោ ពុទ្ធោ វិយាករិ
តំ ភាចំ អនុមោទន្តី  ឃរំការី អហុម្ហ សោ ។
តស្ស កម្មស្ស សុកតស្ស  តត្ថ ចិត្តំ បសាទយុំ
ទេវមានុសកំ យោនឹ  អនុភោត្វា អសង្ខយំ ។
សុខទុក្ខនុភោត្វាន  ទេវេសុ មានុសេសុ ច
បច្ឆិមេ ភវសម្បត្តេ  ជាតាម្ហ សាកិយេ កុលេ ។
រូបវតី ភោគវតី  យសសីលវតី តតោ
សព្វង្គសម្បន្នា ហោម  កុលេសុ អភិសក្កតា ។
លាភសិ លោកសក្ការំ  លោកជម្មសមាគមំ
ចិត្តញ្ច ទុក្ខិតំ ឆត្តិ  វសាម អកុតោភយា ។

ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ ព្រះពុទ្ធព្យាករនូវយើងខ្ញុំ ដោយព្រះពុទ្ធដីកាណា យើងខ្ញុំ រមែងរីកពាយតាមព្រះពុទ្ធដីកានោះ ជាអ្នកធ្វើតាមយ៉ាងនោះ ៗ ជនទាំងឡាយ បានចាប់កំណើត ជារបស់ទេវតានិងមនុស្ស រាប់មិនអស់ ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធនោះ ដោយអំណាចនៃកម្មនោះ ដែលខ្លួនធ្វើល្អហើយ ៗ យើងខ្ញុំបានសោយសុខទុក្ខក្នុងទេវតាផង មនុស្សផង ដល់មកក្នុងបច្ឆិម-ភពនេះ បានមកកើតក្នុងត្រកូលសក្យៈ ៗ យើងខ្ញុំជាអ្នកមានរូបល្អ មានភោគសម្បត្តិច្រើន មានយស និងសីលដ៏ល្អបរិបូណ៌ដោយអវយវៈសព្វគ្រប់ ជាអ្នកអង់អាចលើសក្នុងត្រ-កូលទាំងឡាយ ៗ ចិត្តនៃយើងខ្ញុំ ដែលប្រជុំចុះក្នុងលោក-ធម៌ មានលាភៈ សេចក្ដីសរសើរនិងគ្រឿងសក្ការៈ ជាចិត្តមិនដល់នូវសេចក្ដីទុក្ខទេ តើយើងខ្ញុំនឹងមានភ័យអំពីណា ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

វុឌ្ឍិ ហោតិ ភគវតា  រញ្ញោ អន្តេបុរេ តទា
ខត្តិយានំ បុរេ តាសំ(១)  ឧបការញ្ច និច្ចិសិ ។
ឧបការី ច យា នារី  យា ច នារី សុខេ ទុក្ខេ
អត្ថក្ខាយី ច យា នារី  យា ច នារីនុកម្បិកា ។
ធម្មញ្ចរេ សុចរិតំ  ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច ។
អគារំ បជហិត្វាន  បព្វជិម្ហានគារិយំ
អឌ្ឍមាសេ អសម្បត្តេ  ចតុស្សច្ចំ ផុសិម្ហ នោ ។
ចីវរំ បិណ្ឌបាតញ្ច  បច្ចយំ សយនាសនំ
ឧបនេន្តិ ពហូ អម្ហេ  សាគរស្សេវ ឧម្មិយោ ។
កិលេសា ឈាបិតា មយ្ហំ  ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា  វិហរាម អនាសវា ។

---

១ ឱ. ម. រី ។

សមដូចជាព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះតម្រាស់នេះ ចំពោះស្តេចខាងក្នុងបុរី ក្នុងកាលនោះដូច្នេះថា មហាពជបាន សម្តែង នូវឧបការគុណរបស់នារី នៃពួកក្សត្រក្នុងបុរីនោះ គឺនារីអ្នកមានឧបការៈ នារីរួមសុខទុក្ខ នារីដែលប្រាប់នូវប្រយោជន៍ និងនារីជាអ្នកមានសេចក្តីអនុគ្រោះ ។ បុគ្គលគប្បីប្រព្រឹត្តធម៌ឲ្យជាសុចរិត កុំគប្បីប្រព្រឹត្តធម៌នោះ ឲ្យជាទុច្ចរិតឡើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។ យើងខ្ញុំបានលះបង់ផ្ទះហើយ ហើយចូលទៅកាន់ផ្នួស មិនទាន់បានដល់កន្លះខែ ស្រាប់តែយើងខ្ញុំបាននូវសច្ចៈ ៤ ។ ពួកជនដ៏ច្រើន តែងបង្អោនមកនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ និងសេនាសនប្បច្ច័យ ចំពោះយើងខ្ញុំ បីដូចរលកនៃសាគរ ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំដកចោលចេញហើយ យើងខ្ញុំ ជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង ។

## ទសមំ អដ្ឋារសថេរីសហស្សានមបទានំ

ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនំ ។
ឃរំ ពហុវិធំ ទុក្ខំ   សម្បត្តិញ្ច ពហុព្វិធំ
វិសុទ្ធភាវំ សម្បត្តា   លភាម សព្វសម្បទា ។
យា ទទន្តិ សកត្តានំ   បុញ្ញតាយ មហេសិនោ
សហាយសម្បទា[1] ហោន្តិ   និព្វានំ បទមសង្ខតំ[2] ។
បរិក្ខីណំ អតីតញ្ច   បច្ចុប្បន្នំ អនាគតំ
សព្វកម្មំបិ នោ ខីណំ   បាទេ វន្ទាម ចក្ខុមា ។

---

១ ឱ. បហាយសម្បទា ។ ២ ឱ. និព្វានមតសង្ខតំ ។

អដ្ឋារសបេរីសហស្សានមបទាន ទី ១០

ឱ / យើងខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ យើងខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ៗ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ៗ យើងខ្ញុំដល់នូវភាពបរិសុទ្ធ បរិបូណ៌ដោយគុណទាំងពួង តែងបាននូវទុក្ខ មានប្រការច្រើន និងសម្បត្តិមានប្រការច្រើន យ៉ាងនេះឯង ៗ ស្រីទាំងឡាយណា ឲ្យនូវខ្លួនជារបស់ខ្លួន ដល់បុគ្គលស្វែងរកនូវគុណដ៏ធំ ដើម្បីប្រយោជន៍ដល់បុណ្យ ស្រីទាំងឡាយនោះ ឈ្មោះថាអ្នកបរិបូណ៌ដោយសំឡាញ់ តែងបាន នូវព្រះនិព្វាន មានបំណែកមិនមានបច្ច័យប្រជុំតាក់តែង ៗ កម្មជាអតីត ជាបច្ចុប្បន្ន ជាអនាគតនៃយើងខ្ញុំអស់ហើយ កម្មទាំងពួង របស់យើងខ្ញុំ អស់រលីងហើយ បពិត្រព្រះអង្គមានបក្ខុ យើងខ្ញុំសូមថ្វាយបង្គំនូវព្រះបាទា ៗ

និព្វាណាយ វទន្តិនំ កឹ តេ(១) វក្ខាម ឧត្តរឹ
សទ្ធសង្ឃគតោសោ(២) យោ បប្បោថ(៣) អមតំ បទន្តិ ។

ឥត្ថំ សុទំ យសោធរាបមុខានិ អដ្ឋារស ភិក្ខុនី សហស្សានិ ភគវតោ សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ។

អដ្ឋារសថេរីសហស្សានមបទានំ សមត្តំ ។

## ឧទ្ទានំ

កុណ្ឌលា គោតមី ចេវ ធម្មទិន្នា ច សកុលា
នន្ទា ច សោណា ច កាបិលានី យសោធរា ។
ទសសហស្សភិក្ខុនី អដ្ឋារសសហស្សកា(៤)
សតានិ ចេវ ចត្តារិ អដ្ឋសត្តតិមេវ ច(៥) ។

កុណ្ឌលកេសវគ្គោ តតិយោ ។

---

១ ឱ. កិញ្ច ។ ២ ម. សទ្ធិសង្ឃគតោសោ ។ ៣ ម. បប្បោតំ ។ ៤ ឱ ៖ សដ្ឋារសសហស្សា គាថាយោ គណិតាវិហាតិ ទិស្សន្តិ ។ ៥ ម. គាថាសតានិ ។ ចត្តារិ ឆ ច សត្តតិមេវ ចាតិ ទិស្សន្តិ ។

បុគ្គលណា មានទោសគឺបច្ច័យប្រជុំតាក់តែងស្ងប់រម្ងាប់ហើយ ដល់នូវចំណែកព្រះនិព្វាន ឈ្មោះអមតៈ យើងខ្ញុំនឹងក្រាបទូលដល់ព្រះអង្គ នូវបុគ្គលនោះ ទៀតក្រៃលែងជាងពួកស្រី ដែលពោលពីព្រះនិព្វាន ដូចម្ដេចកើត ។

បានឮថា ព្រះភិក្ខុនី ១៨.០០០ រូប មានព្រះនាងយសោធរាភិក្ខុនីជាប្រមុខ បានសម្ដែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ អដ្ឋារសថេរីសហស្សានមបទាន ។

## ឧទ្ទាន

កុណ្ឌលកេសីថេរិយាបទាន ១ កិសាគោតមីថេរិយាបទាន ១ ធម្មទិន្នាថេរិយាបទាន ១ សកុលាថេរិយាបទាន ១ នន្ទាថេរិយាបទាន ១ សោណាថេរិយាបទាន ១ ភទ្ទកាបិលានីថេរិយាបទាន ១ យសោធរាថេរិយាបទាន ១ ទសសហស្សថេរីនមបទាន ១ អដ្ឋារសថេរីសហស្សានមបទាន ១ មានគាថាបំរួន ៤៧៨ ។

ចប់ កុណ្ឌលកេសវគ្គ ទី ៣ ។

# ចតុត្ថោ ខត្តិយកញ្ញាវគ្គោ

## បឋមំ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទានំ

(៣១) ភវា សព្វេ បរិក្ខីណា ភវសន្ធិ(១) វិមោចិតា
សព្វាសវា ច នោ នត្ថិ អារោចេម មហាមុនេ ។
បរិកម្មញ្ច កុសលំ យង្កិញ្ចិ សាធុ បត្ថិតំ
បរិភោគំ មយា(២) ទិន្នំ តុយ្ហត្ថាយ មហាមុនេ ។
ពុទ្ធបច្ចេកពុទ្ធានំ សាវកានញ្ច បត្ថិតំ
បរិភោគំ មយា(២) ទិន្នំ តុយ្ហត្ថាយ មហាមុនេ ។
ឧច្ចានីចំ មយា កម្មំ ភិក្ខូនំ សាធុ បត្ថិតំ
ឧច្ចាកុលបរិកម្មំ កតម្ហេហិ មហាមុនេ ។
តេនេវ សុក្កមូលេន ចោទិតា កម្មសម្បទា
មានុសិកមតិក្កន្តា ជាយឹសុ ខត្តិយេ កុលេ ។

---

១ ម. ភវាសត្តិ ។ ២ ឱ. បរិភោគំ អយំ ។ ម. បរិភោគមយំ ។ ៣ ឱ. ឧច្ចានីចមយំ ។

# ខត្តិយកញ្ញាវគ្គ ទី ៤

## អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ទី ១

(៣១) បពិត្រព្រះមហាមុនី យើងខ្ញុំសូមក្រាបទូលថា ភពទាំងពួងនៃយើងខ្ញុំអស់ហើយ តំណានៃភព យើងខ្ញុំបានដោះចេញហើយ អាសវៈទាំងពួង របស់យើងខ្ញុំ មិនមានឡើយ ។ បពិត្រព្រះមហាមុនី កុសលណាមួយ ដែលយើងខ្ញុំបរិកម្មហើយ ទាំងប្រាថ្នាដោយប្រពៃហើយ គ្រឿងប្រើប្រាស់ យើងខ្ញុំបានឲ្យហើយ ដើម្បីប្រយោជន៍ព្រះអង្គ ។ បពិត្រព្រះមហាមុនី គ្រឿងប្រើប្រាស់ យើងខ្ញុំបានឲ្យហើយ ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័កទាំងឡាយ បានប្រាថ្នាហើយដើម្បីប្រយោជន៍ នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កម្មខ្ពស់និងទាប យើងខ្ញុំបានតម្កល់ទុក ដើម្បីពួកភិក្ខុដោយប្រពៃ ការបរិកម្មក្នុងត្រកូលដ៏ខ្ពស់ យើងខ្ញុំបានធ្វើរួចហើយ ។ នាងខត្តិយកញ្ញាទាំងឡាយ ជាអ្នកបរិបូណ៌ដោយកម្ម ត្រូវកុសលមូលនោះឯង មកដាស់តឿន ហើយកន្លងនូវធម៌របស់មនុស្ស បានមកកើតក្នុងខត្តិយត្រកូល ។

ឧបចិតេ(១) កតេ កម្មេ   ជាតិយា ចាបិ ឯកតោ
បច្ឆិមេ ឯកតោ ជាតា   ខត្តិយា កុលសម្ភវា ។
រូបវតី ភោគវតី   លាភសក្ការបូជិតា
អន្តេបុរេ មហាវីរ   ទេវានំ ឥវ នន្ទនេ ។
និព្វិន្ទិត្វា អគារម្ហា   បព្វជិម្ហានគារិយំ
កតិបាហំ ឧបាទាយ   សព្វា បត្តម្ហ និព្វុតឹ ។
ចីវរំ បិណ្ឌបាតញ្ច   បច្ចយំ សយនាសនំ
ឧបនេន្តិ ពហូ អម្ហេ   សទា សក្កតបូជិតា ។
កិលេសា ឈាបិតា មយ្ហំ   ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា   វិហរាម អនាសវា ។
ស្វាគតំ វត មេ អាសិ   ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា   កតំ ពុទ្ធស្ស សាសនំ ។

---

១ ម. កតមេតំ ។

កម្មដែលយើងខ្ញុំបានសន្សំ បានធ្វើហើយ ក្នុងជាតិជាមួយគ្នា ក្នុងបច្ឆិមជាតិ យើងខ្ញុំក៏កើតក្នុងខត្តិយត្រកូលជាមួយគ្នា ។ បពិត្រព្រះអង្គមានព្យាយាមធំ យើងខ្ញុំមានរូបល្អ ទាំងមានភោគសម្បត្តិច្រើន ទាំងមានលាភៈនិងគ្រឿងសក្ការៈ ត្រូវពួកជនបូជាហើយ នៅក្នុងព្រះរាជវាំង បីដូចជានៅក្នុងនន្ទនឧទ្យាននៃពួកទេវតា ។ យើងខ្ញុំទាំងអស់គ្នា នឿយណាយហើយចេញចាកផ្ទះ ចូលទៅកាន់ផ្នួស នៅអាស្រ័យត្រឹមតែពីរបីថ្ងៃ ក៏បានដល់ព្រះនិព្វាន ។ ជនទាំងឡាយដ៏ច្រើន តែងបង្អោននូវចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ដើម្បីយើងខ្ញុំ បូជានូវគ្រឿងសក្ការៈ ដល់យើងខ្ញុំ សព្វ ៗ កាល ។ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ យើងខ្ញុំដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្ទឹង ។ ឱ! យើងខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនារបស់ព្រះពុទ្ធ យើងខ្ញុំបានធ្វើហើយ ។

កាចិ បព្វជិតា អត្ថិ   សព្វទស្សាវិនោ(១) ពហូ
ទេវា ច កិន្នរា នាគា   ពុជ្ឈិស្សន្តិ អនាគតេ ។
បដិសម្ភិទា ចតស្សោ   វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា   កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ យសវតីបមុខានិ ខត្តិយកញ្ញា ភិក្ខុនិយោ អដ្ឋារសសហស្សានិ ភគវតោ សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ។

អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទានំ សមត្តំ ។

## ទុតិយំ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានំ

(៣២) ចូឡាសីតិសហស្សានិ   ព្រាហ្មណកុលសម្ភវា(២)
សុខុមាលហត្ថបាទា   បុរេ តុយ្ហំ មហាមុនេ ។
វេស្សសុទ្ទកុលេ ជាតា   ទេវា នាគា ច កិន្នរា
ចតុទ្ទីបា ពហូ កញ្ញា   បុរេ តុយ្ហំ មហាមុនេ ។

---

១ ឱ. សព្វទស្សាវិនោ ។ ២ ឱ. ព្រាហ្មញ្ញកុលសម្ភវា ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបាន ធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខត្តិយកញ្ញាភិក្ខុនី ចំនួន ១៨.០០០ រូប មានព្រះនាងយសោធរាភិក្ខុនីជាប្រធាន បានសម្ដែងនូវគាថាទាំងនេះ ចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីអបទាន ។

# ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីអបទាន ទី ២

(៣៤) បពិត្រព្រះមហាមុនី ភិក្ខុនី ៨៤.០០០ កើតក្នុងត្រកូលព្រាហ្មណ៍ មានជើងដៃទន់ល្វន់ ក្នុងបុរីនៃព្រះអង្គ ។ បពិត្រព្រះមហាមុនី ពួកស្ត្រី កើតក្នុងវេស្សត្រកូល និងសុទ្ទ-ត្រកូល ពួកទេវតា ពួកនាគ ពួកកិន្នរ ពួកនាងកញ្ញាដ៏ច្រើន ទាំង ៤ ទ្វីប ក្នុងបុរីរបស់ព្រះអង្គ ។ ពួកស្រីខ្លះ ក៏បានបួស ពួកទេវតាច្រើន ពួកកិន្នរ និងពួកនាគដែលជាអ្នកឃើញធម៌ទាំងពួងហើយ គង់នឹងបានត្រាស់ដឹង ក្នុងអនាគតកាល ។

អនុភោត្វា យសំ សព្វំ   បត្វាន សព្វសម្បទា
តុម្ហំ(១) បសាទំ បដិលទ្ធា   ពុជ្ឈិស្សន្តិ អនាគតេ ។
អម្ហេ ព្រាហ្មណជាតា តុ   ព្រហ្មញ្ញកុលសម្ភវា(២)
លក្ខណេ ច(៣) មហាវីរ   ធារេម វត្ថាម ចក្ខុមា ។
ឧទាហរា(៤) ករា សព្វេ   មូលតណ្ហា សមូហតា
សមុច្ឆិន្នា អនុសយា   បុញ្ញសង្ខារឃាលិតា ។
សមាធិគោចរា សព្វេ   សមាបត្តិវសី តថា(៥)
ឈានេន ធម្មរតិយា   វិហរិស្សាម តោ សទា ។
ករេន្តិ អរិដ្ឋា ច   សង្ខាភបិ ច ខេបិតា
សុទុទ្ទសំ បទំ គន្ត្វា   អនុជានិម្ហ នាយក ។

---

១ ឱ. តុយ្ហិ ។ ២ ឱ. ព្រហ្មញ្ញកុលសម្ភវា ។ ៣ ឱ. ម. បេក្ខតោ តោ ។ ៤ ឱ. ម. ឱបា-គតា ។ ៥ ម. កតា ។

ជនទាំងឡាយនោះ បានទទួលនូវយសទាំងពួង សម្រេចសម្បត្តិទាំងពួង ហើយបាននូវសេចក្តីជ្រះថ្លាក្នុងព្រះអង្គ មុខជានឹងបានត្រាស់ដឹង ក្នុងអនាគតកាល ។ បពិត្រព្រះអង្គមានព្យាយាមធំ មានចក្ខុ យើងខ្ញុំជាធីតានៃព្រាហ្មណ៍ កើតក្នុងត្រកូលព្រាហ្មណ៍ ប្រកបដោយលក្ខណៈ សូមក្រាបថ្វាយបង្គំព្រះបាទា (របស់ព្រះអង្គ) ។ ភពទាំងឡាយ យើងខ្ញុំលះបង់ចោលហើយ ឫសគល់នៃតណ្ហា យើងខ្ញុំបានដកចេញហើយ អនុស័យ យើងខ្ញុំបានផ្តាច់ផ្តិលហើយ បុញ្ញាភិសង្ខារ យើងខ្ញុំបានទំលាយចេញហើយ ។ យើងខ្ញុំទាំងអស់មានសមាធិជាអារម្មណ៍ ជាអ្នកស្ទាត់ជំនាញក្នុងសមាបត្តិ នឹងប្រព្រឹត្តនៅ ដោយការត្រេកអរក្នុងធម៌ ដោយឈានសព្វ ៗ កាល ។ បពិត្រព្រះអង្គជានាយក តណ្ហាដែលនាំសត្វទៅកាន់គត អវិជ្ជា និងសង្ខារទាំងឡាយ យើងខ្ញុំបានធ្វើឲ្យអស់ហើយ យើងខ្ញុំយល់ច្បាស់នូវធម៌ ព្រោះដល់នូវបទគឺព្រះនិព្វាន ដែលបុគ្គលឃើញបានដោយកម្រ ។

## ទុតិយំ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានំ

ឧបការា មមំ តុម្ហេ ទីឃរត្តំ កតទ្ធិនោ(១)
ចតុន្នំ(២) សំសយំ ឆេត្វា សព្វា កង្ខជ និព្វុតឹ ។
វឌ្ឍិត្វា មុនិនោ បាទេ កត្វា ឥទ្ធិវិកុព្វនំ
កាចិ ទស្សេន្តិ អាលោកំ អន្ធការំ តថាបរំ(៣) ។
ទស្សេន្តិ ចន្ទសុរិយេ សាគរញ្ច សមច្ឆកំ
សិនេរុំ បរិភណ្ឌញ្ច ទស្សេន្តិ បារិជត្តកំ ។
តាវត្តឹសញ្ច ភវនំ យាមំ ទស្សេន្តិ ឥទ្ធិយា
តុសិតា និម្មិតា ទេវា វសវត្តី មហិស្សរា ។
ព្រហ្មានោ កាចិ ទស្សេន្តិ សង្កមញ្ច មហារហំ
ព្រហ្មវណ្ណញ្ច មាបេត្វា ធម្មំ ទេសេន្តិ សុញ្ញតំ ។
នានាវិកុព្វនំ កត្វា ឥទ្ធឹ ទស្សិយ សត្ថុនោ
ទស្សយឹសុ ពលំ សព្វា បាទេ វន្ទឹសុ សត្ថុនោ ។

---

១ ឱ. កតាវិនោ ។ ២ ឱ. ពហុន្នំ ។ ៣ ម. អន្ធការមថាបរំ ។

នាងទាំងឡាយ មានឧបការៈដល់តថាគត នាងទៅកាន់ផ្លូវឆ្ងាយ អស់កាលមានរាត្រីវែង នាងទាំងអស់គ្នា ចូរកាត់នូវសេចក្តីសង្ស័យ នៃបរិស័ទទាំង ៤ ហើយទៅកាន់ព្រះនិព្វានចុះ ។

ពួកភិក្ខុនីខ្លះ ថ្វាយបង្គំព្រះបាទានៃព្រះមុនីរួចហើយ ក៏ធ្វើនូវការផ្លែងឫទ្ធិ សម្តែងនូវពន្លឺ ហើយសម្តែងនូវងងឹតដទៃទៀត ពួកភិក្ខុនីខ្លះ សម្តែងព្រះចន្ទ្រនិងព្រះអាទិត្យ ខ្លះសម្តែងសាគរប្រកបដោយត្រី ខ្លះសម្តែងភ្នំសិនេរុនិងភ្នំបរិកណ្ណ ខ្លះសម្តែងដើមបារិច្ឆត្តព្រឹក្ស ។ ខ្លះសម្តែងភពតាវត្តឹង្ស ខ្លះសម្តែងភពឈ្មោះយាមៈដោយឫទ្ធិ ខ្លះនិម្មិតជាទេវតាមានឥស្សរៈធំ នៅក្នុងជាន់តុសិតនិងវសវត្តី ។ ពួកខ្លះនិម្មិតជាព្រហ្ម សម្តែងទីចង្ក្រមមានតម្លៃច្រើន ខ្លះនិម្មិតភេទជាព្រហ្ម សម្តែងនូវធម៌ដ៏សូន្យ ។ លុះពួកស្រីទាំងអស់ បានផ្លែងឫទ្ធិប្លែកៗ ហើយសម្តែងឫទ្ធិ សម្តែងកម្លាំងថ្វាយព្រះសាស្តារួចហើយ ថ្វាយបង្គំព្រះបាទាព្រះសាស្តា ទូលថា

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ឥទ្ធីសុ ច វសី ហោម ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោម មហាមុនេ ។
បុព្វេនិវាសំ ជានាម ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភានេ តថេវ ច
ញាណំ អម្ហំ មហាវីរ ឧប្បន្នំ តវ សន្តិកេ ។
ពុទ្ធានំ លោកនាថានំ សង្គមន្តេហិ ឧស្សិតំ
អធិការ ពហូ អម្ហេ តុយ្ហត្ថាយ មហាមុនេ ។
យំ អម្ហំ បុរិមំ កម្មំ(១) កុសលំ សរ តំ មុនិ
តុយ្ហត្ថាយ មហាវីរ បុញ្ញុបចិតានិ នោ ។

---

១ ម. យំ អម្ហេហិ កតំ កម្មន្តិ ទិស្សន្តិ ។

បពិត្រព្រះមហាមុនី យើងខ្ញុំជាអ្នកស្ទាត់ទំនាញក្នុងឫទ្ធិទាំង-ឡាយផង ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ យើងខ្ញុំដឹងច្បាស់ នូវបុព្វេនិវា-សៈ ទិព្វចក្ខុ យើងខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងរបស់យើងខ្ញុំអស់ហើយ ភពថ្មីទៀត ក្នុងកាលឥឡូវនេះគ្មានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្ប-ដិសម្ភិទាផង ក្នុងធម្មប្បដិសម្ភិទាផង ក្នុងនិរុត្តិប្បដិសម្ភិទាផង ក្នុងបដិភាណប្បដិសម្ភិទាផង របស់យើងខ្ញុំ កើតឡើងហើយ ក្នុងសំណាក់ព្រះអង្គ ។ បពិត្រព្រះមហាមុនី ការគប់រកព្រះពុទ្ធទាំងឡាយ ដែលជាទីពឹងនៃសត្វលោក យើងខ្ញុំបានជួបហើយ យើងខ្ញុំបានកសាងបុណ្យដ៏ច្រើន ដើម្បីប្រយោជន៍នៃព្រះអង្គ ។ បពិត្រព្រះមហាមុនី កម្មណា ដែលយើងខ្ញុំបានធ្វើហើយ ក្នុងកាលមុន សូមព្រះអង្គរឭក នូវកម្មជាកុសលនោះចុះ បពិត្រព្រះមហាវីរៈ បុណ្យទាំងឡាយ យើងខ្ញុំបានសាងសន្សំហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។

## ទុតិយំ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានំ

សតសហស្សេ ឥតោ កប្បេ បទុមុត្តរោ មហាមុនិ
បុរំ ហំសវតី នាម សម្ពុទ្ធស្ស កុលាលយំ(១)។
ទ្វារេន ហំសវតិយំ គង្គា សន្ទតិ សព្វទា
ឧព្វាឡ្ហា នទិយា ភិក្ខូ គមនំ ន លភន្តិ តេ ។
ទិវសំ ទ្វេ តយោ ចេវ សត្តាហំ មាសិកំ តតោ
ចាតុម្មាសម្បិ សម្បុណ្ណំ គមនំ ន លភន្តិ តេ ។
តទា អហុ សត្តសារោ ជដ្ឋិយោ នាម(២) រដ្ឋកោ
ឱរតីរេ(៣) ភិក្ខវោ ទិស្វា សេតុំ គង្គាយ ការយិ(៤)។
តទា សតសហស្សេហិ សេតុំ គង្គាយ ការយិ
សង្ឃស្ស ចារិមេ(៥) តីរេ វិហារញ្ច អការយិ ។
ឥត្ថិយោ បុរិសា ចេវ ឧច្ចានីចកុលានិ ច
តស្ស សេតុំ វិហារំ(៦) ច សមភាគំ អកំសុ តេ ។

---

១ ឱ. ម. កុណសយំ ។ ២ ឱ. ម. ជដិលោ នាម ។ ៣ ឱ. ម. ឱរុទ្ធេ ។ ៤ ឱ. សេតុ-តោ សត្តការយិ ។ ៥ ឱ. ម. ឱរិមេ ។ ៦ ឱ. ម. វិហារេ ។

## ចតុរាសីតិសហស្សព្រាហ្មណកញ្ញាបេរិនមបកាន ទី ២

ក្នុងកប្បទីមួយសែន អំពីកប្បនេះ មានព្រះមហាមុនីមួយព្រះអង្គព្រះនាមបទុមុត្តរៈ ឯបុរីឈ្មោះហង្សវតី ជាលំនៅនៃត្រកូលព្រះសម្ពុទ្ធ ។ ស្ទឹងគង្គាតែងហូរទៅ ក្នុងបុរីឈ្មោះហង្សវតី តាមទ្វារសព្វៗកាល ពួកភិក្ខុទាំងនោះត្រូវទឹកស្ទឹងបៀតបៀន ក៏ទៅមកមិនបាន ។ ភិក្ខុទាំងឡាយនោះ ទៅមិនបាន អស់ពីរថ្ងៃ អស់បីថ្ងៃ អស់ ៧ ថ្ងៃ អស់មួយខែដរាបទាល់តែពេញបួនខែ ។ គ្រានោះ មានបុរសជាខ្ញុំមសាររបស់សត្វ ឈ្មោះជដ្ឋៈ ជាអ្នកនៅក្នុងដែន បានឃើញពួកភិក្ខុនៅត្រើយខាងអាយ ក៏ឲ្យគេសាងស្ពាន ត្រង់ស្ទឹងគង្គា ។ គ្រានោះ បុរសនោះ បានសាងស្ពាននាស្ទឹងគង្គា ដោយតម្លៃមួយសែនកហាបណៈផង បានសាងវិហារក្នុងត្រើយខាងនាយនិងត្រើយខាងអាយ ដើម្បីភិក្ខុសង្ឃផង ។ ពួកស្រីពួកបុរស ពួកត្រកូលខ្ពស់និងទាប ជនទាំងនោះ បានធ្វើស្ពានផង វិហារផង មានភាគស្មើគ្នា ដើម្បីភិក្ខុសង្ឃនោះ ។

អម្ហេ អញ្ញេ ច មនុជា   វិប្បសន្នេន ចេតសា
តស្ស ធម្មេសុ ទាយាទា   នគរេ ជនបទេសុ ច ។
ឥត្ថី បុមា កុមារា ច   ពហូ ចេវ កុមារិកា
សេតុនោ ច វិហារស្ស   វាលុកា អាកិរឹសុ តេ ។
វីថិសម្មជ្ជនំ កត្វា   កទលីបុណ្ណឃដទ្ធជា(១)
ធូបំ(២) ចុណ្ណញ្ច មាលញ្ច   ការំ(៣) កត្វាន សត្ថុនោ ។
សេតុវិហារេ កត្វាន   និមន្តេត្វា វិនាយកំ
មហាទានំ ទទិត្វាន   សម្ពោធឹ អភិបត្ថយឹ ។
បទុមុត្តរោ មហាវីរោ   គរុកោ(៤) សព្វបាណិនំ
អនុមោទនិយំ កត្វា   ព្យាកាសិ(៥) មហាមុនិ ។
សតសហស្សេ អតិក្កន្តេ   កប្បោ ហេស្សតិ ភទ្ទកោ
ភវាភវេ សុខំ លទ្ធា(៦)   បាបុណិស្សតិ ពោធិយំ ។
យេ កេចិ ហត្ថកម្មញ្ច(៧)   កតាវី នរនារិយោ
អនាគតម្ហិ អទ្ធានេ   សព្វេ ហេស្សន្តិ សម្មុខា ។

---

១ ខ. កទលីបុណ្ណកុដទ្ធជា ។ ២ ឱ. ម. ធូមំ ។ ៣ ឱ. សក្ការំ ។ ៤ ឱ. ម. តារកោ ។ ៥ ឱ. ម. ពាសិ ជដិលស្ស ។ ៦ ឱ. ម. ភវាភវេនុភោត្វាន ។ ៧ ឱ, កេចិ ហត្ថបទំ កម្មំ ។ ម. កេចិ ហត្ថបរិកម្មំ ។

ពួកយើងខ្ញុំផង ពួកមនុស្សដទៃផង ក្នុងនគរ ក្នុងជនបទ មានចិត្តជ្រះថ្លា ជាអ្នកទទួលមតិកក្នុងធម៌នៃព្រះសម្ពុទ្ធនោះ ។ ពួកស្រី ពួកប្រុស ពួកកុមារ ពួកកុមារិកាជាច្រើន ជនទាំងនោះ បាននាំគ្នាពេយកាយដីខ្សាច់ ដល់ស្ពានផង ដល់វិហារផង ។ ជនទាំងនោះ នាំគ្នាដាំដើមចេក តម្កល់ក្អមពេញដោយទឹក លើកទង់ ពោសសំអាតផ្លូវថ្នល់ បូជាធូប គ្រឿងលំអិត កម្រងផ្កា ជាគ្រឿងសក្ការៈថ្វាយព្រះសាស្តា ។ លុះជនទាំងនោះ បានធ្វើស្ពាននិងវិហាររួចហើយ និមន្តព្រះសាស្តាជានាយក ថ្វាយមហាទាន ហើយប្រាថ្នានូវសម្ពោធិញ្ញាណ ។

ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ ជាមហាវីរៈ ជាទីគោរពរបស់សព្វសត្វទាំងឡាយ ទ្រង់បានធ្វើអនុមោទនា ហើយព្យាករថា ក្នុងកប្បទីមួយសែនកន្លងទៅ មានកប្បកើតឡើង បុរសនោះ បាននូវសេចក្ដីសុខ ក្នុងភពតូចភពធំ ហើយនឹងដល់ពោធិញ្ញាណ ។ ពួកនរៈ នារីណាមួយ ដែលបានធ្វើនូវហត្ថកម្ម លុះដល់កាលជាអនាគត ជនទាំងអស់នោះ នឹងមានក្នុងទីចំពោះព្រះភក្ត្រ (នៃព្រះពុទ្ធនោះ) ។

## ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានំ

តេន កម្មវិបាកេន ចេតនាបណិធីហិ ច
ឧប្បន្នា ទេវភវនេ តុយ្ហន្តេ បរិចារិកា ។
ទិព្វសុខំ អសង្ខេយ្យំ មានុសញ្ច អសង្ខិយំ
អនុភោន្តិ ចិរំ កាលំ(១) សំសរិត្វា(២) ភវាភវេ ។
សតសហស្សិតោ កប្បេ សុកតំ កម្មសម្បទំ
សុខុមាលិមនុស្សេសុ(៣) អហោ ទេវបុរេ វរេ ។
រូបភោគយសញ្ចេវ អហោ កិត្តិសុខំ បិយំ(៤)
លភាម សតតំ សព្វំ សុកតំ កម្មសម្បទំ ។
បច្ឆិមេ ភវសម្បត្តេ ជាយាម ព្រាហ្មណេ កុលេ
សុខុមាលហត្ថបាទា សក្យបុត្តនិវេសនេ ។
សព្វកាលម្បិ បថវឹ ន បស្សាម នលង្កតំ
ចិក្ខល្លំ ភូមឹ គមនំ ន បស្សាម មហាមុនិ ។

---

១ ឱ. តុយ្ហំ ភោ បរិចារ ប ។ ម. តុម្ហន្តេ បរិចារេម ។ ២ ម. សំសរិម្ហ ។ ៣ ឱ. ម. សុខុមាលី មនុស្សានំ ។ ៤ ឱ. កិត្តិតសក្កតា ។ ម. កិត្តី ច សក្កតា ។

## ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីអបទាន ទី ២

ពួកស្រីជាអ្នកបម្រើទាំងអស់នោះរបស់ព្រះអង្គ កើតហើយក្នុងគតិនៃទេវតា ព្រោះផលនៃកុសលកម្មនោះផង ព្រោះការតម្កល់ទុកនូវចេតនានោះផង ។ ជនទាំងនោះ សោយទិព្វសុខរាប់មិនអស់ផង សោយសុខរបស់មនុស្សរាប់មិនអស់ផង ត្រាច់រង្គាត់ក្នុងភពតូចភពធំ អស់កាលជាយូរអង្វែង ។ ក្នុងកប្បទីមួយសែន អំពីកប្បនេះ កម្មសម្បត្តិ យើងខ្ញុំធ្វើល្អហើយក្នុងពួកមនុស្សជាអ្នកល្អិតល្អ ទាំងក្នុងទេវបុរីដ៏ប្រសើរ ។ យើងខ្ញុំតែងបាន នូវរូបល្អ នូវភោគសម្បត្តិនិងយស នូវសេចក្តីសរសើរ សេចក្តីសុខនិងសេចក្តីស្រឡាញ់ ឯកម្មសម្បត្តិទាំងអស់ យើងខ្ញុំធ្វើល្អហើយ ដល់មកក្នុងបច្ឆិមភព យើងខ្ញុំបានមកកើតក្នុងត្រកូលព្រាហ្មណ៍ មានដៃជើងទន់ល្វន់ ក្នុងព្រះរាជនិវេសន៍នៃសក្យបុត្រ ។ បពិត្រព្រះមហាមុនី យើងខ្ញុំមិនដែលឃើញផែនដី ដែលពួកជនមិនបានប្រដាប់រៀបចំសព្វកាលផង មិនដែលឃើញដំណើរទៅកាន់ទីមានភក់ផង ។

អគារាភវសន្តេ អម្ហេ សក្ការំ សព្វកាលិកំ
ឧបេន្តិ សទា សព្វំ បុព្វកម្មជលេន នោ(១) ។
អគារំ បជហិត្វាន បព្វជិត្វានគារិយំ
សំសារបថំ និតិណ្ណា នត្ថិ ទានិ បុនព្ភវោ ។
ចីវរំ បិណ្ឌបាតញ្ច បច្ចយំ សយនាសនំ
ឧបេន្តិ សទា អម្ហេ សហស្សនិតោ តតោ ។
កិលេសា ឈាបិតា អម្ហាកំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហារាម អនាសវា ។
ស្វាគតំ វត នោ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

---

១ ឱ. បុព្វកម្មផលំ គតោ ។

កាលយើងខ្ញុំទៅគ្រប់គ្រងផ្ទះ ពួកជនតែងនាំគ្រឿងសក្ការៈប្រកបដោយកាលទាំងពួង អស់កាលគ្រប់កាល ដោយផលនៃបុព្វកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានលះបង់ផ្ទះ ហើយចូលទៅកាន់ផ្នួស បានឆ្លងផ្លូវគឺសំសារវដ្ដ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ជនទាំងឡាយ តែងនាំនូវចីវរប្បច្ច័យផង បិណ្ឌបាតប្បច្ច័យផង សេនាសនប្បច្ច័យផង ឲ្យដល់យើងខ្ញុំចំនួនមួយពាន់កហាបណៈ អំពីទីនោះ ៗ សព្វ ៗ កាល ៗ កិលេសទាំងឡាយ យើងខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់យើងខ្ញុំ ដកចោលហើយ យើងខ្ញុំជាបុគ្គលមិនមានអាសវៈព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្ដាច់នូវទន្លឹង ។ ឱ! យើងខ្ញុំមកល្អហើយ ក្នុងសំណាក់ព្រះពុទ្ធ ជាបុគ្គលប្រសើរវិជ្ជា ៣ យើងខ្ញុំបានដល់ហើយ សាសនា របស់ព្រះពុទ្ធយើងខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ យើងខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ យើងខ្ញុំក៏បានប្រតិបត្តិហើយ ។

ឥត្ថំ សុទំ ចតុរាសីតិ ព្រាហ្មណកញ្ញាភិក្ខុនីសហ-ស្សានិ ភគវតោ សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ។

ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទានំ សមត្តំ ។

## តតិយំ ឧប្បលទាយិកាថេរិយាបទានំ

(៣៣) នគរេ អរុណវតិយា អរុណោ នាម(១) ខត្តិយោ
តស្ស រញ្ញោ អហំ ភរិយា ឯកជ្ឈំ ចារយាមហំ(២) ។
រហោគតា និសីទិត្វា ឯវំ ចិន្តេសហំ តទា
កុសលំ មេ កតំ នត្ថិ អាទាយ គមិយំ មម ។
មហាភិតាបំ កដុកំ ឃោររូបំ សុទារុណំ
និរយំ នូន គច្ឆាមិ ឯត្ថ មេ នត្ថិ សំសយោ ។
ឯវាហំ ចិន្តយិត្វាន បហំសេត្វាន មានសំ
រាជានំ ឧបគន្ត្វាន ឥទំ វចនមព្រវី ។

---

១ ម. អរុណវា នាម ។ ២ ម. វារយាមហំ ។

ឧប្បលទាយិកាថេរិយាបទាន ទី ៣

បានឮថា ព្រះព្រាហ្មណកញ្ញាគិក្ខុនី ៨៤.០០០ រូប បានសម្តែងនូវគាថាទាំងនេះ ចំពោះព្រះភក្រ្តព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន ។

# ឧប្បលទាយិកាថេរិយាបទាន ទី ៣

(៣៣) ក្នុងនគរអរុណវតី មានក្សត្រមួយព្រះអង្គ ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ ខ្ញុំបានញុំាងផននូវពួកខ្លះឲ្យបម្រើ ៗ ក្នុងកាលនោះ ខ្ញុំអង្គុយក្នុងទីស្ងាត់ហើយត្រិះរិះយ៉ាងនេះថា បើអាត្មាអញមិនបានធ្វើកុសល ដែលគប្បីកាន់យកទៅបានទេ អាត្មាអញនឹងទៅកាន់នរក មានសេចក្តីក្តៅក្រហាយធំ ខ្លាចផ្សា មានសភាពយោរយៅ អាក្រក់ក្រៃលែង ដោយពិត សេចក្តីសង្ស័យរបស់អាត្មាអញ ក្នុងរឿងនេះគ្មានទេ ៗ លុះខ្ញុំគិតយ៉ាងនេះហើយ ក៏ញុំាងចិត្តឲ្យរីករាយចូលទៅគាល់ព្រះរាជា ហើយក្រាបបង្គំទូល នូវពាក្យនេះថា

ឥត្ថី នាម មយំ ទេវ   បុរិសា ន ភវាម នោ(១)
ឯកំ មេ សមណំ ទេហិ   ភោជយិស្សាមិ ខត្តិយ ។
អទាសិ មេ តទា រាជា   សមណំ ភាវិតិន្ទ្រិយំ
តស្ស បត្តំ គហេត្វាន   បរមន្នេន បូរយឹ ។
បូរេត្វា បរមំ អន្នំ   សហ សុគន្ធលេបនំ
មហាចេលេន ឆាទេត្វា   អទាសឹ តុដ្ឋមានសា ។
តេន កម្មេន សុកតេន   ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ   តាវតឹសំ អគញ្ឆហំ ។
សហស្សទេវរាជូនំ   មហេសិត្តមការយឹ
សហស្សចក្កវត្តីនំ   មហេសិត្តមការយឹ ។
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ
នានាវិធំ ពហុំ អញ្ញំ(២)   តស្ស កម្មផលំ តតោ ។

---

១ ឱ. បុរិសាសនំ ភវិមយំ ។ ម. បុរិសា និត្ថា អហុ ។ ២ ឱ. បុញ្ញំ ។

បពិត្រព្រះសម្មតិទេព យើងខ្ញុំជាស្រី យើងខ្ញុំមិនមែនជាប្រុស បពិត្រព្រះមហាក្សត្រ សូមព្រះអង្គព្រះរាជទានសមណៈមួយរូប ដល់ខ្ញុំម្ចាស់ ៗ នឹងញុំាងសមណៈនោះឲ្យឆាន់ ៗ គ្រានោះឯង ព្រះរាជាបានទ្រង់ប្រទានសមណៈ មានឥន្ទ្រិយអប់រំហើយ ដល់ខ្ញុំ ទាំងខ្ញុំបានកាន់យកបាត្រ របស់សមណៈនោះ ហើយញុំាងបាត្រឲ្យពេញ ដោយបាយដ៏ឧត្តម ៗ លុះដាក់បាយដ៏ឧត្តម ព្រមទាំងគ្រឿងអប់ និងគ្រឿងលាបហើយ ក៏មានចិត្តត្រេកអរ បានយកសំពត់ផ្ទាំងធំគ្របបាត្រ ហើយនាំយកទៅប្រគេន ៗ ដោយកុសលកម្ម ដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ៗ ខ្ញុំបានធ្វើជាមហេសី នៃស្តេចទេវតាមួយពាន់ដង បានធ្វើជាមហេសី នៃស្តេចចក្រពត្តិមួយពាន់ដង ៗ ខ្ញុំបានធ្វើជាមហេសី នៃស្តេចប្រទេសរាជដ៏ធំទូលាយ រាប់ជាតិមិនអស់ ឯបុណ្យដទៃច្រើន មានប្រការផ្សេង ៗ ផលនៃបុណ្យនោះ ច្រើនលើសនោះទៅទៀត ៗ

## តតិយំ ឧប្បលទាយិកាថេរិយាបទានំ

ឧប្បលស្សេវ មេ វណ្ណោ  អភិរូបា សុទស្សនា
ឥត្ថី សព្វង្គសម្បន្នា  អភិជាតា ជុតិន្ធរា ។
បច្ឆិមេ ភវសម្បត្តេ  អជាយឹ សាកិយេ កុលេ
នារីសហស្សបាមោក្ខា  សុទ្ធោទនសុតស្សហំ ។
និព្វិន្ទិត្វា អគារេហំ  បព្វជឹ អនគារិយំ
សត្តមីរត្តិមប្បត្តា(១)  ចតុសច្ចំ អបាបុណឹ ។
ចីវរំ បិណ្ឌបាតញ្ច  បច្ចយំ សយនាសនំ
បរិមេតុំ ន សក្កោមិ  បិណ្ឌបាតស្សិទំ ផលំ ។
យំ មយ្ហំ បុរិមំ កម្មំ  កុសលំ សរសេ(២) មុនិ
តុយ្ហត្ថាយ មហាវីរ  បរិចត្តំ ពហុំ មយា(៣) ។
ឯកត្តឹសេ ឥតោ កប្បេ  យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ  បិណ្ឌបាតស្សិទំ ផលំ ។

---

១ ឱ. សត្តមីរត្តិ អប្បត្តា ។ ម. សត្តមីរត្តិសម្បត្តា ។ ២ ម. សរ មេ ។ ៣ ឱ. មម ។

ឧប្បលទាយិកាថេរិយាបទាន ទី ៣

សម្បុររបស់ខ្ញុំដូចផ្កាឧប្បល ខ្ញុំជាស្រីមានរូបល្អល្អះ គួរមើល មើល បរិបូណ៌ដោយអវយវៈទាំងអស់ កើតក្នុងត្រកូលខ្ពស់ ទ្រទ្រង់សេចក្តីរុងរឿង ដល់មកក្នុងបច្ឆិមភព ខ្ញុំបានមកកើត ក្នុងសក្យត្រកូល ជាប្រធាននៃស្រីមួយពាន់ នៃព្រះរាជបុត្រ របស់ព្រះបាទសុទ្ធោទនៈ ។ ខ្ញុំនឿយណាយក្នុងផ្ទះ ហើយ បួសទៅកាន់ផ្នួស លុះគ្រប់ ៧ រាត្រី ក៏បានយល់ច្បាស់នូវ សច្ចៈ ៤ ។ ខ្ញុំមិនអាចនឹងរាប់នូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យបានទេ នេះឯងជាផលនៃបិណ្ឌបាត ។ បពិត្រព្រះមុនីមានព្យាយាមធំ កុសលកម្មណា ដែលខ្ញុំបាន ធ្វើហើយ ក្នុងកាលមុន សូមព្រះអង្គលើកនូវកម្មជាកុសល នោះចុះ ឯអំពើល្អមានច្រើន ដែលខ្ញុំបានលះបង់ហើយ ដើម្បីប្រយោជន៍នៃព្រះអង្គ ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំ បានឲ្យបិណ្ឌបាតទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិឡើយ នេះជាផលនៃបិណ្ឌបាត ។

ទុវេ គតី បជានាមិ ទេវត្តំ អថ មានុសំ
អញ្ញំ គតឹ ន ជានាមិ បិណ្ឌបាតស្សិទំ ផលំ ។
ឧច្ចេ កុលេ បជានាមិ មហាសាលេ(១) មហទ្ធនេ
អញ្ញេ កុលេ ន ជានាមិ បិណ្ឌបាតស្សិទំ ផលំ ។
ភវាភវេ សំសរិត្វា សុក្កមូលេន ចោទិតោ
អមនាបំ ន បស្សាមិ សោមនស្សស្សិទំ(២) ផលំ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនិ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភានេ តថេវ ច
ញាណំ មម មហាវីរ ឧប្បន្នំ តវ សន្តិកេ ។

---

១ ឱ. ម. តយោ សាលេ ។ ២ ឱ. ម. សោមនស្សកតំ ។

ខ្ញុំស្គាល់តែគតិពីរ គឺទេវតានិងមនុស្ស ខ្ញុំមិនដែលស្គាល់គតិដទៃឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំស្គាល់តែត្រកូលខ្ពស់ ជាមហាសាល មានទ្រព្យច្រើន មិនដែលស្គាល់ត្រកូលដទៃឡើយ នេះជាផលនៃបិណ្ឌបាត ។ ខ្ញុំត្រាច់រង្គាត់ទៅក្នុងភពតូចភពធំ ត្រូវកុសលមូលដាស់តឿន មិនដែលបានជួបប្រទះ នឹងវត្ថុមិនពេញចិត្តឡើយ នេះជាផលនៃសេចក្ដីត្រេកអរ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មី មិនមានទៀតឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំព្រះអង្គ កើតឡើងក្នុងសំណាក់របស់ព្រះអង្គ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ៗ
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ៗ
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ៗ

ឥត្ថំ សុទំ អាយស្មា ឧប្បលទាយិកា ភិក្ខុនី
ភគវតោ សម្មុខា ឥមា គាថាយោ អភាសិត្ថាតិ ៗ

ឧប្បលទាយិកាថេរិយាបទានំ សមត្តំ ៗ

# ចតុត្ថំ សិង្គាលមាតាថេរិយាបទានំ

(៣៨) បទុមុត្តរេ នាម ជិនោ សព្វធម្មាន បារគូ
ឥតោ សតសហស្សម្ហិ កប្បេ ឧប្បជ្ជិ នាយកោ ៗ

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដក ចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុង សំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧប្បលទាយិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថា ទាំងនេះ ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ឧប្បលទាយិកាថេរិយាបទាន ។

## សិង្គាលមាតាថេរិយាបទាន ទី ៤

(៣៤) ព្រះជិនស្រីព្រះនាមបទុមុត្តរៈ ទ្រង់ដល់នូវត្រើយនៃធម៌ទាំង ពួង ជានាយក ទ្រង់កើតឡើង ក្នុងកប្បទីមួយសែនអំពីភទ្ទកប្បនេះ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

តទាហំ ហំសវតិយា ជាតាមច្ចកុលេ អហុំ
នានារតនបជ្ជោតេ ឥទ្ធេ ផីតេ មហទ្ធនេ ។
បិតុនា សហ គន្ត្វាន មហាជនបុរក្ខតា
ធម្មំ ពុទ្ធស្ស សុត្វាន បព្ពជឹ អនគារិយំ ។
បព្ពជិត្វាន កាយេន បាបកម្មំ វិវជ្ជយឹ
វចីទុច្ចរិតំ ហិត្វា អាជីវំ បរិសោធយឹ ។
ពុទ្ធេ បសន្នា ធម្មេ ច សង្ឃេ ច តិព្វគារវា
សទ្ធម្មស្សវនេ យុត្តា ពុទ្ធទស្សនសាលយា(១) ។
អគ្គំ សទ្ធាធិមុត្តានំ(២) អស្សោសឹ ភិក្ខុនឹ តទា
តំ ឋានំ បត្ថយិត្វាន តិស្សោ សិក្ខា អបូរយឹ ។
តតោ មំ សុគតោ អាហ ករុណានុគតាសយោ
យស្ស សទ្ធា តថាគតេ អចលា សុប្បតិដ្ឋិតា ។
សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ
សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ ។

---

១ ឱ. ម. ពុទ្ធទស្សនសាលសាតិ ទិស្សតិយេវ ។ ២ ឱ. ម. អង្គិរមុត្តានំ ។

កាលនោះ ខ្ញុំកើតក្នុងត្រកូលអាមាត្យ ដែលរុងរឿង ដោយកែវផ្សេងៗ ជាស្ដុកស្ដម្ភទូលំទូលាយ មានទ្រព្យច្រើន នៅក្នុងនគរហង្សវតី ។ ខ្ញុំបានទៅជាមួយនឹងបិតា មានមហាជនចោមរោម បានស្ដាប់ធម៌ របស់ព្រះពុទ្ធជាម្ចាស់ ហើយក៏ចូលទៅកាន់ផ្នួស ។ លុះខ្ញុំបួសរួចហើយ បានវៀរបាបកម្មដោយកាយ លះបង់វចីទុច្ចរិត ហើយជំរះអាជីវៈ ។ ខ្ញុំជ្រះថ្លាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានសេចក្ដីគោរពដ៏ក្លៀវក្លា ប្រកបក្នុងការស្ដាប់នូវព្រះសទ្ធម្ម ទាំងប្រកបដោយសេចក្ដីអាល័យចង់ឃើញនូវព្រះពុទ្ធ ។ គ្រានោះ ខ្ញុំបានឮនូវភិក្ខុនីដ៏ប្រសើរលើសជាងពួកភិក្ខុនីដែលមានសទ្ធាស៊ប់សួន ខ្ញុំប្រាថ្នានូវតំណែងនោះ បានបំពេញនូវត្រៃសិក្ខា ។ លំដាប់នោះ ព្រះសុគតមានអធ្យាស្រ័យប្រព្រឹត្តទៅតាមសេចក្ដីករុណា ទ្រង់ត្រាស់នឹងខ្ញុំថា បុគ្គលណាមានសទ្ធាមិនញាប់ញ័រ តម្កល់មាំក្នុងតថាគត ។ បុគ្គលណាមានសីលល្អជាទីពេញចិត្តនៃព្រះអរិយៈ ដែលអ្នកប្រាជ្ញសរសើរហើយ បុគ្គលណាមានសេចក្ដីជ្រះថ្លា មានការឃើញត្រង់ក្នុងព្រះសង្ឃ ។

បត្តំ សិង្គាលមាតាថេរិយាបទានំ

អនសិទ្ធោតិ តំ អហុ　　អហោសិំ តស្ស ជីវិតំ
តស្សា សទ្ធញ្ច សីលញ្ច　　បសាទំ ធម្មទស្សនំ ។
អនុយុញ្ជេ មេធាវី　　សរំ ពុទ្ធាន សាសនំ
តំ សុត្វាហំ បមុទិតា　　អបុច្ឆឹ បណិធឹ មម ។
តទា អនោមោ អមិតោ　　ព្យាករិត្ថ វិនាយកោ
ពុទ្ធស្ស បសន្នា កល្យាណី　　លទ្ធសេតំ សុបត្ថិតំ ។
សតសហស្សេតោ កប្បេ　　ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន　　សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទា　　ឱរសា ធម្មនិម្មិតា
សិង្គាលកស្ស យា មាតា(១) ហេស្សតិ សត្ថុសាវិកា ។

---

១ ឱ. ម. ឯត្ថ មាតាតិ បទេ ឥតិសទ្ទោ អត្ថិ ។ យាសទ្ទោ នត្ថិ ។

តថាគតត្រាស់ហៅនូវបុគ្គលនោះ ថាជាអ្នកមិនទំលក្រ តាំង ជីវិតរបស់បុគ្គលនោះ ក៏មិនសោះសូន្យ ហេតុនោះ បុគ្គល មានប្រាជ្ញាជាគ្រឿងកំចាត់បង់កិលេស កាលរពុកឃើញព្រះ ពុទ្ធសាសនា គប្បីប្រកបរឿយ ៗ នូវសទ្ធាផង សីលផង សេចក្តីជ្រះថ្លាផង ការឃើញធម៌ផង ៗ លុះខ្ញុំបានស្តាប់ពុទ្ធ-ភាសិតនោះហើយ ក៏រីករាយ ហើយបានទូលសួរនូវសេចក្តី ប្រាជ្ញារបស់ខ្ញុំ ៗ

វេលានោះ ព្រះនាយកមិនថោកទាប មានគុណភាពមិន អស់ ទ្រង់ព្យាករថា នាងមានលំអ ជ្រះថ្លាក្នុងព្រះពុទ្ធ នឹង បានតំណែងនុ៎ះ ដែលនាងប្រាជ្ញាល្អហើយ ៗ ក្នុងកប្ប ទីមួយសែន អំពីកប្បនេះ ព្រះមហាបុរស សម្ពុតក្នុង ត្រកូលនៃស្តេចឧក្កាកៈ នឹងបានជាសាស្តា ព្រះនាមគោតម ក្នុងលោក ៗ នាងនឹងបានជាឱរស ដែលព្រះធម៌និម្មិតហើយ ជាអ្នកទទួលមត៌ក ក្នុងធម៌នៃព្រះសម្ពុទ្ធនោះ ជាមាតានៃ សិង្គាលមាណព នឹងបានជាសាវិកា របស់ព្រះសាស្តា ៗ

តំ សុត្វា មុទិតា ហុត្វា    យាវជីវំ តទា ជិនំ
មេត្តចិត្តា បរិចរឹ    បដិបត្តីហិ នាយកំ ។

តេន កម្មេន សុកតេន    ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ    តាវត្តិំសំ អគញ្ឆហំ ។

បច្ឆិមេ ច ភវេ ទានិ    គិរិព្វជបុរុត្តមេ
ជាតា សេដ្ឋិកុលេ ផីតេ    មហារតនសញ្ចយេ ។

បុត្តា សិង្គាលកោ នាម    មមាសិ(១) វិបថេ រតោ
ទិដ្ឋិគហណបក្ខន្ទោ    ទិសាបូជនតប្បរោ ។

នានាទិសា នមស្សន្តិ(២)    បិណ្ឌាយ នគរំ វជំ
តំ ទិស្វា អវទិ(៣) ពុទ្ធោ    មគ្គេ ឋត្វា វិនាយកោ ។

តស្ស ទេសយតោ ធម្មំ    បនាទោ វិម្ហយោ អហុ
ទ្វេកោដិនរនារីនំ    ធម្មាភិសមយោ អហុ ។

---

១ ឱ. មមាសី ។ ២ ឱ. ម. នមស្សន្តំ ។ ៣ ឱ. ម. ឱវទិ ។

គ្រានោះ ខ្ញុំបានស្តាប់ពុទ្ធភាសិតនោះហើយ ក៏រីករាយ មានចិត្តមេត្តា ខំបម្រើព្រះជិនស្រី ជានាយក ដោយការប្រតិបត្តិ ដរាបដល់អស់ជីវិត ។ ខ្ញុំលះបង់រាងកាយ ជារបស់មនុស្សហើយ ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង ។ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានកើត ក្នុងគិរិព្វជបុរីដ៏ឧត្តម ក្នុងត្រកូលសេដ្ឋី ស្តុកស្តម្ភទូលំទូលាយ ពាសពេញដោយកែវដ៏ច្រើន ។ កូនប្រុសរបស់ខ្ញុំ ឈ្មោះសិង្គាល ជាអ្នកត្រេកអរក្នុងផ្លូវខុស ស្ទុះទៅកាន់ទីសាំញ៉ាំគឺទិដ្ឋិ មានចិត្តជាប់ចំពាក់ក្នុងការបូជាទិស តែងនមស្ការទិសផ្សេងៗ ។ ព្រះពុទ្ធជានាយក ទ្រង់ស្តេចទៅបិណ្ឌបាត ក្នុងរាជនគរ ទ្រង់ឃើញសិង្គាល-មាណពនោះ ទ្រង់គង់នៅប្របផ្លូវហើយឲ្យឱវាទ ។ កាលព្រះពុទ្ធជាម្ចាស់នោះ ទ្រង់សម្តែងធម៌ ក៏កើតមានសម្លេងគឹកកងអស្ចារ្យ ពួកនារីពីរកោដិក្នុងទីក្រុង ក៏បានសម្រេចមគ្គផល ។

## ចតុត្ថំ សិង្គាលមាតាថេរិយាបទានំ

តទា តំ បរិសំ គន្ត្វា សុត្វា សុគតភាសិតំ
សោតាបត្តិផលំ បត្វា បព្វជឹ អនគារិយំ ។
ន ចិរេនេវ កាលេន ពុទ្ធទស្សនសាលយា
អនុស្សតឹ តំ ការេត្វា អរហត្តំ អបាបុណឹ ។
ទស្សនត្ថាយ ពុទ្ធស្ស សព្វទា ច វជាមហំ(១)
អតិត្តាយេវ បស្សាមិ រូបំ នយននន្ទនំ(២) ។
សព្វបារមិសម្ភូតំ លក្ខិនិលយនំ បរំ
រូបំ សព្វសុភាកិណ្ណំ អតិត្តា វិហរាមហំ ។
ជិនោ តស្មឹ គុណេ តុដ្ឋោ ឯតទគ្គេ ឋបេសិ មំ
សិង្គាលកស្ស យា មាតា អគ្គា សទ្ធាធិមុត្តិកា(៣) ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។

---

១ ឱ. សព្វទា ឯវ ជាមហំ ។ ២ ឱ. យេន វន្ទនំ ។ ៣ ឱ. សទ្ធាវិមុត្តិកា ។ ម. មមាធិ-មុត្តិកា ។

## សិង្គាលមាតាថេរីយាបទាន ទី ៤

កាលនោះ ខ្ញុំបានទៅកាន់បរិស័ទនោះ ស្តាប់ភាសិតរបស់ព្រះសុគតហើយ បានសម្រេចសោតាបត្តិផល ក៏ចូលទៅកាន់ផ្ទះ ។ ខ្ញុំប្រកបដោយសេចក្តីអាល័យ ក្នុងការឃើញនូវព្រះពុទ្ធ មិនយូរប៉ុន្មាន ក៏បម្រើនអនុស្សតិនោះ ហើយបានដល់ព្រះអរហត្ត ។ ខ្ញុំទៅដើម្បីប្រយោជន៍ដល់ការចូលគាល់ព្រះពុទ្ធគ្រប់កាល ខ្ញុំមិនបេះឆ្អែតឆ្អន់ (ក្នុងការមើលរូប) តែងមើលរូបដែលជាទីត្រេកអរនៃភ្នែកនោះ ។ ខ្ញុំនៅតែមិនឆ្អែតឆ្អន់នឹងរូបដទៃ ដែលកើតអំពីបារមីធម៌ទាំងអស់ ជាទីកើតនៃបុណ្យ កុះករដោយធម៌ដ៏ល្អទាំងអស់ឡើយ ។ ព្រះជិនស្រីទ្រង់ត្រេកអរក្នុងគុណនៃខ្ញុំនោះ ទ្រង់តាំងខ្ញុំក្នុងទីជាឯតទគ្គៈជាមាតានៃសិង្គាលមាណព ថាជាស្រីប្រសើរ មានសទ្ធាស៊ប់ស្ងួន ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវេ បរិញ្ញាយ នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មម មហាវីរ ឧប្បន្នំ តវ សន្តិកេ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សិង្គាលមាតា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

សិង្គាលមាតាថេរិយាបទានំ សមត្តំ ។

## សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន

ខ្ញុំដឹងនូវបុព្វេនិវាស ទាំងទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតល្អហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ព្រោះកំណត់ដឹងនូវអាសវៈទាំងពួង ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំកើតឡើង ក្នុងសំណាក់របស់ព្រះអង្គ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយក្នុងសំណាក់នៃព្រះពុទ្ធ ដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនានៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសិង្គាលមាតាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សិង្គាលមាតាថេរិយាបទាន ។

# បញ្ចមំ សុក្កាបេរិយាបទានំ

(៣៩) ឯកនវុតេ ឥតោ កប្បេ វិបស្សី នាម នាយកោ

ឧប្បជ្ជិ ចារុនយនោ(១)　សព្វធម្មវិបស្សកោ ។
តទាហំ ពន្ធុមតិយំ　ជាតា អញ្ញតរេ កុលេ
ធម្មំ សុត្វាន មុនិនោ　បព្វជឹ អនគារិយំ ។
ពហុស្សុតា ធម្មធរា　បដិភាណវតី តថា
វិចិត្តកថិកា ចាបិ(២)　ជិនសាសនការិកា ។
តទា ធម្មកថំ កត្វា　ហិតាយ ជនតំ សទា(៣)
តតោ ចុតាហំ តុសិតំ　ឧបបន្នា យសស្សិនី ។
ឯកត្តឹសេ ឥតោ កប្បេ　សិខី វិយ សិខី ជិនោ
តបន្តោ យសសា លោកំ　ឧប្បជ្ជិ វទតំ វរោ ។
តទាបិ បព្វជិត្វាន　ពុទ្ធសាសនកោវិទា
ជោតេត្វា ជិនវាក្យានិ　តតោបិ តិទិវង្គតា ។

---

១ ម. ចារុទស្សនោ ។ ២ ឱ. ចាសឹ ។ ៣ ឱ. ជនសំសរឹ ។ ម. ជនតំ ពហុំ ។

# សុក្កាថេរិយាបទាន ទី ៥

[៣៥] ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយក ព្រះនាម វិបស្សី មានព្រះនេត្រដូចមាស ពិចារណាឃើញធម៌ទាំងអស់ កើតឡើងហើយ ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលមួយក្នុងនគរ ពន្ធុមតី បានស្តាប់ធម៌របស់ព្រះមុនី ហើយចូលទៅកាន់ផ្នួស ។ ខ្ញុំជាអ្នកស្តាប់ច្រើន ចងចាំនូវធម៌ ជាអ្នកមានប្រាជ្ញា មួយទៀត ជាអ្នកពោលពាក្យវិចិត្រ ទាំងជាអ្នកធ្វើតាមសាសនា នៃព្រះជិនស្រី ។ កាលនោះ ខ្ញុំបានធ្វើនូវធម្មកថា ដើម្បីប្រយោជន៍ដល់ប្រជុំជនគ្រប់កាល លុះខ្ញុំច្យុតចាកអត្តភាពនោះ ក៏ចូលទៅកើតក្នុងឋានតុសិត ជាស្រីមានយស ។ ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រះជិនស្រី ព្រះនាមសិខី រុងរឿងដោយយស ដូចជាភ្លើង ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ កើតឡើងក្នុងលោក ។ គ្រានោះ ខ្ញុំបានបួស ជាស្រីវាងវៃ ក្នុងព្រះពុទ្ធសាសនា ញុំាងព្រះពុទ្ធដីកាព្រះជិនស្រីឲ្យរុងរឿង លុះច្យុតចាកអត្តភាពនោះ ក៏បានទៅកាន់ឋានតាវត្តិង្ស ។

ឯកត្តឹសេ ឥតោ កប្បេ វេស្សភូ នាម នាយកោ
ឧប្បជ្ជិត្ថ មហាយានី តទាបិច តទេវហំ ។
បព្ពជិត្វា ឧម្មក ជោតយឹ ជិនសាសនំ
កត្វា មរុបុរំ រម្មំ អនុភោមិ មហាសុខំ ។
ឥមម្ហិ ភទ្ទកេ កប្បេ កកុសន្ធោ ជិនុត្តមោ
ឧប្បជ្ជិ នរសទ្ទូលោ(១) តទាបិច តទេវហំ ។
បព្ពជឹ ជិនសាសនំ ជោតយិត្វា យថាយុកំ(២)
តតោ ចុតាហំ តិទសំ(៣) អគំ សភវំ យថា ។
ឥមស្មឹយេវ កប្បម្ហិ កោណាគមននាយកោ
ឧប្បជ្ជិ វទតំ វរោ(៤) សព្វសត្តានមុត្តមោ(៥) ។

---

១ ឱ. វីរសទ្ទូលោ ។ ម. នរសារណោ ។ ២ ឱ. យថាសុខំ ។ ៣ ម. តិទិវំ ។ ៤ ឱ. ឧប្បជ្ជិ ប ទីបវរោតិ ទិស្សតិ ។ ម. ឧប្បជ្ជិ លោកសរណោតិ ទិស្សតិ ។ ៥ ម. អរណោ អមតង្គតោតិ ទិស្សតិ ។

ក្នុងកប្បទី ៣១ អំពីកប្បនេះ ព្រះនាយកព្រះនាមវេស្សភូ ទ្រង់កើតឡើង (ក្នុងលោក) ឯខ្ញុំក៏កើតឡើង តំណាលនឹងព្រះនាយកនោះ ក្នុងកាលនោះដែរ ជាអ្នកមានយានដ៏ធំ ។ ខ្ញុំបួសហើយ ជាអ្នកបង់ចាំនូវធម៌ ញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ហើយទៅកើតក្នុងបុរីរបស់ទេវតា ដែលជាទីរីករាយ ទទួលសេចក្តីសុខដ៏ច្រើន ។ ក្នុងភទ្ទកប្បនេះ ព្រះជិនស្រីដ៏ឧត្តម ព្រះនាមកកុសន្ធៈ ជានរៈដ៏ខ្ពង់ខ្ពស់ កើតឡើងក្នុងលោក កាលនោះ ខ្ញុំក៏បានកើតឡើងដែរ ។ ខ្ញុំបានបួសរួចហើយ ញុំាងសាសនានៃព្រះជិនស្រី ឲ្យរុងរឿងតាមសប្បាយ ខ្ញុំច្យុតចាកអត្តភាពនោះ ក៏បានទៅកើតក្នុងឋានត្រៃត្រឹង្ស ដូចជាភពរបស់ខ្លួនដដែល ។ ក្នុងកប្បនេះដដែល ព្រះនាយក ព្រះនាមកោនាគមនៈ ប្រសើរជាងអ្នកប្រាជ្ញ ឧត្តមជាងពួកសត្វទាំងពួង ទ្រង់កើតឡើង ។

## បញ្ចមំ សុក្កាថេរិយាបទានំ

តទាបិ បព្វជិត្វាន　　សាសនេ តស្ស តាទិនោ
ពហុស្សុតា ធម្មធរា　　ជោតយឹ ជិនសាសនំ ។
ឥមស្មឹយេវ កប្បម្ហិ　　កស្សបោ មុនិ សត្តមោ(១)
ឧប្បជ្ជិ លោកសរណោ　　អរណោ មរណន្តគូ ។
តស្សាបិ នរវីរស្ស　　បព្វជិត្វាន សាសនេ
បរិយាបុដសទ្ធម្មា　　បរិបុច្ឆាវិសារទា ។
សុសីលា លជ្ជិនី ចេវ　　តីសុ សិក្ខាសុ កោវិទា
ពហុំ ធម្មកថំ កត្វា　　យាវជីវំ មហាមុនេ ។
តេន កម្មវិបាកេន　　ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ　　តាវត្តឹសំ អគញ្ឆហំ ។
បច្ឆិមេ ច ភវេទានិ　　គិរិព្វជបុរុត្តមេ
ជាតា សេដ្ឋិកុលេ ផីតេ　　មហារតនសញ្ចយេ ។

---

១ ម. មុនិមុត្តមោ ។

## សក្កាថេរិយាបទាន ទី ៨

គ្រានោះ ខ្ញុំបានបួសក្នុងសាសនា នៃព្រះកោនាគមនៈនោះ ព្រះអង្គប្រកបដោយតាទិគុណ ជាអ្នកបានស្តាប់ច្រើន ចងចាំនូវធម៌ ញុំាងសាសនា នៃព្រះជិនស្រី ឲ្យរុងរឿង ៗ ក្នុងកប្បនេះឯង ព្រះមុនីទី ៧ ព្រះនាមកស្សបៈ ជាទីពឹងនៃសត្វលោក មិនមានកិលេស ដល់នូវព្រះនិព្វាន ជាទីបំផុតនៃមរណៈ កើតឡើង ៗ ចំណែកខ្ញុំបានបួស ក្នុងសាសនារបស់ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ជាងពួកជននោះ មានព្រះសទ្ធម្មបែកសព្វគ្រប់ ដ៏ក្លៀវក្លាខាងការសាកសួរ ៗ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកមានសីលល្អ មានសេចក្តីអៀនខ្មាស វាងវៃក្នុងត្រៃសិក្ខា ហើយធ្វើនូវធម្មកថាមានប្រមាណច្រើន ដរាបដល់អស់ជីវិត ៗ ដោយកម្មវិបាកនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់នូវរាងកាយ ជារបស់មនុស្ស ក៏បានទៅកើត ក្នុងឋានតាវត្តិង្ស ៗ ដល់មកក្នុងបច្ឆិមភព ឥឡូវនេះ ខ្ញុំបានកើតក្នុងត្រកូលនៃសេដ្ឋី ដ៏ធំទូលាយ ដេរដាសដោយរតនៈច្រើន ក្នុងគិរិព្វជបុរីដ៏ឧត្តម ៗ

យទា ភិក្ខុសហស្សេន បរេតោ លោកនាយកោ
ឧបាគមិ រាជគហំ សហស្សក្ខេហិ វណ្ណិតោ ។

ទន្តោ ទន្តេហិ សហ បុរាណជដិលេហិ
វិប្បមុត្តោ វិប្បមុត្តេហិ
សិង្គិនិក្ខសវណ្ណោ(១)
រាជគហំ បាវិសិ ភគវា ។

ទិស្វា ពុទ្ធានុភាវន្តំ សុត្វា ច គុណសញ្ចយំ
ពុទ្ធេ ចិត្តំ បសាទេត្វា ពូជយឹ តំ មហាពលំ(២) ។

អបរេន ច កាលេន ធម្មទិន្នាយ សន្តិកេ
អគារា និក្ខមិត្វាន បព្វជឹ អនគារិយំ ។

កោសេសុ ជិដ្ឋមានេសុ កិលេសេ ឈាបយឹ អហំ
ឧគ្គហឹ សាសនំ សព្វំ បព្វជិត្វា ន(៣) ជិនេហំ ។

១ ម. សិង្គិនិក្ខសុវណ្ណោ ។ ២ ឱ ម. យថាពលំ ។ ៣ ឱ. ម. នសទ្ទោ នត្ថិ ។

កាលព្រះលោកនាយក មានភិក្ខុចំនួនមួយពាន់រូបចោមរោម ទ្រង់ស្តេចទៅកាន់ក្រុងរាជគ្រឹះ ព្រះឥន្ទ្រក៏បានពោលសរសើរថា

ព្រះមានព្រះភាគ មានឥន្ទ្រិយទូន្មានហើយ មានព្រះហឫទ័យផុតចាកកិលេសហើយ ព្រមដោយ

បុរាណជដិលទាំងឡាយ ដែលមានឥន្ទ្រិយទូន្មាន

មានចិត្តផុតស្រឡះហើយ ទ្រង់មានពណ៌ដូច

ជាពណ៌នៃមាសឆ្តោឈ្មោះសិង្គី ស្តេចយាងចូល

ទៅកាន់ក្រុងរាជគ្រឹះ ។

ខ្ញុំបានឃើញអានុភាព នៃព្រះពុទ្ធនោះផង បានស្តាប់ការប្រជុំនូវគុណនោះផង ហើយញុំាងចិត្តឲ្យជ្រះថ្លាក្នុងគុណរបស់ព្រះពុទ្ធ បានបូជាព្រះពុទ្ធនោះ សមគួរតាមកម្លាំង ។ ក្នុងកាលជាខាងក្រោយមក ខ្ញុំចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងសំណាក់នៃនាងធម្មទិន្នាថេរី ។ កាលសក់កំពុងដាច់ចុះ ខ្ញុំបានផុតបំផ្លាញពួកកិលេសហើយ ខ្ញុំបួសមិនយូរប៉ុន្មាន ក៏បានរៀននូវព្រះពុទ្ធសាសនា ចប់សព្វគ្រប់ ។

## បញ្ចមំ សុក្កាថេរិយាបទានំ

តតោ ធម្មំ អទេសេសឹ មហាជនសមាគមេ
ធម្មេ ទេសិយមានម្ហិ ធម្មាភិសមយោ អហុ ។
នេកបាណសហស្សានំ តំ វិទិត្វា វិជិម្ហិតោ
អភិប្បសន្នោ មេ យក្ខោ ភមិត្វាន គិរិព្វជំ ។
កឹ មេ កតា រាជគហេ (មនុស្សា) មធុំ បីតាវ អច្ឆរេ
យេ សុក្កំ ន បយិរុបាសន្តិ ទេសេន្តឹ អមតំ បទំ ។
តញ្ច បន អប្បដិវានិយំ អសេចនកមោជវំ
បិវន្តិ មញ្ញេ សប្បញ្ញា វណាហកមិវទ្ធគូ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។

## សុក្កាថេរីយាបទាន ទី ៤

លំដាប់តពីនោះមក ខ្ញុំបានសម្ដែងធម៌ ក្នុងទីប្រជុំជនដ៏ច្រើន កាលដែលខ្ញុំកំពុងតែសម្ដែងធម៌ ធម្មាភិសម័យ ក៏កើតមាន (ដល់ជនទាំងឡាយ) ។ បណ្ដាពួកសត្វជាច្រើនពាន់ មានយក្សមួយ ដឹងច្បាស់នូវធម៌នោះ ហើយសង្វេគ ជ្រះថ្លានឹងខ្ញុំហើយបានទៅកាន់ក្រុងគិរិព្វជៈ ដោយគិតថា មនុស្សណា មិនចូលទៅអង្គុយជិត នាងសុក្កាថេរី ដែលកំពុងសម្ដែងនូវអមតបទគឺនិព្វាន អាត្មាអញធ្វើដូចម្ដេចហ្ន៎ ឲ្យមនុស្សទាំងនោះ ដែលនៅក្នុងក្រុងរាជគហៈ មូលគ្នា ដូចពួកសត្វរោមផឹកនូវទឹកផ្អែម ។ ចំណែកខាងពួកបុគ្គល អ្នកប្រកបដោយបញ្ញា ទំនងជាផឹកទឹកអម្រឹតនោះ ដែលកិលេស មិនគប្បីតស៊ូបាន មានទុជាមិនបាច់ស្រោចថែម ដូចជាបុគ្គលដើរផ្លូវឆ្ងាយ ផឹកទឹកភ្លៀង ។

បពិត្រព្រះពុទ្ធ ជាមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញ ក្នុងចេតោបរិយញ្ញាណផង ។

បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មម មហាវីរ ឧប្បន្នំ តវ សន្តិកេ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហារាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សុក្កា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

សុក្កាថេរិយាបទានំ សមត្តំ ។

បញ្ចមំ ភាណវារំ ។

ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំជម្រះស្អាតល្អហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹង ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំព្រះអង្គ កើតឡើង ក្នុងសំណាក់នៃព្រះអង្គ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសុក្កាភិក្ខុនី មានអាយុ បានសំដែង នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សុក្កាថេរិយាបទាន ។

ចប់ ភាណវារៈ ទី ៥ ។

## ឆដ្ឋំ អភិរូបនន្ទាថេរិយាបទានំ

(៣៦) ឯកនវុតេ ឥតោ កប្បេ វិបស្សី នាម នាយកោ

ឧប្បជ្ជិ ចារុនយនោ សព្វធម្មេសុ ចក្ខុមា ។
តទាហំ ពន្ធុមតិយា ឥព្ភេ ជីតេ មហាកុលេ
ជាតា សុរូបា ទយិតា បូជនីយា(១) ជនស្ស ច ។
ឧបគន្ត្វា មហាវីរំ វិបស្សឹ លោកនាយកំ
ធម្មំ សុត្វាន សរណំ ឧបេសឹ នរនាយកំ ។
សីលេសុ សំវុតា ហុត្វា និព្វុតេ ច នរុត្តមេ
ធាតុថូបស្ស ឧបរិ សោណ្ណច្ឆត្តំ អប្បយឹ ។
មុត្តចាគា សីលវតី យាវជីវំ តតោ ចុតា
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគញ្ឆហំ(២) ។

---

១ ឱ. សុរូបទស្សិកា សជនស្ស ។ ២ ម. តាវត្តឹសូបគា អហំ ។

# អភិរូបនន្ទាថេរិយាបទាន ទី ៦

(៣៦) ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះនាយក ព្រះនាមវិបស្សី មានព្រះនេត្រដូចជាមាស មានចក្ខុក្នុងធម៌ទាំងពួង កើតឡើង ។ គ្រានោះ ខ្ញុំកើតក្នុងត្រកូលធំ ស្តុកស្តម្ភ ទូលំទូលាយ ក្នុងពន្ធុមតីនគរ ជាស្ត្រីមានរូបល្អ គួរមហាជនបូជា ។ ខ្ញុំបានចូលទៅគាល់ព្រះលោកនាយក ព្រះនាមវិបស្សី ទ្រង់មានព្យាយាមធំ បានស្តាប់ធម៌ហើយ ដល់នូវព្រះពុទ្ធជានាយកនៃពួកជនជាទីពឹង ។ ខ្ញុំជាអ្នកសង្រួមល្អក្នុងសីលទាំងឡាយ កាលដែលព្រះលោកនាយក ដ៏ខ្ពង់ខ្ពស់ជាងពួកជន ទ្រង់បរិនិព្វានទៅហើយ ខ្ញុំបានបូជាឆត្រមាសតម្កល់ពីខាងលើ នៃព្រះស្តូបដែលបញ្ចុះព្រះធាតុ ។ ខ្ញុំបានបរិច្ចាគទានរួចផុតហើយ ជាអ្នកមានសីលល្អ រស់នៅរហូតកំណត់អាយុ ក៏បានច្យុតចាកទីនោះ លុះខ្ញុំលះបង់រាងកាយជារបស់នៃមនុស្សហើយ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

តទា(១) ទសហិ ឋានេហិ អភិភោត្វា អសេសតោ(២)
រូបសទ្ទេហិ គន្ធេហិ រសេហិ ផុស្សេហិ ច ។
អាយុនាបិ វណ្ណេន សុខេន យសសាបិ ច
តថេវាធិបតេយ្យេន អធិគយ្ហ វិរោចហំ ។
បច្ឆិមេ ច ភវេ ទានិ ជាតាហំ កបិលវ្ហយេ
ធីតា ខេមកសក្កស្ស នន្ទា នាមេន វិស្សុតា ។
អភិរូបសម្បទម្បិ(៣) អាហុ មេកន្តិ សូចកំ
យទាហំ យោព្វនំ បត្តា រូបវណ្ណវិភូសិតា(៤) ។
ឥធ មមត្ថ(៥) សក្យានំ វិវាទោ សុមហា អហុ
បព្វាជេសិ តតោ តាតោ មា សក្យា វិនស្សុំ ឥតិ ។
បព្វជិត្វាន តថាគតំ(៦) រូបទេស្សឹ នរុត្តមំ
សុត្វាន នោបគច្ឆាមិ មម រូបេន គព្ភិតា ។

---

១ ម. សទា ។ ២ ឱ. ម. ៩សេសកេ ។ ៣ ឱ. អភិរូបំ ឧប្បាទំ ។ ម. អភិរូបំ ឧបបទំ ។
៤ ម. រូបលាវញ្ញភូសិតា ។ ៥ ឱ. ឥទំ មេ មត្ថេ ។ ៦ ឱ. តថាហំ ។

កាលនោះ ខ្ញុំគ្របសង្កត់ នូវពួកទេវតាដទៃ មិនសេសសល់ ដោយហេតុ ១០ យ៉ាង គឺបានរុងរឿងគ្របសង្កត់ដោយរូប ១ សម្លេង ១ ក្លិន ១ រស ១ សម្ផស្ស ១ អាយុ ១ ពណ៌ ១ សេចក្តីសុខ ១ យស ១ ភាពនៃខ្លួនជាធំ ១ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំបានកើតជាធីតា នៃខេមកសាក្យៈ ប្រាកដនាមថានន្ទា ក្នុងក្រុងកបិលពស្តុ ។ កាលណាខ្ញុំដល់ នូវសេចក្តីចម្រើន ស្អិតស្អាងដោយរូបនិងពណ៌ កាលនោះ ពួកជនបានពោលថា ខ្ញុំជាស្រីស្រួបមួយ មានរូបសម្បត្តិល្អ ។ សេចក្តីវិវាទដ៏ធំក្រៃលែង កើតមានដល់ពួកសក្យៈ ក្នុងនគរ នេះ ព្រោះតែស្រឡាញ់ខ្ញុំ លំដាប់នោះ បិតាបានឲ្យខ្ញុំបួស ដោយគិតថា កុំឲ្យពួកសក្យៈវិនាសឡើយ ។ លុះខ្ញុំបួសរួច ហើយ បានឮព្រះតថាគត ជាបុគ្គលប្រសើរជាងពួកជន ទ្រង់ តិះដៀលរូប ខ្ញុំជាស្រីប្រកាន់រូប មិនចូលទៅជិតព្រះអង្គ ។

## ជន្ល អភិរូបនន្ទាថេរិយាបទានំ

ឱវាទំបិ ន គច្ឆាមិ ពុទ្ធទស្សនភីរុកា
តទា ជិនោ ឧបាយេន ឧបនេត្វា សសន្តិកំ ។
តិស្សិត្ថិយោ និទស្សេសិ ឥទ្ធិយា មគ្គកោវិទោ
អច្ឆរារូបសទិសិំ តរុណឹ ជរិកំ មតំ ។
តយោ ទិស្វា សុសំវិគ្គា វិរត្តាសេ កលេវរេ
អដ្ឋាសឹ ភវនិព្វិន្នា តតោ មំ អាហ នាយកោ ។
អាតុរំ អសុចឹ បូតឹ បស្ស នន្ទេ សមុស្សយំ
ឧគ្ឃរន្តំ បគ្ឃរន្តំ ពាលានំ អភិបត្ថិតំ(១) ។
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ ។

---

១ ម. អភិនន្ទិតំ ។

## អភិរូបនន្ទាថេរិយាបទ ទី ៦

ខ្ញុំជាអ្នកមានសេចក្ដីខ្លាច ក្នុងការឃើញព្រះពុទ្ធ មិនហ៊ាន ចូលទៅស្ដាប់ធម៌ទេសនា គ្រានោះ ព្រះជិនស្រីទ្រង់ដឹកនាំខ្ញុំ ទៅកាន់សំណាក់របស់ព្រះអង្គ ដោយឧបាយ ៗ ព្រះជិនស្រី ទ្រង់វាងវៃខាងផ្លូវឫទ្ធិ បាននិម្មិតនូវស្ត្រីគេ ៣ នាក់ គឺ ស្ត្រីក្រមុំមានរូបល្អ ស្រដៀងនឹងស្ត្រីអប្សរ ១ ស្ត្រីចាស់ ១ ស្ត្រីស្លាប់ ១ ៗ លុះខ្ញុំបានឃើញនូវស្ត្រីទាំង ៣ នោះហើយ ក៏មានសេចក្ដីសង្វេគធុញទ្រាន់ ក្នុងរាងកាយ មានសេចក្ដីនឿយណាយក្នុងភព លំដាប់នោះ ព្រះលោកនាយក ទ្រង់ត្រាស់នឹងខ្ញុំថា

ម្នាលនាងនន្ទា នាងចូររមិលមើលនូវរូបនេះ ដែលក្ដៅក្រហាយ មិនស្អាត ស្អុយ ហូរចេញហូរចូល ដែលជនពាលទាំងឡាយប្រាថ្នាក្រៃពេក ៗ នាងចូរចម្រើននូវចិត្ត ដែលមានអារម្មណ៍តែមួយ ជាចិត្តតម្កល់មាំ ដោយអសុភភាវនាចុះ រូបនេះ យ៉ាងណា រូបនៃនាងនុ៎ះ ក៏យ៉ាងនុ៎ះដែរ រូបនៃនាងនុ៎ះ យ៉ាងណា រូបនេះ ក៏យ៉ាងនេះដែរ ៗ

ឯវមេតំ អវេក្ខន្តី រត្តិន្ទិវមតន្ទិតា
តតោ សកាយ បញ្ញាយ អភិនិព្ពិជ្ឈ វច្ចសិ(១) ។
តស្សា មេ អប្បមត្តាយ វិចិនន្តីធ យោនិសោ
យថាភូតំ អយំ កាយោ ទិដ្ឋោ សន្តរពាហិរោ ។
អថ និព្ពិន្ទហំ កាយេ អជ្ឈត្តញ្ច វិរជ្ជហំ
អប្បមត្តា វិសំយុត្តា ឧបសន្តម្ហិ និព្វុតា ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មម មហាវីរ ឧប្បន្នំ តវ សន្តិកេ ។

---

១ ម. វិច្ចសិ ។

កាលខ្ញុំពិចារណារូបនុ៎ះ យ៉ាងនេះហើយ ក៏មិនមានខ្ជិលប្រអូសទាំងយប់ទាំងថ្ងៃ លំដាប់នោះ ក៏នឿយណាយដោយបញ្ញារបស់ខ្លួន ខ្ញុំនោះមិនមានសេចក្តីប្រមាទ ពិចារណាក្នុងទីនេះដោយឧបាយ ក៏ឃើញកាយនេះ ទាំងខាងក្នុងទាំងខាងក្រៅ តាមសភាពពិត ។ កាលនោះ ខ្ញុំនឿយណាយក្នុងកាយផង ប្រាសចាកការត្រេកអរនឹងកាយ ប្រព្រឹត្តទៅខាងក្នុងផង ហើយជាអ្នកមិនមានសេចក្តីប្រមាទ អស់កិលេសជាគ្រឿងផ្សំ ស្ងប់ម្ងាប់កិលេស មានទុក្ខរលត់ហើយ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញ ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំជម្រះស្អាតល្អហើយ មានអាសវៈទាំងពួង អស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ បពិត្រព្រះអង្គមានព្យាយាមធំ សេចក្តីដឹង ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំព្រះអង្គ កើតឡើងក្នុងសំណាក់នៃព្រះអង្គ ។

សត្តមំ អឌ្ឍកាសីថេរិយាបទានំ

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អភិរូបនន្ទា ឥមា គាថាយោ អភាសិត្ថាតិ ។

អភិរូបនន្ទាថេរិយាបទានំ សមត្តំ ។

## សត្តមំ អឌ្ឍកាសីថេរិយាបទានំ

(៣៧) ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដក
ចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់
បំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អហើយ
ក្នុងសំណាក់នៃព្រះពុទ្ធ ដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ
សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤
វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ
ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអភិរូបនន្ទាភិក្ខុនី មានអាយុ បានសម្តែង នូវគាថា
ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អភិរូបនន្ទាថេរិយាបទាន ។

# អឌ្ឍកាសីថេរិយាបទាន ទី ៧

(៣៧) ព្រះជិនស្រីព្រះនាមកស្សបៈ មានផៅពង្សប្រសើរ មានយសធំ
ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ក្នុងកប្បនេះ ។

តទាហំ បព្វជិត្វាន តស្ស ពុទ្ធស្ស សាសនេ
សំវុតា បាតិមោក្ខម្ហិ ឥន្ទ្រិយេសុ ច បញ្ចសុ ។
មត្តញ្ញូ នីចអាសនេ យុត្តា ជាគរិយេបិ ច
វសន្តី យុត្តយោគាហំ ភិក្ខុនី វិគតាសវំ ។
អក្កោសឹ ទុដ្ឋចិត្តាហំ គណិកោតិ សតី តទា
តេន បាបេន កម្មេន និរយម្ហិ អបច្ចិសំ ។
តេន កម្មសេសេន អជាយឹ គណិកាកុលេ
ពហុសោ បរាធីនា បច្ឆិមាយ ច ជាតិយា ។
កាសិសេដ្ឋិកុលេ ជាតា ព្រហ្មចរិយផលេនហំ
អច្ឆរា វិយ ទេវេសុ អហោសឹ រូបសម្បទា ។
ទិស្វាន ទស្សនីយំ មំ គិរិព្វជបុរុត្តមេ
គណិកត្តេ និវេសេសុំ អក្កោសនផលេន មេ ។

កាលនោះ ខ្ញុំបានបួសក្នុងសាសនា របស់ព្រះពុទ្ធអង្គនោះ បានសង្រួមក្នុងបាតិមោក្ខផង ក្នុងឥន្ទ្រិយទាំង ៥ ផង ។ ខ្ញុំជាអ្នកដឹងប្រមាណក្នុងអាសនៈដ៏ទាបផង ប្រកបក្នុងការភ្ញាក់រឭកផង មានសេចក្តីព្យាយាមប្រកបហើយផង កាលនោះខ្ញុំមានចិត្តប្រទូស្ត បានជេរភិក្ខុនី ដែលប្រាសចាកអាសវៈអស់វារៈម្តងថា នែស្ត្រីផ្កាមាស ខ្ញុំក៏ទៅឆេះក្នុងនរក ព្រោះបាបកម្មនោះឯង ។ ដោយកម្មដ៏សេសនោះ ដល់មកក្នុងបច្ឆិមជាតិ ខ្ញុំកើតក្នុងត្រកូលនៃស្ត្រីផ្កាមាស ជាអ្នកអាស្រ័យចិញ្ចឹមជីវិតដោយបុគ្គលដទៃទៀត ជាច្រើន ។ ខ្ញុំបានកើតក្នុងត្រកូលសេដ្ឋី នៅក្នុងដែនកាសី ដោយផលដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកបរិបូណ៌ដោយរូប បីដូចជាស្រីអប្សរ ក្នុងទេវលោក ។ ជនទាំងឡាយបានឃើញខ្ញុំដែលគួររមិលមើល ក្នុងគិរិព្វជបុរីដ៏ឧត្តម ក៏ញ៉ាំងខ្ញុំឲ្យនៅក្នុងពួកនៃស្ត្រីផ្កាមាស ព្រោះផលនៃការជេររបស់ខ្ញុំនោះ ។

## សត្តមំ អឌ្ឍកាសីថេរិយាបទានំ

សាហំ សុណិត្វាន សទ្ធម្មំ ពុទ្ធសេដ្ឋស្ស ភាសិតំ[១]
បុព្វវាសនសម្បន្នា បព្វជិំ អនគារិយំ ។
តទុបសម្បទត្ថាយ គច្ឆន្តី ជិនសន្តិកំ
មគ្គេ ធុត្តេ ឋិតេ ទិស្វា លភិំ ទូតោបសម្បទំ ។
សព្វកម្មំ បរិក្ខីណំ បុញ្ញបាបំ តថេវ ច
សព្វសំសារមុត្តិណ្ណា គណិកត្តញ្ច ខេបិតំ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។

---

១ ឱ. ម. ពុទ្ធសេដ្ឋេន ទេសិតំ ។

## អឌ្ឍកាសីថេរិយាបទាន ទី ៧

ខ្ញុំនោះបានស្តាប់នូវព្រះសទ្ធម្ម ដែលព្រះពុទ្ធដ៏ប្រសើរ ទ្រង់សម្តែងហើយ ក៏បរិបូណ៌ដោយបុព្វវាសនា ហើយបានចូលទៅកាន់ផ្នួស ។ ខ្ញុំទៅកាន់សំណាក់ព្រះជិនស្រី ដើម្បីប្រយោជន៍ដល់ឧបសម្បទានោះ បានឃើញពួកអ្នកលេងឈរនៅក្បែរផ្លូវ ក៏បានឧបសម្បទាអំពីទូត ។ កម្មទាំងពួងរបស់ខ្ញុំអស់ហើយ បុណ្យនិងបាបអស់ហើយ សំសារវដ្តទាំងពួងខ្ញុំបានធ្លងផុត ទាំងភាពជាស្រីផ្កាមាស ខ្ញុំធ្វើឲ្យអស់ហើយ ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ស្ទាត់ជំនាញក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់បុព្វេនិវាសទាំងទិព្វចក្ខុ ខ្ញុំបានជម្រះឲ្យស្អាតល្អហើយ អាសវៈទាំងពួងរបស់ខ្ញុំអស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មម មហាវីរ ឧប្បន្នំ តវ សន្តិកេ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អឌ្ឍកាសិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

អឌ្ឍកាសីថេរិយាបទានំ សមត្តំ ។

បពិត្រព្រះអង្គមានព្យាយាមធំ សេចក្ដីដឹងក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា នៃខ្ញុំ កើតឡើង ក្នុងសំណាក់ នៃព្រះអង្គ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដកចោលអស់ហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង់ ដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា នៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអឌ្ឍកាសីភិក្ខុនី មានអាយុ បានសំដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អឌ្ឍកាសីថេរិយាបទាន ។

# អដ្ឋមំ បុណ្ណិកាថេរិយាបទានំ

(៣៨) វិបស្សិនោ ភគវតោ សិខិនោ វេស្សភុស្ស ច
កកុសន្ធស្ស មុនិនោ កោណាគមនតាទិនោ ។
កស្សបស្ស ច ពុទ្ធស្ស បព្វជិត្វាន សាសនេ
ភិក្ខុនី សីលសម្បន្នា និបកា សំវុតិន្ទ្រិយា ។
ពហុស្សុតា ធម្មធរា ធម្មត្ថបរិបុច្ឆិតា(១)
ឧគ្គហេតា ច ធម្មានំ សោតា បយិរុបាសិកា ។
ទេសេន្តី ជនមជ្ឈេហំ អហោសឹ ជិនសាសនំ
ពាហុសច្ចេន តេនាហំ បេសលា អតិមញ្ញិសំ ។
បច្ឆិមេ ច ភវេ ទានិ សាវត្ថិយំ បុរុត្តមេ
អនាថបិណ្ឌិនោ គេហេ ជាតាហំ កុម្ភទាសិយា ។

---

១ ឱ. អត្ថត្ថបរិបុច្ឆិកា ។ ម. អត្ថត្ថបដិបុច្ឆិកា ។

# បុណ្ណិកាថេរីយាបទាន ទី ៨

(៣៨) ខ្ញុំបានបួសក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះនាមវិបស្សីផង ព្រះនាមសិខីផង ព្រះនាមវេស្សភូផង ព្រះនាមកកុសន្ធៈផង ព្រះនាមកោនាគមនៈ ប្រកបដោយតាទិ-គុណផង ព្រះនាមកស្សបៈផង ខ្ញុំជាភិក្ខុនីបរិបូណ៌ដោយសីល មានប្រាជ្ញាចាស់ក្លា មានឥន្ទ្រិយសង្រួមល្អ ។ ជាពហុស្សូត បានចាំនូវធម៌ ជាអ្នកសាកសួរនូវធម៌និងអត្ថ ហើយរៀនធម៌ ស្តាប់ធម៌ ទាំងជាអ្នកចូលទៅអង្គុយជិតព្រះពុទ្ធជាម្ចាស់ ។ ខ្ញុំបានសម្តែង នូវសាសនា របស់ព្រះជិនស្រី ក្នុងកណ្តាលនៃប្រជុំជន ខ្ញុំមានសីលជាទីស្រឡាញ់ បានមើលងាយគេ ដោយអាងខ្លួនជាពហុស្សូតនោះ ។ ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំបានកើតក្នុងផ្ទៃ នៃស្រីកុម្ភទាសី ក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋី ក្នុងបុរីដ៏ឧត្តម ឈ្មោះសាវត្ថី ។

តទា ឧទកហារិយំ    សោត្ថិយំ និជមត្ថុសំ
សីតន្តិំ តោយមជ្ឈម្ហិ    តំ និស្សា ឥទមព្រវី ។
ឧទកហារី[១] អហំ សីតេ    សទា ឧទកមោតរី
អយ្យានំ ទណ្ឌភយភីតា    វាចាទោសភយដ្ដិតា[២] ។
កស្ស ព្រាហ្មណ ត្វំ ភីតោ    សទា ឧទកមោតរិ
វេធមានេហិ គត្តេហិ    សីតំ វេទយសេ ភុសំ ។
ជានន្តី វត មំ ភោតិ    បុណ្ណិកេ បរិបុច្ឆសិ
ករោន្តំ កុសលំ កម្មំ    រុន្ធន្តំ[៣] កម្មបាបកំ ។
យោ វុឌ្ឍោ ទហរោ វាបិ    បាបកម្មំ បកុព្វតិ
ឧទកាភិសេចនា សោបិ    បាបកម្មា បមុច្ចតិ ។
ឧត្តរន្តស្ស អក្ខាសិ    ធម្មត្ថសហិតំ បទំ
តញ្ច សុត្វា សុសំវិគ្គោ    បព្វជិត្វារហា អហុ ។

---

១ ឱ. ឧទភារី ។ ម. ឧទហារី ។ ២ ឱ. ម. វាចាទោសភយដ្ដិតា ។ ៣ ឱ. និទ្ធន្តំ ។ ម. រុទ្ធន្តំ ។

ខ្ញុំទៅកាន់កំពង់ទឹក បានឃើញសោត្ថិយព្រាហ្មណ៍ ដែលជាអ្នកត្រូវត្រជាក់គ្របសង្កត់ ក្នុងកណ្ដាលទឹក លុះខ្ញុំឃើញព្រាហ្មណ៍នោះហើយ បានពោលពាក្យនេះថា ខ្ញុំជាស្រីដងទឹក ចុះទឹកដ៏ត្រជាក់ សព្វ ៗ កាល ព្រោះភ័យភិតទឹងអាជ្ញានៃម្ចាស់ ព្រោះភ័យទឹងពាក្យកំហឹងគ្របសង្កត់ ៗ នៃព្រាហ្មណ៍ ចុះអ្នកខ្លាចនរណា បានជាមកចុះត្រាំទឹកសព្វ ៗ កាល មានខ្លួនញាប់ញ័រ រងនូវត្រជាក់ដ៏ក្រៃលែង ។

ម្នាលនាងបុណ្ណិកាដ៏ចម្រើន យីអើ ! នាងស្គាល់យើងច្បាស់ បានជាហ៊ានសាកសួរយើង ដែលកំពុងធ្វើកុសលកម្មបន្ទោបង់នូវកម្មដ៏លាមក ៗ បុគ្គលណាទោះបីចាស់ក្ដី ក្មេងក្ដី ធ្វើបាបកម្មហើយ បុគ្គលនោះឯង លុះតែដងទឹកមកស្រោចស្រពកាយ ទើបរួចចាកបាបកម្មបាន ។

កាលព្រាហ្មណ៍នោះ ឡើងមកពីទឹកវិញ ខ្ញុំក៏បានពោលនូវបទប្រកបដោយធម៌និងអត្ថ ឯព្រាហ្មណ៍បានឮភាសិតនោះហើយ ក៏តក់ស្លុតចេញទៅបួស បានសម្រេចជាព្រះអរហន្ត ។

## អដ្ឋមំ បុណ្ណិកាថេរីយាបទានំ

បូរេត្វា ឯកកសតំ ជាតា ទាសិកុលេ យតោ
តតោ បុណ្ណាតិ នាមំ មេ ភុជិស្សំ មំ អកំសុ តេ ។
សេដ្ឋី តតោនុមោទិត្វា(១) បព្វជឹ អនគារិយំ
ន ចិរេនេវ កាលេន អរហត្តំ អបាបុណិំ ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ បដិភាណេ តថេវ ច
ញាណំ មេ វិមលំ(២) សុទ្ធំ ពុទ្ធសេដ្ឋស្ស វាហសា ។

---

១ ឱ. តតោនុមាទេត្វា ។ ម. តតោនុជានេត្វា ។ ២ ឱ. វិបុលំ ។

## បុណ្ណិកាថេរីយាបទាន ទី ៨

ខ្ញុំតាំងពីកើតក្នុងទាសីត្រកូល បានបំពេញជាទាសីមួយរយខ្វះមួយ ចាប់ដើមអំពីនោះមក នាមរបស់ខ្ញុំឈ្មោះថាបុណ្ណា ជនទាំងនោះ បានធ្វើខ្ញុំឲ្យរួចជាអ្នកជា ។ លំដាប់នោះ ខ្ញុំបានញុំាងសេដ្ឋីឲ្យរីករាយតាម ហើយចូលទៅកាន់ផ្នួស អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ។ បពិត្រព្រះមហាមុនី ខ្ញុំម្ចាស់ជាអ្នកស្ទាត់ជំនាញ ក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោតធាតុដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញ ក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំម្ចាស់ដឹងច្បាស់នូវបុព្វេនិវាស ទាំងទិព្វចក្ខុ ខ្ញុំម្ចាស់បានជម្រះស្អាតល្អហើយ អាសវៈទាំងពួង អស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ខ្ញុំម្ចាស់មានសេចក្ដីដឹង ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធប្រសើរ ។

ភាវនាយ មហាបញ្ញា សុតេនេវ សុតាវិនី
មានេន នីចកុលជា ន ហិ កម្មំ បនស្សតិ[១] ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បុណ្ណិកា ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

បុណ្ណិកាថេរិយាបទានំ សមត្តំ ។

---

១ ម. វិនស្សតិ ។

ខ្ញុំមានប្រាជ្ញាច្រើន ព្រោះការអប់រំ ជាអ្នកចេះដឹង ព្រោះការស្តាប់ ជាអ្នកកើតក្នុងត្រកូលទាប ព្រោះមានះ ព្រោះថាកម្មរបស់ខ្ញុំ មិនបានវិនាសឡើយ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំដកចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង ដូចជាមេដំរីកាត់ផ្តាច់នូវទន្ទឹង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាងបុណ្ណិកាភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បុណ្ណិកាថេរិយាបទាន ។

# ទសមំ អដ្ឋបាលីថេរិយាបទានំ

[៣៩] យោ រំសិរុចិតាវេឡោ(១) ផុស្សោ នាម មហាមុនិ

តស្សាហំ ភគិនី អាសឹ អជាយឹ ខត្តិយេ កុលេ ។

តស្ស ធម្មំ សុណិត្វាហំ វិប្បសន្នេន ចេតសា

មហាទានំ ទទិត្វាន បត្ថយឹ រូបសម្បទំ ។

ឯកត្តឹសេ ឥតោ កប្បេ សិខី លោកគ្គនាយកោ

ឧប្បន្នោ លោកបជ្ជោតោ តិលោកសរណោ ជិនោ ។

តទា អរុណបុរេ រម្មេ ព្រហ្មញ្ញកុលសម្ភវា

វិមុត្តចិត្តំ កុបិតា ភិក្ខុនឹ អភិសាបយឹ ។

វេសិកា ច អនាចារា ជិនសាសនទូសិកា

ឯវំ អក្កោសយិត្វាន តេន បាបេន កម្មុនា ។

---

១ ឱ. ម. រំសិផុសិតាវេលោ ។

# អម្ពបាលីថេរិយាបទាន ទី ៩

(៣៩) ព្រះមហាមុនី ព្រះនាមផុស្សៈណា មានជួរនៃរស្មីដ៏រុងរឿង ខ្ញុំបានកើតក្នុងខត្តិយត្រកូល ជាប្អូនស្រីនៃព្រះមហាមុនីនោះ ៗ ខ្ញុំបានស្តាប់ព្រះធម៌ នៃព្រះមហាមុនីនោះហើយ មានចិត្តជ្រះថ្លា បានថ្វាយមហាទាន ហើយប្រាថ្នានូវរូបសម្បត្តិ ៗ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះជិនស្រីព្រះនាមសិខី ជានាយកដ៏ប្រសើរក្នុងលោក ជាពន្លឺនៃលោក ជាទីពឹងនៃត្រៃភព កើតឡើង ៗ កាលនោះ ខ្ញុំកើតក្នុងត្រកូលនៃព្រាហ្មណ៍ ក្នុងអរុណបុរី ជាទីក្រុងរីករាយ បានខឹងជេរផ្តាសាភិក្ខុនី ដែលមានចិត្តរួចស្រឡះចាកកិលេសហើយ ៗ មួយទៀត ខ្ញុំបានកើតជាស្រីផ្កាមាស ឥតមានអាចារៈ ជាអ្នកប្រទូស្តចំពោះសាសនា នៃព្រះជិនស្រីសម្ពុទ្ធ បានជេរភិក្ខុនី តាមទំនងដូចគ្នា ព្រោះតែបាបកម្មនោះឯង

ទារុណំ និរយំ គន្ត្វា មហាទុក្ខសមប្បិតា
តតោ ចុតា មនុស្សេសុ ឧបបន្នា តបស្សិនី ។
ទសជាតិសហស្សានិ គណិកត្តំ អការយិំ
តតោ បាបា ន មុច្ចិស្សំ(១) ភុត្វា ទុដ្ឋវិសំ យថា ។
ព្រហ្មចេរមសេវិស្សំ(២) កស្សបេ ជិនសាសនេ
តេន កម្មវិបាកេន អជាយឹ តិទសេ បុរេ ។
បច្ឆិមេ ភវសម្បត្តេ អហោសិំ ឱបបាតិកា
អម្ពសាខន្តរេ ជាតា អម្ពបាលីតិ តេនហំ ។
បរិវុតា បាណកោដីហិ បព្វជឹ ជិនសាសនេ
បត្តាហំ អចលំ ឋានំ ធីតា ពុទ្ធស្ស ឱរសា ។
ឥទ្ធីសុ ច វសី ហោមិ ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា នត្ថិ ទានិ បុនព្ភវោ ។

---

១ ឧ. តំ បាបំ ន វិមុច្ចិស្សំ ។ ម. តម្ហា បាបា ន មុច្ចិស្សំ ។ ២ ឧ. ព្រហ្មចរមសេវិស្សំ ។ ម. ព្រហ្មចារមសេវិស្សំ ។

ខ្ញុំបានទៅកើត ក្នុងនរកដ៏អាក្រក់ ក្តៅក្តួលដោយសេចក្តីទុក្ខ
យ៉ាងខ្លាំង លុះខ្ញុំរួចចាកនរកនោះ បានមកកើត ក្នុងមនុស្ស
ជាស្រីមានតបៈ ។ ខ្ញុំកើតជាស្រីផ្កាមាស អស់ ១០ ពាន់ជាតិ
ខ្ញុំមិនរួចចាកបាបនោះទេ ដូចបុគ្គលបរិភោគថ្នាំពិស ដ៏កាចអា-
ក្រក់ ។ ខ្ញុំបានសេពគប់នូវភេទដ៏ប្រសើរ កើតក្នុងសាសនានៃ
ព្រះជិនស្រី ព្រះនាមកស្សប ដោយអំណាចនៃផលកម្មនោះ
ខ្ញុំបានទៅកើត ក្នុងបុរីឋានត្រៃត្រឹង្ស ។ លុះមកដល់បច្ឆិមភព
ខ្ញុំជាឧបបាតិកកំណើត បានកើតក្នុងចន្លោះ នៃមែកស្វាយ
ព្រោះហេតុនោះ បានជាខ្ញុំឈ្មោះថាអម្ពបាលី ។ ខ្ញុំមានពួក
សត្វមួយកោដិចោមរោមហើយ បួសក្នុងសាសនា ព្រះជិនស្រី
បានជាធីតា ជាឱរសនៃព្រះពុទ្ធ ហើយបានដល់ឋានដ៏មិន
កម្រើក ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិ
ទាំងឡាយផង ជាអ្នកស្ទាត់ជំនាញ ក្នុងសោតធាតុដ៏ជាទិព្វផង
ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់
នូវបុព្វេនិវាស ទិព្វចក្ខុខ្ញុំបានជម្រះស្អាតហើយ អាសវៈទាំងពួង
របស់ខ្ញុំ អស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។

## នវមំ អម្ពបាលីថេរិយាបទានំ

អត្ថធម្មនិរុត្តីសុ    បដិភាណេ តថេវ ច
ញាណំ មេ វិមលំ សុទ្ធំ    ពុទ្ធសេដ្ឋស្ស វាហសា ។
កិលេសា ឈាបិតា មយ្ហំ    ភវា សព្វេ សមូហតា
នាគីវ ពន្ធនំ ឆេត្វា    វិហរាមិ អនាសវា ។
ស្វាគតំ វត មេ អាសិ    ពុទ្ធសេដ្ឋស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា    កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ    វិមោក្ខាបិ ច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា    កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា អម្ពបាលី ភិក្ខុនី ឥមា គាថាយោ អភាសិត្ថាតិ ។

អម្ពបាលីថេរិយាបទានំ សមត្តំ ។

## អម្ពបាលីថេរិយាបទាន ទី ៩

ខ្ញុំមានសេចក្តីដឹងច្បាស់ ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធដ៏ប្រសើរ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំដកចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់បំណង់ដូចជាមេដំរី កាត់ផ្តាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយ ក្នុងសំណាក់ នៃព្រះពុទ្ធដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបានដល់ហើយ សាសនា នៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអម្ពបាលីភិក្ខុនី មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ អម្ពបាលីថេរិយាបទាន ។

## ទសមំ សេលាបេរិយាបទានំ

[៨០] ឥមម្ហិ ភទ្ទកេ កប្បេ ព្រហ្មពន្ធុ មហាយសោ
កស្សបោ នាម នាមេន ឧប្បជ្ជិ វទតំ វរោ ។
សាវត្ថិយំ បុរវរេ ឧបាសកកុលេ អហំ
បសុតា តំ ជិនវរំ ទិស្វា សុត្វា ច ទេសនំ ។
តំ វីរំ សរណំ គន្ត្វា សិលានិ ច សមាទយឹ
កទាចិ សោ មហាវីរោ មហាជនសមាគមេ ។
អត្តនោ អភិសម្ពោធឹ បកាសេសិ នរាសភោ
អននុស្សុតធម្មេសុ បុព្វេ ទុក្ខាទិកេសុ ច ។
ចក្ខុ ញាណញ្ច បញ្ញា ច វិជ្ជាលោកំ ច អាសិ មេ
តំ សុត្វា ឧគ្គហេត្វាន បរិបុច្ឆាមិ ភិក្ខវោ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អគញ្ឆហំ ។

# សោណាថេរិយាបទាន ទី ១០

(៨០) ព្រះជិនស្រី ព្រះនាមកស្សប មានផៅពង្សប្រសើរ ទ្រង់មានយសធំ ប្រសើរជាងអ្នកប្រាជ្ញទាំងឡាយ ទ្រង់កើតឡើង ក្នុងកប្បនេះ ។ ខ្ញុំកើតក្នុងត្រកូល នៃឧបាសកក្នុងក្រុងសាវត្ថី ជាបុរីដ៏ប្រសើរ ជាអ្នកខ្វល់ខ្វាយ បានឃើញព្រះជិនស្រីដ៏ប្រសើរនោះផង បានស្តាប់នូវទេសនាផង ។ ខ្ញុំដល់នូវព្រះពុទ្ធ ទ្រង់មានសេចក្តីព្យាយាមនោះ ជាទីពឹងផង សមាទាននូវសីលទាំងឡាយផង ជួនកាល ព្រះពុទ្ធមានព្យាយាមធំនោះ ប្រសើរជាងពួកជន ទ្រង់ប្រកាសនូវអភិសម្ភោធិញ្ញាណរបស់ព្រះអង្គ ក្នុងទីប្រជុំមហាជន ក្នុងសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម ជាធម៌ដែលព្រះអង្គមិនធ្លាប់ឮ ក្នុងកាលមុន ៗ ចក្ខុក្តី ញាណក្តី បញ្ញាក្តី វិជ្ជាក្តី ពន្លឺក្តី កើតមានដល់ខ្ញុំ បពិត្រភិក្ខុទាំងឡាយ ខ្ញុំបានស្តាប់ បានរៀននូវរឿងនោះ ហើយសាកសួរ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់នូវចេតនានោះផង លុះខ្ញុំលះបង់រាងកាយជារបស់នៃមនុស្ស ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។

## ទសមំ សោណថេរិយាបទានំ

បច្ឆិមេ ច ភវេ ទានិ    ជាតា សេដ្ឋិមហាកុលេ
ឧបេច្ច ពុទ្ធំ សទ្ធម្មំ    សុត្វា មច្ចុបសំហិតំ[១] ។
បព្វជិត្វា ន[២] ចិរេនេវ    សព្វត្ថានិ[៣] វិចិន្តយិំ
ខេបេត្វា អាសវេ សព្វេ    អរហត្តំ អបាបុណិំ ។
ឥទ្ធីសុ ច វសី ហោមិ    ទិព្វាយ សោតធាតុយា
ចេតោបរិយញាណស្ស    វសី ហោមិ មហាមុនេ ។
បុព្វេនិវាសំ ជានាមិ    ទិព្វចក្ខុំ វិសោធិតំ
សព្វាសវបរិក្ខីណា    នត្ថិ ទានិ បុនព្ភវោ ។
អត្ថធម្មនិរុត្តីសុ    បដិភាណេ តថេវ ច
ញាណំ មេ វិមលំ សុទ្ធំ    ពុទ្ធសេដ្ឋស្ស វាហសា ។

---

១ ឱ. សច្ចុបសំហិតំ ។ ម. បច្ចុបសំហិតំ ។ ២ ឱ. ម. នសត្វោ នត្ថិ ។ ៣ ឱ. សច្ចត្ថានិ ។

## សោណថេរិយាបទានទី ១០

ឥឡូវនេះ ដល់មកក្នុងបច្ឆិមភព ខ្ញុំកើតក្នុងត្រកូលមហាសេដ្ឋី បានចូលទៅជិតព្រះពុទ្ធ ហើយបានស្តាប់នូវព្រះសទ្ធម្មដែលប្រកបព្រមដោយមធុ ។ ខ្ញុំបួសហើយ មិនយូរប៉ុន្មាន ក៏បានត្រិះរិះ នូវប្រយោជន៍ទាំងពួង បានញុំាងអាសវៈទាំងពួងឲ្យអស់ ហើយបានសម្រេចព្រះអរហត្ត ។ បពិត្រព្រះមហាមុនី ខ្ញុំជាអ្នកស្ទាត់ជំនាញក្នុងឫទ្ធិទាំងឡាយផង ជាអ្នកស្ទាត់ជំនាញក្នុងសោតធាតុ ដ៏ជាទិព្វផង ជាអ្នកស្ទាត់ជំនាញក្នុងចេតោបរិយញ្ញាណផង ។ ខ្ញុំដឹងច្បាស់ នូវបុព្វេនិវាស ទិព្វចក្ខុ ខ្ញុំបានជម្រះស្អាតល្អហើយ អាសវៈទាំងពួង របស់ខ្ញុំ អស់ហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានឡើយ ។ ខ្ញុំមានសេចក្តីដឹង ក្នុងអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ជាញាណស្អាត ឥតមានមន្ទិល ព្រោះហេតុនៃព្រះពុទ្ធដ៏ប្រសើរ ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

នាគីវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវា ។

សាគតំ វត មេ អាសិ ពុទ្ធសេដ្ឋស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា សោណា(១) ភិក្ខុនី ឥមា គាថា-
យោ អភាសិត្ថាតិ ។

សោណាថេរិយាបទានំ សមត្តំ ។

---

១ ម. បេសលា ។

កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងពួង ខ្ញុំដក

ចោលចេញហើយ ខ្ញុំជាស្រីមិនមានអាសវៈ ព្រោះបានកាត់

បំណង ដូចជាមេដំរី កាត់ផ្តាច់នូវទន្ទឹង ។ ឱ! ខ្ញុំមកល្អ

ហើយ ក្នុងសំណាក់នៃព្រះពុទ្ធ ដ៏ប្រសើរ វិជ្ជា ៣ ខ្ញុំបាន

សម្រេចហើយ សាសនា នៃព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ

ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន

ប្រតិបត្តិហើយ ។

បានឮថា ព្រះសោណាភិក្ខុនី មានអាយុ បានសំដែងនូវគាថា

ទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ សោណាថេរិយាបទាន ។

## ឧទ្ទានំ

ខត្តិយព្រាហ្មណី ចេវ តថា ឧប្បលទាយិកា
សិង្គាលមាតា សុក្កា ច អភិរូបនន្ទា ចេវ(១)
អឌ្ឍកាសិកា ចេវ បុណ្ណា ច អម្ពបាលី សេលា
ភិក្ខុនីតិ(២) ។

ខត្តិយកញ្ញាវគ្គោ ចតុត្ថោ ។

អបទានំ និដ្ឋិតំ ។

---

១ ឱ. ម. អភិរូបា អឌ្ឍកាសិកា ។ ២ ឱ. គណិកា ចេវ បុណ្ណា ច អម្ពបាលី ច ភិក្ខុនីតីតិ ទិស្សន្តិ ។ ម. បុណ្ណា ច អម្ពបាលី ច បេសលាតិ ច ៣ ទស គាថាយោ ទ្វិសតានេត្ថ ទ្វិបញ្ញាឡីស ចុត្តរីតិ បាឋា ទិស្សន្តិ ។

## ឧទ្ទាន

អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ១ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន ១ ឧប្បលទាយិកាថេរិយាបទាន ១ សិង្គាលមាតាថេរិយាបទាន ១ សុក្កាថេរិយាបទាន ១ អភិរូបនន្ទាថេរិយាបទាន ១ អឌ្ឍកាសីថេរិយាបទាន ១ បុណ្ណិកាថេរិយាបទាន ១ អម្ពបាលីថេរិយាបទាន ១ សេលាថេរិយាបទាន ១ ។

ចប់ ខត្តិយកញ្ញាវគ្គ ទី ៤ ។

ចប់ អបទាន ។

# សុត្តន្តបិដកេ

# ខុទ្ទកនិកាយស្ស អបទានំ

# បញ្ចមោ ភាគោ

---

## មាតិកាបត្តានិ

មាតិកា | អង្កេ

### បឋមោ សុមេធាវគ្គោ


សុមេធាវគ្គ   បឋមំ សុមេធាថេរិយាបទានំ . . . . . ១

ទុតិយំ មេខលទាយិកាថេរិយាបទានំ . . . ៥

តតិយំ មណ្ឌបទាយិកាថេរិយាបទានំ . . . ៦

ចតុត្ថំ សង្កមនទាថេរិយាបទានំ . . . . . ៧

បញ្ចមំ នឡមាលិកាថេរិយាបទានំ . . ៨

ឆដ្ឋំ ឯកបិណ្ឌបាតទាយិកាថេរិយាបទានំ . . ១០

សត្តមំ កដច្ឆុភិក្ខទាយិកាថេរិយាបទានំ . . . ១២

អដ្ឋមំ សត្តុប្បលមាលិកាថេរិយាបទានំ . . ១៤

នវមំ បញ្ចទីបិកាថេរិយាបទានំ . . . . ១៧

ទសមំ ឧទកទាយិកាថេរិយាបទានំ , , , ២១

# សុត្តន្តបិដក

# ខុទ្ទកនិកាយ អបទាន

# បញ្ចមភាគ

---

## សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

### សុមេធាវគ្គ ទី ១


| | | |
|---|---|---|
| សុមេធាវគ្គ | សុមេធាថេរិយាបទាន ទី ១ . . . . . . . | ១ |
| | មេខលទាយិកាថេរិយាបទាន ទី ២ . . . . . | ៥ |
| | មណ្ឌបទាយិកាថេរិយាបទាន ទី ៣ . . . . . | ៦ |
| | សង្កមនទាថេរិយាបទាន ទី ៤ . . . . . . | ៧ |
| | នឡមាលិកាថេរិយាបទាន ទី ៥ . . . . . . | ៨ |
| | ឯកបិណ្ឌបាតទាយិកាថេរិយាបទាន ទី ៦ . . . | ១០ |
| | កដច្ឆុភិក្ខទាយិកាថេរិយាបទាន ទី ៧ . . . . | ១២ |
| | សត្តុប្បលមាលិកាថេរិយាបទាន ទី ៨ . . . . | ១៤ |
| | បញ្ចទីបិកាថេរិយាបទាន ទី ៩ . . . . . . | ១៧ |
| | ឧទកទាយិកាថេរិយាបទាន ទី ១០ . . . . . | ២១ |

# មាតិកាបត្តានិ

| មាតិកា | | | អង្កេ |
|---|---|---|---|

## ទុតិយោ ឯកុបោសថវគ្គោ


| | | | |
|---|---|---|---|
| ឯកុបោសថវគ្គ | បឋមំ | ឯកុបោសថិកាថេរិយាបទានំ . . . | ២៥ |
| | ទុតិយំ | សលឡបុប្ផិកាថេរិយាបទានំ . . . | ២៨ |
| | តតិយំ | មោទកទាយិកាថេរិយាបទានំ . . . | ៣០ |
| | ចតុត្ថំ | ឯកាសនទាយិកាថេរិយាបទានំ . . . | ៣១ |
| | បញ្ចមំ | បញ្ចទីបទាយិកាថេរិយាបទានំ . . | ៣៦ |
| | ឆដ្ឋំ | នឡមាលិកាថេរិយាបទានំ . . . | ៤០ |
| | សត្តមំ | មហាបជាបតិគោតមីថេរិយាបទានំ . | ៤២ |
| | អដ្ឋមំ | ខេមាថេរិយាបទានំ . . . . . | ៧៧ |
| | នវមំ | ឧប្បលវណ្ណាថេរិយាបទានំ . . . . | ៩៤ |
| | ទសមំ | បដាចារាថេរិយាបទានំ . . . . | ១១០ |

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## ឯកុបោសថវគ្គ ទី ២


ឯកុបោសថវគ្គ ឯកុបោសថិកាថេរិយាបទាន ទី ១ . . . . . ២៥

សលឡបុប្ផិកាថេរិយាបទាន ទី ២ . . . . . ២៨

មោទកទាយិកាថេរិយាបទាន ទី ៣ . . . ៣០

ឯកាសនទាយិកាថេរិយាបទាន ទី ៤ . . . ៣១

បញ្ចទីបទាយិកាថេរិយាបទាន ទី ៥ . . . ៣៦

នឡមាលិកាថេរិយាបទាន ទី ៦ . . . ៤០

មហាបជាបតិគោតមីថេរិយាបទាន ទី ៧ . . ៤២

ខេមាថេរិយាបទាន ទី ៨ . . . . . . ៧៧

ឧប្បលវណ្ណាថេរិយាបទាន ទី ៩ . . . . . ៩៤

បដាចារាថេរិយាបទាន ទី ១០ . . . . . ១១០

# មាតិកាបត្តានិ

មាតិកា អង្កេ

## តតិយោ កុណ្ឌលកេសវគ្គោ


កុណ្ឌលកេសវគ្គ បឋមំ កុណ្ឌលកេសីថេរិយាបទានំ . . ១១៨

ទុតិយំ កិសាគោតមីថេរិយាបទានំ . . . ១២៧

តតិយំ ធម្មទិន្នាថេរិយាបទានំ . . . ១៣៤

ចតុត្ថំ សកុលាថេរិយាបទានំ . . . ១៤១

បញ្ចមំ នន្ទាថេរិយាបទានំ . . . . ១៤៧

ឆដ្ឋំ សោណាថេរិយាបទានំ . . . . ១៥៧

សត្តមំ ភទ្ទាកាបិលានីថេរិយាបទានំ . . ១៦១

អដ្ឋមំ យសោធរាថេរិយាបទានំ . . . ១៧៣

នវមំ ទសសហស្សថេរីនមបទានំ . . ១៨៨

ទសមំ អដ្ឋារសថេរីសហស្សានមបទានំ . ១៩១

# សន្លឹកប្រាក់មាតិកា


| មាតិកា | | ទំព័រ |
|---|---|---|

## កុណ្ឌលកេសវគ្គ ទី ៣

| | | |
|---|---|---|
| កុណ្ឌលកេសវគ្គ | កុណ្ឌលកេសីថេរិយាបទាន ទី ១ . . . . | ១១៨ |
| | កិសាគោតមីថេរិយាបទាន ទី ២ . . . . | ១២៧ |
| | ធម្មទិន្នាថេរិយាបទាន ទី ៣ . . . . | ១៣៤ |
| | សកុលាថេរិយាបទាន ទី ៤ . . . . | ១៤១ |
| | នន្ទាថេរិយាបទាន ទី ៥ . . . . . | ១៤៧ |
| | សោណាថេរិយាបទាន ទី ៦ . . . . | ១៥៧ |
| | ភទ្ទកាបិលានីថេរិយាបទាន ទី ៧ . . . | ១៦១ |
| | យសោធរាថេរិយាបទាន ទី ៨ . . . | ១៧៣ |
| | ទសសហស្សថេរីនមបទាន ទី ៩ . . . | ១៨៨ |
| | អដ្ឋារសថេរីសហស្សានមបទាន ទី ១០ . . | ១៩១ |

# មាតិកាបត្តានិ

មាតិកា | អង្ក

## ចតុត្ថោ ខត្តិយកញ្ញាវគ្គោ

ខត្តិយកញ្ញាវគ្គ បឋមំ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទានំ ២០៣
ទុតិយំ ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនម-
បទានំ ២០៥
តតិយំ ឧប្បលទាយិកាថេរិយាបទានំ . . . ២១៣
ចតុត្ថំ សិង្គាលមាតាថេរិយាបទានំ . . . ២១៧
បញ្ចមំ សុក្កាថេរិយាបទានំ . . . . . ២២៣
ឆដ្ឋំ អភិរូបនន្ទាថេរិយាបទានំ . . . . ២២៩
សត្តមំ អឌ្ឍកាសីថេរិយាបទានំ . . . . ២៣៣
អដ្ឋមំ បុណ្ណិកាថេរិយាបទានំ . . . . ២៣៧
នវមំ អម្ពបាលីថេរិយាបទានំ . . . . ២៤១
ទសមំ សេលាថេរិយាបទានំ . . . . . ២៤៤

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## ខត្តិយកញ្ញាវគ្គ ទី ៤

ខត្តិយកញ្ញាវគ្គ អដ្ឋារសសហស្សខត្តិយកញ្ញាថេរីនមបទាន ទី ១ . ២០៣

ចតុរាសីតិសហស្សព្រាហ្មណកញ្ញាថេរីនមបទាន ទី ២ . . . ២០៥

ឧប្បលទាយិកាថេរិយាបទាន ទី ៣ . . . ២១៣

សិង្គាលមាតាថេរិយាបទាន ទី ៤ . . . ២១៧

សុក្កាថេរិយាបទាន ទី ៥ . . . . . ២២៣

អភិរូបនន្ទាថេរិយាបទាន ទី ៦ . . . . ២២៩

អឌ្ឍកាសីថេរិយាបទាន ទី ៧ . . . . ២៣៣

បុណ្ណិកាថេរិយាបទាន ទី ៨ . . . . . ២៣៧

អម្ពបាលីថេរិយាបទាន ទី ៩ . . . . . ២៤១

សេលាថេរិយាបទាន ទី ១០ . . . . . ២៤៤

# វិសុទ្ធាវិសុទ្ធបត្តំ

| វិសុទ្ធបាឋោ | អវិសុទ្ធបាឋោ | អង្កេ | បង្តិលេខាយំ |
|---|---|---|---|
| សំវិទ្ធិតោ | សំវទ្ធិតោ | ៤៨ | ៦ |
| សាសនំ | សាសំ | ៥៨ | ៥ |
| ភិក្ខុនីយោ | ភិក្ខុនិយោ | ៦៥ | ៤ |
| និវេទេហី | និវេទេហិ | ៧១ | ៧ |
| តិដ្ឋិតោ | តិដ្ឋតោ | ៧៥ | ៧ |
| កោប | កោបិ | ៨១ | ៣ |
| អហិ | អហំ | ៨១ | ៧ |
| ផណ្ណេនា | ផិណ្ណេន | ៨៦ | ៩ |
| អាពេ បមិ | អាពេបេមិ | ៩៥ | ៣ |
| សសម្ពុទ្ធោ | ស សម្ពុទ្ធោ | ១០០ | ៤ |
| លាកេ | លោកេ | ១១១ | ៧ |
| បណ្ឌិតា | បណ្ឍិតា | ១២៣ | ៧ |
| វិជានន្តិ | វិជានន្តិ | ១២៥ | ៣ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ដូជា | ដូចជា | ២៩ | ៨ |
| អង្គយ | អង្គុយ | ៣៦ | ៧ |
| ក៏ខ្សក | ក៏ខ្សឹក | ៤៤ | ១៤ |
| ខ្សឹកខ្សល | ខ្សឹកខ្សួល | ៥៤ | ១៣ |
| ដើម្ប | ដើម្បី | ៥៦ | ៧ |
| តាកតែង | តាក់តែង | ៦៨ | ៩ |
| បរិទិញ្ញា | បរិទិញ្ញាន | ៧៤ | ៥ |
| មានក្លិន | មានខ្លឹម | ៧៥ | ៩ |
| ក្អែ | ក្អែក | ៨៧ | ១៦ |
| មូយសែន | មួយសែន | ៩៩ | ៥ |
| ខ្ញុំបានក៏ | ខ្ញុំក៏បាន | ១០៨ | ១៧ |
| ឈ្មាះ | ឈ្មោះ | ១១៩ | ៦ |
| ដ៏ប្រសីរ | ដ៏ប្រសើរ | ១២០ | ១៥ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| សុខេដ្ឋិតា | សុខេដ្ឋិតោ | ១៣១ | ២ |
| យាវជីវំ | យាវជីវំ | ១៣៦ | ១០ |
| អាសវ | អាសវេ | ១៤៥ | ១៣ |
| មហាវិរំ | មហាវីរំ | ១៤៨ | ១០ |
| ឈាបិតា មយ្ហំ | ឈាបិតា ម្ហាកំ | ១៩០ | ៨ |
| វិហាកមិ | វិហាកម | ១៩០ | ៩ |
| មេ | នោ | ១៩០ | ១០ |
| ឈាបិតា មយ្ហំ | ឈាបិតា ម្ហាកំ | ២០០ | ១២ |
| មេ | នោ | ២០១ | ២ |
| កិត្តុនី | កិត្តុនី- | ២០២ | ៤ |
| ឈាបិតា មយ្ហំ | ឈាបិតា ម្ហាកំ | ២០៤ | ១០ |
| មេ | នោ | ២០៤ | ១២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| អញ | ខ្ញុំ | ១២៣ | ២ |
| ,, | ,, | ,, | ៣ |
| នាង | អ្នក | ,, | ៣ |
| ឈ្មោះបណ្ឌិត | ឈ្មោះជាបណ្ឌិត | ,, | ១៤ |
| ជីវីត | ជីវិត | ១២៩ | ៧ |
| ព្រះថេរ | ព្រះថេរៈ | ១៣៥ | ៤ |
| ស្តាប់ព្យាករ | ស្តាប់ព្យាករណ៍ | ១៣៦ | ១១ |
| ទ្រង់ព្យាករណ៍ | ទ្រង់ព្យាករ | ១៤៩ | ៦ |
| ជាទេតា | ជាទេវតា | ១៨៥ | ៤ |
| យៈសាធកាបេរិយាបទាន | ទសសហស្សបេរិនមបទាន | ១៨៩ | ១ |
| បំពោះ | បំពោះ | ១៩១ | ៣ |
| បានសម្តែង | បានជួប | ១៩៧ | ៨ |
| ព្រជីនស្រី | ព្រះជិនស្រី | ២២០ | ៣ |
| ទុក | ដក | ២២៤ | ១០ |
| សក្កាបេរិយាបទាន | សុក្កាបេរិយាបទាន | ២២៥ | ៩ |
| មានអាសវៈ | អាសវៈ | ២៣២ | ១៣ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

Mrs. Kumiko Futagami · Mr. Seison Futagami
581 Taijima, Tamukaecho, Kumamoto-shi, Kumamoto-ken 862 Japan

この本は次の方によって復刻されました。

為慈香院 釋浄和信士一周忌供養
施主 二神クミ子・二神成尊
〒862 熊本県熊本市田迎町田井島581
☎096-378-3644

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 76 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第76巻スッタンタピタカ（経部）

発　　行：プノンペン仏教研究所
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月8日

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE